# ការឃ្លាំមើលសេរីភាពមូលដ្ឋាន នៅកម្ពុជា

## របាយការណ៍ឆ្នាំ២០២២




**គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន**

ខែកញ្ញា ឆ្នាំ២០២៣

គាំទ្រដោយ៖

ICNL
INTERNATIONAL CENTER FOR NOT-FOR-PROFIT LAW

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សមាគមអាដហុក
ADHOC

SOLIDARITY CENTER
AFL-CIO

# មាតិកា


មូលន័យសង្ខេប ........ 1

សេចក្ដីផ្ដើម ........ 6

១. ចំណុចគន្លឹះទី ១៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ស្របតាមបទដ្ឋានច្បាប់អន្តរជាតិដែរឬទេ? ........ 8

១.១. កង្វះខាតភាពច្បាស់លាស់ក្នុងការកំណត់អង្គភាពដែលតម្រូវឱ្យចុះបញ្ជីឈ្មោះដែនជាតិ ........ 11

១.២. អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ដោយហាមឃាត់មាតិកាលើគេហទំព័រ ........ 12

១.៣. អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិដោយហាមឃាត់ឈ្មោះដែនមួយចំនួន ........ 13

២. ចំណុចគន្លឹះទី ២ ៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ? ........ 15

២.២. សេរីភាពខាងសមាគម ........ 21

២.៣. សេរីភាពខាងការជួបប្រជុំ ........ 27

២.៤. សេរីភាពខាងការបញ្ចេញមតិ ........ 31

៣. ចំណុចគន្លឹះទី ៣៖ តើបុគ្គលម្នាក់ៗយល់អំពីសេរីភាពមូលដ្ឋាន និងយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះដែរឬទេ? ........ 37

៣.១. ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋានមានការកើនឡើងបន្តិច ........ 38

៣.២. ទោះបីជាមានពលរដ្ឋកាន់តែច្រើនឡើងយល់ថាមានសេរីភាពក្នុងការអនុវត្ត ........ 39

៣.៣. ចំនួនអ្នកដែលរឹតត្បិតសេរីភាពខ្លួនឯង នៅតែបន្តកើនឡើង ........ 41

៣.៤. ស្ត្រី និងបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទផ្សេងៗ ........ 41

៣.៥. ពលរដ្ឋភាគច្រើនយល់ថាខ្លួនអាចចូលរួម ឬចាកចេញពីសមាគម ឬ សហជីពដោយសេរី ........ 42

៣.៦. បុគ្គលម្នាក់ៗយល់ថាមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយ ........ 43

៣.៧. អ្នកឆ្លើយតបយល់ថាមិនសូវមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយ ........ 44

៣.៨. សាធារណជនមានការយល់ដឹងកាន់តែច្រើនអំពីច្បាប់ជាតិទាក់ទងនឹងសេរីភាពមូលដ្ឋាន ........ 44

៣.៩. បុគ្គលម្នាក់ៗមានការយល់ដឹងកាន់តែប្រសើរឡើង អំពីជាតុផ្សំស្នូល ........ 45

៣.១០. ពលរដ្ឋវ័យក្មេងមានទំនោរចូលរួមការជួបប្រជុំដោយសន្តិវិធីច្រើនជាងក្រុមមនុស្សផ្សេងទៀត ........ 47

៣.១១. បុគ្គលម្នាក់ៗនៅតែមានការលំបាក ក្នុងការរាយការណ៍អំពីការរំលោភសិទ្ធិមនុស្ស ........ 47

៣.១២. ពលរដ្ឋកម្ពុជាបន្តប្រឈមនៅពេលស្វែងរកដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្ស ........ 48

៤. ចំណុចគន្លឹះទី ៤ ៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជាបានដែរឬទេ? ........ 49
៤.១. កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរមតិយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល និងសហជីព នៅតែមានកម្រិត ........ 49
៤.២. ការបានដឹងពីឱកាសទទួលបានហិរញ្ញប្បទានសម្រាប់អង្គការសង្គមស៊ីវិល និងសហជីពមានការពិបាកក្នុងការស្វែងរក ........ 52
៤.៣. ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ប្រឈមនឹងការទទួលបានព័ត៌មាន ........ 53
សេចក្តីសន្និដ្ឋាន ........ 55
ឧបសម្ព័ន្ធទី១ ៖ វិធីសាស្រ្ត និងការប្រមូលទិន្នន័យ ........ 57
ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ........ 61
ឧបសម្ព័ន្ធទី៣ ៖ សំណួរ និងលទ្ធផល នៃការស្ទង់មតិជាសាធារណៈ ........ 106
ឧបសម្ព័ន្ធទី៤ ៖ សំណួរ និងលទ្ធផលនៃការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ........ 117

# មូលន័យសង្ខេប

| ពណ៌កំណត់ចំណាំក្នុងរបាយការណ៍នេះ | |
|---|---|
| | សេរីភាពខាងសមាគម |
| | សេរីភាពខាងការបញ្ចេញមតិ |
| | សេរីភាពខាងការជួបប្រជុំ |
| | សេរីភាពទាំងបី |

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានពិនិត្យមើលទៅលើសេរីភាពមូលដ្ឋានចំនួន៣ គឺសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ[1] (សេរីភាពមូលដ្ឋាន) នៅក្នុងប្រទេសកម្ពុជា។ គម្រោងប្រើប្រាស់ឧបករណ៍ឃ្លាំមើលជាច្រើន ដោយផ្តល់នូវទិដ្ឋភាពបែបសត្យានុម័ត ថាតើសេរីភាពមូលដ្ឋានចែងនៅក្នុងច្បាប់នឹងអនុវត្តបែបណានៅទូទាំងប្រទេសកម្ពុជា។ ទិន្នន័យគម្រោងប្រមូលបាននៅចន្លោះថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ (ឆ្នាំ ២០២២) បានបង្ហាញថា លំហនៃការអនុវត្តសេរីភាពមូលដ្ឋាននៅតែមានកម្រិតនៅឡើយ។ ក្របខណ្ឌច្បាប់ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ និងសមាគម បន្តរឹងការគាបសង្កត់ ជាពិសេសការអនុម័តនូវច្បាប់ថ្មីៗដូចជាអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិតដែលរាជរដ្ឋាភិបាល (“រដ្ឋាភិបាល”) បានអនុម័ត។ សាធារណជនបានរាយការណ៍អំពីការរឹតត្បិតខ្លួនឯងនៅមានកម្រិតខ្ពស់ និងមានភាពស្ទាក់ស្ទើរខ្លាំងក្នុងការចូលរួមតវ៉ា ព្រមទាំងការសហការរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល និងសហជីព នៅមិនទាន់មានច្រើនញឹកញាប់នៅឡើយ។

*តួលេខទី១ ៖ ចំនួនហេតុការណ៍ដែលមានការការពារ រឹតត្បិត ឬរំលោភបំពាន សេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២២*




*តួលេខទី២ ៖ ផែនទីភូមិសាស្ត្របង្ហាញហេតុការណ៍ពាក់ព័ន្ធនឹងការពារ រឹតត្បិត ឬការរំលោភបំពាន សេរីភាពមូលដ្ឋាន*




គម្រោងបានកត់ត្រាហេតុការណ៍សរុបចំនួន ៥៦៦ ករណី ទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២២។ ក្នុងចំណោមទាំងនេះ មាន ៣៥៤ ករណី បង្ហាញថាមានការរឹតត្បិត ឬការរំលោភសេរីភាពមូលដ្ឋានយ៉ាងហោចណាស់មួយករណី។[2]

ហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភសេរីភាពមូលដ្ឋានត្រូវបានកត់ត្រានូវគ្រប់រាជធានី-ខេត្តនៃប្រទេសកម្ពុជា។ ករណីភាគច្រើន កើតឡើងនៅក្នុងរាជធានីភ្នំពេញ ដោយមានហេតុការណ៍ចំនួន ២៨៧ ករណី ត្រូវបានកត់ត្រា។

[1] សម្រាប់គោលបំណងនៃរបាយការណ៍នេះ សេរីភាពមូលដ្ឋានរួមមានសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ។ គម្រោងអនុម័តយកនិយមន័យនៃពាក្យ «សមាគម» ដែលប្រើដោយអ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម។

[2] ភាពខុសគ្នារវាងការរឹតត្បិត និងការរំលោភបំពានសិទ្ធិ គឺជាការរឹតត្បិតអាចធ្វើបានដោយមានច្បាប់អនុញ្ញាតជាក់លាក់ ខណៈដែលការរំលោភបំពានគឺផ្ទុយពីបទដ្ឋានអន្តរជាតិ។

របកគំហើញសំខាន់ៗចំនួន៤ គាំទ្រដល់ការសន្និដ្ឋានរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ថាលំហនៃការអនុវត្តសេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២២ ត្រូវបានរឹតត្បិត។ ទី១ ការអនុម័ត អនុក្រឹត្យស្តីពី ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត រឹតត្បិតសេរីភាពខាងការបញ្ចេញមតិ និងមិនអនុលោមតាមច្បាប់អន្តរជាតិ (**របកគំហើញទី១**)។ ទិន្នន័យក្នុងឆ្នាំ២០២២ ដែលគម្រោងបានកត់ត្រា ក៏បានបង្ហាញដែរថា សេរីភាពមូលដ្ឋាន នៅតែបន្តធ្លាក់ចុះ ដោយមានករណីជាច្រើន ដែលបុគ្គលត្រូវបានឃាយីផ្លូវកាយ ឬផ្លូវច្បាប់ សម្រាប់ការអនុវត្តសិទ្ធិរបស់ខ្លួន (**របកគំហើញទី២**)។ ការយល់ដឹងអំពីសេរីភាពមូលដ្ឋាននៅតែមានកម្រិតទាប ហើយការភ័យខ្លាចនៃផលប៉ះពាល់នៅពេលអនុវត្តសេរីភាពមូលដ្ឋាននៅតែបន្តកើតមាន (**របកគំហើញទី៣**)។ ចុងក្រោយ កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល/សហជីព នៅមានកម្រិតទាប ដោយសារ អង្គការសង្គមស៊ីវិល/សហជីព មិនត្រូវបានរដ្ឋាភិបាលមើលឃើញថាជាដៃគូមានសមត្ថភាពក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការតាក់តែងច្បាប់នៅឡើយ (**របកគំហើញទី៤**) ។

**របកគំហើញទី១៖ ការអនុម័តអនុក្រឹត្យស្តីពី ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត ដែលរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ និងមិនអនុលោមតាមច្បាប់អន្តរជាតិ។**

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១[3] រដ្ឋាភិបាលបានអនុម័ត *អនុក្រឹត្យស្តីពី ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត* ហើយការរកឃើញបានគូសបញ្ជាក់ពីបញ្ហាសំខាន់ៗចំនួន៣ ទាក់ទងអនុក្រឹត្យនេះ៖

- កង្វះភាពច្បាស់លាស់ក្នុងការកំណត់អង្គភាពដែលតម្រូវឱ្យចុះបញ្ជីឈ្មោះដែនជាតិ។ ការប្រើប្រាស់ភាសាឱ្យបានច្បាស់លាស់ជាងនេះ គឺចាំបាច់ណាស់ដើម្បីធានាថា អនុក្រឹត្យនេះមិនបើកទូលាយដែលនាំឱ្យមានការបកស្រាយខុសៗគ្នា ក៏ដូចជាការអនុវត្តច្បាប់តាមអំពើចិត្ត ឬដោយមិនស៊ីសង្វាក់គ្នាពីសំណាក់អាជ្ញាធរ។
- អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ដោយហាមឃាត់មាតិកាលើគេហទំព័រ ។ មាត្រា ១១ នៃអនុក្រឹត្យនេះចែងថា អង្គភាពដែលបានចុះបញ្ជីឈ្មោះដែនរបស់ខ្លួន មិនត្រូវប្រើប្រាស់ឈ្មោះដែនជាតិដើម្បីផ្សព្វផ្សាយព័ត៌មានផ្សេងៗដែលប៉ះពាល់ដល់ “វប្បធម៌ សីលធម៌ ទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ ផលប្រយោជន៍សាធារណៈស្របច្បាប់ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈនោះទេ” ដែលជាការរឹតត្បិតមួយលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ការប្រើប្រាស់ភាសា និងខ្លឹមសារមិនច្បាស់លាស់នៃអនុក្រឹត្យនេះ គឺបើកចំហចំពោះការបកស្រាយផ្សេងៗ និងងាយរងគ្រោះចំពោះការអនុវត្តតាមអំពើចិត្ត ឬមិនសមាមាត្រដោយអាជ្ញាធរ។ ឧទាហរណ៍ ការចុះ

[3] ទោះបីជាអនុក្រឹត្យចូលជាធរមាននៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ក៏ដោយ ប៉ុន្តែគម្រោងបានធ្វើវិភាគផ្នែកច្បាប់លើអនុក្រឹត្យនេះក្នុងឆ្នាំ ២០២២។

បញ្ជីឈ្មោះដែនអាចត្រូវបានកំណត់ដោយរដ្ឋាភិបាលតែប៉ុណ្ណោះ ដែលមានអំណាចលុបការចុះបញ្ជីឈ្មោះដែនរបស់អង្គភាពណាមួយ។

- អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិដោយហាមឃាត់ឈ្មោះដែនមួយចំនួន។ មាត្រា ៨.ឃ នៃអនុក្រឹត្យនេះចែងថា ឈ្មោះដែន "ដែលបង្កផលប៉ះពាល់ដល់សីលធម៌ ប្រពៃណី ជំនឿសាសនា និងផ្ទុយពីច្បាប់ និងបទបញ្ញត្តិជាធរមាន" គឺមិនអាចចុះបញ្ជីបានទេ។ អនុក្រឹត្យនេះអាចរារាំងអង្គភាពនានាក្នុងការជ្រើសរើសឈ្មោះដែនរបស់ខ្លួនដោយសេរី ហើយរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

**របកគំហើញទី២៖ សេរីភាពខាងការបញ្ចេញមតិនៅតែបន្តធ្លាក់ចុះ។**

ទិន្នន័យពីរបកគំហើញទី២ បង្ហាញថាសេរីភាពមូលដ្ឋាននៅកម្ពុជា នៅតែបន្តធ្លាក់ចុះ។ ក្នុងចំណោមហេតុការណ៍ចំនួន ៥៦៦ ករណី[4] មាន ២០៩ ករណី បង្ហាញថាមានការរឹតត្បិតសេរីភាពមូលដ្ឋាន យ៉ាងហោចណាស់មួយករណី (កើនឡើងរហូតដល់ ១៥០% បើប្រៀបធៀបទៅនឹងឆ្នាំ២០២១)[5] និងមាន ៣៥៤ ករណីបង្ហាញថាមានការរំលោភសេរីភាពមូលដ្ឋាន យ៉ាងហោចណាស់មួយករណី (កើនឡើងរហូតដល់ ៤៣% បើប្រៀបទៅឆ្នាំ២០២១)។ អាជ្ញាធរបានបង្កើនការឃាំឃើទៅលើបុគ្គលដែលអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួនបើធៀបទៅនឹងឆ្នាំមុនៗ។ ការរឹតត្បិតភាគច្រើនទៅលើសេរីភាពមូលដ្ឋាន មិនអនុលោមតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ដោយកំណត់មុខសញ្ញាអ្នកនយោបាយជំទាស់ បុគ្គលដែលធ្វើការតស៊ូមតិដើម្បីលក្ខខណ្ឌការងារប្រសើរជាងមុន និងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដែលបានរិះគន់រដ្ឋាភិបាល។ ឧទាហរណ៍ កាលពីថ្ងៃទី២៩ ខែសីហា ក្រសួងព័ត៌មានបានប្រកាសថាស្ថាប័នព័ត៌មានណាដែលផ្សព្វផ្សាយព័ត៌មានប្រើពាក្យអសុរោះ នឹងត្រូវលុបអាជ្ញាបណ្ណចេញ។[6] ហើយនៅថ្ងៃទី២៤ ខែឧសភា ក្រុមកូដករណាហ្គាវើលដ៍ចំនួន ១០៦ នាក់ បានប្រឈមនឹងហិង្សាពីសំណាក់អាជ្ញាធរ ខណៈដែលព្យាយាមធ្វើកូដកម្មដោយសន្តិវិធីនៅមុខអគាណាហ្គាវើលដ៍។ កូដករ

[4] ពាក្យហេតុការណ៍ គឺសំដៅលើករណី រំលោភបំពាន ការរឹតត្បិត ឬការការពារ លើសេរីភាពណាមួយនៃសេរីភាពមូលដ្ឋានទាំងបីដែលបានកត់ត្រា។

[5] ភាពខុសគ្នារវាងការរឹតត្បិត និងការរំលោភបំពានសិទ្ធិ គឺថាការរឹតត្បិតអាចអនុញ្ញាតបានតាមផ្លូវច្បាប់ក្នុងកាលៈទេសៈណាមួយ ខណៈដែលការរំលោភបំពាន បានបំពានលើស្តង់ដារច្បាប់អន្តរជាតិ។ ឧទាហរណ៍ ដើម្បីកំណត់ថាតើការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ឈានដល់ការរំលោភបំពាន គម្រោងពិនិត្យមើលថាតើការរឹតត្បិតនោះមិនជាប់លក្ខខណ្ឌទាំង៣ នៃមាត្រា១៩ ក.អ.ស.ព.ន ដែរឬទេ។ ប្រសិនប្រើការរឹតត្បិតមិនជាប់ក្នុងលក្ខខណ្ឌទាំង៣ នោះចាត់ទុកថាជាការរំលោភបំពាន។

[6] ឌុច ឧត្តម,"ក្រសួងព័ត៌មានព្រមានលុបអាជ្ញាបណ្ណសារព័ត៌មានប្រើពាក្យអសុរោះក្រោយបញ្ជាលោក ហ៊ុន សែន" (វីអូឌី,ថ្ងៃទី៣០ខែសីហា ឆ្នាំ២០២២) <https://www.vodkhmer.news/2022/08/30/moi-warns-to-revoke-media-license-using-abusive-language/ > ។

ម្នាក់ត្រូវអាជ្ញាធរទះកំផ្លៀង ហើយម្នាក់ទៀតត្រូវបានដាល់ចំ ពោះ។ កូដករផ្សេងទៀតត្រូវបានអូស និងរុញចូលរថយន្តក្រុង ហើយបានដឹកចេញទៅកន្លែងដែលអាជ្ញាធរតែងតែទម្លាក់នៅជាយរាជធានីភ្នំពេញ។[7]

**របកគំហើញទី៣៖ ការយល់ដឹងអំពីសេរីភាពមូលដ្ឋាននៅតែមានកម្រិតទាប ហើយមានការភ័យខ្លាចពីផលប៉ះពាល់នៅពេលអនុវត្តសេរីភាពមូលដ្ឋាន នៅតែបន្តមាន។**

ចំណេះដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាន និងក្របខណ្ឌច្បាប់ទាក់ទងនឹងសិទ្ធិទាំងនេះ នៅតែមានកម្រិតថេរដដែលបើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។ ការយល់ដឹងអំពីសេរីភាពមូលដ្ឋាន គឺចាំបាច់សម្រាប់ការអនុវត្តសិទ្ធិមនុស្ស ទប់ស្កាត់ការរំលោភបំពានធ្ងន់ធ្ងរ និងការទទួលបាននូវគណនេយ្យភាព។ ភាគរយនៃអ្នកឆ្លើយថាយល់ច្បាស់អំពីអត្ថន័យនៃសេរីភាពនីមួយៗមានកម្រិតទាប (១០% ចំពោះសេរីភាពខាងការជួបប្រជុំ ១២% ចំពោះសេរីភាពខាងការបញ្ចេញមតិ និង ៥% ចំពោះសេរីភាពខាងសមាគម)។ បន្ថែមពីលើនេះ ពលរដ្ឋជាច្រើននៅតែបន្តភ័យខ្លាចចំពោះផលប៉ះពាល់នៅពេលអនុវត្តសេរីភាពមូលដ្ឋាន ដោយមាន ៦៨% នៃអ្នកឆ្លើយតប[8]ពីការស្ទង់មតិជាសាធារណៈរាយការណ៍ថាបានរឹតត្បិតសេរីភាពរបស់ខ្លួន ១២% ឆ្លើយថាកម្រណាស់ ហើយមានតែ ៧% ប៉ុណ្ណោះដែលមិនរឹតត្បិតសេរីភាពរបស់ខ្លួន។ ភាពវិជ្ជមាននៃទិន្នន័យឆ្នាំ២០២២ បង្ហាញពីការកើនឡើងភាគរយស្ត្រីដែលរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយ។ ហើយចុងក្រោយ បើទោះជាការស្ទង់មតិឃើញថាមានការកើនឡើងភាគរយអ្នកឆ្លើយតប ដែលរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមតវ៉ាដោយសន្តិវិធី ក៏បុគ្គល នៅតែមានអារម្មណ៍ស្ទាក់ស្ទើរក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី ដោយ ២៥% នៃអ្នកឆ្លើយតបរាយការណ៍ថាមានសេរីភាពតិចតួច និង ៣% រាយការណ៍ថាមិនមានសេរីភាពទាល់តែសោះក្នុងការចូលរួមជួបប្រជុំដោយសន្តិវិធី។ ទោះបីជាមានភាពប្រសើរឡើងពីឆ្នាំមុនៗក៏ដោយ លទ្ធផលបង្ហាញថាពលរដ្ឋនៅតែមិនមានសេរីភាពពេញលេញក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំរបស់ខ្លួន ប្រហែលជាដោយសារតែការភ័យខ្លាច នៃការជ្រៀតជ្រែក ឬការសងសឹក។

---

[7] សន ចាន់រដ្ឋា,"អាជ្ញាធរប្រើកម្លាំងបង្ក្រាបស្ត្រីកូដករក្រុមហ៊ុនណាហ្គាវើលដ៍កាន់តែខ្លាំង" (វិទ្យុអាស៊ីសេរី ថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២២ ) < https://www.rfa.org/khmer/news/social-economy/authorities-continue-to-violently-crack-down-on-nagaworld-strikers-not-to-demand-a-solution-from-employer-05242022195807.html >។

[8] ទិន្នន័យនេះរួមមានអ្នកឆ្លើយតបដែលរាយការណ៍ថា "ជានិច្ចកាល" "ជាប្រចាំ" ឬ "នៅពេលខ្លះ" បានរឹតត្បិតខ្លួនឯង។

## របកគំហើញទី៤៖ អង្គការសង្គមស៊ីវិល/សហជីព នៅតែមិនត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលថាជាដៃគូដ៏មានសារៈសំខាន់។




កិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល/សហជីព នៅមានកម្រិតទាប ដោយសារតែមិនត្រូវបានរដ្ឋាភិបាល ចាត់ទុកជាដៃគូមានសមត្ថភាពក្នុងដំណើរការសេចក្ដីសម្រេចចិត្ត និងការបង្កើតច្បាប់ឡើយ។ អង្គការសង្គមស៊ីវិល/សហជីព ជារួមមិនបានដឹងអំពីឱកាសធ្វើជាដៃគូជាមួយរដ្ឋាភិបាលក្នុងការធ្វើសេចក្ដីសម្រេចចិត្តដែលពាក់ព័ន្ធ ដោយបង្ហាញពីគម្លាតយ៉ាងរួមតូច នៃទំនាក់ទំនងរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល/សហជីព ព្រមទាំងការចូលរួមពីភាគីចម្រុះ។ ទិន្នន័យដែលប្រមូលក្នុងឆ្នាំ២០២២ ក៏បង្ហាញថាឱកាសផ្ដល់មូលនិធិសម្រាប់អង្គការសង្គមស៊ីវិល/សហជីព ពិបាកស្វែងរកនិងទទួលបាន។ ចុងក្រោយ ការឆ្លើយតបពីការស្ទង់មតិរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលគម្រោងបានធ្វើឡើងដោយមានការឆ្លើយតបចំនួន ១៥០ តំណាងឱ្យ ១៥០ អង្គការសង្គមស៊ីវិល/សហជីព មកពី២០ រាជធានី-ខេត្តទូទាំងប្រទេស បង្ហាញពីការលំបាកដែលស្ថាប័នទាំងនេះប្រឈម នៅពេលព្យាយាមទទួលព័ត៌មានពីអាជ្ញាធរសាធារណៈ។ ការលំបាកដែលជួបប្រទះក្នុងការទទួលបានបានឱកាសការផ្ដល់មូលនិធិ និងទទួលព័ត៌មាន បានបង្ហាញថាអង្គការសង្គមស៊ីវិល/សហជីព មិនត្រូវបានទទួលស្គាល់ និងចាត់ទុកជាភាគីពាក់ព័ន្ធដែលមានសារៈសំខាន់ពីសំណាក់រដ្ឋាភិបាលនោះទេ។

# សេចក្ដីផ្ដើម

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានចាប់ផ្ដើមអនុវត្តពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ គឺជាគម្រោងមានរយៈពេលវែងដែលពិនិត្យតាមដាន និងវាយតម្លៃអំពីស្ថានភាពសេរីភាពមូលដ្ឋានចំនួនបី គឺសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ ("សេរីភាពមូលដ្ឋាន")[9] នៅក្នុងប្រទេសកម្ពុជា។ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន តាមដានការអនុវត្តសេរីភាពមូលដ្ឋានដោយប្រើប្រាស់ឧបករណ៍តាមដានការឃ្លាំមើល ("MTT") ។ នេះជារបាយការណ៍ឆ្នាំ២០២២ (ឆ្នាំទី៧) គូសបញ្ជាក់ចំណុចគន្លឹះសំខាន់ៗចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ ក្នុងអំឡុងពេលរបាយការណ៍នេះតទៅ គម្រោងបានប្ដូរមកប្រើឆ្នាំប្រតិទិនក្នុងរបាយការណ៍របស់ខ្លួនវិញ។[10]

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានមានគោលបំណងបង្ហាញពីទិដ្ឋភាពបែបសត្យានុម័ត អំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជានាពេលបច្ចុប្បន្ននេះដោយកំណត់និន្នាការដែលទាក់ទងទៅនឹងច្បាប់ និងការអនុវត្តសេរីភាពមូលដ្ឋាន។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ក្រុមការងារគម្រោងបានបង្កើតនូវឧបករណ៍តាមដានការឃ្លាំមើលក្នុងការផ្ដល់ជាក្របខណ្ឌសត្យានុម័តនិងតុល្យភាព សម្រាប់ពិនិត្យអំពីស្ថានភាពសេរីភាពមូលដ្ឋាននៅកម្ពុជាដោយផ្ដោតលើការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងពលរដ្ឋ ព្រមទាំងភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល ជាមួយនឹងរដ្ឋាភិបាល។ ឧបករណ៍តាមដានឃ្លាំមើលវាយតម្លៃនេះវាយតម្លៃជាលក្ខណៈប្រព័ន្ធថាតើសេរីភាពមូលដ្ឋានត្រូវបានធានា និងអនុវត្តនៅក្នុងប្រទេសកម្ពុជាដល់កម្រិតណា។

ឧបករណ៍តាមដានការឃ្លាំមើលមានធាតុផ្សំចំនួន ១៥២ ដែលឆ្លើយតបទៅនឹងចំណុចគន្លឹះសំខាន់ៗចំនួន ៤ ដែលពិនិត្យមើលថាតើ៖

**ចំណុចគន្លឹះទី១៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**ចំណុចគន្លឹះទី២៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងប្រតិបត្តិតាម

**ចំណុចគន្លឹះទី៣៖** បុគ្គលយល់ដឹងអំពីសេរីភាពមូលដ្ឋាននិងសិទ្ធិដែលពាក់ព័ន្ធនិងយល់ថាខ្លួនអាចអនុវត្តសេរីភាពនេះដោយសេរី និង

**ចំណុចគន្លឹះទី៤៖** អង្គការសង្គមស៊ីវិលនិងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

---

[9] ក្នុងគោលបំណងនៃរបាយការណ៍នេះ សេរីភាពមូលដ្ឋានរួមមាន៖ សេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបជុំ។ គម្រោងប្រើប្រាស់នូវនិយមន័យនៃពាក្យសមាគម ដែលកំណត់ដោយអ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី និងសមាគម។

[10] នៅក្នុងរបាយការណ៍កន្លងមក ឆ្នាំទី១ សំដៅដល់ឆ្នាំ២០១៦ ឆ្នាំទី២ សំដៅដល់ឆ្នាំ២០១៧ ឆ្នាំទី៣ សំដៅដល់ ឆ្នាំ២០១៨ ឆ្នាំទី៤ សំដៅដល់២០១៩ ឆ្នាំទី៥ សំដៅដល់ឆ្នាំ២០២០ ឆ្នាំទី៦ សំដៅដល់ឆ្នាំ២០២១។

នៅក្នុងរបាយការណ៍ឆ្នាំ២០២២ នេះ វិធីសាស្ត្រប្រមូលទិន្នន័យចំនួន ៦ ត្រូវបានប្រើដើម្បីវាស់ចំណុចគន្លឹះទាំងនេះ៖ ការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន[11] យន្តការរាយការណ៍ពីហេតុការណ៍ដែលបានកើតឡើង[12] ការពិនិត្យមើលទៅលើច្បាប់ដែលពាក់ព័ន្ធ (“ការពិនិត្យច្បាប់”)[13] ឧបករណ៍វាយតម្លៃការចុះបញ្ជិកាសហជីព[14] ការស្ទង់មតិជាសាធារណៈ[15] និងការស្ទង់មតិជាមួយនឹងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព (“ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព”)[16]។ របាយការណ៍នេះបង្ហាញអំពីការវិភាគនៃចំណុចគន្លឹះនីមួយៗ និងរបស់ផ្សេងៗដោយផ្អែកលើទិន្នន័យដែលប្រមូលបាននៅក្នុងឆ្នាំ២០២២។

[11] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាគឺជាអ្នកតាមដានជាប្រចាំទៅលើការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ការតាមដាននេះផ្តោតទៅលើការផ្សព្វផ្សាយរបស់សារព័ត៌មានពីសេរីភាពខាងសមាគមនិងសិទ្ធិទាក់ទិនដទៃទៀត និងត្រូវកំណត់ដោយគោលការណ៍ណែនាំអំពីការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយផ្អែកទៅលើឧបករណ៍តាមដានការឃ្លាំមើល។

[12] ការរាយការណ៍ពីហេតុការណ៍ត្រូវបានប្រមូលតាមរយៈទម្រង់មួយដែលត្រូវបានបង្កើតឡើងដើម្បីកត់ត្រានូវការរឹតត្បិតទៅលើសេរីភាពខាងសមាគមនិងសិទ្ធិដែលទាក់ទងដទៃទៀតជាមួយបុគ្គល និងសមាគម។

[13] ការពិនិត្យលើច្បាប់ត្រូវបានធ្វើឡើងដោយមានការវិភាគពីអ្នកជំនាញទៅលើខ្លឹមសារនៃច្បាប់ គោលនយោបាយ របាយការណ៍ និងឯកសារផ្លូវការដទៃទៀតដើម្បីធ្វើការវាយតម្លៃឱ្យដឹងថាតើមានការធានាដោយច្បាប់ប៉ុណ្ណា និងមានលក្ខខណ្ឌណាផ្សេងទៀតដែរឬទេដែលធានាដល់សេរីភាពមូលដ្ឋាន ។

[14] ឧបករណ៍វាយតម្លៃការចុះបញ្ជីសហជីពកត់ត្រាទុកនូវបទពិសោធន៍របស់តំណាងសហជីព ដែលព្យាយាមចុះបញ្ជីរបស់ពួកគេដែលតម្រូវតាមច្បាប់សហជីព។

[15] ការស្ទង់មតិជាសាធារណៈគឺដើម្បីស្វែងយល់ពីការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាន។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងជាភាសាខ្មែរចន្លោះពីថ្ងៃទី០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

[16] ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវធ្វើឡើងជាប្រចាំឆ្នាំតាមរយៈប្រព័ន្ធអ៊ីនធឺណិត និងការសម្ភាសផ្ទាល់ដើម្បីស្វែងយល់ពីទស្សនៈ និងបទពិសោធន៍របស់ថ្នាក់ដឹកនាំពាក់ព័ន្ធនឹងលទ្ធភាពរបស់ពួកគេក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ នៅក្នុងឆ្នាំ២០២២ ការស្ទង់មតិនេះត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៧ ខែកញ្ញា ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។

## ១. ចំណុចគន្លឹះទី ១៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ស្របតាមបទដ្ឋានច្បាប់អន្តរជាតិដែរឬទេ?

ចំណុចគន្លឹះទី១ ពិនិត្យមើលទៅលើវិសាលភាពក្របខណ្ឌច្បាប់កម្ពុជា ដែលអនុលោមតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន។[17] នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័ត*អនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត* ដែលមានលក្ខណៈរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ និងមិនអនុលោមតាមច្បាប់អន្តរជាតិ។

កម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន) ដែលមានចែងនៅក្នុងច្បាប់កម្ពុជាមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។[18] ចំពោះការរឹតត្បិតទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិសេរីភាពខាងការជួបប្រជុំ ឬសិទ្ធិសេរីភាពខាងការបង្កើតសមាគម ដែលបានអនុញ្ញាតនៅក្រោមច្បាប់អន្តរជាតិ ការរឹតត្បិតនោះត្រូវតែអនុលោមតាមគោលការណ៍នៃលក្ខខណ្ឌតម្រូវបី មានចែងនៅក្នុងមាត្រា ១៩ មាត្រា ២១ ឬមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

---

[17] របកគំហើញនៅក្នុងចំណុចគន្លឹះទី១ ផ្តែកចម្បងលើការពិនិត្យឯកសារច្បាប់។ ការពិនិត្យឯកសារនេះ ធ្វើការវិភាគទៅលើវិសាលភាពដែលក្របខ័ណ្ឌច្បាប់ជាតិទាក់ទងនឹងសេរីភាពមូលដ្ឋានអនុលោមតាមច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលកើតចេញពី សន្ធិសញ្ញាអន្តរជាតិ និងបទដ្ឋានអន្តរជាតិដូចដែលគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UN) និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានបកស្រាយ។ នៅក្នុងរបាយការណ៍នេះ "ច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ" សំដៅដល់ច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងសេរីភាពមូលដ្ឋានរួមមានសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ដែលបានកើតចេញពីសន្ធិសញ្ញាអន្តរជាតិមានប្រទេសកម្ពុជាជារដ្ឋហត្ថលេខី។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាផ្តល់ធម្មនុញ្ញភាពដល់សិទ្ធិមនុស្សដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ព្រមទាំងកតិកាសញ្ញា និងអនុសញ្ញាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ។ សេចក្តីសម្រេចចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបកស្រាយជាផ្លូវការនូវមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថាសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នគឺអាចអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សន្ធិសញ្ញាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួមមាន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច និងវប្បធម៌ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ បន្ថែមក្រៅពីសន្ធិសញ្ញាទាំងនេះ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ក៏ប្រើបទដ្ឋានអន្តរជាតិផ្សេងៗ ដែលគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានបកស្រាយផងដែរ។

[18] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧) ទំព័រ ២ https://ccc.gov.kh/detail_info_en.php?_txtID=453 ។

| មាត្រានៃ ក.អ.ស.ព.ន | លក្ខខណ្ឌតម្រូវបី |
| --- | --- |
| មាត្រា ១៩៖ សិទ្ធិសេរីភាពខាងការបញ្ចេញមតិ | ដើម្បីអាចអនុញ្ញាតស្របតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវតែ៖<br>១) មានចែងដោយច្បាប់មានភាពជាក់លាក់ និងច្បាស់លាស់។<br>២) គោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឬការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ ឬសីលធម៌ និង<br>៣) ភាពចាំបាច់ និងសមាមាត្រជាមួយនឹងគោលបំណង។[19] |
| មាត្រា ២១៖ សិទ្ធិសេរីភាពខាងការជួបប្រជុំ | ដើម្បីអាចអនុញ្ញាតស្របតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតលើសិទ្ធិសេរីភាពខាងការជួបប្រជុំត្រូវតែ៖<br>១) អនុវត្តស្របតាមច្បាប់ ដែលមានភាពជាក់លាក់ និងច្បាស់លាស់។<br>២) ដើម្បីផលប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការពារសុខភាពសាធារណៈ សីលធម៌ ឬការពារសិទ្ធិ និងសេរីភាពអ្នកដទៃ និង<br>៣)មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ និងសមាមាត្រទៅនឹងគោលបំណង។[20] |
| មាត្រា ២២៖ សិទ្ធិសេរីភាពខាងសមាគម | ដើម្បីអាចអនុញ្ញាតស្របតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតលើសិទ្ធិសេរីភាពខាងសមាគមត្រូវតែ៖<br>១) មានចែងក្នុងច្បាប់ ដែលជាក់លាក់ និងច្បាស់លាស់។<br>២) ដើម្បីផលប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការពារសុខភាពសាធារណៈ សីលធម៌ ឬការពារសិទ្ធិ និងសេរីភាពអ្នកដទៃ និង<br>៣) ភាពចាំបាច់ និងសមាមាត្រទៅនឹងគោលបំណង។[21] |

[19] ក.អ.ស.ព.ន មាត្រា ១៩(៣), គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, អនុសាសន៍ទូទៅលេខ ៣៤៖ មាត្រា ១៩៖ សេរីភាពខាងការបញ្ចេញយោបល់ និងមតិ CCPR/C/GC/៣៤ (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) វាក្យខណ្ឌ ២៥ https://www2.ohchr.org/english/bodies/hrc/docs/gc34.pdf។

[20] ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "របាយការណ៍រួមរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី និងសមាគម និងរបស់អ្នករាយការណ៍ពិសេសអំពីការអនុវត្តដោយបង្ខំក្រៅប្រព័ន្ធតុលាការភ្លាមៗ ឬតាមអំពើចិត្តលើការគ្រប់គ្រងត្រឹមត្រូវនៃការជួបប្រជុំ" A/HRC/៣១/៦៦ (ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦) វាក្យខណ្ឌ ៣០ https://undocs.org/A/HRC/31/66 ។

[21] ក.អ.ស.ព.ន មាត្រា ២២។

*អនុក្រឹត្យស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត* (“អនុក្រឹត្យ”) ត្រូវបានអនុម័តនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ឈ្មោះដែន គឺជាអាសយដ្ឋានតែមួយគត់របស់គេហទំព័រដែលភ្ជាប់ជាមួយអាសយដ្ឋានវិធីការអ៊ីនធឺណិតជាក់ស្តែង។[22] ឈ្មោះដែន ជាធម្មតាជាឈ្មោះដែលងាយស្រួលចងចាំសម្រាប់ជាជំនួយដល់អ្នកប្រើប្រាស់អ៊ីនធឺណិតក្នុងការស្វែងរកគេហទំព័រដោយផ្ទាល់។ ឈ្មោះដែនរួមមានឈ្មោះគេហទំព័រ និងការបន្ថែមសញ្ញា (ដូចជា .com ឬ .net) ហៅថា ដែនកម្រិតទី១។ ដែនកម្រិតទី១ សំដៅដល់ឋានានុក្រមនៃឈ្មោះដែនជាតិ (ដូចជា .fr សម្រាប់ប្រទេសបារាំង ឬ .kh សម្រាប់ប្រទេសកម្ពុជា) ត្រូវបានគេហៅថាលេខកូដប្រទេស ឬឈ្មោះដែនជាតិ។ រដ្ឋាភិបាលនៃប្រទេសដែលមានលេខកូដតំណាង មិនតម្រូវឱ្យចូលរួមជាផ្លូវការក្នុងការគ្រប់គ្រងលេខកូដប្រទេសនោះទេ ប៉ុន្តែក៏នៅតែអាចចូលរួមបាន។[23] លេខកូដប្រទេសកម្ពុជាគឺ .kh ត្រូវបានគ្រប់គ្រងដោយនិយ័តករទូរគមនាគមន៍កម្ពុជា។[24] ខណៈដែលគេហទំព័ររបស់និយ័តករទូរគមនាគមន៍កម្ពុជាលើកឡើងថា ខ្លួនជា "ស្ថាប័នឯករាជ្យ" ក៏ដោយ ប៉ុន្តែយោងតាមឈ្មោះដែន gov.kh របស់ខ្លួនបង្ហាញថាខ្លួនជាស្ថាប័នរដ្ឋ។[25]

យោងតាមសាជីវកម្មសម្រាប់កំណត់ឈ្មោះ និងលេខអ៊ីនធឺណិត ការគ្រប់គ្រងលេខកូដប្រទេស ភាគច្រើនគឺកំណត់ក្នុងស្រុក ដោយស្របតាមគោលការណ៍នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ។[26] ទោះជាយ៉ាងណា រដ្ឋាភិបាលត្រូវអនុវត្តតាមកាតព្វកិច្ចសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិរបស់ខ្លួន នៅពេលអនុម័តច្បាប់ ឬអនុវត្តការធ្វើសេចក្តីសម្រេចដែលប៉ះពាល់ដល់ការគ្រប់គ្រងលេខកូដប្រទេស។[27]

អនុក្រឹត្យនេះកំណត់អាជ្ញាធរពីរ ពោលគឺក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (ក.ប.ទ) និង និយ័តករទូរគមនាគមន៍កម្ពុជា ជាស្ថាប័នទទួលបន្ទុកគ្រប់គ្រង និងនិយតកម្មលើការប្រើប្រាស់ឈ្មោះដែនជាតិ។ អនុក្រឹត្យនេះកំណត់នូវអ្វីដែលឈ្មោះដែនជាតិអាចប្រើប្រាស់បាន គ្រប់គ្រងលើការប្រើប្រាស់ឈ្មោះដែនជាតិ និងតម្រូវឱ្យអង្គភាពមួយចំនួនចុះបញ្ជីឈ្មោះដែនរបស់ខ្លួន។ វិធានដែលមានចែងក្នុងអនុក្រឹត្យនេះ មានលក្ខណៈរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ។

---

[22] ក្រុមហ៊ុនហសស្ទីងជឺ (Hostinger) “តើអ្វីជាឈ្មោះដែន? មគ្គុទ្ទេសក៍កម្រិតសម្រាប់អ្នកចាប់ផ្តើមដំបូង”, https://www.hostinger.com/tutorials/what-is-a-domain-name។

[23] សាជីវកម្មកំណត់ឈ្មោះ និងលេខអ៊ីនធឺណិត (ICANN) “សំណួរដែលសួរញឹកញាប់អំពីដែនកម្រិតទី១នៃលេខកូដប្រទេស” https://ccnso.icann.org/sites/default/files/field-attached/cctld-agenda-faqs-19oct17-en.pdf, ទំព័រ ៤; ICNL, ការវិភាគផ្នែកច្បាប់លើអនុក្រឹត្យរបស់កម្ពុជាស្តីពីឈ្មោះដែនជាតិ (ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២)។

[24] អាជ្ញាធរកំណត់លេខអ៊ីនធឺណិត “វិធានកំណត់ឈ្មោះអាស័យដ្ឋានលើអ៊ីនធឺណិត” https://www.iana.org/domains/root/db; ICNL, ការវិភាគផ្នែកច្បាប់លើអនុក្រឹត្យរបស់កម្ពុជាស្តីពីឈ្មោះដែនជាតិ (ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២)។

[25] សូមមើលមាត្រា ៥.គ នៃអនុក្រឹត្យ។ គេហទំព័ររបស់ ន.ទ.ក គឺ៖ https://trc.gov.kh/en/។

[26] សាជីវកម្មកំណត់ឈ្មោះ និងលេខអ៊ីនធឺណិត (ICANN) “សំណួរដែលសួរញឹកញាប់អំពីដែនកម្រិតទី១នៃលេខកូដប្រទេស” https://ccnso.icann.org/sites/default/files/field-attached/cctld-agenda-faqs-19oct17-en.pdf, ទំព័រ ៥ ។

[27] ICNL, ការវិភាគផ្នែកច្បាប់លើអនុក្រឹត្យរបស់កម្ពុជាស្តីពីឈ្មោះដែនជាតិ (ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២) ។

## ១.១. កង្វះខាតភាពច្បាស់លាស់ក្នុងការកំណត់អង្គភាពដែលតម្រូវឱ្យចុះបញ្ជីឈ្មោះដែនជាតិ

យោងតាមមាត្រា ៧ នៃអនុក្រឹត្យនេះ ចែងថា *"នីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់អាសយដ្ឋានអេឡិចត្រូនិកដែលមានឈ្មោះដែនជាតិ [...] នៅពេលប្រកាសប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម"*។ មាត្រានេះបង្កប់ន័យថានីតិបុគ្គលដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម មានន័យថាក្រុមហ៊ុនរកប្រាក់ចំណេញ[28] – ត្រូវមាន និងចុះបញ្ជីឈ្មោះដែនជាតិ។ អនុក្រឹត្យនេះមិនបានបញ្ជាក់ឱ្យច្បាស់ថាតើលក្ខខណ្ឌតម្រូវនេះអនុវត្តចំពោះអង្គភាពផ្សេងទៀតដែរឬអត់?

យោងតាមមាត្រា ៦ ចែងថា *"ក្រសួង ស្ថាប័នរដ្ឋដែលមានបំណងប្រើប្រាស់ឈ្មោះដែនជាតិ [...] ត្រូវដាក់ពាក្យស្នើសុំនៅ ន.ទ.ក"*។ ការប្រើប្រាស់ពាក្យ "មានបំណង" បង្ហាញថា ការមានឈ្មោះដែនជាតិមិនមែនជាកាតព្វកិច្ចរបស់ក្រសួង និងស្ថាប័នរដ្ឋនោះទេ។ ដោយឡែក យោងតាមមាត្រា ២២ ហាក់ដូចជាចែងផ្ទុយពីនេះ ព្រោះមាត្រានេះតម្រូវឱ្យក្រសួង ស្ថាប័នរដ្ឋដែលកំពុងប្រើប្រាស់ឈ្មោះដែនផ្សេងទៀត ផ្លាស់ប្តូរឈ្មោះទៅជាឈ្មោះដែនជាតិក្នុងរយៈពេល១២ខែ ចាប់ពីពេលដែលអនុក្រឹត្យនេះចូលជាធរមាន។[29]

ចំពោះអង្គភាពនានាក្រៅពីក្រុមហ៊ុនរកប្រាក់ចំណេញ ក្រសួង ស្ថាប័នរដ្ឋ ហាក់ដូចជាត្រូវស្ថិតក្រោមមាត្រា ៩ ដែលចែងថា *"បុគ្គលដែលមានបំណងប្រើប្រាស់ឈ្មោះដែនជាតិ អាចបំពេញពាក្យស្នើសុំនៅ ន.ទ.ក តាមរយៈប្រព័ន្ធស្វ័យប្រវត្តិ ឬតាមរយៈភ្នាក់ងារចុះឈ្មោះដែនជាតិ"*។ ជាថ្មីម្តងទៀត ការប្រើប្រាស់ពាក្យ "មានបំណង" អាចបង្កប់ន័យមិនត្រឹមត្រូវដូចជា ករណីរបស់ក្រសួង និងស្ថាប័នរដ្ឋ ការមានឈ្មោះដែនជាតិមិនមែនជាកាតព្វកិច្ចសម្រាប់អង្គភាពផ្សេងទៀតនោះទេ។

ការប្រើប្រាស់ភាសាឱ្យបានច្បាស់លាស់ជាងនេះ គឺចាំបាច់ណាស់ដើម្បីធានាថា អនុក្រឹត្យនេះមិនបើកទូលាយដែលនាំឱ្យមានការបកស្រាយខុសៗគ្នា ក៏ដូចជាការអនុវត្តច្បាប់តាមតែអំពើចិត្ត ឬដោយមិនស៊ីសង្វាក់គ្នាពីសំណាក់អាជ្ញាធរ។[30] បច្ចុប្បន្ន អនុក្រឹត្យនេះមិនមានភាពច្បាស់លាស់គ្រប់គ្រាន់ដែលអនុញ្ញាតឱ្យអង្គភាពផ្សេងៗក្រៅពីក្រុមហ៊ុនរកប្រាក់ចំណេញ ក្រសួង និងស្ថាប័នរដ្ឋ យល់ថាខ្លួនត្រូវបានតម្រូវឱ្យចុះបញ្ជីឈ្មោះដែនជាតិដែរឬទេ។

---

[28] អង្គការសង្គមស៊ីវិលចុះបញ្ជីនៅក្រសួងមហាផ្ទៃ ចំណែកនីតិបុគ្គលផ្សេងទៀតចុះបញ្ជីនៅក្រសួងផ្សេងៗទៀត។

[29] មាត្រា ២២ នៃអនុក្រឹត្យ៖ *"គ្រប់ក្រសួង ស្ថាប័នរដ្ឋដែលកំពុងប្រើប្រាស់ឈ្មោះដែនផ្សេងទៀត/ឬកំពុងផ្ទុកទិន្នន័យនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្តូរមកប្រើឈ្មោះដែនជាតិ និងត្រូវបង្វែរការផ្ទុកទិន្នន័យមកនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ១២ (ដប់ពីរ) ខែបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន លើកលែងតែមានការកំណត់ដោយឡែកដោយរាជរដ្ឋាភិបាល"*។

[30] តម្រូវការនៃភាពច្បាស់លាស់ថាតើអង្គភាពណាខ្លះដែលត្រូវបានតម្រូវឱ្យចុះបញ្ជីឈ្មោះដែនជាតិ បង្ហាញយ៉ាងច្បាស់ ទោះបីជាភាសានៃអនុក្រឹត្យនេះបង្ហាញថា ការចុះបញ្ជីមិនមែនជាកាតព្វកិច្ចសម្រាប់អង្គភាពក្រៅពីក្រុមហ៊ុនរកប្រាក់ចំណេញ ក្រសួង និងស្ថាប័នរដ្ឋាភិបាលក៏ដោយ ប៉ុន្តែយោងតាមកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយ ICNL បានបង្ហាញថា អង្គការសង្គមស៊ីវិលកម្ពុជាមួយចំនួនត្រូវបានមន្ត្រីប្រាប់ថា ខ្លួនត្រូវបានតម្រូវឱ្យមានឈ្មោះដែនជាតិ និងត្រូវចុះបញ្ជីផងដែរ។

## ១.២. អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ដោយហាមឃាត់មាតិកាលើគេហទំព័រ

ការណ៍ដែលក្រុមហ៊ុនរកប្រាក់ចំណេញ ក្រសួង ស្ថាប័នរដ្ឋ រួមទាំងអង្គភាពផ្សេងទៀតផងដែរដូចជា សមាគម អង្គការ និងសហជីព ត្រូវបានតម្រូវឱ្យចុះបញ្ជីឈ្មោះដែនជាតិ ដែលការចុះបញ្ជីនេះមានន័យថា ពួកគេនឹងត្រូវមានកាតព្វកិច្ចដូចមានចែងនៅក្នុងអនុក្រឹត្យ។ កាតព្វកិច្ចទាំងនេះរឹតត្បិតលើសមត្ថភាពរបស់ម្ចាស់ឈ្មោះដែនជាតិ ក្នុងការចែកចាយព័ត៌មានដែលជាធាតុផ្សំដ៏សំខាន់នៃសេរីភាពខាងការបញ្ចេញមតិ ដែលមិនអនុលោមតាមបទដ្ឋានអន្តរជាតិសេរីភាពខាងការបញ្ចេញមតិឡើយ។

យោងតាមមាត្រា ១១ នៃអនុក្រឹត្យនេះចែងថា អង្គភាពដែលបានចុះបញ្ជីឈ្មោះដែនរបស់ខ្លួន មិនត្រូវប្រើប្រាស់ឈ្មោះដែនជាតិដើម្បីផ្សព្វផ្សាយព័ត៌មានផ្សេងៗដែលប៉ះពាល់ដល់ *"វប្បធម៌ សីលធម៌ ទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ ផលប្រយោជន៍សាធារណៈស្របច្បាប់ សន្តិសុខជាតិ ឬ សណ្តាប់ធ្នាប់សាធារណៈនោះទេ"* ដែលជាការរឹតត្បិតមួយលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

ពាក្យ *"វប្បធម៌ សីលធម៌ ទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ ផលប្រយោជន៍សាធារណៈស្របច្បាប់ [និង...] សណ្តាប់ធ្នាប់សាធារណៈ"* គឺជាកម្មវត្ថុសំខាន់ដែលធ្វើឱ្យម្ចាស់ឈ្មោះដែនជាតិមានការពិបាកក្នុងការស្វែងយល់ឱ្យបានច្បាស់ថា តើខ្លឹមសារអ្វីខ្លះបំពានលើមាត្រា ១១ ដែលរារាំងដល់ការកែសម្រួលការអនុវត្តរបស់ខ្លួន ដើម្បីធានាឱ្យបាននូវការអនុលោមតាមកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាម្ចាស់ឈ្មោះដែនជាតិ។ ចំពោះការប្រើពាក្យថា *"សន្តិសុខជាតិ"* ក្រុមប្រឹក្សាសិទ្ធិមនុស្សបានបញ្ជាក់យ៉ាងច្បាស់ថា *"ការផ្តល់ហេតុផលមិនច្បាស់លាស់ និងទូលំទូលាយខ្លាំងពេក" ការចែងមិនជាក់លាក់អំពី "សន្តិសុខជាតិ" គឺមិនមានលក្ខណៈគ្រប់គ្រាន់ច្បាស់លាស់ជាច្បាប់នោះទេ។*[31]

មាត្រា ១១ មិនបានអនុលោមតាមចំណុចទីមួយនៃលក្ខខណ្ឌតម្រូវបីចំណុចនៃមាត្រា ១៩ នោះទេ ដែលតម្រូវឱ្យច្បាប់ត្រូវមានភាពច្បាស់លាស់ក្នុងកម្រិតជាក់លាក់មួយសម្រាប់ការរឹតត្បិតលើសេរីភាពមូលដ្ឋាន។ ដោយពិចារណាលើភាពទូលំទូលាយ និងភាពមិនច្បាស់លាស់នៃលក្ខខណ្ឌទាំងនេះ ខ្លឹមសារស្ទើរតែទាំងអស់ រួមទាំងខ្លឹមសារទូទៅផងនោះ អាចត្រូវបានចាត់ទុកថាបង្កការប៉ះពាល់ដល់ *"វប្បធម៌ សីលធម៌ ទំនៀមទម្លាប់ប្រពៃណីល្អ សិទ្ធិបុគ្គល សិទ្ធិអ្នកប្រើប្រាស់ ផលប្រយោជន៍សាធារណៈស្របច្បាប់ សន្តិសុខជាតិ ឬ សណ្តាប់ធ្នាប់សាធារណៈ"*។ ដូច្នេះមាត្រា១១ អនុញ្ញាតឱ្យរដ្ឋាភិបាល តាមរយៈអាជ្ញាធរទូរគមនាគមន៍ ធ្វើការសម្រេចតាមតែអំពើចិត្តនៅពេលដែលឈ្មោះដែនជាតិ ត្រូវបានប្រើប្រាស់ដោយហេតុផលមិនត្រឹមត្រូវ និងដាក់ទណ្ឌកម្មចំពោះអង្គភាពណាដែលប្រើប្រាស់ឈ្មោះដែនជាតិទាំងនេះ ដោយបំពានលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

[31] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សិទ្ធិឯកជនភាពក្នុងយុគសម័យឌីជីថល A/HRC/39/39 (ថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០១៨) វាក្យខណ្ឌទី ៣៥,https://documents-dds-ny.un.org/doc/UNDOC/GEN/G18/239/58/PDF/G1823958.pdf។

ទាំងមាត្រា ៤ មាត្រា ១៥ មានបញ្ញត្តិចែងថា ក្នុងករណីមិនអនុវត្តតាមកាតព្វកិច្ចក្រោមមាត្រា ១១ នោះ ន.ទ.ក អាចលុបឈ្មោះដែនជាតិរបស់អង្គភាពនោះចេញពីប្រព័ន្ធគ្រប់គ្រងឈ្មោះដែនជាតិ។ ចំពោះក្រុមហ៊ុនរកប្រាក់ចំណេញដែលមានស្ថានភាពគតិយុត្ត អាស្រ័យលើការមានឈ្មោះដែនជាតិដែលបានចុះបញ្ជី[32] ការដាក់ទណ្ឌកម្មបែបនេះអាចមានន័យថា ក្រុមហ៊ុនមិនអាចធ្វើប្រតិបត្តិការបានដោយស្របច្បាប់នៅកម្ពុជានោះទេ។ ដោយសារតែការដាក់ទណ្ឌកម្មអាចនាំមកនូវផលវិបាកធ្ងន់ធ្ងរ ដោយការពិន័យនេះហាក់មានលក្ខណៈហួសហេតុ ដែលចាំបាច់ក្នុងការពិចារណាលើវិធានការដែលមិនសូវធ្ងន់ធ្ងរ ដោយអនុវត្តស្របតាមគោលបំណងស្របច្បាប់នៃមាត្រា ១៩ ។ មាត្រា ១៥ នៃអនុក្រឹត្យនេះរំលោភលើលក្ខខណ្ឌដែលការរឹតត្បិតត្រូវតែមានភាពចាំបាច់ និងសមាមាត្រ ដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់ក្នុងចំណុចទីបីចំពោះលក្ខខណ្ឌតម្រូវទាំងបីនៃមាត្រា ១៩ ។

## ១.៣. អនុក្រឹត្យនេះរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិដោយហាមឃាត់ឈ្មោះដែនមួយចំនួន

យោងតាមមាត្រា ៨.ឃ នៃអនុក្រឹត្យនេះចែងថា ឈ្មោះដែន *"ដែលបង្កផលប៉ះពាល់ដល់សីលធម៌ ប្រពៃណី ជំនឿសាសនា និងផ្ទុយពីច្បាប់ និងបទបញ្ញត្តិជាធរមាន"* គឺមិនអាចចុះបញ្ជីបានទេ។ ឈ្មោះដែនគឺជាមធ្យោបាយមួយសម្រាប់អង្គភាពក្នុងការផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់គេហទំព័រ ស្វែងរកគេហទំព័ររបស់ខ្លួន។ ដូចនេះ ឈ្មោះដែនអាចជាការរួមបញ្ចូលគ្នានៃពាក្យគន្លឹះដើម្បីបង្កើតឈ្មោះពិសេសមួយខុសប្លែកពីគេ ដែលអាចប្រាប់អ្នកប្រើប្រាស់ និងម៉ាស៊ីនស្វែងរកអំពីអ្វីដែលមាននៅលើគេហទំព័រ និងអាចជាមធ្យោបាយមួយនៃការបញ្ចេញមតិផងដែរ។ ដោយការហាមឃាត់ឈ្មោះដែនដែលប៉ះពាល់ដល់ *"សីលធម៌ ប្រពៃណី និងសាសនា"* អនុក្រឹត្យនេះអាចរារាំងអង្គភាពនានាក្នុងការជ្រើសរើសឈ្មោះដែនរបស់ខ្លួនដោយសេរី។ ដូច្នេះ មាត្រា ៨.ឃ គឺរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

ពាក្យ *"សីលធម៌"*និង *"ប្រពៃណី"* មិនមានភាពច្បាស់លាស់គ្រប់គ្រាន់ ដើម្បីទប់ស្កាត់ការបកស្រាយខ្លឹមសារដោយអត្តនោម័តនោះទេ។ ន.ទ.ក អាចបកស្រាយក្នុងន័យទូលាយនូវលក្ខខណ្ឌទាំងនេះ ដើម្បីបង្ហាញពីហេតុផលដែលខ្លួនបដិសេធមិនផ្តល់ឱ្យអង្គភាព នូវឈ្មោះដែនដែលខ្លួនបានជ្រើសរើស។ ដោយសារការប្រើប្រាស់ពាក្យមិនច្បាស់លាស់ បញ្ញត្តិនេះបំពានចំណុចទីមួយនៃលក្ខខណ្ឌតម្រូវបីចំណុចមាត្រា១៩ ដែលតម្រូវឱ្យច្បាប់ត្រូវមានភាពច្បាស់លាស់ក្នុងកម្រិតជាក់លាក់មួយ សម្រាប់ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ។

ចំពោះពាក្យ *"សាសនា"* នេះក៏ហាក់មានផលប៉ះពាល់ផងដែរ។ គណៈកម្មាធិការសិទ្ធិមនុស្សបានរកឃើញថា ការហាមឃាត់ការបញ្ចេញមតិដោយមិនមានការគោរពចំពោះសាសនា គឺមានវិសមិតភាពជាមួយនឹង

[32] មាត្រា ៧ នៃអនុក្រឹត្យ។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[33] បើការបញ្ចេញមតិបែបនេះមិនមែនជា *"ការអំពាវនាវ [...] ឱ្យមានការស្អប់ខ្ពើមសាសនា ដែលជាការញុះញង់ឱ្យមានការរើសអើង ការប្រទូស្តរាយ ឬអំពើហិង្សា"*[34] ម្យ៉ាងវិញទៀត ការហាមឃាត់ឈ្មោះដែន *"ដែលប៉ះពាល់"* ដល់សាសនា មានលក្ខណៈទូលំទូលាយពេក ហើយមិនអនុលោមតាមបទដ្ឋានអន្តរជាតិទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ។

បន្ថែមលើការព្រួយបារម្ភទាំងនេះ ការកំណត់ឈ្មោះដែនជាតិណាមួយដែលត្រូវហាមឃាត់ គឺជាភារកិច្ចរបស់ ន.ទ.ក ដែលជាស្ថាប័នរដ្ឋាភិបាល។ ដូច្នេះ អនុក្រឹត្យនេះតម្រូវឱ្យអង្គភាពបង្កើតឈ្មោះដែន ដោយមានតែរាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះដែលអាចកំណត់ពីការចុះបញ្ជីបាន។ តាមរយៈនេះនាំឱ្យមានការព្រួយបារម្ភថារាជរដ្ឋាភិបាលកម្ពុជាអាចបំពានលើឆន្ទានុសិទ្ធិដែលខ្លួនមាន ក្នុងការបដិសេធផ្តល់ឈ្មោះដែនដោយហេតុផលតាមអំពើចិត្ត ដោយត្រួតពិនិត្យលើអង្គភាពដែលបានបញ្ជូនឈ្មោះដែនរបស់ខ្លួន ដែលជាការបំពានលើសេរីភាពខាងការបញ្ចេញមតិ។

[33] អត្ថាធិប្បាយទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ៖ មាត្រា ១៩៖ សេរីភាពខាងការគិត និងការបញ្ចេញមតិ CCPR/C/GC/34 (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) វាក្យខណ្ឌទី៤៨ ,https://www2.ohchr.org/english/bodies/hrc/docs/gc34.pdf។

[34] មាត្រា ២០ កថាខណ្ឌទី ២ នៃ ក.អ.ស.ព.ន។

## ២. ចំណុចគន្លឹះទី ២ ៖ តើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវដែរឬទេ?

ចំណុចគន្លឹះទីពីរ ពិនិត្យមើលថា តើក្របខណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្ត និងពង្រឹងការអនុវត្តបានត្រឹមត្រូវក្នុងកម្រិតណាដែរ?[35] ដើម្បីឱ្យបុគ្គលម្នាក់ៗទទួលបានសេរីភាពមូលដ្ឋានរបស់ខ្លួន មិនមែនគ្រាន់តែក្របខណ្ឌច្បាប់ជាតិអនុលោមតាមបទដ្ឋាន និងច្បាប់សិទ្ធិមនុស្សអន្តរជាតិប៉ុណ្ណោះទេ។ ការអនុវត្តច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋាន ត្រូវធ្វើឡើងស្របតាមលិខិតគតិយុត្ត ដោយសង្គតិភាព និងមិនមែនតាមទំនើងចិត្ត។

**<u>របកគំហើញសំខាន់ៗ៖</u>** ទិន្នន័យពីចំណុចគន្លឹះទីពីរបង្ហាញថា សេរីភាពមូលដ្ឋាននៅកម្ពុជាបានបន្តធ្លាក់ចុះក្នុងឆ្នាំ២០២២។ អាជ្ញាធរបានបង្កើនការយាយីទៅលើបុគ្គល ដែលអនុវត្តសេរីភាពមូលដ្ឋានកាន់តែខ្លាំងឡើងៗ។ ជាងនេះទៀត ការរឹតត្បិតសេរីភាពមូលដ្ឋាន ភាគច្រើនមិនបានអនុវត្តតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិទេ។ សកម្មជនបក្សជំទាស់ បុគ្គលដែលតស៊ូមតិដើម្បីនាំមកនូវលក្ខខណ្ឌការងារកាន់តែប្រសើរ ក៏ដូចជាអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដែលរិះគន់រដ្ឋាភិបាល ភាគច្រើនត្រូវបានរដ្ឋាភិបាលកំណត់ជាមុខសញ្ញា។

### ២.១. ការរឹតត្បិត ឬការរំលោភលើសេរីភាពមូលដ្ឋាន

#### ចំនួនហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានលើសេរីភាពមូលដ្ឋាន

*តួលេខទី ៤៖ ចំនួនហេតុការណ៍សរុបដែលបានរាយការណ៍ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២២*




ក្នុងរយៈពេលពេញមួយឆ្នាំនៃឆ្នាំ២០២២ គម្រោងសេរីភាពមូលដ្ឋាន បានកត់ត្រាហេតុការណ៍ចំនួន ៥៦៦[36] ទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋាន (តួលេខទី៤)។ មានតែសេរីភាពមូលដ្ឋានចំនួនបីប៉ុណ្ណោះដែលត្រូវបានការពារ (តួលេខទី១)។ ២០៩ នៃហេតុការណ៍ទាំងនេះរួមមានយ៉ាងហោចណាស់ការរឹតត្បិតចំនួនមួយ (កើនឡើង ១២៥% បើប្រៀបធៀបទៅនឹងឆ្នាំ ២០២១)[37] និង ៣៥៤ ហេតុការណ៍ផ្សេងទៀតរួមមានយ៉ាងហោច

[35] របកគំហើញនៅក្នុងចំណុចគន្លឹះនេះផ្អែកតាមទិន្នន័យដែលប្រមូលបានពីការឃ្លាំមើលតាមប្រព័ន្ធផ្សព្វផ្សាយ ការរាយការណ៍ពីហេតុការណ៍ ការស្ទង់មតិសាធារណៈ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព និងការពិភាក្សាក្រុម។

[36] ពាក្យ *ហេតុការណ៍* សំដៅដល់ករណីរំលោភបំពាន រឹតត្បិត ឬការការពារសេរីភាពមូលដ្ឋានមួយក្នុងចំណោមសេរីភាពមូលដ្ឋានទាំងបីដែលត្រូវបានកត់ត្រា។

[37] ការរឹតត្បិត និងការរំលោភ មានភាពខុសគ្នានៅត្រង់ថា ការរឹតត្បិតអាចអនុញ្ញាតបានតាមផ្លូវច្បាប់ក្នុងកាលៈទេសៈជាក់លាក់មួយចំនួន ខណៈដែលការរំលោភបំពានជាក់ស្តែង គឺជាអំពើផ្ទុយទៅនឹងបទដ្ឋានច្បាប់អន្តរជាតិ។ ឧទាហរណ៍ ដើម្បីកំណត់ថាតើការរឹតត្បិតសេរី

ណាស់ការរំលោភបំពានចំនួនមួយ (កើនឡើង ៤៣% បើប្រៀបធៀបទៅនឹងឆ្នាំ២០២១)។ តួលេខទាំងនេះចង្អុលបង្ហាញពីនិន្នាការដ៏គួរឱ្យព្រួយបារម្ភនៃការរឹតត្បិត និង ការរំលោភលើសេរីភាពមូលដ្ឋាន ដែលបន្តកើនឡើងដល់កម្រិតមុនពេលកើតមានវិបត្តិនៃជំងឺកូវីដ (២០២០)។ មានការវិវត្តបន្ថែម បានលេចឡើងក្នុងអំឡុងពេលប្រាំឆ្នាំ។ ទីមួយ ក្នុងឆ្នាំ២០១៦ និងឆ្នាំ២០២០ ជាឆ្នាំដែលមិនមានការបោះឆ្នោត ចំនួនហេតុការណ៍ដែលបានសង្កេតមើលគឺមានកម្រិតទាប បើប្រៀបធៀបទៅនឹងឆ្នាំផ្សេងទៀត។ បើប្រៀបធៀបរវាងឆ្នាំ២០១៧ និងឆ្នាំ២០២២ ដែលជាឆ្នាំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ បានសង្កេតឃើញហេតុការណ៍មានតួលេខខ្ពស់ប្រហាក់ប្រហែលគ្នា ពោលគឺចំនួន ៥៩៣ ហេតុការណ៍ និង ៥៦៦ ហេតុការណ៍។ ចុងក្រោយ យើងសង្កេតឃើញថា នៅឆ្នាំ២០១៨ ដែលជាឆ្នាំបោះឆ្នោតសកលចុងក្រោយនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវចំនួនហេតុការណ៍។ ដូច្នេះ យើងរំពឹងថាឆ្នាំ២០២៣ ដែលជាឆ្នាំបោះឆ្នោតសកលនាអាណត្តិបន្ទាប់នឹងបង្ហាញលំនាំដូចគ្នា ហើយអាចនឹងកត់ត្រាចំនួនហេតុការណ៍ខ្ពស់ជាងក្នុងឆ្នាំ២០២២។

*តួលេខទី ៥៖ ចំនួនហេតុការណ៍ដែលបានកត់ត្រាដោយគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានដែលក្នុងនោះសេរីភាពមូលដ្ឋានត្រូវបានការពារ រឹតត្បិត ឬរំលោភបំពានក្នុងឆ្នាំ២០២២ ដោយបែងចែកតាមខែនីមួយៗ*




ករណីរំលោភបំពានជាច្រើន (២៣៨ ករណី ឬស្មើនឹង៦៧%) បានកើតឡើងក្នុងរយៈពេល៦ខែដំបូងនៅមុន និងក្រោយពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ថ្ងៃទី០៥ ខែមិថុនា ចំនួននៃការរឹតត្បិត និងការរំលោភបំពាន[38] បានឈានដល់កម្រិតខ្ពស់បំផុតនៅអំឡុងខែមីនា ឆ្នាំ២០២២ ដោយមាន ១៩ ហេតុការណ៍ក្នុងចំណោម ៨៨ ហេតុការណ៍ ដែលបានកត់ត្រា ពាក់ព័ន្ធជាមួយនឹងករណីអាជ្ញាធរកំណត់មុខសញ្ញាលើគណបក្សនយោបាយ និងបេក្ខជនគណបក្សនយោបាយជំទាស់។ បេក្ខជនចំនួនពីររូប នៃគណបក្សភ្លើងទៀនត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ពីបទក្លែងឯកសារ ដើម្បីចុះបញ្ជីបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់នៅ ខេត្ត

ភាពខាងបញ្ចេញមតិគឺជាការរំលោភបំពានឬអត់នោះ គម្រោងពិនិត្យមើលថាតើការរឹតត្បិតនោះបានបំពេញលក្ខខណ្ឌ៣ចំណុចដែលមានចែងក្នុងមាត្រា ១៩ នៃអនុសញ្ញា ក.អ.ស.ព.ន ដែរឬទេ។ ប្រសិនបើការរឹតត្បិតនោះមិនបំពេញតាមលក្ខខណ្ឌ៣ចំណុចនោះទេ នឹងត្រូវចាត់ទុកថាជាការរំលោភបំពាន។

[38] ចំនួននៃការរឹតត្បិត និងការរំលោភបំពានសរុបខ្ពស់ជាងចំនួនហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពាន ព្រោះហេតុការណ៍មួយជារឿយៗតែងមានការរឹតត្បិតលើសពី១។

ពោធិ៍សាត់។[39] បេក្ខជនពីគណបក្សខ្មែរស្រឡាញ់ជាតិក្នុងខេត្តកណ្ដាល ក៏ត្រូវបានចាប់ខ្លួនផងដែរ។[40] កាលពីថ្ងៃទី១៧ ខែមីនា សាលាដំបូងរាជធានីភ្នំពេញ ក៏បានកាត់ទោសសមាជិកក្រុមប្រឹក្សា និងសកម្មជនអតីតគណបក្សសង្គ្រោះជាតិចំនួន ២១ នាក់ ឱ្យជាប់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ។[41]

ជាងនេះទៀត ក្នុងអំឡុងខែមីនានេះដែរ បុគ្គលិកកាស៊ីណូណាហ្គាវើលដ៍ដែលត្រូវបានបញ្ឈប់ពីការងារបានរៀបចំការជួបប្រជុំគ្នាដោយសន្តិវិធីជាទៀងទាត់ក្នុងរាជធានីភ្នំពេញ ដើម្បីទាមទារឱ្យមានការដោះស្រាយវិវាទការងារដោយយុត្តិធម៌ជាមួយភាគីនិយោជក។ កងកម្លាំងសន្តិសុខសាធារណៈ និងឯកជនបានរារាំងកម្មករនិយោជិតមិនឱ្យចូលទៅជិតអគារ ព្រមទាំងបានវាយដំ ចាប់ខ្លួន និងឃុំខ្លួនអ្នកចូលរួមក្នុងសកម្មភាពប្រមូលផ្តុំផងដែរ។ ក្នុងករណីមួយចំនួន ពួកគេក៏បានរារាំងអ្នកឃ្លាំមើលការជួបប្រជុំ និងអ្នកសារព័ត៌មានក្នុងការយកព័ត៌មានពីហេតុការណ៍ និងតាមដានសកម្មភាពរបស់អាជ្ញាធរ។[42]

## ២.១.១. ឆ្នាំ២០២២ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវការឃុំខ្លួនបុគ្គលដែលបានអនុវត្តសេរីភាពមូលដ្ឋាន

ក្នុងឆ្នាំ២០២២ មានការកើនឡើងគួរឱ្យកត់សម្គាល់ នូវចំនួនបុគ្គលដែលត្រូវបានអាជ្ញាធរឃុំខ្លួន បន្ថែមលើការបន្តកើតមាននូវករណីនៃការចាប់ខ្លួន ការកាត់ទោសនិងសួរចម្លើយបុគ្គលដែលអនុវត្តសេរីភាពមូលដ្ឋាន។ ក្នុងឆ្នាំ២០២២នេះ បុគ្គលចំនួន ២,៦២៦ នាក់ ត្រូវបានឃុំខ្លួន ដែលចំនួននេះកើនឡើង ២,១០៧% បើប្រៀបធៀបទៅនឹងឆ្នាំ២០២១។ ចំនួន ២,៥៥៣ នៃចំនួនខាងលើនេះ (ស្មើនឹង៩៧%) ពាក់ព័ន្ធនឹងបុគ្គលិកក្រុមហ៊ុន

---

39 បុគ្គលិកវីអូឌី "គណបក្សភ្លើងទៀនចោទប្រកាន់ថាមានការគំរាមកំហែងច្រើន រីឯបេក្ខជនគណបក្សតូចៗបដិសេធអំពីសំណូក" (វីអូឌី, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២) <https://vodenglish.news/candlelight-party-alleges-more-intimidation-small-party-candidate-denies-bribery/>, ណាត សុភាព មន្ត្រីគណបក្សភ្លើងទៀនចំនួន ០២ រូប ត្រូវបានបញ្ជូនទៅតុលាការជុំវិញការក្លែងឯកសារ', (វីអូឌី, ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២) <https://www.vodkhmer.news/2022/03/14/pursat-authorities-send-two-candlelight-party-candidates-to-court-involved-in-falsification-of-documents>។

40 ម៉ៅ សុធានី, នគរបាលស្រុកខ្សាច់កណ្ដាលចាប់ខ្លួនសមាជិកម្នាក់នៃគណបក្សខ្មែរស្រឡាញ់ជាតិ (អាស៊ីសេរី, ថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០២២)< https://www.rfa.org/khmer/news/politics/kandal-authorities-arrested-candidate-for-chief-commune-of-cambodia-national-love-party-03052022183107.html>។

41 ឃួន ណារីម "អ្នកនយោបាយគណបក្សប្រឆាំងចំនួន ២១នាក់ មានទោសចន្លោះពី៥ ទៅ ១០ឆ្នាំ បន្ទាប់ពីការកាត់ក្ដីដោយអយុត្តិធម៌" (ខេមបូចារ, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២) < https://cambojanews.com/21-opposition-politicians-get-between-5-and-10-years-after-unfair-trial >។

42 រិទ្ធី 'អាជ្ញាធរប្រើហិង្សាលើក្រុមអ្នកចូលរួមកូដកម្មក្រុមហ៊ុនណាហ្គាវើលដ៍ ជាង ១០០ នាក់ ដែលបន្តទាមទារឱ្យមានដំណោះស្រាយ' (អាស៊ីសេរី, ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២) < https://www.rfa.org/khmer/news/human-rights/follow-up-the-nagaworld-strikers-peaceful-gathering-03202022123343.html > ខៃ សុណង 'អាជ្ញាធរបង្ខំឱ្យក្រុមអ្នកចូលរួមកូដកម្មនៅណាហ្គាវើលដ៍ចាកចេញ' (អាស៊ីសេរី, ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២២) < https://www.rfa.org/khmer/news/social-economy/authorities-continue-to-force-nagaworld-employees-to-stop-strikers-03272022035928.html >, គាត សុរិទ្ធដារី 'ក្រុមអ្នកតវ៉ាក្រុមហ៊ុនណាហ្គាវើលដ៍បានប្រមូលផ្ដុំគ្នាម្ដងទៀត អាជ្ញាធរដាក់សម្ពាធអ្នកឃ្លាំមើលជុំវិញការរូបថត' (វីអូឌី, ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២) <https://vodenglish. news/nagaworld-protesters-rounded-up-again-authorities-pressure-observers-over-photographs >។

ណាហ្គាវើលដ៍ (សូមមើលព័ត៌មានខាងលើ)[43] ដែលត្រូវបានចាប់ដាក់លើរថយន្តក្រុង និងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ហើយត្រូវបានកងកម្លាំងសន្តិសុខឃុំខ្លួនបណ្ដោះអាសន្នជាច្រើនលើកច្រើនសារ។[44] ករណីឃុំខ្លួនចំនួន ៧៣ នាក់ ដែលនៅសល់គឺទាក់ទងនឹងសមាជិកគណបក្សជំទាស់ ដែលជាប់ពាក់ព័ន្ធជាមួយហេតុការណ៍បោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ សកម្មជនដីធ្លី និងសិទ្ធិការងារ និងអ្នកសារព័ត៌មាន។[45]

*តួលេខទី ៦៖ ចំនួនអ្នកដែលទទួលរងទណ្ឌកម្មព្រហ្មទណ្ឌចំពោះការអនុវត្តសេរីភាពមូលដ្ឋាន*




[43] តួលេខនៃការឃុំខ្លួនដែលបានបង្ហាញនៅក្នុងផ្នែកនេះ រួមបញ្ចូលគ្រប់ករណីនៃការឃុំខ្លួនដែលកត់ត្រាដោយគម្រោង ហើយមិនឆ្លុះបញ្ចាំងពីចំនួនជាក់ស្តែងនៃចំនួនអ្នកដែលត្រូវបានឃុំខ្លួនដោយកងកម្លាំងក្នុងឆ្នាំ២០២២ នោះទេ។

[44] ម៉ៅ សុជានី "អាជ្ញាធរបន្តបង្ក្រាបក្រុមអ្នកចូលរួមកូដកម្មនៅណាហ្គាវើលដ៍ជិត ៨០ នាក់" (អាស៊ីសេរី, ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២) <https://www.rfa.org/khmer/news/social-economy/authorities-continue-to-crack-down-on-nagaworld-strikers-from-demanding-a-solution-near-the-company-building-06102022134903.html >, យួន ណារីម "ក្រុមអ្នកចូលរួមកូដកម្មនៅណាហ្គាវើលដ៍ជិត ៦០ នាក់ ត្រូវបានឃុំខ្លួនដើម្បីធ្វើចត្តាឡីស័ក បន្ទាប់ពីបានបន្តធ្វើការតវ៉ា" (ខេមបូចា, ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២) <https://cambojanews.com/about-60-nagaworld-strikers-detained-for-quarantine-after-resuming-protest/ >, Eugene Whong "កម្ពុជាឃាត់ខ្លួនបុគ្គលិកកាស៊ីណូណាហ្គាវើលដ៍ជាង ១០០ នាក់" (អាស៊ីសេរី, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២) < https://www.rfa.org/english/news/cambodia/nagaworld-02222022165541.html >។

[45] ញ៉ែម សុខន ' អ្នកសារព័ត៌មានបីនាក់ដែលគេចាប់ខ្លួន ត្រូវបានដោះលែងនៅកំពង់ឆ្នាំង' (វីអូឌី, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២) < https://vodenglish.news/three-journalists-arrested-released-in-kampong-chhnang/ >, ហា ណូយ, 'អ្នកសារព័ត៌មានត្រូវបានចាប់ខ្លួននៅក្នុងទិវាសេរីភាពសារព័ត៌មានពិភពលោក' (វីអូអេ, ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២) < https://khmer.voanews.com/a/authorities-detain-journalist-as-civil-society-celebrates-world-press-freedom-day/6553696.html>, ប៉ា សុខេង 'អ្នកសារព័ត៌មានចោទថាមានការគំរាមកំហែងចំពោះការថតរូបនគរបាលចរាចរណ៍យកលុយ' (វីអូឌី, ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២) < https://vodenglish.news/journalist-alleges-threats-after-filming-traffic-police-taking-money/ >។

## ២.១.២. ការរឹតត្បិត និងការរំលោភលើសេរីភាពមូលដ្ឋាន បានកំណត់មុខសញ្ញាទៅលើក្រុមផ្សេងៗដូចជា អ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និងកម្មករនិយោជិតដែលជាសមាជីព[46]

*តួលេខទី ៧៖ ប្រភេទជនរងគ្រោះពីការរឹតត្បិត ការរំលោភបំពាន សេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២២*




ការរឹតត្បិតឬការរំលោភបំពាសេរីភាពមូលដ្ឋានក្នុងឆ្នាំ២០២២ ភាគច្រើនបានកំណត់មុខសញ្ញាលើអ្នកការពារសិទ្ធិមនុស្ស (១៩០ ហេតុការណ៍) សកម្មជននយោបាយ ឬអ្នកនយោបាយ (១៤១) និងកម្មករឬសមាជិក សហជីព (១៣៥)។ ៨៤ ករណីក្នុងចំណោម ១៣៥ ហេតុការណ៍នៃការរឹតត្បិត ឬការរំលោភបំពានកើតឡើងលើកម្មករ ឬសមាជិកសហជីពក្រុមហ៊ុនណាហ្គាវើលដ៍ ដែលត្រូវបានគេបញ្ឈប់ពីការងារ (៦២%)។ ហេតុការណ៍ចំនួន ១០៩ ក្នុងចំណោម ១៤១ ហេតុការណ៍ដែលកំណត់មុខសញ្ញាលើសកម្មជននយោបាយឬអ្នកនយោបាយ ពាក់ព័ន្ធនឹងសមាជិក ឬអ្នកគាំទ្រគណបក្សភ្លើងទៀនដែលជាគណបក្សជំទាស់ (៧៧%)។ រាជរដ្ឋាភិបាលក៏បានកំណត់មុខសញ្ញាអ្នកសារព័ត៌មាន និងស្ថាប័នផ្សព្វផ្សាយដែលបានផ្សាយប្រធានបទសើបពាក់ព័ន្ធនឹងរដ្ឋាភិបាល រួមទាំងការដកហូតអាជ្ញាបណ្ណបណ្ដាញសារព័ត៌មាន Bayong Times, KCTV និង Cambodia Today។[47]

---

[46] តួលេខសរុបមានច្រើនជាងចំនួនហេតុការណ៍សរុប ដោយសារជនរងគ្រោះម្នាក់អាចស្ថិតក្នុងក្រុមលើសពី១។

[47] ណាត សុភាព, 'ក្រសួងព័ត៌មានដកហូតអាជ្ញាបណ្ណបណ្ដាញផ្សព្វផ្សាយឌីជីថលចំនួនបី', (វីអូឌី, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២) < https://vodenglish.news/information-ministry-revokes-licenses-for-three-digital-publications >។

## ២.១.៣. ការយល់ដឹងរបស់រដ្ឋាភិបាលអំពីសេរីភាពមូលដ្ឋានតាមរយៈការថ្លែងជាសាធារណៈនៅតែមានដែនកំណត់នៅឡើយ

*តួលេខទី ៨៖ សេរីភាពមូលដ្ឋានត្រូវបកស្រាយមិនបានត្រឹមត្រូវនៅក្នុងការថ្លែងរបស់រដ្ឋាភិបាលនៅក្នុងឆ្នាំ២០២២ តាមប្រភេទសេរីភាពនីមួយៗ*




នៅឆ្នាំ២០២២ ការថ្លែងរបស់រដ្ឋាភិបាលចំនួន ១៦[48] បានបង្ហាញពីកង្វះការយល់ដឹងរបស់ខ្លួនអំពីក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានទាំងបី។ ៣៨% នៃករណីទាំងនេះ (ការថ្លែងចំនួន ៦) រដ្ឋាភិបាលបានបកស្រាយមិនបានត្រឹមត្រូវ លើក្របខណ្ឌច្បាប់ ដែលទាក់ទងនឹងសេរីភាពខាងសមាគម ៣១% (ការថ្លែងចំនួន ៥) ពាក់ព័ន្ធនឹងសេរីភាពខាងបញ្ចេញមតិ និង ៣១% (ការថ្លែងចំនួន៥) ពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់ទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ។ លើសពីនេះទៀត គម្រោងមិនបានកត់ត្រាករណីណាមួយដែលជនប្រព្រឹត្តអំពីរំលោភបំពានសេរីភាពមូលដ្ឋានបានទទួលខុសត្រូវអំពើប្រព្រឹត្តរបស់ខ្លួននោះទេ។

នៅខែមេសា លោក អាំ ធូ អធិការនគបាលស្រុកលើកដែក បានការពារនគរបាលមូលដ្ឋានដែលចាប់ឃុំខ្លួន ពលរដ្ឋអ្នកសារព័ត៌មានម្នាក់គឺលោក សួន វុត្ថា បន្ទាប់ពីបានថតវីដេអូមន្ត្រីចរាចរណ៍ទទួលសំណូកនៅខេត្តកណ្តាល។ ពួកគេបានគំរាមចាប់ខ្លួនគាត់ និងចាត់ការតាមផ្លូវច្បាប់ បញ្ជាឱ្យលុបវីដេអូ និងឱ្យចុះកិច្ចសន្យាបញ្ឈប់សកម្មភាពបែបនេះ។ លោក អាំ ធូ បាននិយាយថា *"ប្រសិនបើអ្នកលួចថតរូប មានន័យថាអ្នកកំពុងយកចំណុចអវិជ្ជមាន ដើម្បីធ្វើរឿងមិនល្អ [...] "* ។[49] ការថ្លែងបែបនេះបង្ហាញពីកង្វះការយល់ដឹងរបស់អាជ្ញាធរអំពីសេរីភាពខាងការបញ្ចេញមតិ ប្រៀបដូចជាពួកគេបានហាមឃាត់លោក សួន វុត្ថា ក្នុងការចែករំលែកព័ត៌មានដែលគាត់បានរកឃើញ។ ការយល់ខុសបែបនេះ និងផលប៉ះពាល់ដែលមិនគួរកើតមាន អាចបង្កឱ្យមានការភ័យខ្លាចអំពីការយាយី និងការរឹតត្បិតសេរីភាពខ្លួនឯងជាបន្តបន្ទាប់ ដែលទីបំផុតរារាំងដល់លទ្ធភាពក្នុងការនិយាយស្តី និងធ្វើសកម្មភាពដោយសេរី។

កាលពីថ្ងៃទី២៧ ខែមិថុនា កងកម្លាំងសន្តិសុខសាធារណៈ និងឯកជន (កងកម្លាំងនគរបាល សេវាពិសេស និងកងទ័ព) បានប្រើអំពើហិង្សាដើម្បីបំបែកក្បួនកម្មករនិយោជិត ដែលដើរដង្ហែឆ្ពោះទៅកាន់កាស៊ីណូណាហ្គាវើលដ៍ ដើម្បីធ្វើការជួបប្រជុំដោយសន្តិវិធី បណ្តាលឱ្យមនុស្សយ៉ាងតិច១០នាក់រងរបួស។ លោក កត្តា អ៊ន អ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានចោទប្រកាន់កម្មករនិយោជិតក្រុមហ៊ុនណាហ្គាវើលដ៍

---

[48] ជាក់ស្តែង គម្រោងបានកត់ត្រាការថ្លែងចំនួន ១៤ ករណី ដែលបង្ហាញពីកង្វះការយល់ដឹងរបស់រដ្ឋាភិបាលអំពីសេរីភាពមូលដ្ឋាន។ ទោះយ៉ាងណា ក្នុងករណីខ្លះ ការថ្លែង នេះបានបកស្រាយមិនត្រឹមត្រូវអំពីសេរីភាពមូលដ្ឋានលើសពី១។

[49] ប៉ា សុខេង, "អ្នកសារព័ត៌មានចោទប្រកាន់ថាមានការគំរាមបន្ទាប់ពីបានថតនគរបាលចរាចរណ៍យកលុយ" (វីអូឌី, ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២២ ) <https://vodenglish.news/journalist-alleges-threats-after-filming-traffic-police-taking-money/>។

ថាបានធ្វើប្រមូលផ្តុំខុសច្បាប់ ហើយបានចាត់ទុកការឆ្លើយតបនេះថាជា " *វិធានការអប់រំ*" ដោយលើកឡើងថា៖ *"ក្នុងករណីមានអំពើខុសច្បាប់ អាជ្ញាធរមានសិទ្ធិចាត់វិធានការចាំបាច់នានាដើម្បីបញ្ឈប់ បំបែកឬបង្ក្រាប"។*[50] សេចក្តីថ្លែងការណ៍នេះបង្ហាញពីកង្វះការយល់ដឹងរបស់អាជ្ញាធរទាក់ទងនឹងសេរីភាពខាងការជួបប្រជុំដោយសារពួកគេយល់ថាការជួបប្រជុំដោយសន្តិវិធីជាសកម្មភាពខុសច្បាប់។ ការយល់ឃើញបែបនេះ និងការប្រព្រឹត្តដោយហិង្សាទៅលើអ្នកចូលរួមក្នុងការតវ៉ាដោយសន្តិវិធី ទំនងជានឹងបន្តចបង្អាក់អ្នកដទៃទៀតមិនឱ្យអនុវត្តសិទ្ធិក្នុងការជួបប្រជុំដោយសេរី។ សេចក្តីថ្លែងការណ៍នេះធ្វើឱ្យមានការព្រួយបារម្ភកាន់តែខ្លាំងឡើងចំពោះការការពារ និងអនុវត្តសេរីភាពមូលដ្ឋាន ក៏ដូចជានិទណ្ឌភាពជាប់ជាប្រចាំចំពោះការបំពាន ឬការរឹតត្បិតហួសហេតុរបស់ពួកគេ។

## ២.២. សេរីភាពខាងសមាគម

*តួលេខទី ៩៖ ផែនទីភូមិសាស្ត្រនៃហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬ ការរំលោភបំពានសិទ្ធិសេរីភាពខាងសមាគម*




នៅឆ្នាំ២០២២ គម្រោងបានកត់ត្រាការរឹតត្បិតសេរីភាពខាងសមាគមចំនួន ២៧៧ ករណី ស្មើរពាក់កណ្តាលនៃហេតុការណ៍ទាំងអស់ ដែលបានកត់ត្រាក្នុងឆ្នាំ២០២២។ ចំនួន ១៤៨ ហេតុការណ៍ (៥៣%) នៃការរឹតត្បិតទាំងនេះ មិនត្រូវបានអនុញ្ញាតក្រោមមាត្រា ២២ នៃអនុសញ្ញា ក.អ.ស.ព.ន ដែលចាត់ទុកជាការរំលោភសិទ្ធិសេរីភាពខាងសមាគម។[51] រាជធានីភ្នំពេញមានហេតុការណ៍ច្រើនជាងគេ ដែលភាគច្រើនទាក់ទងនឹងកូដកម្មរបស់និយោជិតណាហ្គាវើលដ៍ (តួលេខទី ៩) ។

---

[50] សុ ជីវី "អាជ្ញាធររាជធានីភ្នំពេញបង្កើនការបង្ក្រាបដោយហិង្សាលើស្ត្រីដែលធ្វើកូដកម្មនៅក្រុមហ៊ុនណាហ្គាវើលដ៍" (អាស៊ីសេរី, ថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២២)<https://www.rfa.org/khmer/news/human-rights/authorities-firer-naga-world-strike-0627202205 0714 .html >។

[51] មាត្រា ២២ នៃអនុសញ្ញា ក.អ.ស.ព.ន។

## ២.២.១. ការរឹតត្បិតសិទ្ធិសេរីភាពខាងសមាគមជារឿយៗត្រូវបានប្រើដើម្បីកំណត់មុខសញ្ញាសមាជិកគណបក្សជំទាស់

*តួលេខទី ១០៖ ប្រភេទសមាគមដែលសេរីភាពខាងសមាគមត្រូវបានរឹតត្បិត*




យ៉ាងហោចណាស់មានមនុស្សចំនួន ២៥០ នាក់ដែលអនុវត្តសេរីភាពខាងសមាគមត្រូវបានរឹតត្បិតនៅក្នុងឆ្នាំ២០២២ ដែលបង្ហាញពីបរិយាកាសដ៏លំបាកក្នុងការអនុវត្តសេរីភាពនេះ។ ក្នុងចំណោមនោះមនុស្ស ចំនួន ១០០ នាក់ (៤០%) គឺជាសមាជិកគណបក្សជំទាស់ ដែលរួមមានមនុស្សចំនួន ៧៥ នាក់ ជាសមាជិក គណបក្សភ្លើងទៀន។ លើសពីនេះ មានករណីមួយចំនួនទាក់ទងនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវបានកត់ត្រាក្នុងអំឡុងឆ្នាំ២០២២ កំណត់មុខសញ្ញាដាក់លាក់ទៅលើសមាជិកគណបក្សជំទាស់។

ឧទាហរណ៍៖ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២ មេឃុំគណបក្សប្រជាជនកម្ពុជាក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល បានបង្ខំសមាជិកក្រុមប្រឹក្សាគណបក្សភ្លើងទៀនគឺ លោក គង់ ណារិទ្ធ និងលោក ឡុង សេងប៊ុន ឱ្យផ្តិតមេដៃលើញត្តិថ្កោលទោសលោក សម រង្ស៊ី។ ទោះបីជាមេឃុំចូលរួមក្នុងកិច្ចប្រជុំដែលពួកគាត់បានរិះគន់ថាបានរងការដាក់សម្ពាធឱ្យគាំទ្រញត្តិថ្កោលទោសក៏ដោយ ក៏អ្នកទាំងពីរបានបដិសេធចុះហត្ថលេខាលើឯកសារនោះដែរ។[52]



*តួលេខទី ១១៖ ទណ្ឌកម្មព្រហ្មទណ្ឌលើសមាជិកនៃសមាគមក្នុងឆ្នាំ២០២២*

នៅឆ្នាំ២០២២ គម្រោងបានកត់ត្រាការចាប់ខ្លួនមនុស្សចំនួន ៥៨ នាក់ ការកាត់ទោសចំនួនមនុស្ស ៧១ នាក់ និងឃុំខ្លួនចំនួន ៥៤ ពីបទល្មើសដែលត្រូវបានចោទប្រកាន់ខណៈកំពុងអនុវត្តសេរីភាពខាងសមាគម ក្នុងនោះ ១៧ នាក់ក្នុងចំណោម ២១ នាក់ បានរងការចោទប្រកាន់ ព្រមទាំង ៦០ នាក់ ក្នុងចំណោម ៧១ នាក់ ត្រូវបានកាត់ទោស គឺជាអតីតសមាជិកគណបក្សសង្គ្រោះជាតិ ដែលបច្ចុប្បន្នត្រូវបានរំលាយ។

---

[52] ឡេង ម៉ាលី "ក្រុមប្រឹក្សាឃុំសង្កាត់គណបក្សភ្លើងទៀន ក្រុងតាខ្មៅ បដិសេធមិនព្រមផ្តិតមេដៃលើញត្តិថ្កោលទោស", (អាស៊ីសេរី, ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០២២)<https://www.rfa.org/khmer/news/politics/commune-chiefs-from-cpp-in-takhmao-kandal-keep-putting-pressure-on-all-commune-councilors-from-clp-to-condemn-sam-rainsy-11012022140441.html>។

### ២.២.២. គណបក្សជំទាស់មិនអាចអនុវត្តសេរីភាពខាងសមាគមបានដោយសេរីក្នុងអំឡុងពេលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់

*តួលេខទី ១២៖ ចំនួនហេតុការណ៍នៃការជ្រៀតជ្រែកលើការដំឡើងស្លាកគណបក្សរបស់គណបក្សជំទាស់ ដោយបែងចែកតាមខេត្តនីមួយៗ*




គម្រោងបានកត់ត្រាហេតុការណ៍ចំនួន ២៣ ដែលរដ្ឋាភិបាល និងភាគីទីបី រំខានសកម្មភាពរបស់គណបក្សជំទាស់ក្នុងអំឡុងពេល និងក្រោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។ ឧទាហរណ៍រួមមានការរំខាន ឬការជ្រៀតជ្រែកក្នុងការដំឡើងផ្ទាំងស្លាកគណបក្ស និងបដារបស់គណបក្ស។ ឧទាហរណ៍ ២១ ក្នុងចំណោម ២៣ ហេតុការណ៍ដែលបានកត់ត្រាទាក់ទងនឹងការជ្រៀតជ្រែកស្លាកគណបក្សនយោបាយ បានកំណត់មុខទៅលើសញ្ញាគណបក្សភ្លើងទៀន។ ខេត្តស្ទឹងត្រែង និងប៉ៃលិន ជាខេត្តដែលហេតុការណ៍នេះបានកើតឡើងច្រើនជាងគេ ត្រូវបានកត់ត្រាទាក់ទងនឹងករណីស្លាកប៉ាណូរបស់គណបក្សភ្លើងទៀន ត្រូវបានរំខានដោយអាជ្ញាធរមូលដ្ឋាន ឬជនមិនស្គាល់អត្តសញ្ញាណ។[53, 54]

### ២.២.៣. បុគ្គលម្នាក់ៗ អង្គការសង្គមស៊ីវិល និងសហជីព បានជួបប្រទះការជ្រៀតជ្រែកក្នុងការអនុវត្តសេរីភាពខាងសមាគម

ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មានការឃាយី អំពើហិង្សាលើរូបរាងកាយ និងសកម្មភាពធ្ងន់ធ្ងរផ្សេងទៀតដែលធ្វើឡើងប្រឆាំងនឹងសមាជិកគណបក្សជំទាស់ និងសមាជិកសមាគម មានកម្រិតកាន់តែខ្លាំងក្លាឡើង ដែលធ្វើឱ្យប៉ះពាល់ដល់លំហសង្គមស៊ីវិល និងនយោបាយនៅកម្ពុជា។ ការវាយប្រហារភាគច្រើនមានលំនាំស្រដៀងគ្នា ដែលអាចបង្ហាញថា ជនល្មើសគឺជាជនដដែលៗនៅក្នុងករណីទាំងអស់ ហើយរឿងទាំងនេះអាចកើតឡើងដោយសារតែការចូលរួមរបស់ពួកគេនៅក្នុងសកម្មភាពទាក់ទងនឹងសមាជិកភាពរបស់ខ្លួនជាមួយនឹងគណបក្សនយោបាយ ឬសមាគម។

---

[53] ណាត សុភាព "គណបក្សកម្ពុជានិយមថាអាជ្ញាធររារាំងមិនឱ្យស្ទើលើស្លាកគណបក្ស" (វីអូឌី, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២) <https://www.vodkhmer.news/2022/01/24/parties-say-authorities-prevent-them-from-holding-banner-party/ >។

[54]លោក ខេ សូណង់ 'គណបក្សកម្ពុជានិយមសង្ឃឹមថាលោក ស ខេង នឹងធ្វើអន្តរាគមន៍តាមសំណើដំឡើងផ្ទាំងប៉ាណូ', (អាស៊ីសេរី, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២) <https://www.rfa.org/khmer/news/politics/kampucheaniyum-party-hopes-ministry-of-interior-to-stop-local-authorities-from-discrimination-04302022192724.html >។

# សមាជិកនៃគណបក្សនយោបាយ ឬសមាគមត្រូវបានកំណត់ជាមុខសញ្ញា និងរងការវាយប្រហារដោយជនមិនស្គាល់អត្តសញ្ញាណពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២២

នៅឆ្នាំ២០២២ មនុស្សចំនួន៦នាក់ដែលជាសកម្មជននៃសមាគមឬសមាជិកគណបក្សនយោបាយជំទាស់ត្រូវបានរងការវាយដំ។ ម្នាក់ក្នុងចំណោមនោះគឺជាបេក្ខជនក្រុមប្រឹក្សាឃុំមកពីគណបក្សភ្លើងទៀនបានស្លាប់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍។ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នៅខែមិថុនា ឆ្នាំ២០២២ ជនរងគ្រោះ ២នាក់ផ្សេងទៀតដែលជាមន្ត្រីគណបក្សជំទាស់ត្រូវបានជនល្មើសវាយដំ។ មនុស្សម្នាក់ដែលស្គាល់ថាជាអ្នកគាំទ្រគណបក្សជំទាស់បានស្លាប់ក្រោយមានការវាយដំ។

## កុម្ភៈ

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២ លោក មុី សោភ័ណ្ឌ ដែលជាអតីតសកម្មជនគណបក្សសង្គ្រោះជាតិ ហើយថ្មីៗលោកបានចូលរួមជាមួយគណបក្សភ្លើងទៀន ត្រូវបានជនមិនស្គាល់អត្តសញ្ញាណដែលជិះម៉ូតូចំនួន២គ្រឿងវាយប្រហារនៅពេលដែលលោកកំពុងធ្វើដំណើរតាមផ្លូវបន្ទាប់ជួយដំឡើងស្លាកគណបក្សនៅសង្កាត់ស្វាយរលំ ខេត្តកណ្តាល។



## មេសា

នៅថ្ងៃទី០៩ ខែមេសា លោក ប្រាក់ សីហា ប្រធានចលនាយុវជននៃគណបក្សភ្លើងទៀនប្រចាំខណ្ឌកំបូល រាជធានីភ្នំពេញ ត្រូវជនមិនស្គាល់មុខលួចវាយប្រហារ។ នេះគឺជាលើកទី២ ដែលលោកត្រូវបានគេលួចវាយ បន្ទាប់ពីការវាយដំលើកទី១កើតឡើងនៅខែកម្ភៈ ឆ្នាំ២០២១។ លោក ជឿថាការលួចវាយប្រហារនេះគឺជារឿងនយោបាយ ដោយសារតែព្រឹត្តការណ៍នេះកើតឡើងក្រោយពីលោកបានបដិសេធចូលរួមជាមួយគណបក្សកាន់អំណាច។

នៅថ្ងៃទី០៩ ខែមេសា លោក ជឿន សារឹម បេក្ខជនក្រុមប្រឹក្សាឃុំសង្កាត់គណបក្សភ្លើងទៀនខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បានស្លាប់នៅខេត្តតាកែវនៅពេលកំពុងបើកបរម៉ូតូឆ្ពោះមករាជធានីភ្នំពេញ។ ភរិយារបស់គាត់ជឿជាក់ថាករណីស្លាប់នេះគឺជារឿងនយោបាយ ខណៈដែលប៉ូលីសបញ្ជាក់ថាលោកបានស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ គ្រួសារលោក ជឿន សារឹម នឹងមិនប្តឹងសមត្ថកិច្ចទេ ពីព្រោះពួកគេពុំមានលទ្ធភាព និងគ្មានមានជំនឿ។ ភរិយារបស់លោកបាននិយាយថា ផ្នែកខាងក្រោយផុងលលាដ៏ក្បាលអាចត្រូវគេលបវាយ។



មានដុំថ្មបានគប់សំដៅចូលផ្ទះរបស់អ្នកស្រី ខន ទន ដែលជាបេក្ខជនក្រុមប្រឹក្សាគណបក្សភ្លើងទៀន កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២។ អ្នកស្រីបានដាក់ពាក្យបណ្តឹងទៅនគរបាលអំពីហេតុការណ៍នោះដែលអ្នកស្រីជឿជាក់ថា វាគឺជាការលបវាយប្រហារ។

នៅថ្ងៃទី១១ ខែមេសា លោក ខឹម មុនីកុសល បានជិះម៉ូតូធ្វើដំណើរតាមផ្លូវ ស្រាប់តែជនសង្ស័យឈ្មោះ ទ្រី ធា បានព្យាយាមជិះម៉ូតូកៀរផ្តួលម៉ូតូរបស់លោកម្តងហើយម្តងទៀត ប៉ុន្តែមិនបណ្តាលឱ្យលោកគ្រោះថ្នាក់ដល់អាយុជីវិតនោះទេ។ លោកបានដាក់ពាក្យបណ្តឹងទៅតុលាការខេត្តប៉ៃលិន ពីបទប៉ុនប៉ងមនុស្សឃាតដោយចេតនា។ លោកយល់ថា នេះជាការប៉ុនប៉ងលើជីវិតរបស់លោក និងជារឿងនយោបាយ។ ទោះជាបែបនេះក្តី ប៉ូលីសព្យាយាមដោះស្រាយករណីក្រៅតុលាការដោយអះអាងថាជនបង្កនោះស្រវឹង និងមិនបានប៉ងសម្លាប់លោកទេ។

កាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ខណៈពេលកំពុងជិះម៉ូតូក្នុងរាជធានីភ្នំពេញ កញ្ញា អេង ម៉ាឡៃ (សូ មេត្តា) យុវជនខ្មែរថាវរៈត្រូវបានម៉ូតូ១គ្រឿងបុកពីក្រោយ។ ជនមិនស្គាល់មុខបានសើចចំអក ខណៈពេលដែលនាងដួល រួចជិះចេញទៅបាត់។ កញ្ញា អេង ម៉ាឡៃ បានរងរបួសធ្ងន់ធ្ងរ។ នាងយល់ថានេះជាការវាយប្រហារដែលចង់បំបាក់នាងពីភាពសកម្ម។

## ឧសភា

នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ អ្នកស្រី សន ចាន់ថន ហៅ ហុង អានបេក្ខជនគណបក្សភ្លើងទៀននៅឃុំត្រពាំងប្រាសាទ ត្រូវបានមនុស្ស២នាក់វាយធ្វើបាបនៅពេលដែលនាងជិះម៉ូតូទៅបំពេញមុខងារឃោសនាបោះឆ្នោត។ ជនដៃដល់បានធាក់ម៉ូតូគាត់ឱ្យដួល។ អ្នកស្រីជឿជាក់ថាការវាយប្រហារនេះមានជាប់ពាក់ព័ន្ធនឹងរឿងនយោបាយ ហើយបាននិយាយថាគាត់នឹងមិនដាក់ពាក្យបណ្តឹងនោះទេ ព្រោះគាត់គ្មានទំនុកចិត្តលើនគរបាល។



## កក្កដា



នៅថ្ងៃទី១៧ ខែកក្កដា លោក លន់ ពង្សធិរិទ្ធ អនុប្រធានគណបក្សភ្លើងទៀនប្រចាំខណ្ឌពោធិ៍សែនជ័យ ត្រូវមនុស្ស១០នាក់ ជិះម៉ូតូ៤គ្រឿង ព្រួតវាយដោយគំរាមសម្លាប់ និងវាយនឹងដំបងដែក របួសក្បាលធ្ងន់ធ្ងរត្រូវបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ។ លោកក៏ធ្លាប់ត្រូវគេលបវាយម្តងរួចមកហើយកាលពីឆ្នាំ២០១៩ នៅពេលដែលជាសមាជិកគណបក្សសង្គ្រោះជាតិ។

## តុលា

កាលពីថ្ងៃទី១៦ ខែតុលា លោក ប៉ូ ហ៊ីនលាន ដែលជាអ្នកគាំទ្រគណបក្សភ្លើងទៀន ត្រូវបានបាញ់សម្លាប់ ខណៈគាត់កំពុងស្ទូចត្រីនៅវាលស្រែកណ្តាលអជ្រាត្រក្នុងខេត្តត្បូងឃ្មុំ មនុស្សចំនួន៦នាក់ត្រូវបានឃុំខ្លួនពីបទឃាតកម្មលើរូបគាត់ ក្នុងនោះបីនាក់ជាមន្ត្រីនគរបាលឃុំ និងបីនាក់ជាឆ្មាំភូមិ។ គេមិនទាន់ច្បាស់ថា តើជាឃាតកម្មចំពោះលោក ប៉ូ ហ៊ីនលាន មានជាប់ពាក់ព័ន្ធនឹងការចូលជាសមាជិកគណបក្សជំទាស់ ឬដោយសារការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ឬយ៉ាងណានោះទេ។

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ លោក ហឿន ស៊ីណាត ដែលជាសម្មជនដីធ្លី និងជាតំណាងសហគមន៍ស្រែប្រាំង ស្រុកតំបែរ ខេត្តត្បូងឃ្មុំ ត្រូវជនមិនស្គាល់មុខចំនួន ៣នាក់ វាយធ្វើបាបនៅរាជធានីភ្នំពេញ នៅពេលដែលគាត់បានចូលរួមសិក្ខាសាលាមួយដែលរៀបចំឡើងដោយសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា។

## ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព បានបន្តរាយការណ៍អំពីការជ្រៀតជ្រែកលើការប៉ុនប៉ងរបស់ពួកគេក្នុងការបង្កើតសម្ព័ន្ធ ក៏ដូចជាការយាយីដោយសារតែពួកគេជាសមាជិកសមាគម

*តួលេខទី ១៣៖ ចំនួនភាគរយនៃអ្នកឆ្លើយដែលបញ្ជាក់ថាត្រូវបានកំណត់ជាមុខសញ្ញាដោយសារតែពួកគេចូលរួមជាមួយសមាគមណាមួយ*




នៅឆ្នាំ២០២២ ២២% នៃអ្នកឆ្លើយតបការស្ទង់មតិសាធារណៈបានរាយការណ៍ថា ខ្លួនត្រូវបានកំណត់ជាមុខសញ្ញា ដោយសារតែពួកគេចូលរួមជាសមាជិកសមាគម (សហគមន៍តាមមូលដ្ឋាន/[55] អង្គការសង្គមស៊ីវិល សហជីព ឬគណបក្សនយោបាយ)។ ទោះបីជានិន្នាការនេះមិនមានការប្រែប្រួលចាប់ពីឆ្នាំ២០២១ និងមានកម្រិតទាបជាងបន្តិច បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩ និង ឆ្នាំ២០២០ ក៏ដោយ ក៏ទិន្នន័យនេះបង្ហាញពីការបន្តធ្លាក់ចុះនូវការអនុវត្តសេរីភាពខាងសមាគមរបស់បុគ្គលម្នាក់ៗ បើប្រៀបធៀបទៅនឹងពីរឆ្នាំដំបូងនៃការអនុវត្តគម្រោង។[56]

*តួលេខទី ១៤៖ ចំនួនភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ពីការជ្រៀតជ្រែកមកលើពួកគេក្នុងការប៉ុនប៉ងបង្កើតបណ្ដាញ សម្ព័ន្ធ នៅក្នុងឆ្នាំ២០២២*




ម្យ៉ាងវិញទៀត នៅឆ្នាំ២០២២ ឃើញមានការកើនឡើងនូវចំនួនភាគរយនៃ ករណីពាក់ព័ន្ធនឹងការជ្រៀតជ្រែក ក្នុងសកម្មភាពរបស់សមាគម អង្គការសង្គមស៊ីវិល និងសហជីព បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ដោយមានអ្នកឆ្លើយលើសពីមួយភាគបី បានរាយការណ៍ពីការជ្រៀតជ្រែកលើការប៉ុនប៉ងក្នុងការបង្កើតបណ្ដាញ ឬសម្ព័ន្ធជាមួយសហជីព ឬសមាគមផ្សេងទៀត។

*តួលេខទី១៥៖ ចំនួនភាគរយនៃហេតុការណ៍ពាក់ព័ន្ធនឹងសេរីភាពខាងសមាគមដែលមានការត្រួតពិនិត្យ ឬការឃ្លាំមើលហួសហេតុពីសំណាក់រដ្ឋាភិបាល*




ទោះបីជាភាគរយមានចំនួនទាបជាងឆ្នាំមុនៗក៏ដោយ ប៉ុន្តែការត្រួតពិនិត្យ និងការឃ្លាំមើលសកម្មភាពសង្គមស៊ីវិលដ៏ច្រើនហួសហេតុពីសំណាក់រដ្ឋាភិបាលនៅតែមានការរឹតត្បិត ឬការរំលោភបំពានមកលើសេរីភាពខាងសមាគម ដែលបង្ហាញពីការសង្ស័យ និងកង្វះការទុកចិត្តជាប្រចាំពីសំណាក់រាជរដ្ឋាភិបាលកម្ពុជានៅតែមានរហូតដល់ ៣៥%។[57] ៥២% (៣៣ នាក់ក្នុងចំណោម ៦៤ នាក់) នៃថ្នាក់ដឹកនាំសហជីពដែល

---

[55] សហគមន៍តាមមូលដ្ឋាន គឺសំដៅដល់អង្គការសហគមន៍នៅមូលដ្ឋាន។ ពាក្យនេះសំដៅលើក្រុមមិនស្វែងរកប្រាក់ចំណេញ ដែលធ្វើការនៅថ្នាក់មូលដ្ឋានដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាសហគមន៍។ សហគមន៍រួមមានទាំងក្រុមផ្លូវការ និងក្រៅផ្លូវការ ហើយជារឿយៗមានទ្រង់ទ្រាយតូច ដែលផ្ដល់សេវាចម្រុះសម្រាប់អភិវឌ្ឍសហគមន៍របស់ខ្លួន។

[56] សំណួរនេះបានដាក់បញ្ចូលនៅក្នុងការស្ទង់មតិសាធារណៈឆ្នាំ២០១៧។

[57] មិនមានសូចនាករនេះក្នុង២០១៦ និង២០១៧ នោះទេ។

បានស្ទង់មតិ បានរាយការណ៍ពីការជ្រៀតជ្រែកនេះខណៈដែល ២០% (១៦ នាក់ក្នុងចំណោម ៨០ នាក់) នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលបានរាយការណ៍ពីការជ្រៀតជ្រែកនេះ។ ចំនួនភាគរយថ្នាក់ដឹកនាំសហជីពដែលបានរាយការណ៍ពីការជ្រៀតជ្រែកបានកើនឡើងទ្វេដងធៀបនឹងឆ្នាំមុន ដែលបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់នៃការជ្រៀតជ្រែកលើកម្មករនិយោជិត និងសហជីព ក្នុងការប៉ុនប៉ងធ្វើអ្វីមួយ។

*តួលេខទី ១៦៖ ចំនួនភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលយល់ថាការឃ្លាំមើលមានលក្ខណៈហួសហេតុ*




លើសពីនេះ ទោះបីជាមានចំនួនភាគរយខ្ពស់នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានចូលរួមមតិយោបល់ក្នុងរបាយការណ៍នេះ នៅតែចាត់ទុកថាការឃ្លាំមើលនេះមានលក្ខណៈហួសហេតុ (៦៤% ក្នុងឆ្នាំ២០២២) លទ្ធផលនេះគឺជាចំនួនភាគរយដ៏ទាបបំផុតចាប់តាំងពីការចាប់ផ្តើមគម្រោង (លទ្ធផលនេះឈានដល់កម្រិតខ្ពស់បំផុតក្នុងឆ្នាំ២០១៩ ដែលមានរហូត ៧៩% នៃអ្នកឆ្លើយតបថាការឃ្លាំមើលគឺហួសហេតុ)។

## និយោជកបានបន្តចូលរួមក្នុងការបញ្ឈប់សហជីពនៅឆ្នាំ២០២២

*តួលេខទី ១៧៖ ចំនួនភាគរយនៃនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារ ឬបង្ខំឱ្យលាលែងពីតំណែង ដោយសារភាពសកម្មដោយបែងចែកតាមវិស័យ*




នៅឆ្នាំ២០២២ យ៉ាងហោចណាស់មានសមាជិក ឬសកម្មជនសហជីពចំនួន ៥៩ នាក់ត្រូវបានបញ្ឈប់ពីការងារ បង្ខំឱ្យលាលែងពីតំណែង ឬបញ្ចប់កិច្ចសន្យាដោយសារតែពួកគេចូលរួមពាក់ព័ន្ធ ឬជាសកម្មជនសហជីព ដែលប្រហែលពាក់កណ្តាលនៃហេតុការណ៍ទាំងនេះ កើតឡើងនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់។ កាលពីខែមេសា ឆ្នាំ២០២២ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាបានរាយការណ៍ថា ចាប់តាំងពីឆ្នាំ ២០១៥ មក មានកម្មករនិយោជិតចំនួន ១,៤០៨ នាក់មកពីរោងចក្រចំនួន ២៣ ត្រូវបានបញ្ឈប់ពីការងារដោយសារតែអនុវត្តសិទ្ធិក្នុងការបង្កើតអង្គការការងារ។[58] គម្រោង មិនបានកត់ត្រាការចុះបញ្ជីសហជីពថ្មីណា

[58] ឡាយ សាមាន "សហជីពស្នើសុំឱ្យមានការអន្តរាគមន៍ពីនាយករដ្ឋមន្ត្រីនៅក្នុងវិវាទ" ភ្នំពេញប៉ុស្តិ៍, (ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២) <https://www.phnompenhpost.com/national/trade-union-seeks-pms-intervention-dispute>, ឃុត សុគន្ធ "សមាជិកសហជីពពីររូបទៀតត្រូវបានព្យួរការងារនៅរោងចក្រភ្នំពេញ", វីអូឌី, (ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២) <https://vodenglish.news/two-more-unionists-suspended-at-phnom-penh-factory/>, Kelliher Flona និង គាត សូរិទ្ធដារី, "ការបំបែកសហជីពក្រោមលេសនៃជំងឺរាតត្បាតសាកលធ្វើឱ្យមនុស្សរាប់រយនាក់បាត់បង់ការងារ", (វីអូឌី, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២) <https://vodenglish.news/union-busting-under-guise-of-pandemic-leaves-hundreds-out-of-work/ > ។

មួយទេ ទំនងជាដោយសារនិយោជកកំណត់មុខសញ្ញាកម្មករនិយោជិតដែលព្យាយាមបង្កើតសហជីព។ ទិន្នន័យនេះបង្ហាញពីនិន្នាការទាក់ទងនឹងកំណត់មុខសញ្ញាលើកម្មករនិយោជិត និងការជ្រៀតជ្រែកលើសេរីភាពខាងសមាគម ដែលរួមមានសិទ្ធិរបស់កម្មករនិយោជិតក្នុងការរៀបចំ និងការចរចាជាសមូហភាព។

ឧទាហរណ៍៖ កាលពីខែវិច្ឆិកា ឆ្នាំ២០២២ រោងចក្រកាត់ដេរ New Mingda ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ បានបញ្ឈប់អនុប្រធាន និងព្យួរតំណែងប្រធាន និងលេខាសហជីពកម្មករដែលទើបបង្កើតថ្មីភ្លាមៗ បន្ទាប់ពីមានការតវ៉ារបស់កម្មករនិយោជិតនៅរោងចក្រជុំវិញការបញ្ឈប់ប្រធានសហជីពម្នាក់ទៀត។[59]

## ២.៣. សេរីភាពខាងការជួបប្រជុំ

*តួលេខទី ១៨៖ ផែនទីភូមិសាស្ត្រនៃហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬរំលោភបំពានសេរីភាពខាងការជួបប្រជុំ*




នៅឆ្នាំ២០២២ គម្រោងបានកត់ត្រាការរឹតត្បិតសេរីភាពខាងការជួបប្រជុំចំនួន ១៦៩ ករណី ដែលក្នុងនោះ ១៣១ (៧៨%) មិនត្រូវបានអនុញ្ញាត ដូច្នេះ ករណីទាំងនេះចាត់ទុកថាជាការរំលោភបំពាន[60] ៨៨% នៃហេតុការណ៍កើតឡើងនៅរាជធានីភ្នំពេញ (មានចំនួន១៤៩) ។

### ២.៣.១. ការជួបប្រជុំភាគច្រើនធ្វើឡើងដើម្បីតស៊ូមតិដើម្បីសិទ្ធិដីធ្លី និងសិទ្ធិការងារ

*តួលេខទី ១៩៖ ចំនួនការជួបប្រជុំតាមត្រីមាសដោយបែងចែកប្រភេទជួបប្រជុំនីមួយៗ*




ការជួបប្រជុំតែចំនួន ១០២ លើកប៉ុណ្ណោះបានធ្វើឡើងក្នុងឆ្នាំ២០២២ ដែលធ្លាក់ចុះ បើប្រៀបធៀប ទៅនឹងឆ្នាំ២០២១ ដែលមានការជួបប្រជុំបានកើតឡើងចំនួន ១៦៥ លើក ខណៈដែលចំនួននៃការរឹតត្បិតទាក់ទងនឹងសេរីភាពខាងការជួបប្រជុំបានកើនឡើងជិតទ្វេដង (ពី៨៧ ករណី ក្នុងឆ្នាំ២០២១ ដល់ ១៦៩ ករណីក្នុងឆ្នាំ ២០២២)។ ហេតុការណ៍ភាគច្រើនទាក់ទងនឹងកូដកម្មរបស់បុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍ (ចាត់បញ្ចូលក្នុងប្រភេទ"សិទ្ធិការងារ") ការជួបប្រជុំធ្វើឡើងដោយស្ត្រីថ្ងៃសុក្រ[61] ព្រឹត្តិការណ៍ផ្សេងទៀតនៃការជួបប្រជុំរបស់យុវជនបរិស្ថាន ឬក្រុមយុវជន។

---

[59] យុត សុគន្ធ "សមាជិកសហជីពពីររូបទៀតត្រូវបានព្យួរការងារនៅរោងចក្រភ្នំពេញ", (វីអូឌី, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២) <https://vodenglish.news/two-more-unionists-suspended-at-phnom-penh-factory/ >។

[60] មាត្រា ២១ នៃអនុសញ្ញា ក.អ.ស.ព.ន។

[61] ស្ត្រីថ្ងៃសុក្រ គឺជាក្រុមស្ត្រីដែលតែងជួបប្រជុំគ្នារៀងរាល់ថ្ងៃសុក្រ ដើម្បីសុំឱ្យមានការដោះលែងសាច់ញាតិរបស់ខ្លួនពីពន្ធនាគារ ដែលសុទ្ធតែជាសមាជិកអតីតគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សជំទាស់ដ៏ធំមួយដែលត្រូវបានរំលាយកាលពីឆ្នាំ២០១៧។

### ២.៣.២. ទណ្ឌកម្មព្រហ្មទណ្ឌមកលើអ្នកចូលរួមធ្វើកូដកម្មដែលអនុវត្តសិទ្ធិខាងការជួបប្រជុំ ក្នុងវិវាទក្រុមហ៊ុនណាហ្គាវើលដ៍

*តួលេខទី ២០៖ ចំនួនករណីនៃបុគ្គលដែលត្រូវបានសាកសួរ ឃុំខ្លួន ឬទទួលរងវិធានការព្រហ្មទណ្ឌចំពោះការអនុវត្តសេរីភាពខាងការជួបប្រជុំនៅឆ្នាំ២០២២*




នៅឆ្នាំ២០២២ ការធ្វើកូដកម្មបុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍ ត្រូវបានរាយការណ៍ថា បានឈានទៅដល់ចំណាត់ការផ្លូវច្បាប់ ទៅលើអ្នកដែលបានអនុវត្តសេរីភាពជួបប្រជុំ ហើយចំនួននេះកើតឡើងច្រើនជាងពេលណាទាំងអស់ ចាប់ពីការចាប់ផ្តើមគម្រោងក្នុងឆ្នាំ២០១៦។ អ្វីដែលគួរឱ្យកត់សម្គាល់ គឺមានករណីឃុំខ្លួនមនុស្សចំនួន ២៥៧១ នាក់ ដែលក្នុងនោះមនុស្សប្រមាណ ២៥៥៣ នាក់[62] គឺជាអ្នកចូលរួមការធ្វើកូដកម្មក្នុងវិវាទក្រុមហ៊ុនណាហ្គាវើលដ៍ផងដែរ។[63]

### ២.៣.៣. បុគ្គលម្នាក់ៗរាយការណ៍ថាមានសេរីភាពខាងឆ្នាំមុនៗក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធីក្នុងឆ្នាំ ២០២២

*តួលេខទី ២១៖ ចំនួនភាគរយនៃបុគ្គលដែលយល់ថាមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី*




ការស្ទង់មតិសាធារណៈនៅឆ្នាំ២០២២ បង្ហាញថា ៦២% នៃអ្នកឆ្លើយតបបានរាយការណ៍ថាមានសេរីភាព[64]ក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធីនៅទីសាធារណៈ។ ទោះបីនេះគឺជា ចំនួនភាគរយខ្ពស់បំផុតក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះក៏ដោយ ក៏តួលេខនេះនៅតែមានកម្រិតទាបជាងកាលពីឆ្នាំ២០១៦ និង ២០១៧ ដែរ ហើយជិត ៤០% នៃអ្នកដែលបានស្ទង់មតិនៅតែគិតថាមិនមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី។

---

[62] ចំនួននៃការឃុំខ្លួនមិនត្រូវគ្នាជាមួយនឹងចំនួនសរុបនៃនិយោជិតដែលជាសមាជិក សហជីពទ្រទ្រង់សិទ្ធិការងារ បុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ ដោយសារតែបុគ្គលម្នាក់ប្រឈមនឹងការឃុំខ្លួនច្រើនដង។

[63] អនុសាសន៍ទូទៅលេខ៣៧ (២០២០) ស្តីពីសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី (មាត្រា២១)៖ សម័យប្រជុំលើកទី១២៩ របស់គណៈកម្មាធិការសិទ្ធិមនុស្ស CCPR_C_GC_៣៧-EN កថាខណ្ឌ ៧១។

[64] តួលេខនេះតំណាងឱ្យចំនួនអ្នកឆ្លើយការស្ទង់មតិ ដែលបានរាយការណ៍ថា " មានសេរីភាពខ្លាំងណាស់" ឬ " មានសេរីភាពខ្លះដែរ" ក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ។

## ២.៣.៤. រដ្ឋាភិបាលនៅតែបន្តជ្រៀតជ្រែក ឬហាមឃាត់ការជួបប្រជុំដោយសន្តិវិធី

*តួលេខទី ២២៖ ការជួបប្រជុំដោយសន្តិវិធីក្នុងអំឡុងឆ្នាំ*




នៅឆ្នាំ២០២២ គម្រោងបានកត់ត្រាហេតុការណ៍ចំនួន ៩៥ ដែលរដ្ឋាភិបាលបានជ្រៀតជ្រែកលើការជួបប្រជុំដោយសន្តិវិធីក្នុងចំណោមការប្រមូលផ្តុំចំនួន ១៦៩ ហេតុការណ៍ដែលបានរាយការណ៍ក្នុងឆ្នាំដដែលនោះ។ ជាងនេះទៀត ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលធ្វើរបាយការណ៍បង្ហាញថាមានការរឹតត្បិត[65]លើការជួបប្រជុំដោយសន្តិវិធី ហើយការជួបប្រជុំចំនួនបួនផ្សេងទៀត ត្រូវបានហាមឃាត់[66] ដោយសារព្រឹត្តិការណ៍ទាំងនេះមិនបំពេញតាមបទដ្ឋានដែលចាំបាច់នាំឱ្យមានការរឹតត្បិតសេរីភាពខាងការជួបប្រជុំ។ ការហាមឃាត់នេះមិនសមាមាត្រ ឬមិនមានភាពចាំបាច់ក្នុងការការពារសន្តិសុខជាតិ សុវត្ថិភាពសាធារណៈ សុខភាពសាធារណៈ និងសីលធម៌ ឬសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។ ហើយវិធានការហាមឃាត់ក៏មិនមែនជាជម្រើសចុងក្រោយដែរ។[67] ការប្រមូលផ្តុំដែលត្រូវបានហាមឃាត់ រួមមានការប្រារព្ធទិវានារីអន្តរជាតិ[68] ការប្រមូលផ្តុំរបស់យុវជនជំទាស់នឹងការបង្កើតដេប៉ាតឺម៉ង់ភាសាវៀតណាមនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ[69] ការប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ[70] និងគម្រោងតវ៉ារបស់សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ[71] ដើម្បីទាមទារឱ្យដោះលែងគ្រូបង្រៀនចំនួន ០៥ នាក់ដែលជាប់ឃុំ។

---

[65] ណាត សុភាព "ក្រុមយុវជនព្រមានហែក្បួនទៅស្ថាប័នរដ្ឋបើគ្មានការឆ្លើយតបសំណើសុំលុបចោលគម្រោងបង្កើតដេប៉ាតឺម៉ង់ភាសាវៀតណាម" (វីអូឌី, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២) <https://www.vodkhmer.news/2022/12/25/youths-warn-of-march-to-state-institutions-if-they-do-not-respond-to-requests-to-stop-issuing-permanent-residence-permits-to-foreigners/ >។ ហេតុការណ៍ចំនួនពីរដែលមានការរឹតត្បិតបានកើតឡើងគឺកើតចេញពីគោលបំណងតែមួយ។

[66] ស ថេង "ប្រជាសហគមន៍នៅខេត្តពោធិ៍សាត់ខកចិត្តដែលអាជ្ញាធរមិនឱ្យរៀបចំទិវាសិទ្ធិនារី" (វីអូឌី, ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២) <https://www.vodkhmer.news/2022/03/07/pursat-authorities-do-not-allow-citizens-to-organize-womens-rights-day/>

[67] ការរឹតត្បិតសេរីភាពខាងការជួបប្រជុំត្រូវតែ '(ក) ធ្វើឡើងស្របតាមច្បាប់ (ខ) ស្របតាមគោលបំណងគតិយុត្ត និង (គ) មានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ" មាត្រា ២១ នៃអនុសញ្ញា ក.អ.ស.ព.ន។

[68] មាន រិទ្ធ 'អាជ្ញាធរខេត្តពោធិ៍សាត់មិនអនុញ្ញាតឱ្យសហគមន៍ក្បាលត្រាចប្រារព្ធទិវាសិទ្ធិនារី' (អាស៊ីសេរី, ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២)< https://www.rfa.org/khmer/news/human-rights/authorities-in-pursat-donnot-allow-kbal-trach-community-to-celebrate-women-right-day-03072022130951.html >។

[69] ណាត សុភាព "រដ្ឋបាលរាជធានីភ្នំពេញមិនអនុញ្ញាតឱ្យយុវជនជាង ២០០ នាក់ធ្វើបាតុកម្មនៅទីលានប្រជាធិបតេយ្យ" (វីអូឌី, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២)< https://www.vodkhmer.news/២០២២/១០/២៥/phnom-penh-administration-has-not-allowed-youths-to-demonstrate-at-freedom-park/ >។

[70] យួន ណារីម "អាជ្ញាធរខេត្តពោធិ៍សាត់បញ្ឈប់ការប្រារព្ធទិវាសិទ្ធិមនុស្សក្នុងមូលដ្ឋាន" (ខេមបូចារ, ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០២២) < https://cambojanews.com/pursat-authorities-halt-local-human-rights-day-celebrations/ >។

[71] ពេជ្រ សុធារី "អាជ្ញាធរមិនអនុញ្ញាតឱ្យសមាគមគ្រូបង្រៀនសម្តែងមតិនៅទីលានប្រជាធិបតេយ្យ ដោយថាសំណើធ្វើឡើងផ្ទុយនឹងច្បាប់" (វីអូឌី, ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២)< https://www.vodkhmer.news/២០២២/១២/២៦/pp-authority-not-allow-cita-to-gathering-at-freedom-park/ >។

## ២.៣.៥. ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព យល់ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំជាងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ ប៉ុន្តែថ្នាក់ដឹកនាំសហជីពយល់ថាមិនសូវមានសេរីភាពដូចថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល

*តួលេខទី ២៣៖ ចំនួនភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំដោយបែងចែកតាមឆ្នាំនីមួយៗ*




នៅឆ្នាំ២០២២ ៥៤% (៧៩ ក្នុងចំណោម ១៤៥)[72] នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានស្ទង់មតិ បានរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំ ដែលកើនឡើង ១៩ ភាគរយធៀបនឹងឆ្នាំ២០២១។ ទោះបីជាការវិវត្តវិជ្ជមាន បន្ទាប់ពីមានការធ្លាក់ចុះនៅរយៈពេលពីរឆ្នាំក្នុងអំឡុងពេលនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ ក៏ដោយ ក៏តួលេខនេះនៅតែមានកម្រិតទាបខ្លាំងបើធៀបនឹងឆ្នាំ ២០១៦ និង ឆ្នាំ២០១៧ (៧៥% និង ៦៨%)។ តិចជាងពាក់កណ្តាលនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព បន្តមានការព្រួយបារម្ភអំពីការអនុវត្តសេរីភាពក្នុងការជួបប្រជុំ។

*តួលេខទី ២៤៖ ចំនួនភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំនៅឆ្នាំ២០២២*




នៅឆ្នាំ២០២២ ៥៩% នៃថ្នាក់ដឹកនាំសហជីព (៣៨ ក្នុងចំណោម ៦៥ ដែលបានស្ទង់មតិ) បាននិយាយថាពួកគេយល់ថាមិនមានសេរីភាពក្នុងការអនុវត្តសិទ្ធិនេះ បើធៀបទៅនឹង ២២ ក្នុងចំណោម ៨០ នាក់នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល (២៧%) ។ ភាពខុសប្លែកគ្នាយ៉ាងខ្លាំងនេះឆ្លុះបញ្ចាំងពីផលប៉ះពាល់នៃការជ្រៀតជ្រែកយ៉ាងខ្លាំងពីសំណាក់រដ្ឋាភិបាល រួមទាំងការចាត់វិធានការផ្លូវច្បាប់ និងទណ្ឌកម្មព្រហ្មទណ្ឌប្រឆាំងនឹងកូដកម្មរបស់បុគ្គលិកក្រុមហ៊ុនណាហ្គាវើលដ៍ និងបង្ហាញពីការវិវត្តគួរឱ្យព្រួយបារម្ភចំពោះកម្មករនិយោជិត និងសហជីពដែលយល់ថាត្រូវបានរឹតត្បិតក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ រួមទាំងសិទ្ធិក្នុងការរៀបចំ និងការចរចាជាសមូហភាព។

[72] តួលេខនេះតំណាងឱ្យចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពនៅក្នុងការស្ទង់មតិដែលបានរាយការណ៍ថា "មានសេរីភាពខ្លាំងណាស់" ឬ "មានសេរីភាពខ្លះដែរ" ក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំ។

# ២.៤. សេរីភាពខាងការបញ្ចេញមតិ

## ២.៤. សេរីភាពខាងការបញ្ចេញមតិនៅតែបន្តរងការរឹតត្បិតពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងភាគីទីបី

*តួលេខទី ២៥៖ ហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬរំលោភបំពានសេរីភាពខាងការបញ្ចេញមតិតាមខេត្តនីមួយៗ*




ក្នុងឆ្នាំ២០២២ គម្រោងបានកត់ត្រាហេតុការណ៍ចំនួន ១២៩ ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិយ៉ាងតិចមួយករណី ដោយហេតុការណ៍ភាគច្រើន (៦៧) កើតឡើងនៅរាជធានីភ្នំពេញ។ ៧៩ (ឬ ៦១%) នៃហេតុការណ៍ទាំងនេះមិនត្រូវបានអនុញ្ញាត និងជាការរំលោភបំពានច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

### ២.៤.១. ចំនួនហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិបានថយចុះបន្តិច[73]

*តួលេខទី ២៦៖ ចំនួននៃហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិតឬរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិ*




នៅឆ្នាំ២០២២ បានកត់ត្រាការធ្លាក់ចុះបន្តិចបន្តួចជាងឆ្នាំមុនៗនូវចំនួនហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិត ឬការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិ លើកលែងតែឆ្នាំ២០២០ (តួលេខទី ២៦)។ ប្រមាណ ៣៨% (៤៩ ក្នុងចំណោម ១២៩) នៃហេតុការណ៍ដែលបានកត់ត្រា បានកើតឡើងនៅត្រីមាសដំបូងខណៈដែលរដ្ឋាភិបាលបានបង្កើនការបង្ក្រាបលើការបញ្ចេញមតិ (តួលេខទី ២៧)។ ចំនួននៃហេតុការណ៍បានកើនឡើងម្តងទៀតបន្ទាប់ពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់កាលពីខែមិថុនា ឆ្នាំ២០២២ ដែលជាសញ្ញាមួយនៃការគាបសង្កត់ប្រឆាំងនឹងការបញ្ចេញមតិ និងទស្សនៈនយោបាយ។ ទោះបីជាការថយចុះជារួមនូវចំនួនហេតុការណ៍បង្ហាញពីនិន្នាការវិជ្ជមានក៏ដោយ ក៏អាជ្ញាធរបានបន្តចាត់វិធានការចំពោះអ្នកដែលអនុវត្តសេរីភាពខាងបញ្ចេញមតិ ជាពិសេសអ្នកដែលព្យាយាមទទួលបានព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានដល់សាធារណជន។

*តួលេខទី ២៧៖ ចំនួនហេតុការណ៍ពាក់ព័ន្ធនឹងការរឹតត្បិតឬរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិដោយបែងចែកតាមខែនីមួយៗ*




[73] សំណួរនេះមិនបានបញ្ចូលទេក្នុងការស្ទង់មតិឆ្នាំ២០១៦នោះទេ។

## ២.៤.២. អាជ្ញាធរបានបន្តប្រើនីតិវិធីច្បាប់ និងទណ្ឌកម្មព្រហ្មទណ្ឌមកលើការអនុវត្តការបញ្ចេញមតិដោយសេរី

*តួលេខទី ២៨៖ ចំនួនភាគរយនៃករណីពាក់ព័ន្ធនឹងការរឹតត្បិតរបស់រាជរដ្ឋាភិបាលកម្ពុជា លើសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត*




នៅឆ្នាំ២០២២ ចំនួនភាគរយនៃការរឹតត្បិតលើការបញ្ចេញមតិ តាមគ្រប់រូបភាពនៅលើប្រព័ន្ធអ៊ីនធឺណិតបានថយចុះយ៉ាងខ្លាំងពី ៧៧% ក្នុងឆ្នាំ២០២១ មកនៅត្រឹម ៤៥% ក្នុងឆ្នាំ២០២២។[74] ៥៩% (ឬ ៣៤ ហេតុការណ៍) នៃព្រឹត្តិការណ៍ ទាំងអស់ត្រូវបានចាត់ទុកជាការរំលោភបំពានលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត ខណៈដែល៤១% (ឬ ២៤ ហេតុការណ៍) ផ្សេងទៀត ត្រូវបានចាត់ទុកថាជាការរឹតត្បិតលើការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត។ គួរកត់សម្គាល់ថាលទ្ធផលនោះនៅតែមានកម្រិតទាបជាងលទ្ធផលដែលបានកត់ត្រាក្នុងអំឡុងឆ្នាំ២០២១ ទោះបីជាជាង ៤០% នៃការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតនៅតែបន្តរងការរឹតត្បិតក៏ដោយ។ ទិន្នន័យនេះបង្ហាញថា សេរីភាពតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជានៅតែទទួលរងការគំរាមកំហែង។ អ្នកប្រើប្រាស់បណ្ដាញអ៊ីនធឺណិត តែងប្រឈមមុខនឹងការចាប់ខ្លួនចំពោះការធ្វើសកម្មភាពលើប្រព័ន្ធអ៊ីនធឺណិត ដោយបន្តបរិយាកាសដែលមានការភ័យខ្លាច និងរឹតត្បិតសេរីភាពខ្លួនឯង។

*តួលេខទី ២៩៖ ការរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត ចាប់ពីខែមករាដល់ខែធ្នូ ឆ្នាំ ២០២២*




ទោះបីជាមានការថយចុះបើប្រៀបធៀបនឹងបុគ្គលដែលបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតអំពីវិធានការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះការរាតត្បាតសាកលជំងឺកូវីដ-១៩ និង បរិយាកាសនយោបាយ[75] ក៏ដោយ ក៏អាជ្ញាធរនៅតែបន្តប្រើប្រាស់នីតិវិធីច្បាប់ និងទណ្ឌកម្មព្រហ្មទណ្ឌចំពោះបុគ្គលដែលបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត។ ក្នុងអំឡុងឆ្នាំ២០២២ ៤៥% (ឬ ៥៨) នៃហេតុការណ៍សរុប (១២៩) ពាក់ព័ន្ធនឹងការរឹតត្បិតឬការរំលោភបំពានការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតយ៉ាងហោចណាស់មួយករណី។ ទិន្នន័យដែលប្រមូលបានក្នុងឆ្នាំ២០២២ បានបង្ហាញថា អាជ្ញាធរបានប្រើប្រាស់បទប្បញ្ញត្តិច្បាប់ ជាពិសេសក្រមព្រហ្មទណ្ឌ ដើម្បីជ្រៀតជ្រែកលើការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិត។

[74] ទិន្នន័យនេះមិនអាចគណនាបានសម្រាប់ឆ្នាំ២០១៦ និងឆ្នាំ២០១៧។

[75] ទំព័រទី ២០ របាយការណ៍ប្រចាំឆ្នាំទីប្រាំមួយរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ។

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមចំនួន ៣ នាក់ ត្រូវបានការិយាល័យនគរបាលបង្ការពន្លត់អគ្គីភ័យ និងសង្គ្រោះនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ កោះហៅដើម្បីសាកសួរជុំវិញមតិមួយចំនួនរបស់ពួកគេនៅលើបណ្ដាញហ្វេសប៊ុក នៅក្នុងហេតុការណ៍អគ្គីភ័យមួយនៅរាជធានីភ្នំពេញ ដែលចុះផ្សាយដោយសារព័ត៌មាន Post News TV ។ អ្នកប្រើប្រាស់បណ្ដាញសង្គមបានលើកឡើងថាក្រុមពន្លត់អគ្គីភ័យប្រព្រឹត្តអំពើពុករលួយ និងទាមទារប្រាក់ដើម្បីពន្លត់ភ្លើង។ ពួកគេត្រូវបានបង្ខំឱ្យសារភាពថាបានប្រព្រឹត្តកំហុសហើយពួកគេពីរនាក់បានប្រកាសសុំទោសកម្លាំងនគរបាលពន្លត់អគ្គីភ័យជាសាធារណៈ។ បុគ្គលទី៣ ឈ្មោះ វ៉ា សៀកលីវ មិនទាន់បង្ហាញខ្លួននៅការិយាល័យនៅឡើយ។ នាយកដ្ឋានពន្លត់អគ្គីភ័យបានអំពាវនាវឱ្យគាត់បង្ហាញខ្លួន បើមិនដូច្នោះទេនឹងត្រូវប្រឈមនឹងវិធានការតាមផ្លូវច្បាប់។[76]

## ២.៤.៣. ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពតែងតែរឹតត្បិតសេរីភាពខ្លួនឯងដោយសារតែកង្វះលទ្ធភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ

*តួលេខទី ៣០៖ ចំនួនភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងចំនួនភាគរយនៃអ្នកដែលបានរឹតត្បិតសេរីភាពខ្លួនឯងក្នុងអំឡុងឆ្នាំ២០២២*




ចំនួនភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានរាយការណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ បានធ្លាក់ចុះក្នុងប៉ុន្មានឆ្នាំនេះ។ ក្នុងអំឡុងឆ្នាំ២០២១ និង ២០២២ មានតែអ្នកឆ្លើយប្រហែលពាក់ កណ្ដាលប៉ុណ្ណោះដែលនិយាយថាខ្លួនមានសេរីភាពខាងការបញ្ចេញមតិ (៥៣% និង ៥៤% ដោយឡែកពីគ្នា)។ ភាគច្រើន (៨៦%) នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពបានរាយការណ៍ថាកាលពីឆ្នាំមុន ពួកគេបានរឹតត្បិតសេរីភាពខ្លួនឯង។ ចំនួនភាគរយដ៏ខ្ពស់នៃការរឹតត្បិតសេរីភាពខ្លួនឯង បង្ហាញពីបរិយាកាសមួយដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព មិនយល់ថាមានសេរីភាពខាងការបញ្ចេញមតិ អាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថាប័នរបស់ពួកគេក្នុងការអនុវត្តការងារ។

---

[76] ម៉ិច ដារ៉ា, 'មតិនៅក្នុងផ្សាយបន្តផ្ទាល់អំពីក្រុមអ្នកពន្លត់អគ្គីភ័យប្រឈមនឹងបញ្ហា' (វីអូឌី, ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២) <https://vodenglish.news/live-comments-about-firefighters-land-residents-in-hot-water/ >។

## ២.៤.៤. អ្នកសារព័ត៌មាន និងសមាជិកគណបក្សជំទាស់ ត្រូវបានកំណត់មុខសញ្ញានៃបណ្ដឹងផ្លូវច្បាប់ចំពោះការបញ្ចេញមតិ

*តួលេខទី ៣១៖ ចំនួនភាគរយនៃអ្នកដែលបានទទួលពាក្យបណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈចន្លោះខែមករា ដល់ ខែធ្នូ ឆ្នាំ២០២២*




យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ (យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់)[77] បានឡើងចំនួន ៣៧ ដងប្រឆាំងនឹងបុគ្គលចំនួន៧៩ នាក់ជាការឆ្លើយតបចំពោះការអនុវត្តសេរីភាពខាងបញ្ចេញមតិ។ គួរកត់សម្គាល់ថា ៤១% កំណត់គោលដៅមកលើសមាជិកសហគមន៍ដែលធ្វើការលើសិទ្ធិដីធ្លី ឬបញ្ហាបរិស្ថាន ១៣% នៃចំនួនយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់សរុប កំណត់គោលដៅមកលើសមាជិកគណបក្សជំទាស់ និង ១០% មកលើអ្នកសារព័ត៌មាន។

***<u>ការជ្រៀតជ្រែកលើសកម្មជនសហគមន៍ដីធ្លី និងអ្នកសារព័ត៌មានដែលរាយការណ៍អំពីបញ្ហាដីធ្លី</u>***

- កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២ តំណាងសហគមន៍ឡពាងចំនួន ០៤ នាក់ រួមទាំងកុមារអាយុ ០១ ឆ្នាំម្នាក់ ត្រូវបាននគរបាលខេត្តកំពង់ឆ្នាំងឃាត់ខ្លួន និងបញ្ជូនទៅតុលាការដើម្បីសាកសួរ។ តំណាងសហគមន៍ឈ្មោះ អ្នកស្រី អ៊ុំ សុភី និង លោក សួន ញឿន និងប្រជាពលរដ្ឋឈ្មោះ ទូន សេង និងចៅប្រុសរបស់គាត់ ត្រូវបានចាប់ខ្លួន បន្ទាប់ពីពួកគេបានថតវីដេអូជម្លោះរវាងអាជ្ញាធរ និងអ្នកភូមិជុំវិញដីមានជម្លោះ ហើយបានបង្ហោះនៅលើបណ្ដាញសង្គមហ្វេសប៊ុក ដោយមិនបានសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានជាមុន។ អ្នកទាំងនោះត្រូវបានបញ្ជូនទៅកាន់ការិយាល័យបទល្មើសកម្រិតធ្ងន់ និងត្រូវបានគេសាកសួរ។ អាជ្ញាធរចោទប្រកាន់ សួន ញឿន និង អ៊ុំ សុភី ថាបាននិយាយបំផ្លើសជុំវិញជម្លោះដីធ្លីតាមបណ្ដាញសង្គមហ្វេសប៊ុក។ ទោះជាយ៉ាងនេះក្ដី អធិការនគរបាលស្រុកជលគិរី បានឱ្យដឹងថាសមត្ថកិច្ចចាប់ខ្លួនអ្នកភូមិ ពីបទបំផ្លាញទ្រព្យសម្បត្តិឯកជន មិនមែនដោយសារតែបង្ហោះរូបភាពតាមបណ្ដាញសង្គមនោះទេ។ ក្រោយពីបានឃុំខ្លួនអស់រយៈពេលបីយប់រួចមក អ៊ុំ សុភី និង សួន ញឿន ត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយគ្មានកំណត់។ ទាំងឈ្មោះសុភី និងឈ្មោះ ញឿន ត្រូវបានចោទប្រកាន់ពីបទសមគំនិតធ្វើឱ្យខូចខាតដោយចេតនា ។[78]
- កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២២ អ្នកស្រី ដេត ហួរ តំណាងសហគមន៍ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង ត្រូវបានផ្ដន្ទាទោសពីបទបង្ខូចកេរ្ដិ៍ និងបរិហារកេរ្ដិ៍ ហើយត្រូវបានតុលាការខេត្តកោះកុងផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេល ០១ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ០២ លានរៀល (៥០០ ដុល្លារ)។

---

[77] យុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ប្រឆាំងនឹងការចូលរួមជាសាធារណៈ គឺជាឧបករណ៍បណ្ដឹងវិវាទមួយដែលត្រូវបានគេប្រើដើម្បីបំបាក់ទឹកចិត្ត បំភិតបំភ័យ បង្កការលំបាក រំខាន ឬរឹបអូសយកហិរញ្ញវត្ថុរបស់ចុងចម្លើយ បំបិទមាត់សំឡេងប្រឆាំង ការរិះគន់ ឬការជំទាស់។

[78]ណាត សុភាព និងខាន់ លក្ខិណា 'សកម្មជនដីធ្លីត្រូវបានចាប់ខ្លួននៅខេត្តកំពង់ឆ្នាំង' (វីអូឌី, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២) <https://vodenglish.news/land-activists-arrested-in-kampong-chhnang/> ។

ឧកញ៉ា ហេង ហ៊ុយ បានប្ដឹង អ្នកស្រី ដេត ហួរ បន្ទាប់ពីអ្នកស្រី បានបង្ហោះរូបថតគាត់នៅលើបណ្ដាញសង្គមហ្វេសប៊ុក និងរិះគន់ពីការរំលោភបំពានយកដីសហគមន៍។ តាមពាក្យបណ្ដឹងរបស់ឈ្មោះ ហេង ហ៊ុយ តុលាការក៏បានផ្ដន្ទាទោសឈ្មោះ ដេត ហួរ ហើយ ហេង ហ៊ុយ បានដាក់ពាក្យបណ្ដឹងស្រដៀងគ្នានេះប្រឆាំងនឹងសមាជិកសហគមន៍ផ្សេងទៀត ដែលការតវ៉ាចោទប្រកាន់ថាក្រុមហ៊ុនរបស់ឧកញ៉ាទន្ទ្រានយកដីសហគមន៍។[79]

- អ្នកសារព័ត៌មានក៏ត្រូវបានកំណត់ជាមុខសញ្ញានៃពាក្យយុទ្ធសាស្ត្របណ្ដឹងផ្លូវច្បាប់ចំពោះការរាយការណ៍អំពីបញ្ហាដីធ្លីផងដែរ។ លោក ទ្រី សុផល ដែលជាអ្នកសារព័ត៌មានប្រចាំកាសែត *Everyday* ត្រូវបានកោះហៅមកសាកសួរបន្ទាប់ពីបានថត និងរាយការណ៍អំពីការកាប់ឆ្ការដីរដ្ឋនៅស្រុកគូលែន ខេត្តព្រះវិហារ។[80] ដូចគ្នាដែរ លោក សេន វីរៈ ដែលជាអ្នកសារព័ត៌មានរបស់ *'SBP Post News'* ប្រចាំខេត្តបាត់ដំបង ត្រូវបានសាលាដំបូងខេត្តបាត់ដំបង កោះហៅមកសាកសួរ បន្ទាប់ពីលោកបានយកព័ត៌មាន និងរាយការណ៍អំពីជម្លោះដីធ្លី។[81]

### ២.៤.៥. អ្នកសារព័ត៌មានបានជួបការយាយីនៅពេលព្យាយាមចូលរួមសន្និសីទសារព័ត៌មានរបស់រដ្ឋាភិបាល

*តួលេខទី ៣២៖ អ្នកសារព័ត៌មានដែលប្រឈមនឹងការយាយីនៅពេលរាយការណ៍អំពីករណីរសើប*




នៅឆ្នាំ២០២២ គម្រោងបានកត់ត្រាករណីអ្នកសារព័ត៌មានពីរនាក់មកពីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលត្រូវបានហាមឃាត់ចូលរួមសន្និសីទដែលរៀបចំដោយរដ្ឋាភិបាល ដោយមិនមានការបកស្រាយអ្វីឡើយ បើទោះបីជាគាត់មាន ប័ណ្ណចូលរួមក៏ដោយ។ ក្នុងករណីនេះ រដ្ឋាភិបាលបានអះអាងថា អ្នកសារព័ត៌មានមិនបានបង្ហាញភស្តុតាងបញ្ជាក់អត្តសញ្ញាណ[82] ឬចុះឈ្មោះជាមុន ឬអះអាងថាមិនមានកន្លែងទំនេរ។[83]

---

[79] យុត សុគន្ធ "ក្រុមអ្នកតវ៉ាដីធ្លីនៅខេត្តកោះកុង ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ប៉ុន្តែមិនត្រូវបានឃុំខ្លួនទេ" (វីអូឌី, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០២២ )< https://vodenglish.news/koh-kong-land-protester-sentenced-to-jail-but-not-detained >។

[80] ញ៉ែម សុខន " "អ្នកសារព័ត៌មានប្រឈមមុខនឹងដីកាចាប់ខ្លួន បន្ទាប់ពីថតរូបភាពឈូសឆាយដី" (វីអូឌី, ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ )< https://vodenglish.news/journalist-faces-arrest-warrant-after-filming-land-clearing/ >។

[81] សុខ សាវី "តុលាការខេត្តបាត់ដំបងបានចាប់ខ្លួនអ្នកសារព័ត៌មានក្រោយជម្លោះដីធ្លីនៅកម្ពុជា" (ខេមបូចារ, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ )<https://khmer.cambojanews.com/battambang-provincial-court-ordered-a-journalist-to-very-at-the-court-after-land-dispute/ >។

[82] ម៉ិច ដារ៉ា "អ្នកសារព័ត៌មានមួយចំនួនត្រូវបានរារាំងមិនឱ្យចូលរួមសន្និសីទសារព័ត៌មានរបស់នគរបាល ស្ដីពីការចាប់ខ្លួនមនុស្សបុគ្គលិកណាហ្គាវើលដ៍", (វីអូឌី, ថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២)< https://vodenglish.news/some-journalists-barred-from-police-press-conference-on-nagaworld-arrests/>។

[83] សុត សុខប្រាថ្នា, "អ្នកយកព័ត៌មាន វីអូឌី និងវីអូអេ ត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងពិធីថ្លែងសុន្ទរកថារបស់នាយករដ្ឋមន្ត្រីក្រោយកិច្ចប្រជុំអាស៊ាន" (វីអូឌី, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ),< https://vodenglish.news/vod-voa-reporters-banned-from-pms-post-asean-speech/>។

ការរារាំងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មានចូលរួមសន្និសីទដែលរៀបចំដោយរដ្ឋាភិបាល ជាការរារាំងដល់អ្នកសារព័ត៌មានក្នុងការរាយការណ៍អំពីបញ្ហាផលប្រយោជន៍សាធារណៈ និងជាការជ្រៀតជ្រែកដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ជាងនេះទៀត មានករណីចំនួនបីដែលផ្សេងទៀតដែលអាជ្ញាធរបានរឹបអូសយកទូរសព្ទរបស់អ្នកសារព័ត៌មាន ខណៈដែលកំពុងថតរូប ឬវីដេអូ ហើយក៏មានករណីចំនួន ០៥ ផងដែរត្រូវបានរាយការណ៍ពាក់ព័ន្ធនឹងអំពើហិង្សាលើរូបរាងកាយមកលើពួកគេ។

### ការដកហូតអាជ្ញាបណ្ណបណ្តាញផ្សព្វផ្សាយឯករាជ្យ ធ្វើឱ្យប៉ះពាល់ដល់សេរីភាពសារព័ត៌មាន និងសេរីភាពខាងបញ្ចេញមតិ




នៅឆ្នាំ២០២២ មានប្រព័ន្ធផ្សព្វផ្សាយចំនួនបីត្រូវបានបិទ។ សារព័ត៌មាន Bayong Times, KCTV និង Cambodia Today ត្រូវបានដកហូតអាជ្ញាបណ្ណ បន្ទាប់ពីបានចុះផ្សាយអត្ថបទជុំវិញការចោទប្រកាន់អាជ្ញាធរសាធារណៈថាបានប្រព្រឹត្តអំពើពុករលួយ។[84] ការដកហូតអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយទាំងនេះឆ្លុះបញ្ចាំងពីការធ្លាក់ចុះបន្ថែមទៀតនូវស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា និងជាសញ្ញានៃការដើរថយក្រោយដ៏គួរឱ្យព្រួយបារម្ភនៃសេរីភាពខាងការបញ្ចេញមតិ និងនីតិរដ្ឋនៅក្នុងប្រទេស។

ការរឹតត្បិតសេរីភាពមូលដ្ឋានជាច្រើនដែលបានកត់ត្រាក្នុងឆ្នាំ២០២២ បង្ហាញពីលំនាំនៃការអនុវត្តក្របខណ្ឌច្បាប់កម្ពុជាដោយមិនត្រឹមត្រូវ និងតាមទំនើងចិត្ត។ ច្បាប់នៅតែត្រូវបានគេបន្តប្រើប្រាស់ដើម្បីបង្រួមលំហសង្គមស៊ីវិល ជាជាងផ្តល់ការការពារសេរីភាពមូលដ្ឋាន។ សកម្មភាពរបស់អាជ្ញាធរតែងធ្វើលើសពីដែនកំណត់នៃការរឹតត្បិតដែលច្បាប់បានអនុញ្ញាត ដែលត្រូវបានចាត់ទុកជាការរំលោភបំពាន។ សមាគមប្រភេទផ្សេងៗ ទទួលរងការជ្រៀតជ្រែក ហើយសមាជិករបស់ពួកគេត្រូវបានកំណត់ជាមុខសញ្ញា និងមានការឃាយឃីតាមផ្លូវតុលាការ។ អ្នកតវ៉ាដែលធ្វើការទាមទារពាក់ព័ន្ធនឹងរឿងនយោបាយ ត្រូវបានរដ្ឋាភិបាលកំណត់មុខសញ្ញាថាជាអ្នកប្រឆាំងដោយមិនត្រឹមត្រូវ។ ការពង្រីកវិសាលភាពនៃការឃ្លាំមើល និងដាក់វិធានការចំពោះការនិយាយស្តីតាមប្រព័ន្ធអ៊ីនធឺណិតពីសំណាក់រដ្ឋាភិបាល ការសម្រេចបិទប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក៏ដូចជាការជ្រៀតជ្រែកលើការងារសារព័ត៌មាន គឺជាការរំលោភលើបទដ្ឋាននៃការបញ្ចេញមតិ ធ្វើឱ្យសេរីភាពមូលដ្ឋាននៅក្នុងប្រទេស កាន់តែមានសភាពយ៉ាប់យ៉ឺនខ្លាំងឡើងៗ។ ការប្រើច្បាប់ដើម្បីរាំងក្នុងការអនុវត្តសេរីភាពមូលដ្ឋានបានពេញលេញទំនងជាមិននាំទៅដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ឬលទ្ធិប្រជាធិបតេយ្យដ៏រស់រវើកនោះទេ។

[84] ណាត សុភាព, 'ក្រសួងព័ត៌មានដកហូតអាជ្ញាបណ្ណបណ្តាញផ្សព្វផ្សាយឌីជីថលចំនួនបី', (វីអូឌី, ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២២) <https://vodenglish.news/information-ministry-revokes-licenses-for-three-digital-publications/ >។

## ៣. ចំណុចគន្លឹះទី ៣៖ តើបុគ្គលម្នាក់ៗយល់អំពីសេរីភាពមូលដ្ឋាន និងយល់ថាខ្លួនមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនេះដែរឬទេ?

ចំណុចគន្លឹះទី៣ វាយតម្លៃពីកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា អំពីសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ និងកម្រិតដែលពួកគេយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិទាំងនោះ។[85] ទិន្នន័យចំណុចគន្លឹះទី៣ត្រូវបានប្រមូលតាមរយៈការស្ទង់មតិជាសាធារណៈជាមួយពលរដ្ឋកម្ពុជាចំនួន ១,៤២៤ នាក់នៅទូទាំង ២៥ រាជធានី-ខេត្ត (តួលេខទី ៣៤) ចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (តួលេខទី ៣៥ បង្ហាញថា ៥០% ជាស្ត្រី ៤៧% ជាបុរស និង ៣% ទៀតត្រូវបានកំណត់ថាជា "បុគ្គលផ្សេងៗ")។ វិធីសាស្ត្រការជ្រើសរើសសំណាកងាយៗត្រូវបានប្រើសម្រាប់ការស្ទង់មតិនេះ។

*តួលេខទី ៣៤៖ ចំនួនអ្នកឆ្លើយតបការស្ទង់មតិជាសាធារណៈពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២២*




*តួលេខទី ៣៥៖ ចំនួនភាគរយនៃអ្នកឆ្លើយតបការស្ទង់មតិជាសាធារណៈក្នុងឆ្នាំ២០២២ បែងចែកតាមនិន្នាការភេទ និង/ឬអត្តសញ្ញាណយេនឌ័រ*




**របកគំហើញសំខាន់ៗ៖** ចំណេះដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋាន និងក្របខណ្ឌច្បាប់ទាក់ទងនឹងសិទ្ធិទាំងនេះ នៅតែមានកម្រិតថេរដដែលបើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។ ចំនួនភាគរយនៃអ្នកដែលយល់ច្បាស់អំពីសេរីភាពមូលដ្ឋាននីមួយៗ នៅតែមានកម្រិតទាប។ ពលរដ្ឋជាច្រើននៅតែមានការភ័យខ្លាចចំពោះផលប៉ះពាល់នៅពេលអនុវត្តសេរីភាពមូលដ្ឋាន ដោយយល់ថាខ្លួនមានលទ្ធភាពកាន់តែតិចតួចក្នុងការអនុវត្តសេរីភាពទាំងនេះ។ ម្យ៉ាងវិញទៀត ទិន្នន័យឆ្នាំ២០២២ បង្ហាញថាមានការកើនឡើងនូវចំនួនស្ត្រីដែលយល់ថាមានសេរីភាពក្នុងការចូលរួមក្នុងជីវភាពនយោបាយ។ ទោះបីជាការស្ទង់មតិបានបង្ហាញថាមានការកើនឡើងនូវចំនួនភាគរយនៃអ្នកឆ្លើយតបដែលយល់ថា មានសេរីភាពក្នុងការចូលរួមតវ៉ាដោយសន្តិវិធីក៏ដោយ ក៏បុគ្គលម្នាក់ៗនៅតែមានអារម្មណ៍ស្ទាក់ស្ទើរក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី។

---

[85] ទិន្នន័យសម្រាប់ចំណុចគន្លឹះទី៣ បានមកពីការស្ទង់មតិជាសាធារណៈរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន ដែលបានធ្វើឡើងក្នុងអំឡុងខែតុលា ឆ្នាំ២០១៦ (ឆ្នាំ២០១៦ ឬឆ្នាំទី១) ខែមីនា ឆ្នាំ២០១៨ (ឆ្នាំ២០១៧ ឬឆ្នាំទី២) ខែមីនា ឆ្នាំ២០១៩ (ឆ្នាំ២០១៨ ឬឆ្នាំទី៣) ខែមីនា ឆ្នាំ២០២០ (ឆ្នាំ២០១៩ ឬឆ្នាំទី៤) ខែធ្នូ ឆ្នាំ២០២០ (ឆ្នាំ២០២០ ឬឆ្នាំទី៥) ខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២១ (ឆ្នាំ២០២១ ឬឆ្នាំទី៦) និងខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២២ (ឆ្នាំ២០២២ ឬ ឆ្នាំទី៧)។

## ៣.១. ការយល់ដឹងរបស់សាធារណជនអំពីសេរីភាពមូលដ្ឋានមានការកើនឡើងបន្តិច




*តួលេខទី ៣៦៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាបានយល់ច្បាស់អំពីសេរីភាពមូលដ្ឋាន*

ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយថាខ្លួនបានដឹង*"ច្បាស់ណាស់"*ពីអត្ថន័យនៃសេរីភាពនីមួយៗមានកម្រិតទាប (១០% ចំពោះសេរីភាពខាងការជួបប្រជុំ ១២% ចំពោះសេរីភាពខាងការបញ្ចេញមតិ និង ៥% ចំពោះសេរីភាពខាងសមាគម)។ ភាគរយនៃអ្នកឆ្លើយតបដែលបានឆ្លើយថាខ្លួន *"ដឹងច្បាស់ណាស់"* អំពីធាតុផ្សំនៃសេរីភាពខាងការជួបប្រជុំ គឺមិនមានការប្រែប្រួលទេនៅឆ្នាំ២០២២ បើធៀបទៅនឹងឆ្នាំ២០២១។ ភាគរយនៃអ្នកឆ្លើយតបដែល *"ដឹងច្បាស់ណាស់"* អំពីធាតុផ្សំសំខាន់ៗនៃសេរីភាពខាងសមាគម មានការកើនឡើងពី ៤% ក្នុងឆ្នាំ២០២១ ទៅ ៥% ក្នុងឆ្នាំ២០២២។ ដូចគ្នាដែរ ភាគរយមានការកើនឡើងតិចតួចចំពោះសេរីភាពខាងការបញ្ចេញមតិ ពី៨% ក្នុងឆ្នាំ២០២១ ទៅ ១២% ក្នុងឆ្នាំ២០២២។

ការណ៍ដែលមានពលរដ្ឋមួយចំនួនតូចប៉ុណ្ណោះ ដឹងច្បាស់អំពីសេរីភាពមូលដ្ឋាន និងធាតុផ្សំនៃសិទ្ធិទាំងនេះ[86] គឺអាចដោយសារតែការរារាំងពលរដ្ឋក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនឱ្យបានពេញលេញ ឬការមិនទទួលស្គាល់នូវការរំលោភសិទ្ធិទាំងនេះ។ ហេតុនេះ មានពលរដ្ឋជាច្រើននៅតែមិនបានត្រៀមខ្លួនក្នុងការការពារសេរីភាពមូលដ្ឋាន ឬទាមទារឱ្យជនដែលប្រព្រឹត្តមកទទួលខុសត្រូវនៅពេលដែលសេរីភាពមូលដ្ឋានត្រូវបានរំលោភបំពាន។

[86] ដើម្បីវាយតម្លៃលើការយល់ដឹងអំពីសេរីភាពមូលដ្ឋាន ក្រុមការងារគម្រោង បានសួរអ្នកឆ្លើយតបអំពីធាតុផ្សំពាក់ព័ន្ធមួយចំនួននៃសេរីភាពមូលដ្ឋានទាំងបីដែលមិនអាចកាត់ផ្ដាច់ពីគ្នាបាន និងកំណត់ពីវិសាលភាពនៃការអនុវត្តសិទ្ធិទាំងនោះ។

## ៣.២. ទោះបីជាមានពលរដ្ឋកាន់តែច្រើនឡើងយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិជាសាធារណៈក៏ដោយ មានតែអ្នកឆ្លើយតបមួយចំនួនតូចប៉ុណ្ណោះដែលយល់ថាមានសេរីភាពក្នុងការអនុវត្តសិទ្ធិនេះតាមប្រព័ន្ធអ៊ីនធឺណិត ឬក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មាន [87]

*តួលេខទី ៣៧៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មាន*




នៅឆ្នាំ២០២១ និងឆ្នាំ២០២២ មានការកើនឡើងនូវភាគរយនៃអ្នកឆ្លើយតប ដែលមានអារម្មណ៍ថាមានសេរីភាព ក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មាន បើប្រៀបធៀបទៅនឹងឆ្នាំ ២០២០ ដែលមានចំនួនទាបបំផុតនៃអ្នកឆ្លើយតបត្រឹមតែ ២៧% ប៉ុណ្ណោះ។ លទ្ធផលនៃការស្ទង់មតិសម្រាប់ឆ្នាំ២០២២ បានបង្ហាញថា ៥៥% នៃអ្នកឆ្លើយតបមិនមានសេរីភាពក្នុងការនិយាយទៅកាន់អ្នកសារព័ត៌មានទេ ហើយមានករណីជាច្រើនដែលបុគ្គលស្នើសុំឱ្យរក្សាអត្តសញ្ញាណរបស់ខ្លួនជាជនអនាមិកនៅពេលនិយាយជាមួយអ្នកសារព័ត៌មាន។[88] នេះបង្ហាញថា ពលរដ្ឋជាច្រើននៅតែមានអារម្មណ៍ថាខ្លួនមិនអាចបញ្ចេញការយល់ឃើញរបស់ខ្លួនដោយសេរី ហើយឆ្លុះបញ្ចាំងពីការរឹតត្បិតយ៉ាងធ្ងន់ធ្ងរជាបន្តបន្ទាប់មកលើសេរីភាពខាងការបញ្ចេញមតិ។

*តួលេខទី ៣៨៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ*




ដូចគ្នានេះដែរ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថា មានសេរីភាពក្នុងការនិយាយដោយបើកចំហនៅទីសាធារណៈ បានបន្តកើនឡើងនៅឆ្នាំ២០២២ ពី ២៩% ក្នុងឆ្នាំ២០២០ ទៅ ៤៣% នៅឆ្នាំ២០២១ និង ៥៥% នៅឆ្នាំ២០២២។ នេះបង្ហាញពីរបត់គួរឱ្យកត់សម្គាល់ ដែលពលរដ្ឋអាចពិភាក្សាគ្នាបានកាន់តែច្រើនពីប្រធានបទផ្សេងៗនៅទីសាធារណៈ។

---

87 ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ បានមកពីការបូកចំនួនភាគរយនៃអ្នកដែលឆ្លើយតបថាខ្លួនមានអារម្មណ៍ "មានសេរីភាពខ្លាំងណាស់" និង "មានសេរីភាពខ្លះដែរ" នៅពេលសួរថា "តើអ្នកគិតថា អ្នកមានសេរីភាពកម្រិតណាក្នុងការបញ្ចេញមតិរបស់អ្នកទៅកាន់អ្នកសារព័ត៌មាន ?"។

88 ម៉ិច ដារ៉ា; Danielle Keeton-Olsen "ឧក្រិដ្ឋកម្មស្ថិតក្នុងការបិទបាំង៖ អ្នកសារព័ត៌មានរងសម្ពាធក្នុងការរាយការណ៍បទល្មើសធ្ងន់ធ្ងរក្នុងខេត្តព្រះសីហនុ",(វីអូឌី, ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២)< Crimes in Shadows: Sihanoukville's Grisly Reports, Pressure on Journalists (vodenglish.news)>។

តួលេខទី ៣៩៖ ភាគរយនៃអ្នកឆ្លើយតបយល់ថាមានសេរីភាពក្នុងការនិយាយដោយបើកចំហនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម




ភាគរយនៃអ្នកឆ្លើយតបដែល យល់ថាមានសេរីភាពក្នុងការនិយាយដោយ បើកចំហគ្រប់ប្រធានបទទាំងអស់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម បានថយចុះបន្តិចក្នុងឆ្នាំ២០២២ ពី ៤៧% នៅឆ្នាំ ២០២១ មកត្រឹម ៤៤% នៅឆ្នាំ ២០២២។ ទោះបីជាមានការកើនឡើងក្នុងរយៈពេលពីរឆ្នាំកន្លងមកក៏ដោយ ក៏ភាគរយជារួមនៅតែមានកម្រិតទាបដដែល។ ការណ៍ដែលពលរដ្ឋមិនអាចនិយាយដោយបើកចំហនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម បានឆ្លុះបញ្ចាំងពីសក្ដានុពលនូវបរិយាកាសនៃការភ័យខ្លាច និងការរឹតត្បិតខ្លួនឯងរបស់ពលរដ្ឋនៅតែបន្តកើតមាន។

លទ្ធផលពីតួលេខទី៣៧ តួលេខទី៣៨ និង ទី៣៩ បានបង្ហាញពីគំរូស្រដៀងគ្នា ដែលអ្នកឆ្លើយតបហាក់ដូចជាមានទស្សនៈប្រហាក់ប្រហែលគ្នា ជុំវិញការនិយាយទៅកាន់អ្នកសារព័ត៌មាន ការនិយាយនៅទីសាធារណៈ និងការនិយាយដោយបើកចំហនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ ដែលជាការពិតណាស់ ទាំងនេះគឺជាធាតុផ្សំបីដ៏សំខាន់នៃសេរីភាពខាងការបញ្ចេញមតិ។

ការស្ទង់មតិរបស់គម្រោង បានបង្ហាញនូវភាគរយអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ មានការធ្លាក់ចុះជាបន្តបន្ទាប់។ ទាំងតួលេខទី៣៧ ៣៨ និង ៣៩ បង្ហាញថាពលរដ្ឋភាគច្រើនមានអារម្មណ៍ថាអាចនិយាយបានគ្រប់ប្រធានបទដោយសេរីនៅអំឡុងឆ្នាំ២០១៧។ បន្ទាប់មកមានការធ្លាក់ចុះដល់កម្រិតមួយទាបនៅអំឡុងឆ្នាំ២០២០។ នៅឆ្នាំ២០២១ និងឆ្នាំ២០២២ របត់មានការប្រែប្រួលផ្ទុយពីនេះ។ យ៉ាងណាមិញ ទោះបីជាមានការកើនឡើងបែបនេះក៏ដោយ ប៉ុន្តែភាគរយនៃអ្នកឆ្លើយមានអារម្មណ៍ថាមានសេរីភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិ នៅឆ្នាំ២០២២ មានកម្រិតទាបជាង បើធៀបនឹងឆ្នាំ ២០១៧។ នេះបង្ហាញថា (ក) អ្នកឆ្លើយតបមានការស្ទាក់ស្ទើរក្នុងការបញ្ចេញគំនិត និងមតិរបស់ខ្លួនដោយសារតែមានការភ័យខ្លាចចំពោះការសងសឹក និង (ខ) នៅមានកិច្ចការដែលត្រូវធ្វើបន្ថែមទៀត ដើម្បីធានាបានថាពលរដ្ឋអាចអនុវត្តសេរីភាពខាងការបញ្ចេញមតិ។

## ៣.៣. ចំនួនអ្នកដែលរឹតត្បិតសេរីភាពខ្លួនឯង នៅតែបន្តកើនឡើងជារៀងរាល់ឆ្នាំ ដោយសារតែមានការរឹតត្បិតជាបន្តចំពោះសេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេស

*តួលេខទី ៤០៖ ចំនួនភាគរយនៃសាធារណជនដែលបានរាយការណ៍អំពីការរឹតត្បិតសេរីភាពខ្លួនឯង*




នៅចន្លោះឆ្នាំ២០២០ និង២០២២ ពលរដ្ឋមួយចំនួនតូចនៅតែមិនចង់និយាយអំពីប្រធានបទថ្មីៗ ដោយរឹតត្បិតសេរីភាពខ្លួនឯងក្នុងការបញ្ចេញមតិ។[89] ភាគរយនៃអ្នកដែលរាយការណ៍ថាតែងរឹតត្បិតសេរីភាពខ្លួនឯងបានកើនឡើងពី ៧% ក្នុងឆ្នាំ២០២០ ទៅ ១០% ក្នុងឆ្នាំ២០២២។ នៅឆ្នាំ២០២២ ១៣% នៃអ្នកឆ្លើយតបបាននិយាយថាបានរឹតត្បិតសេរីភាពខ្លួនឯងជាប្រចាំ អ្នកឆ្លើយតបចំនួន ៤៥% រឹតត្បិតសេរីភាពខ្លួនឯងនៅពេលខ្លះ អ្នកឆ្លើយតបចំនួន ១២% ឆ្លើយថាកម្រណាស់ ហើយមានតែ ៧% ប៉ុណ្ណោះដែលមិនរឹតត្បិតសេរីភាពរបស់ខ្លួន។ ទោះបីជាភាគរយនៅតែមានកម្រិតទាបក៏ដោយ ប៉ុន្តែរបត់នេះអាចបង្ហាញថាពលរដ្ឋមានការភ័យខ្លាចចំពោះផលប៉ះពាល់ដែលអាចកើតមាននៅពេលបញ្ចេញមតិ ឬចែករំលែកទស្សនៈរបស់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណិត និងនៅទីសាធារណៈ។ ពលរដ្ឋនៅតែបន្តមិនអនុវត្តនូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិ បើទោះបីជាច្បាប់ជាតិធានានូវសិទ្ធិនេះចំពោះពលរដ្ឋគ្រប់រូបក៏ដោយ។

## ៣.៤. ស្ត្រី និងបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទផ្សេងៗ នៅតែយល់ថាមានសេរីភាពតិចជាងបុរសក្នុងការបញ្ចេញគំនិត ឬមតិយោបល់

*តួលេខទី ៤១៖ ភាគរយនៃសាធារណជនដែលបានរាយការណ៍អំពីការរឹតត្បិតសេរីភាពខ្លួនឯងដោយបែងចែកតាមយេនឌ័រ*




ក្នុងឆ្នាំ២០២២ ៩% នៃអ្នកឆ្លើយតបជាបុរសបានរាយការណ៍ថា *ជានិច្ចកាល* តែងរឹតត្បិតសេរីភាពខ្លួនឯង ១៤% បានរឹតត្បិតសេរីភាពខ្លួនឯង *ជាប្រចាំ* ៤៧% ឆ្លើយថា *នៅពេលខ្លះ* ១២% ឆ្លើយថា *កម្រណាស់* និង ៧% *មិនដែលសោះ ក្នុងការរឹតត្បិតសេរីភាពខ្លួនឯង*។ តាមការប្រៀបធៀប ១១% នៃស្ត្រី *ជានិច្ចកាល* តែងរឹតត្បិតសេរីភាពខ្លួនឯង ១៣% *ជាប្រចាំ* ៤៤% *នៅពេលខ្លះ* ១៣% *កម្រណាស់* និង ៧% *មិនដែល* ធ្វើដូច្នេះ

[89] សំណួរនេះមិនបានសួរទេនៅចន្លោះឆ្នាំ២០១៦ និង២០១៩ ។

ទេ។ អ្វីដែលគួរឱ្យព្រួយបារម្ភគឺថា បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រផ្សេងៗ បានរាយការណ៍ថាមានការរឹតត្បិតសេរីភាពខ្លួនឯងក្នុងភាគរយខ្ពស់បំផុត។ អ្នកឆ្លើយតបទាំងនេះបានរាយការណ៍ពីការរឹតត្បិតសេរីភាពខ្លួនឯងថា *"ជានិច្ចកាល"* កើតឡើង (២១%) *"ជាប្រចាំ"* (២៦%) និង *"នៅពេលខ្លះ"* (៤៤%) ជាសាធារណៈទាំងនៅលើ និងក្រៅប្រព័ន្ធអ៊ីនធឺណិត ដែលនេះឆ្លុះបញ្ចាំងពីការកើនឡើងយ៉ាងមានសក្តានុពល នូវការគំរាមកំហែង ឬការតបត ចំពោះអ្នកដែលមានអត្តសញ្ញាណយេនឌ័រផ្សេងៗ បើប្រៀបធៀបទៅនឹងអ្នកឆ្លើយតបជាបុរស ឬស្ត្រី។

## ៣.៥. ពលរដ្ឋភាគច្រើនយល់ថាខ្លួនអាចចូលរួម ឬចាកចេញពីសមាគម ឬ សហជីពដោយសេរី

*តួលេខទី ៤២៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានសេរីភាព ឬមិនមានសេរីភាពក្នុងការចូលរួមសហជីព*




ចាប់តាំងពីឆ្នាំ២០២០ ការសួរសំណួរទៅកាន់អ្នកឆ្លើយតបដែលជាកម្មករនិយោជិត អំពីការយល់ឃើញរបស់ពួកគេទៅលើកម្រិតនៃសេរីភាពឬមិនមានសេរីភាពក្នុងការចូលរួម និង/ឬចាកចេញពីសហជីព ឬសមាគម ។ តួលេខទី៤២ បង្ហាញថាសាធារណជនភាគច្រើននៅតែយល់ថាខ្លួនអាចអនុវត្តសេរីភាពខាងសមាគមដោយចូលរួមជាមួយសហជីព។ តួយ៉ាង ក្នុងអំឡុងឆ្នាំ២០២២ ១៣% នៃអ្នកឆ្លើយតប យល់ថាមានសេរីភាពខ្លាំងណាស់ ហើយ ២៥% ឆ្លើយថាមានសេរីភាពខ្លះដែរក្នុងការអនុវត្តសិទ្ធិក្នុងការចូលរួមសហជីព ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់ខ្លួន ព្រមទាំងធ្វើការឆ្ពោះទៅសម្រេចបាននូវគោលដៅរួម។ ផ្ទុយទៅវិញ ចំនួនភាគរយនៃអ្នកឆ្លើយតបយល់ថាមិនមានសេរីភាពទាល់តែសោះក្នុងការចូលរួមសហជីព មានកម្រិតទាបដោយមានតែ ៣% នៃអ្នកឆ្លើយតបប៉ុណ្ណោះដែលលើកឡើងដូច្នេះ។

*តួលេខទី ៤៣៖ ចំនួនភាគរយនៃសាធារណជនដែលដែលរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមសមាគម*




តួលេខទី៤៣ បង្ហាញថា ២២% នៃអ្នកឆ្លើយតបយល់ថាមានសេរីភាពខ្លាំងណាស់ ហើយ ៤១% យល់ថាមានសេរីភាពខ្លះដែរក្នុងការចូលរួមជាមួយសមាគម។ ស្រដៀងគ្នានឹងករណីសហជីពដែរ មានតែអ្នកឆ្លើយតប

ចំនួន ៣% ប៉ុណ្ណោះដែលយល់ថាមិនមានសេរីភាពទាល់តែសោះក្នុងការចូលរួមសមាគម ដែលភាគរយនេះនៅតែមានចំនួនតិចតួចក្នុងឆ្នាំកន្លងមក។

*តួលេខទី ៤៤៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានសេរីភាព ឬមិនមានសេរីភាព ក្នុងការចាកចេញពីសមាគម*




ម្យ៉ាងវិញទៀត តួលេខទី៤៤បង្ហាញពីការកើនឡើងតិចតួចនូវភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការចាកចេញពីសមាគម (កើនឡើងពី១៧% ក្នុងអំឡុងឆ្នាំ២០២១ ទៅ ២០% ក្នុងឆ្នាំ២០២២)។ មានតែ ១% នៃអ្នកឆ្លើយតបប៉ុណ្ណោះយល់ថាមិនមានសេរីភាពក្នុងការចាកចេញពីសហជីព។ ទោះបីជាលទ្ធផលក្នុងឆ្នាំ២០២២ បង្ហាញពីបរិបទមួយដែលលើកទឹកចិត្តក្នុងការចូលរួមសមាគម ឬសហជីពកាន់តែច្រើនឡើងក៏ដោយ ជាក់ស្តែងភាគរយនៃអ្នកដែលឆ្លើយថាមានសេរីភាពខ្លាំងណាស់ក្នុងការចូលរួម ឬចាកចេញ គឺមានភាពផ្ទុយគ្នានឹងអ្នកដែលឆ្លើយថាមានសេរីភាពខ្លះដែរ (សូមមើលតួលេខទី៤៣) ដែលនៅតែមានការស្ទាក់ស្ទើរក្នុងការចាកចេញពីសហជីពដែរ បើធៀបនឹងលទ្ធផលឆ្នាំ២០២០។

## ៣.៦. បុគ្គលម្នាក់ៗយល់ថាមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយ

*តួលេខទី ៤៥៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានសេរីភាពក្នុងការចូលរួមក្នុងជីវភាពនយោបាយ*




ទិន្នន័យឆ្នាំ២០២២ បង្ហាញពីការកើនឡើងនូវភាគរយនៃអ្នកដែលឆ្លើយថា "មានសេរីភាពខ្លាំងណាស់" ក្នុងការចូលរួមក្នុងជីវភាពនយោបាយ (៤៤%) បន្ទាប់ពីមានការធ្លាក់ចុះក្នុងអំឡុងឆ្នាំ ២០១៧ ដល់ ឆ្នាំ២០២០។ ទោះបីជាការចូលរួមជីវភាពនយោបាយនៅមានកម្រិតក៏ដោយ ក៏ទិន្នន័យដែលប្រមូលបានក្នុងអំឡុងពេលនៃរបាយការណ៍ បានបង្ហាញពីឆន្ទៈកាន់តែខ្លាំងឡើងក្នុងការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនយោបាយ។

## ៣.៧. អ្នកឆ្លើយតបយល់ថាមិនសូវមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយ ដោយឡែក គម្លាតរវាងបុរស និងស្ត្រីនៅតែបន្តរួមតូច

*តួលេខទី ៤៦៖ ភាគរយនៃសាធារណជនដែលយល់ថាមានសេរីភាពក្នុង ការចូលរួមក្នុងជីវភាពនយោបាយ ដោយបែងចែកតាមយេនឌ័រ*




មានតែ ២១% នៃអ្នកឆ្លើយតបជាស្ត្រី និង ២២% នៃអ្នកឆ្លើយតបជាបុរសប៉ុណ្ណោះ ដែលយល់ថា មានសេរីភាព ក្នុងការចូលរួមក្នុងជីវភាពនយោបាយ។ នេះគឺជាការថយចុះគួរឱ្យកត់សម្គាល់ពី ៦០% នៃបុរស និង ៣៣% នៃស្ត្រី ដែលបានរាយការណ៍ថាយល់ថាមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយក្នុងឆ្នាំ២០១៦។ ទោះបីជា គម្លាតនៃការយល់ឃើញរបស់ស្ត្រី និងបុរសទៅលើសេរីភាពក្នុងការចូលរួមនយោបាយរួមតូចក៏ដោយ និន្នាការទូទៅបង្ហាញពីការព្រួយបារម្ភ និងឆ្លុះបញ្ចាំងពីការរឹតត្បិតសេរីភាពក្នុងការចូលរួមនយោបាយ ស្របពេលជាមួយនឹងបរិយាកាសសង្គម-នយោបាយនៅកម្ពុជាបច្ចុប្បន្ន រួមទាំងការបោះឆ្នោតច្រើនលើកកន្លងមកដែលត្រូវបានគេចាត់ទុកថាមិនសេរី។[90]

## ៣.៨. សាធារណជនមានការយល់ដឹងកាន់តែច្រើនអំពីច្បាប់ជាតិទាក់ទងនឹងសេរីភាពមូលដ្ឋាន

ការស្ទង់មតិជាសាធារណៈពិនិត្យមើលពីកម្រិតនៃការយល់ដឹងអំពីច្បាប់ជាតិដែលទាក់ទងនឹងសេរីភាពមូលដ្ឋាន ដោយសួរទៅកាន់អ្នកឆ្លើយតបអំពីសកម្មភាពជាក់លាក់ណាមួយ ថាតើសកម្មភាពនោះស្របច្បាប់ ឬខុសច្បាប់។ នៅឆ្នាំ២០២២ អ្នកចូលរួមត្រូវបានសួរសំណួរចំនួន ១០ សំណួរចំនួន ៤ ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ សំណួរចំនួន ៣ ទាក់ទងនឹងសេរីភាពខាងសមាគម និងចំនួន ៣ ទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ។[91] ក្នុងអំឡុងឆ្នាំ២០២២ សេរីភាពខាងការបញ្ចេញមតិ នៅតែជាសេរីភាពមួយដែលមានការយល់ដឹងច្រើនបំផុតក្នុងចំណោមពលរដ្ឋកម្ពុជា។ ផ្ទុយទៅវិញសេរីភាពខាងការជួបប្រជុំនៅតែមានការយល់ដឹងតិចជាងគេក្នុងចំណោមសេរីភាពទាំងអស់។

[90] ឡាយ សុភាវតី ប.ជ.គ"រងការចោទប្រកាន់ថាមានភាពលំអៀងក្នុងការបោះឆ្នោតឃុំសង្កាត់ "(ខេមបូឌៀននេស, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២)< https://cambodianess.com/article/nec-accused-of-commune-polls-bias>; ស៊ន សារ៉ាត់, "បេក្ខជនគណបក្សភ្លើងទៀនបន្ថែមទៀតត្រូវបានដកចេញពីការបោះឆ្នោត", (ខេមបូចារ, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២)<https://cambojanews.com/more-candlelight-party-commune-candidates-cut-from-election/>; ម៉ៅ សុធានី "ក្រសួងមហាផ្ទៃលុបឈ្មោះគណបក្សបេះដូងជាតិចេញពីបញ្ជីគណបក្សនយោបាយ», (អាស៊ីសេរី, ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២)<ក្រសួងមហាផ្ទៃលុបឈ្មោះគណបក្សបេះដូងជាតិចេញពីបញ្ជីគណបក្សនយោបាយ ) ខ្មែរ —rfa.org )>។

[91] សំណួរដែលប្រើប្រាស់សម្រាប់វាស់ស្ទង់ការយល់ដឹងអំពីច្បាប់ដែលទាក់ទងនឹងសេរីភាពមូលដ្ឋាន អាចរកបាននៅក្នុងឧបសម្ព័ន្ធទី ៣ នៃរបាយការណ៍នេះ។

*តួលេខទី ៤៧៖ ភាគរយនៃសាធារណជនដែលបានឆ្លើយត្រឹមត្រូវចំពោះសំណួរត្រួតពិនិត្យអំពីសេរីភាពមូលដ្ឋាននីមួយៗ*




នៅឆ្នាំ២០២២ ៤៨% នៃអ្នកឆ្លើយតបបានឆ្លើយត្រឹមត្រូវមកកាន់សំណួរទាក់ទងនឹងសេរីភាពខាងការជួបប្រជុំ។ ដោយមានតែ ៣២% (៤៥៤ នាក់) នៃអ្នកឆ្លើយតបប៉ុណ្ណោះដែលឆ្លើយបានត្រឹមត្រូវថា ការធ្វើកូដកម្មដោយមិនចាំបាច់មានការអនុញ្ញាត គឺជារឿងស្របច្បាប់។ ដូចគ្នាដែរ ៤៦% (៦៦២ នាក់) បានឆ្លើយត្រឹមត្រូវថា ការតវ៉ាដោយសន្តិវិធី គឺជារឿងស្របច្បាប់។ ហើយ ៦៧% នៃអ្នកឆ្លើយតបបានឆ្លើយថា ជារឿងខុសច្បាប់ដែលអាជ្ញាធរប្រើកម្លាំងដើម្បីបំបែកការជួបប្រជុំដោយសន្តិវិធី។ ចំពោះសេរីភាពខាងសមាគម អ្នកឆ្លើយតបចំនួន ៥១% បានឆ្លើយត្រឹមត្រូវមកកាន់សំណួរដែលប្រើសម្រាប់វាស់ស្ទង់ពីកម្រិតនៃការយល់ដឹង អំពីសេរីភាពមូលដ្ឋាននេះ។ តាមការបង្ហាញ មានតែ ២៦% ប៉ុណ្ណោះដែលឆ្លើយថា ជារឿងស្របច្បាប់ដែលសមាគមធ្វើសកម្មភាពដោយមិនចាំបាច់ធ្វើការជូនដំណឹងដល់អាជ្ញាធរ។ ដូចគ្នាដែរ ៤៤% បានឆ្លើយថាការបង្កើតក្រុមសន្សំដោយមិនមានការអនុញ្ញាត គឺស្របតាមច្បាប់។ ជាចុងក្រោយ ៨២% នៃអ្នកឆ្លើយតបបាននិយាយថា ជារឿងខុសច្បាប់ក្នុងការបង្កើតអង្គការមិនមែនរដ្ឋាភិបាលដោយមិនចាំបាច់ចុះបញ្ជី។

៧៧% នៃអ្នកឆ្លើយតប បានឆ្លើយត្រឹមត្រូវទៅនឹងសំណួរទាក់ទងនឹងសេរីភាពខាងសមាគម។ តាមការបង្ហាញ អ្នកឆ្លើយតបចំនួន ៧១% បានឆ្លើយត្រឹមត្រូវថា ជារឿងស្របច្បាប់ក្នុងការជជែកអំពីនយោបាយនៅទីសាធារណៈ។ ៨៨% ឆ្លើយត្រឹមត្រូវថា ការបញ្ចេញមតិនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់ គឺជារឿងស្របតាមច្បាប់ ៨៩% ឆ្លើយថា ជារឿងខុសច្បាប់ដែលជេរប្រមាថបុគ្គលសាធារណៈ ហើយ ៥៩% នៃអ្នកចូលរួមឆ្លើយថា ការរិះគន់គោលនយោបាយរបស់រាជរដ្ឋាភិបាល គឺស្របតាមច្បាប់។

## ៣.៩. បុគ្គលម្នាក់ៗមានការយល់ដឹងកាន់តែប្រសើរឡើង អំពីធាតុផ្សំស្នូលនៃសេរីភាពខាងការជួបប្រជុំ ហើយយល់ថាមានសេរីភាពច្រើនក្នុងការអនុវត្តសិទ្ធិនេះ

ទោះបីជាអ្នកដែលបានស្ទង់មតិក្នុងឆ្នាំ២០២២ បានយល់ដឹងតិចតួចបំផុតអំពីធាតុផ្សំស្នូលនៃសេរីខាងការជួបប្រជុំក្នុងចំណោមសេរីភាពមូលដ្ឋានទាំងបីក៏ដោយ ក៏ទិន្នន័យឆ្នាំ២០២២ នៅតែបង្ហាញថាបុគ្គលម្នាក់ៗយល់ថាមានសេរីភាពច្រើនក្នុងការអនុវត្តសេរីភាពខាងការជួបប្រជុំនៅឆ្នាំ២០២២ ជាងកាលពីឆ្នាំ២០២១។

*តួលេខទី ៤៨៖ ភាគរយនៃអ្នកដែលយល់ថាមានសេរីភាពក្នុងការធ្វើកូដកម្មប្រឆាំងនឹងនិយោជករបស់ខ្លួន*




ជាតួយ៉ាង ១៣% នៃអ្នកឆ្លើយតបយល់ថាមានសេរីភាពខ្លាំងណាស់ក្នុងការធ្វើកូដកម្មប្រឆាំងនឹងនិយោជករបស់ខ្លួន (បើប្រៀបធៀបនឹង ៦% នៃអ្នកឆ្លើយតបក្នុងឆ្នាំ២០២១) ហើយ ២៩% យល់ថាមានសេរីភាពខ្លះដែរក្នុងការធ្វើបែបនេះ បើប្រៀបធៀបនឹង ១៨% ក្នុងឆ្នាំ ២០២១។ ផ្ទុយទៅវិញ ៣៥% នៃអ្នកចូលរួមការស្ទង់មតិយល់ថាមានសេរីភាពតិចតួចហើយមាន៧% បានឆ្លើយថាមិនមានសេរីភាពទាល់តែសោះក្នុងការធ្វើកូដកម្មប្រឆាំងនឹងនិយោជករបស់ខ្លួនបើប្រៀបធៀបនឹងឆ្នាំ២០២១ ដែលក្នុងនោះ ៥០% យល់ថាមានសេរីភាពតិចតួច និង ៦% មិនមានសេរីភាពទាល់តែសោះ។

*តួលេខទី ៤៩៖ ភាគរយនៃអ្នកដែលយល់ថាមានសេរីភាពក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី*




ស្រដៀងគ្នានេះដែរ ២១% នៃអ្នកឆ្លើយតបយល់ថាមានសេរីភាពខ្លាំងណាស់ក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី ចំណែក ៤២% យល់ថាមានសេរីភាពខ្លះដែរក្នុងការធ្វើបែបនេះ។ម្យ៉ាងវិញទៀត ២៥% នៃអ្នកឆ្លើយតបយល់ថាមានសេរីភាពតិចតួច ហើយមានតែ ៣% ប៉ុណ្ណោះដែលយល់ថាមិនមានសេរីភាពទាល់តែសោះក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី។ លទ្ធផលនេះបង្ហាញពីភាពប្រសើរឡើងក្នុងការអនុវត្តសិទ្ធិខាងការជួបប្រជុំក្នុងអំឡុងពេលនៃរបាយការណ៍។

## ៣.១០. ពលរដ្ឋវ័យក្មេងមានទំនោរចូលរួមការជួបប្រជុំដោយសន្តិវិធីច្រើនជាងក្រុមមនុស្សផ្សេងទៀត




*តួលេខទី ៥០៖ ភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានសេរីភាពក្នុងការចូលរួមការជួបប្រជុំដោយសន្តិវិធី ដោយបែងចែកតាមអាយុ*

នៅឆ្នាំ២០២២ ២៩% នៃអ្នកឆ្លើយតបអាយុចន្លោះពី ១៦ ទៅ ២៥ ឆ្នាំ បានលើកឡើងថាមានសេរីខ្លះដែរ ឬមានសេរីភាពខ្លាំងណាស់ក្នុងការចូលរួមក្នុងការតវ៉ាដោយសន្តិវិធី។ ផ្ទុយទៅវិញ មានតែ ៩% នៃអ្នកឆ្លើយតប អាយុចន្លោះពី ៣៦ ទៅ ៤៥ ឆ្នាំប៉ុណ្ណោះដែលយល់ថាមានសេរីភាពខ្លះដែរ ឬមានសេរីភាពខ្លាំងណាស់ក្នុងការធ្វើបែបនេះ ដោយកម្រិតទាបជាងនេះត្រូវបានរាយការណ៍ក្នុងចំណោមក្រុមដែលមានអាយុច្រើនជាងនេះ។ ចំនួនភាគរយនេះបង្ហាញថាយុវជនកាន់តែទទួលបានព័ត៌មាន និងចូលរួមកាន់តែច្រើនឡើងក្នុងសកម្មភាពពលរដ្ឋ និងនយោបាយនៅក្នុងប្រទេស រួមទាំងការអនុវត្តសេរីភាពខាងការជួបប្រជុំផងដែរ។

## ៣.១១. មនុស្សម្នាក់ៗនៅតែមានការលំបាក ក្នុងការរាយការណ៍អំពីការរំលោភសិទ្ធិមនុស្ស

ជារួម យើងអាចសន្និដ្ឋានបានថាភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានការលំបាកបន្តិច និងមានការលំបាកច្រើនក្នុងការដាក់ពាក្យបណ្តឹងនៅចំពោះមុខអាជ្ញាធរ នៅតែមានកម្រិតថេរដដែលនៅគ្រប់ពេលនៃ




*តួលេខទី ៥១៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានការលំបាកបន្តិចក្នុងការដាក់ពាក្យបណ្តឹងនៅចំពោះមុខអាជ្ញាធរ*




*តួលេខទី ៥២៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានការលំបាកច្រើនក្នុងការដាក់ពាក្យបណ្តឹងនៅចំពោះមុខអាជ្ញាធរ*

ការធ្វើរបាយការណ៍។ មានការកើនឡើងតិចតួចនូវចំនួនភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមានការលំបាកបន្តិចក្នុងការដាក់ពាក្យបណ្តឹងក្នុងអំឡុងឆ្នាំ២០២០ ២០២១ និង ២០២២ បើប្រៀបធៀបនឹងឆ្នាំមុនៗ ( តួលេខទី៥១)។ តាមការប្រៀបធៀបភាគរយនៃអ្នកឆ្លើយតបដែលយល់ថាមាន "មានការលំបាកច្រើន" ក្នុងការដាក់

ពាក្យបណ្ដឹងនៅចំពោះមុខអាជ្ញាធរទាក់ទងនឹងការរំលោភសិទ្ធិមនុស្ស បានថយចុះពី ៤៣% ក្នុងឆ្នាំ២០២១ មកត្រឹម ៣៦% ក្នុងឆ្នាំ២០២២ (តួលេខទី ៥២)។

## ៣.១២. ពលរដ្ឋកម្ពុជាបន្តប្រឈមនៅពេលស្វែងរកដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្ស




*តួលេខទី ៥៣៖ ភាគរយនៃសាធារណជនដែលរាយការណ៍ថាមានជំនឿចិត្តខ្លាំងណាស់ថា រាជរដ្ឋាភិបាលកម្ពុជា ឬតុលាការនឹងផ្ដល់យុត្តិធម៌ចំពោះការរំលោភសិទ្ធិមនុស្ស*

ទិន្នន័យដែលប្រមូលបានក្នុងអំឡុងឆ្នាំ២០២២ បង្ហាញថាសាធារណជនមានជំនឿចិត្តកាន់តែច្រើនចាប់តាំងពីគម្រោង បានចាប់ផ្ដើមដំណើរការ ដោយជឿថារាជរដ្ឋាភិបាលកម្ពុជា ឬ តុលាការនឹងផ្ដល់យុត្តិធម៌ចំពោះការរំលោភសិទ្ធិមនុស្ស ដែលមានការកើនឡើងរហូតដល់ ៣៩% បន្ទាប់ពីធ្លាក់ចុះនៅសល់ត្រឹមតែ ឬក្រោម ៣០% ក្នុងអំឡុងឆ្នាំ ២០១៧-២០២១។[92] ទោះបីជាមានការកើនឡើងបែបនេះក៏ដោយ ប៉ុន្តែយោងតាមការវាយតម្លៃលើភាពមានជំនឿចិត្តចំនួន ៣៩% បានគូសបញ្ជាក់ថា នៅមានកិច្ចការជាច្រើនដែលត្រូវធ្វើបន្ថែមទៀត ដើម្បីកែលម្អឱ្យប្រសើរឡើងនូវកម្រិតនៃភាពជឿទុកចិត្តរបស់ពលរដ្ឋ។

ទោះបីជាមានការកើនឡើងនូវជំនឿចិត្តបែបនេះក៏ដោយ ក៏នៅមានមនុស្សជាច្រើនរហូតជិត ៧០% ក្នុងឆ្នាំ២០២០ និង ២០២១ (តួលេខទី ៥៣) ដែលមិនមានជំនឿចិត្តទាល់តែសោះថារាជរដ្ឋាភិបាលកម្ពុជា ឬ តុលាការនឹងផ្ដល់យុត្តិធម៌ជូនជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សឡើយ។

យោងតាមទិន្នន័យពីចំណុចគន្លឹះទី៣ក្នុងឆ្នាំទី២០២២ បង្ហាញថាពលរដ្ឋម្នាក់ៗនៅតែប្រឈមក្នុងការកំណត់ពីធាតុផ្សំសំខាន់ៗនៃសេរីភាពមូលដ្ឋានដែលធ្វើឱ្យពួកគេមិនអាចអនុវត្តសិទ្ធិបានពេញលេញ។ ទោះបីជាការយល់ដឹងអំពីច្បាប់ដែលទាក់ទងនឹងសេរីភាពមូលដ្ឋានមានភាពល្អប្រសើរឡើងបន្តិចនៅឆ្នាំ២០២២ ក៏ដោយ ក៏ចាំបាច់ត្រូវអប់រំពលរដ្ឋ អំពីសេរីភាពមូលដ្ឋាន និងវិសាលភាពនៃការអនុវត្តសិទ្ធិទាំងនេះ។ លើសពីនេះ ទិន្នន័យពីចំណុចគន្លឹះនេះបង្ហាញពីការកើនឡើងនូវលទ្ធភាពរបស់ស្ត្រីក្នុងការចូលរួមជីវភាពនយោបាយ ដោយបង្ហាញពីវឌ្ឍនភាពពាក់ព័ន្ធនឹងសមភាពយេនឌ័រនៅក្នុងវិស័យសាធារណៈ។ ចំនួនអ្នកដែលមានសេរីភាពក្នុងការចូលរួមការតវ៉ាដោយសន្តិវិធីបន្តកើនឡើង ដែលនេះបង្ហាញថា ទោះបីជាបុគ្គលម្នាក់ៗអាចនៅតែមានការភ័យខ្លាចចំពោះការសងសឹកនៅពេលអនុវត្តសិទ្ធិខាងការជួបប្រជុំក៏ដោយ ប៉ុន្តែពួកគេមានឆន្ទៈក្នុងការនិយាយអំពីភាពអយុត្តិធម៌សង្គម ទោះបីជាមានបញ្ហាប្រឈមនឹងបរិយាកាសសង្គមនយោបាយយ៉ាងណាក៏ដោយ។

[92] ដើម្បីឆ្លើយសំណួរនេះ អ្នកឆ្លើយតបត្រូវបានស្នើឱ្យជ្រើសរើសចម្លើយមួយក្នុងចំណោមជម្រើសខាងក្រោម៖ "មានជំនឿចិត្តខ្លាំងណាស់ មានជំនឿចិត្តខ្លះដែរ មិនមានមានជំនឿចិត្តប៉ុន្មានទេ មិនមានជំនឿចិត្តទាល់តែសោះ និងអត់ដឹងទេ" ។

## ៤. ចំណុចគន្លឹះទី ៤ ៖ តើអង្គការសង្គមស៊ីវិល និងសហជីព ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជាបានដែរឬទេ?

ចំណុចគន្លឹះទី៤ ពិនិត្យទៅលើវិសាលភាពដែលអង្គការសង្គមស៊ីវិលអាចធ្វើការជាមួយរាជរដ្ឋាភិបាលក្នុងនាមជាដៃគូនៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ ទិន្នន័យសម្រាប់ចំណុចគន្លឹះទី៤ ដកស្រង់ចេញពីការស្ទង់មតិប្រចាំឆ្នាំជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព។ នៅឆ្នាំ២០២២ នេះ មានអ្នកឆ្លើយតបចំនួន ១៥០ នាក់តំណាងឱ្យអង្គការស្ថាប័នចំនួន ១៥០ ក្នុងនោះមានថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលចំនួន ៨១ នាក់ (អង្គការសង្គមស៊ីវិលក្នុងស្រុកចំនួន៦៧ និងអង្គការអន្តរជាតិចំនួន១៤) និងថ្នាក់ដឹកនាំសហជីពចំនួន ៦៩ នាក់មកពីរាជធានី-ខេត្តចំនួន២០ បានឆ្លើយតបទៅនឹងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពនេះ។

**របកគំហើញសំខាន់ៗ៖** អង្គការសង្គមស៊ីវិល និងសហជីព នៅមិនទាន់រាជរដ្ឋាភិបាលទទួលស្គាល់ថាជាអ្នកពាក់ព័ន្ធដ៏សំខាន់នៅឡើយ។ អង្គការសង្គមស៊ីវិល និងសហជីព មិនបានដឹងពីឱកាសធ្វើការក្នុងភាពជាដៃគូជាមួយរាជរដ្ឋាភិបាលនៅក្នុងកិច្ចដំណើរការធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនានា ដែលនេះបង្ហាញឱ្យឃើញពីចន្លោះដ៏តូចចង្អៀតសម្រាប់ការធ្វើអន្តរកម្ម និងចូលរួមពហុភាគី។ ទិន្នន័យដែលប្រមូលបានក្នុងអំឡុងឆ្នាំ២០២២ បង្ហាញថាមានការលំបាកសម្រាប់អង្គការសង្គមស៊ីវិល និងសហជីពក្នុងការស្វែងរកឱកាសទទួលបានមូលនិធិ។ ជាចុងក្រោយ យោងតាមការឆ្លើយតបពីថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព បង្ហាញពីបញ្ហាលំបាកស្ថាប័នរបស់ពួកគេ នៅពេលដែលព្យាយាមទទួលបានព័ត៌មានពីអាជ្ញាធរសាធារណៈ។

### ៤.១. កិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរមតិយោបល់រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិលនិងសហជីព នៅតែមានកម្រិត ជាហេតុធ្វើឱ្យថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព យល់ថាស្ថាប័នរបស់ខ្លួនមិនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាដៃគូអភិវឌ្ឍន៍ដែលមានសមត្ថភាព

*តួលេខទី ៥៤៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ពីភាពជាដៃគូផ្លូវការ ឬក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាល*




យោងតាមការស្ទង់មតិ កម្រិតកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនិងសហជីព មិនដែលមានលើសពី៥០% នោះទេ។[93] ទោះបីជា នៅមិនទាន់បានដឹងច្បាស់អំពីមូលហេតុពិតប្រាកដនៅពីក្រោយកិច្ច

[93] សំណួរនេះមិនបានដាក់បញ្ចូលនៅក្នុងការស្ទង់មតិឆ្នាំទី១នោះទេ។ ទាក់ទងនឹងកិច្ចសហការក្រៅផ្លូវការ តួលេខទី១០ បង្ហាញពីភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាកាលពីឆ្នាំមុនបានសហការក្រៅផ្លូវការជាមួយរាជរដ្ឋាភិបាល *"ញឹកញាប់ខ្លាំង" "ញឹកញាប់"* ឬ *"នៅពេលខ្លះ"* ដោយបែងចែកតាមប្រភេទរបស់អ្នកឆ្លើយសំណួរ។

សហការនៅមានកម្រិតនេះក៏ដោយ ទិន្នន័យបានបង្ហាញថាបរិយាកាសសង្គម-នយោបាយបច្ចុប្បន្នមិនបានជំរុញឱ្យមានកិច្ចសហប្រតិបត្តិការនោះទេ ដែលជាហេតុរាំងទាំងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនិងសហជីព ក្នុងការសន្ទនាពហុភាគី និងទទួលបានប្រយោជន៍ដែលអាចកើតមាននៅពេលដែលអាជ្ញាធរ និងសង្គមស៊ីវិលធ្វើការជាមួយគ្នា។

កម្រិតនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនិងសហជីព មានការកើនឡើងចាប់ពីឆ្នាំ២០២១ ដល់ ឆ្នាំ២០២២ ដែលទំនងជាដោយសារតែសកម្មភាពក្រោយពីការផ្ទុះឡើងនូវជំងឺកូវីដ-១៩ ដែលកើតឡើងដល់កម្រិតខ្ពស់បំផុតក្នុងឆ្នាំ ២០២១។

*តួលេខទី៥៥៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាបានដឹងពីឱកាសចូលរួមក្នុងការពិគ្រោះយោបល់ ក្រុមប្រឹក្សា និង/ឬគណៈកម្មាធិការជាមួយរាជរដ្ឋាភិបាល*




មានថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពតិចជាង ៣០% បានរាយការណ៍ថាបានដឹងពីឱកាសចូលរួមក្នុងការពិគ្រោះយោបល់កិច្ចពិភាក្សាឬគណៈកម្មាធិការជាមួយរាជរដ្ឋាភិបាលក្នុងឆ្នាំ២០២២។[94] កង្វះខាតនៃការបានដឹងពីឱកាសរបស់អ្នកឆ្លើយតបនឹងការស្ទង់មតិអាចត្រូវបានសន្មតថា បណ្តាលមកពីកង្វះការផ្សព្វផ្សាយឱ្យទូលំទូលាយនៃព័ត៌មានអំពីឱកាស ដែលនេះអាចបញ្ជាក់បានថា រាជរដ្ឋាភិបាលពុំសូវចាប់អារម្មណ៍រួមបញ្ចូលអង្គការសង្គមស៊ីវិលនិងសហជីពក្នុងកិច្ចសហការណ៍ការងារផ្សេងៗ។

*តួលេខទី ៥៦៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាឱកាសនៃការចូលរួមមានភាពច្បាស់លាស់ បើកចំហ និងតម្លាភាព*




បន្ថែមពីកង្វះព័ត៌មានផ្សព្វផ្សាយអំពាវនាវឱ្យមានការចូលរួមរបស់អង្គការសង្គមស៊ីវិល និងសហជីពក្នុងកម្មវិធីនានារបស់រាជរដ្ឋាភិបាលក៏មានកង្វះខាតចំពោះភាពច្បាស់លាស់នៃលក្ខខណ្ឌដែលអាចចូលរួមក្នុងដំណើរការតាក់តែងច្បាប់និងសេចក្តីសម្រេចចិត្តផងដែរ។ យោងតាមលទ្ធផលដែលបានរកឃើញទាំងនេះ បានបង្ហាញថាឱកាសក្នុងការចូលរួមគឺនៅឆ្ងាយពីដំណើរការពហុភាគីប្រកបដោយបរិយាប័ន្ន។ មានតែ ២៣% នៃអ្នកឆ្លើយតបប៉ុណ្ណោះបានលើកឡើងថា ការអំពាវនាវឱ្យចូលរួមក្នុងការពិគ្រោះយោបល់ កិច្ចពិភាក្សា ឬគណៈកម្មាធិការមានភាពច្បាស់លាស់ បើកចំហ និងតម្លាភាពនៅក្នុងឆ្នាំទី៧ នេះ។[95] បន្ថែមលើការផ្សព្វផ្សាយព័ត៌មានពីឱកាសទាំងនេះឱ្យបានកាន់តែប្រសើររាជរដ្ឋាភិបាលគួរតែជានាឱ្យមានការចូលរួមពីតួអង្គផ្សេងៗ និងមានការចែករំលែកនូវទស្សនៈខុសៗគ្នារបស់ពួកគេ។

---

[94] សំណួរនេះមិនដាក់បញ្ចូលនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក្នុងឆ្នាំ២០១៦ នោះទេ។

[95] សំណួរនេះមិនដាក់បញ្ចូលនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក្នុងឆ្នាំ២០១៦ នោះទេ។

*តួលេខទី ៥៧៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាបានចូលរួមយ៉ាងសកម្មក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេច និងតាក់តែងច្បាប់ជាមួយរាជរដ្ឋាភិបាល*




នៅឆ្នាំ២០២២ បានកត់ត្រាចំនួនភាគរយខ្ពស់បំផុត ចាប់តាំងពីគម្រោងបានចាប់ផ្តើម និងមានការកើនឡើងទ្វេដងប្រៀបនឹងឆ្នាំ២០២១ ដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព បានរាយការណ៍ថា ពួកគេបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងតាក់តែងច្បាប់ជាមួយរាជរដ្ឋាភិបាល ដែលនេះកើនឡើងពី ១៩% ក្នុងមួយឆ្នាំ២០២១ ដល់ ៤០% ក្នុងឆ្នាំ២០២២ ។[96] ការកើនឡើងនេះបង្ហាញពីការវិវត្តវិជ្ជមានដែលមានការដាក់បញ្ចូលអ្នកជំនាញមកពីអង្គការសង្គមស៊ីវិលនិងសហជីព នៅក្នុងដំណើរការបង្កើតក្របខណ្ឌច្បាប់ និងរចនាសម្ព័ន្ធអភិបាលកិច្ចរបស់កម្ពុជា។

មានតែ ៤៧% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ប៉ុណ្ណោះបានរាយការណ៍ថាស្ថាប័នរបស់ខ្លួនត្រូវបានរាជរដ្ឋាភិបាល ចាត់ទុកថាជាដៃគូអភិវឌ្ឍន៍ដែលសមត្ថភាពនៅក្នុងឆ្នាំ ២០២២។[97]

*តួលេខទី ៥៨៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាត្រូវបានរាជរដ្ឋាភិបាលទទួលស្គាល់ថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់និងជាដៃគូអភិវឌ្ឍន៍ពេញសមត្ថភាព*




ស្របតាមការវិត្តដែលបានសង្កេតកន្លងមក លទ្ធផលទាំងនេះបង្ហាញថា អង្គការសង្គមស៊ីវិល និងសហជីព នៅតែមិនត្រូវបានរាជរដ្ឋាភិបាលចាត់ទុកថាជាដៃគូដែលមានសមត្ថភាពពេញលេញ។ ជំនាញ សមត្ថភាព និងឯកទេសរបស់ពួកគេក្នុងការចូលរួមក្នុងកិច្ចការសាធារណៈមិនត្រូវបានទទួលស្គាល់ ជាហេតុធ្វើឱ្យកិច្ចសហប្រតិបត្តិការ និងអន្តរកម្មរវាងពួកគេ និងរាជរដ្ឋាភិបាលនៅមានកម្រិត។[98]

[96] តួលេខទី ១២ បង្ហាញពីភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាបានចូលរួមក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចចិត្ត ឬតាក់តែងច្បាប់ជាមួយរាជរដ្ឋាភិបាល *"ញឹកញាប់ខ្លាំង" "ញឹកញាប់" ឬ "នៅពេលខ្លះ"* ។

[97] ដើម្បីចាត់ទុកថាជាដៃគូអភិវឌ្ឍន៍ដែលពេញសមត្ថភាព គឺត្រូវវាយតម្លៃថាមានជំនាញ ចំណេះដឹង និងសមត្ថភាពពាក់ព័ន្ធ ដើម្បីក្លាយជាដៃគូអភិវឌ្ឍន៍ដ៏មានប្រយោជន៍ដល់រាជរដ្ឋាភិបាល។

[98] ដើម្បីចាត់ទុកថាជាដៃគូអភិវឌ្ឍន៍ស្របច្បាប់គឺត្រូវមានការទទួលស្គាល់ថាជាស្ថាប័នស្របតាមគតិយុត្ត ផ្លូវការ និងស្របច្បាប់។

## ៤.២. ការបានដឹងពីឱកាសទទួលបានហិរញ្ញប្បទានសម្រាប់អង្គការសង្គមស៊ីវិល និងសហជីពមានការពិបាកក្នុងការស្វែងរក

*តួលេខទី ៥៩៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាបានដឹងព័ត៌មានអំពីឱកាសហិរញ្ញប្បទាន ពីរាជរដ្ឋាភិបាល*




ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព ដែលបានរាយការណ៍ថាបានដឹងពីឱកាសផ្តល់មូលនិធិពីរាជរដ្ឋាភិបាលដែលអង្គការស្ថាប័នរបស់ពួកគេ មានសិទ្ធិទទួលបាន នៅតែមានកម្រិតទាប ពោលគឺត្រឹមតែ ៦% ក្នុងឆ្នាំ២០២២ (តួលេខទី៥៩)។[99] លទ្ធផលនេះបង្ហាញថា ព័ត៌មានពីឱកាសមិនបានផ្សព្វផ្សាយទូលំទូលាយឬមិនផ្សព្វផ្សាយ។ ប្រសិនបើអង្គការសង្គមស៊ីវិល និងសហជីព មានឱកាសទទួលបានមូលនិធិពីរាជរដ្ឋាភិបាល រាជរដ្ឋាភិបាល គឺត្រូវធានាថាឱកាសទាំងនេះត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងកំណត់គោលដៅលើអង្គការសង្គមស៊ីវិល និងសហជីព។ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព ដែលបានរាយការណ៍ថាមិនអាចទទួលបានមូលនិធិរាជរដ្ឋាភិបាល សម្រាប់ការកសាងសមត្ថភាពនៅតែមានកម្រិតខ្ពស់។[100] ទោះបីជា នៅមិនទាន់បានដឹងច្បាស់អំពីមូលហេតុនៅពីក្រោយកង្វះលទ្ធភាពនេះក៏ដោយ សមត្ថភាពមានកម្រិតក្នុងការកសាងមូលនិធិ អាចមានផលប៉ះពាល់ដល់សុខភាព និងនិរន្តរភាពនៃអង្គការសង្គមស៊ីវិល និងសហជីព ដែលរារាំងក្នុងការអនុវត្តសកម្មភាពរបស់ពួកគេ ព្រមទាំងរារាំងសង្គមស៊ីវិល និងសហជីពក្នុងការជួយដល់អ្នកទទួលផលផងដែរ។

*តួលេខទី ៦០៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ដែលបានរាយការណ៍ថាមិនអាចទទួលបានហិរញ្ញប្បទានដើម្បីកសាងសមត្ថភាពពីរាជរដ្ឋាភិបាល*




[99] សំណួរនេះមិនដាក់បញ្ចូលនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក្នុងឆ្នាំ២០១៦ នោះទេ។

[100] សំណួរនេះមិនដាក់បញ្ចូលនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក្នុងឆ្នាំ២០១៦ នោះទេ។

## ៤.៣. ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ប្រឈមនឹងការទទួលបានព័ត៌មានដោយស្ថាប័នសាធារណៈ

*តួលេខទី ៦១៖ % នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពដែលបានរាយការណ៍ថាមានសេរីភាពក្នុងការទទួលបានព័ត៌មានពីរាជរដ្ឋាភិបាល*




*តួលេខទី៦២៖ % នៃអង្គការសង្គមស៊ីវិល/សហជីពដែលត្រូវបានបដិសេធការចូលប្រើប្រាស់ព័ត៌មានផ្លូវការដែលមិនមែនជាព័ត៌មានសម្ងាត់ និង/ឬសេរីប*




ក្នុងអំឡុងឆ្នាំ២០២២ មានតែ ២៦% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានចូលរួមការស្ទង់មតិប៉ុណ្ណោះបានឆ្លើយតបថា “*ងាយស្រួលខ្លាំងណាស់*” (៤%) ឬ “*ងាយស្រួលខ្លះដែរ*” (២២%) ក្នុងការទទួលបានព័ត៌មានពីរាជរដ្ឋាភិបាល។[101] ១៤% (តួលេខទី៦២) បានលើកឡើងថា ពួកគេត្រូវបានបដិសេធក្នុងការទទួលបានព័ត៌មានដែលមិនមែនជាព័ត៌មានសម្ងាត់និងឬសេរីបដែលគ្រប់គ្រងដោយមន្ត្រីរាជរដ្ឋាភិបាល ។[102] នេះគឺជាបញ្ហាគួរឱ្យបារម្ភ ដោយសារតែសិទ្ធិក្នុងការទទួលបានព័ត៌មានត្រឹមត្រូវរបស់សង្គមស៊ីវិលបង្ហាញពីតម្លាភាព និងគណនេយ្យភាពនៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ នៅពេលដែលច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានបានអនុម័តរួច នាំឱ្យមានភាពងាយស្រួលដល់ដំណើរការនេះ។ ដោយឡែក គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានបានកត់សម្គាល់ថា ការអនុម័តច្បាប់នេះត្រូវបានពន្យារពេលអស់ជាច្រើនឆ្នាំ ហើយខ្លឹមសារនៃច្បាប់នេះចាំបាច់ត្រូវអនុលោមតាមបទដ្ឋានអន្តរជាតិ ដើម្បីធានាថាប្រជាជនកម្ពុជាអាចទទួលបានការកត់ត្រា និងឯកសារដែលមានពីរាជរដ្ឋាភិបាល។

[101] សំណួរនេះបានដាក់បញ្ចូលនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក្នុងឆ្នាំ២០២២។

[102] សំណួរនេះបានដាក់បញ្ចូលនៅក្នុងការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពក្នុងឆ្នាំ២០២២។

*តួលេខទី៦៣៖ ប្រភេទព័ត៌មានដែលអង្គការសង្គមស៊ីវិល/សហជីព បានរាយការណ៍ថាកំពុងព្យាយាមទទួលបានពីរាជរដ្ឋាភិបាល*




*តួលេខទី៦៤៖ ប្រភេទព័ត៌មានដែលថ្នាក់ដឹកនាំសហជីព បានរាយការណ៍ត្រូវបានរាជរដ្ឋាភិបាលបដិសេធផ្តល់ជូន*




*តួលេខទី ៦៥៖ ប្រភេទព័ត៌មានដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល បានរាយការណ៍ត្រូវបានរាជរដ្ឋាភិបាលបដិសេធផ្តល់ជូន*




តួលេខទី៦៣ បង្ហាញថាព័ត៌មានពាក់ព័ន្ធនឹងបញ្ហាការងារ និងដំណើរការតាក់តែងច្បាប់ មានការស្នើសុំច្រើនបំផុតបន្ទាប់ពីប្រភេទព័ត៌មានផ្សេងៗដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ព្យាយាមដើម្បីទទួលបានពីរាជរដ្ឋាភិបាលនៅក្នុងឆ្នាំ២០២២។ ការស្នើសុំព័ត៌មានប្រភេទទាំងនេះក៏ត្រូវបានបដិសេធញឹកញាប់បំផុតពីសំណាក់រាជរដ្ឋាភិបាល (តួលេខទី៦៤ & តួលេខទី៦៥)។ ជាតួយ៉ាង ៤០% នៃចន្លោះពេលនោះដែលរាជរដ្ឋាភិបាលបានបដិសេធការស្នើសុំរបស់អង្គការសង្គមស៊ីវិល ក្នុងការទទួលបានព័ត៌មានទាក់ទងនឹងដំណើរការតាក់តែងច្បាប់។ ដូចគ្នាដែរ ថ្នាក់ដឹកនាំសហជីពក៏បានរាយការណ៍ថា ៥០% នៃចន្លោះពេលស្នើសុំនោះ រាជរដ្ឋាភិបាលបានបដិសេធពួកគេក្នុងការទទួលបានព័ត៌មានអំពីបញ្ហាការងារ។ ទិន្នន័យនេះបង្ហាញថា នៅឆ្នាំទី៧ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព បានចាប់អារម្មណ៍លើប្រធានបទជាច្រើនទាក់ទងនឹងទិដ្ឋភាពបច្ចុប្បន្នភាពនយោបាយ-សង្គមនៅក្នុងប្រទេសជាពិសេសព័ត៌មានទាក់ទងនឹងបញ្ហាការងារ និងដំណើរការតាក់តែងច្បាប់។

**សន្និដ្ឋាន៖** យោងតាមទិន្នន័យពីចំណុចគន្លឹះទីបួនបានបង្ហាញថា ភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល និងសហជីព និងរាជរដ្ឋាភិបាលក្នុងនាមជាដៃគូអភិវឌ្ឍន៍ដ៏មានសមត្ថភាពនៅតែបន្តមានភាពខ្វះខាត។ ដូចគ្នាដែរ មិនមានការកើនឡើងគួរឱ្យកត់សម្គាល់នូវកម្រិតនៃការចូលរួមរបស់អង្គការសង្គមស៊ីវិលនិងសហជីព នៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងតាក់តែងច្បាប់ ឬកិច្ចពិគ្រោះយោបល់ គណៈវិនិច្ឆ័យ និងគណៈកម្មាធិការជាមួយរាជរដ្ឋាភិបាលឡើយ។ អង្គការសង្គមស៊ីវិល និងសហជីព គឺជាតួអង្គដ៏សំខាន់ដែលជំនាញ និងបទពិសោធន៍របស់ពួកគេដើរតួយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។ អង្គការសង្គមស៊ីវិល និងសហជីព គួរត្រូវបានដាក់បញ្ចូលនៅគ្រប់ដំណើរការនៃការធ្វើសេចក្តីសម្រេច និងដំណើរការតាក់តែងច្បាប់ជាមួយរាជរដ្ឋាភិបាល។

# សេចក្ដីសន្និដ្ឋាន

ក្នុងអំឡុងឆ្នាំ២០២២ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានបន្តចងក្រងឯកសារអំពីព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងការរឹតត្បិតលើការអនុវត្តសេរីភាពជាមូលដ្ឋាន (សេរីភាពខាងការបញ្ចេញមតិ សមាគម និងការជួបប្រជុំ) ដែលបានធ្វើឱ្យមានការរាំងស្ទះដល់សេរីភាពនយោបាយ និងជ្រៀតជ្រែកដល់ការចូលរួមរបស់ប្រជាពលរដ្ឋ។ គម្រោង បានកត់ត្រាហេតុការណ៍ចំនួន ៥៦៦ ករណី ដែលពាក់ព័ន្ធនឹងការកម្រិតសេរីភាពមូលដ្ឋានផ្ទុយនឹងច្បាប់ ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិ នៅគ្រប់រាជធានី-ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា។ អាជ្ញាធរបានបន្តប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីយាយី និងគាបសង្កត់បុគ្គលទាំងឡាយណាដែលអនុវត្តសិទ្ធិរបស់ពួកគេ ជាពិសេសសំឡេងមតិផ្ទុយ ឬអ្នកដែលមាននិន្នាការផ្ទុយពីរាជរដ្ឋាភិបាល និងគោលនយោបាយ។ បុគ្គលម្នាក់ៗបានបន្ថយការពិភាក្សាទៅលើប្រធានបទដែលមានភាពរសើប ដោយខ្លាចមានចំណាត់ការពីអាជ្ញាធរ។ ដូចនេះពួកគេបានបន្ត រឹតត្បិតខ្លួនឯង ដោយមិនហ៊ានចែករំលែកគំនិត និងមតិយោបល់ ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណិត។ ការអនុវត្តវិធីរឹតត្បិតខ្លួនឯង ដើម្បីនិយាយក្នុងបរិយាកាសដែលមានកម្រិតទៅលើការអនុវត្តដោយសេរីក្នុងការបញ្ចេញមតិ គឺជាការបំផ្លាញទំនុកចិត្តរបស់ពលរដ្ឋកម្ពុជា អំពីលទ្ធភាពរបស់ខ្លួនក្នុងការអនុវត្តសិទ្ធិជាមូលដ្ឋាន។

ក្របខណ្ឌច្បាប់ទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ និងខាងសមាគម នៅតែបន្តមានលក្ខណៈគាបសង្កត់។ ការវិវឌ្ឍច្បាប់ជាបន្តបន្ទាប់បានបង្កើនការព្រួយបារម្ភយ៉ាងខ្លាំងអំពីការអនុវត្តច្បាប់របស់អាជ្ញាធរ ក្នុងការកាត់បន្ថយសេរីភាពជាមូលដ្ឋានបន្ថែមទៀត។ ឧទាហរណ៍៖ អនុក្រឹត្យស្ដីពីការគ្រប់គ្រងនិងប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត អនុញ្ញាតឱ្យមានការបដិសេធឈ្មោះដែន (Domain Name) ដោយបើកផ្លូវឱ្យអាជ្ញាធរបំពានលើឆន្ទានុសិទ្ធិដែលខ្លួនមាន ក្នុងការបដិសេធផ្តល់ឈ្មោះដែនដោយហេតុផលតាមអំពើចិត្ត ក្នុងការត្រួតពិនិត្យលើអង្គភាពដែលបានបញ្ជូនឈ្មោះដែនរបស់ខ្លួន ដែលជាការបំពានលើសេរីភាពខាងការបញ្ចេញមតិ។ ជាលទ្ធផល បញ្ញត្តិច្បាប់ដែលមានចែងក្នុងអនុក្រឹត្យនេះ មិនគោរពតាមកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងការគោរពនិងការពារសេរីភាពមូលដ្ឋាននោះទេ។

ទោះបីជាការយល់ដឹងរបស់ពលរដ្ឋអំពីសេរីភាពជាមូលដ្ឋានទាំងបីមានភាពប្រសើរឡើងបន្តិច បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ ក៏ពលរដ្ឋជាច្រើននៅតែមិនអាចកំណត់ជាតុផ្សំស្នូល និងវិសាលភាពនៃការអនុវត្តសេរីភាពនីមួយៗបានដែរ ដែលធ្វើឱ្យមានការពិបាកក្នុងការយល់ដឹងអំពីការរំលោភសិទ្ធិរបស់ពួកគេ ស្វែងរកសំណង និងចាប់អ្នកប្រព្រឹត្តមកទទួលខុសត្រូវ។ ចំណេះដឹងអំពីក្របខណ្ឌច្បាប់ដែលគ្រប់គ្រងសេរីភាពខាងការបញ្ចេញមតិ សមាគម និងការជួបប្រជុំបានបន្តថយចុះ ហើយពលរដ្ឋបានយល់ខុសថា ច្បាប់ជាតិរបស់ប្រទេសកម្ពុជាមានការរឹតត្បិតខ្លាំងជាងការអនុវត្តជាក់ស្តែងទៅទៀត។ នេះគឺជាចំណុចគន្លឹះដែលគួរឱ្យបារម្ភ ដែលឆ្លុះបញ្ចាំងពីការសន្មតយ៉ាងទូលំទូលាយថា រាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់ច្បាប់មានលក្ខណៈគាបសង្កត់ ដើម្បីរំលោភសិទ្ធិមនុស្ស។ ស្រដៀងគ្នានេះដែរ ទិន្នន័យដែលប្រមូលបានក្នុងអំឡុងឆ្នាំ២០២២ នេះបានបង្ហាញថា ទោះបីជាពលរដ្ឋម្នាក់ៗមានអារម្មណ៍ថាមានសេរីភាពក្នុងការចូលរួមជីវភាពនយោបាយក៏ដោយ ក៏ពួកគេនៅតែមាន

អារម្មណ៍ស្ទាក់ស្ទើរក្នុងការចូលរួមការតវ៉ា ឬជួបប្រជុំដោយសន្តិវិធី ដើម្បីទាមទារលក្ខខណ្ឌការងារកាន់តែប្រសើរដែរ។

លើសពីនេះទៅទៀត កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសង្គមស៊ីវិល/សហជីព នៅមានកម្រិតតិចតួចនៅឡើយ។ អង្គការសង្គមស៊ីវិល/សហជីព មិនត្រូវបានគេមើលឃើញថាជាដៃគូមានសមត្ថភាពដែលការយល់ដឹងរបស់ពួកគេគួរតែត្រូវបានពិចារណា នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងបង្កើតច្បាប់នោះទេ។ ទាំងនេះបានបង្កើតលំហដ៏ចង្អៀតសម្រាប់ការចូលរួមជាពហុភាគី ដែលគួរតែមានការរួមបញ្ចូលជំនាញ និងចំណេះដឹងរបស់អង្គការសង្គមស៊ីវិល/សហជីព។ អង្គការសង្គមស៊ីវិល និងសហជីពជាច្រើនបានជួបការលំបាកក្នុងការទទួលបានព័ត៌មានសាធារណៈ និងស្នើសុំឱកាសផ្តល់មូលនិធិដែលមិនងាយស្រួលក្នុងការស្វែងរកជាសាធារណៈឡើយ។

តាមរយៈការផ្តល់ទឡ្ហីករណ៍អំពីស្ថានភាពនៃសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជា គម្រោងមានបំណងផ្តល់នូវព័ត៌មានដែលជាមូលដ្ឋានគ្រឹះសម្រាប់ពិចារណា ពិភាក្សាក្នុងន័យស្ថាបនាពិតប្រាកដដែលអាចធ្វើឱ្យច្បាប់ជាតិកម្ពុជាស្របជាមួយច្បាប់អន្តរជាតិ។ គម្រោងស្នើឱ្យមានវិធានការជាក់លាក់ប្រកបដោយអត្ថន័យឆ្ពោះទៅរកការបង្កើតបរិយាកាសអំណោយផល និងលក្ខខណ្ឌចាំបាច់នានាសម្រាប់សង្គមស៊ីវិលធ្វើប្រតិបត្តិការ ដើម្បីឱ្យដំណើរការលទ្ធិប្រជាធិបតេយ្យប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា។

## ឧបសម្ព័ន្ធទី១ ៖ វិធីសាស្ត្រ និងការប្រមូលទិន្នន័យ

ឧបសម្ព័ន្ធនេះ បង្ហាញអំពីវិធីសាស្ត្រនិងឧបករណ៍ប្រមូលទិន្នន័យ ដែលបានប្រើប្រាស់ដើម្បីប្រមូលនិងវិភាគទិន្នន័យរបស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន។

## វិធីសាស្ត្រ

ក្រុមការងារគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន បានប្រើប្រាស់ឧបករណ៍តាមដានការឃ្លាំមើលផ្សេងៗ ដើម្បីឃ្លាំមើលស្ថានភាពសេរីភាពមូលដ្ឋាននេះ។ ទិន្នន័យទាំងនេះត្រូវបានប្រមូលចងក្រងរៀបចំជាប្រព័ន្ធនិងវាយតម្លៃយ៉ាងត្រឹមត្រូវស្របតាមគោលការណ៍នៃឧបករណ៍តាមដានការឃ្លាំមើល ដែលមានគោលបំណងផ្តល់នូវតុល្យភាព និងសត្យានុម័តជាក់លាក់មួយ សម្រាប់ត្រួតពិនិត្យតាមដានអំពីសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ (“សេរីភាពមូលដ្ឋាន”) នៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យនេះក៏ផ្តោតសំខាន់ទៅលើការចូលរួមរបស់ពលរដ្ឋផងដែរ។

ឆ្នាំ២០២២ របស់គម្រោងគឺរាប់ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ លទ្ធផលដែលបានពីការឃ្លាំមើលនេះត្រូវបានយកមកប្រៀបធៀប និងពិនិត្យឡើងវិញជារៀងរាល់ត្រីមាស៖ ត្រីមាសទី១ ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២, ត្រីមាសទី២ ចាប់ពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២, ត្រីមាសទី៣ ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២, និងត្រីមាសទី៤ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

ឧបករណ៍តាមដានការឃ្លាំមើលនេះមានសូចនាករ ១៥២ ដែលឆ្លើយតបចំពោះចំណុចគន្លឹះចំនួន៤[103]៖

**ចំណុចគន្លឹះទី១ ៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានស្របតាមបទដ្ឋានអន្តរជាតិ

**ចំណុចគន្លឹះទី២ ៖** ក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានត្រូវបានអនុវត្តនិងប្រតិបត្តិតាមត្រឹមត្រូវ

**ចំណុចគន្លឹះទី៣ ៖** បុគ្គលយល់ដឹងអំពីសេរីភាពមូលដ្ឋាននិងសិទ្ធិដែលពាក់ព័ន្ធនិងយល់ថាខ្លួនអាចអនុវត្តសេរីភាពនេះដោយសេរី និង

**ចំណុចគន្លឹះទី៤ ៖** អង្គការសង្គមស៊ីវិលនិងសហជីពត្រូវបានទទួលស្គាល់ និងអាចធ្វើការក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល។

ឧបករណ៍តាមដានការឃ្លាំមើល បានគូសបញ្ជាក់អំពីសកម្មភាពសំខាន់ៗជាលម្អិតសម្រាប់ក្រុមការងារអនុវត្តផងដែរ។ ឧបករណ៍នេះបង្កើតនិយមន័យដើម្បីជានាន្ទូវការអនុវត្តស៊ីសង្វាក់គ្នានូវគោលគំនិតជាគន្លឹះ ព្រមទាំងបង្ហាញយ៉ាងច្បាស់នូវធាតុទាំងឡាយនៃចំណុចគន្លឹះទាំង៤។ ឧបករណ៍តាមដានការឃ្លាំមើលនេះលម្អិតអំពីសូចនាករ និងមានតារាងវិភាគដែលត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃនូវការផ្លាស់ប្តូរធៀបជាមួយធាតុ

[103] ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្ត្រ សូមមើល៖ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងមជ្ឈមណ្ឌលអន្តរជាតិដើម្បីច្បាប់ដោយមិនយកកម្រៃ ‘គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបាយការណ៍ឆ្នាំទី៣’(ខែកក្កដា ឆ្នាំ២០១៩) ឧបសម្ព័ន្ធទី១ <https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=130&id=5>។

នីមួយៗ និងចំណុចគន្លឹះទាំងនោះ ក៏ដូចជាធ្វើការប្រៀបធៀបជាមួយប្រភពទិន្នន័យ បុគ្គលទទួលខុសត្រូវចំពោះការប្រមូលទិន្នន័យ និងភាពញឹកញាប់នៃការប្រមូលទិន្នន័យផងដែរ។[104]

## វិធីសាស្ត្រប្រមូលទិន្នន័យ

ក្រុមការងារអនុវត្តគម្រោងបានប្រើប្រាស់នូវវិធីសាស្ត្រប្រមូលទិន្នន័យចំនួន ៦ យ៉ាងដើម្បីវាស់វែងសូចនាករពាក់ព័ន្ធនឹងធាតុនីមួយៗនៅក្រោមចំណុចគន្លឹះទាំងនោះ។




## ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ការតាមដានប្រព័ន្ធផ្សព្វផ្សាយផ្តោតលើការផ្សព្វផ្សាយព័ត៌មានអំពីសេរីភាពមូលដ្ឋាន។ វិធីសាស្ត្រនេះត្រូវបានប្រើជាពីរវិធី៖ ទីមួយប្រើដើម្បីប្រមូលទិន្នន័យ សម្រាប់សូចនាករដែលវាស់វែងការផ្លាស់ប្តូរ នៅក្នុងការអនុវត្តរបស់រដ្ឋាភិបាលឬការបកស្រាយច្បាប់ដែលជះឥទ្ធិពលដល់សេរីភាពមូលដ្ឋាន។ ទីពីរផ្តល់នូវមធ្យោបាយនៃការតាមដានចំនួន និងប្រភេទនៃហេតុការណ៍ដែលសេរីភាពមូលដ្ឋានត្រូវបានរំលោភឬរឹតត្បិត។ ក្រុមការងារគម្រោងបានអនុវត្តជាប្រចាំថ្ងៃក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

ភាគច្រើនជាសារព័ត៌មានក្នុងស្រុក និងប្រភពបណ្តាញផ្សព្វផ្សាយដទៃទៀតត្រូវបានតាមដានឃ្លាំមើលដើម្បីរកនូវអត្ថបទរឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធ ។[105]

ក្រុមការងារបានកំណត់និងត្រួតពិនិត្យទៅលើអត្ថបទរឿងដែលពាក់ព័ន្ធនានា ហើយបញ្ចូលព័ត៌មានសំខាន់ៗទាំងនោះចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ ប្រព័ន្ធទិន្នន័យនេះក៏បានធ្វើចំណាត់ថ្នាក់អត្ថបទរឿងនីមួយៗទៅតាមប្រភេទដែលឆ្លើយតបជាមួយសូចនាករនីមួយៗ និងធាតុទាំងឡាយដែលមាននៅក្នុងឧបករណ៍តាមដានការឃ្លាំមើល។ ប្រព័ន្ធទិន្នន័យនេះត្រូវបានពិនិត្យមើលជារៀងរាល់ត្រីមាសនីមួយៗ។

គម្រោងបានកត់ត្រានូវហេតុការណ៍ដាក់លាក់ចំនួន ៣២៩ ករណីតាមរយៈការតាមដានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងឆ្នាំ២០២២។

## យន្តការរាយការណ៍អំពីហេតុការណ៍

ការរាយការណ៍អំពីហេតុការណ៍ កត់ត្រាអំពីហេតុការណ៍នៃការរឹតត្បិត និងការរំលោភបំពានលើសេរីភាពមូលដ្ឋានដែលមិនមានចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ការរាយការណ៍អំពីហេតុការណ៍ត្រូវ

---

[104] សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្ត្រនៃឧបករណ៍តាមដានការឃ្លាំមើលអាចរកបានតាមការស្នើសុំ។

[105] ប្រភពព័ត៌មានរួមបញ្ចូល៖ កាសែតភ្នំពេញប៉ុស្តិ៍ (ខ្មែរ និងអង់គ្លេស) កាសែតខ្មែរថាមស៍ វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ កាសែតដើមអម្ពិល វិទ្យុសំឡេងប្រជាធិបតេយ្យ (ខ្មែរ និងអង់គ្លេស) វិទ្យុសំឡេងសហរដ្ឋអាមេរិកវីអូអេ វិទ្យុវាយោ សារព័ត៌មានកោះសន្តិភាព កាសែតរស្មីកម្ពុជា កាសែតថ្មីថ្មី កាសែតកម្ពុជាថ្មី, សារព័ត៌មានហ្វ្រេសញូវ, សារព័ត៌មានដើមត្នោត, មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា, កាសែតព្រៃនគរ, ស្វីហ្វ៍ញូវដេលី, TVFB, ខ្លីខ្លី, ស៊ីអ៊ីអិន, ខេមញូវ, ខេមបូចារ, Cambodia Peace Channel, ខេមបូណូមីស, ខេមបូឌៀននីស ស៊ីជេខ្មែរ ខ្មែរណាស់ ញូវរ៉ូម ខេធីដេលី ខ្មែរវីផត និងនគរវត្ត។ ចំណុចសំខាន់ដែលកំណត់នៅក្នុងវិធីសាស្ត្រនេះគឺការថយចុះចំនួនប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ ដែលការរាយការណ៍អាចមានភាពលំអៀង។ ប្រភពព័ត៌មានអន្តរជាតិរួមមាន៖ Al Jazeera, The Diplomat, UCA News, The Star and Reuters ។

បានប្រមូលតាមរយៈទម្រង់រាយការណ៍អំពីហេតុការណ៍ដែលរាយការណ៍ទៅក្រុមការងាររបស់គម្រោង។ ទម្រង់រាយការណ៍ហេតុការណ៍នេះផ្តល់ជាមធ្យោបាយសម្រាប់បុគ្គល ឬសមាគមដែលជឿថាសេរីភាពមូលដ្ឋានរបស់ខ្លួនត្រូវបានរំលោភបំពាន។

ទម្រង់រាយការណ៍អំពីហេតុការណ៍នេះត្រូវបានបំពេញនៅពេលដែលជនរងគ្រោះទៅជួបជាមួយក្រុមការងារគម្រោង ហើយក្រុមការងារនឹងស្វែងយល់ពីបញ្ហានេះ ព្រមទាំងធ្វើការសាកសួរព័ត៌មានលម្អិតជាមួយជនរងគ្រោះបន្ថែមទៀត។ ទម្រង់រាយការណ៍ពីហេតុការណ៍កត់ត្រានូវទិន្នន័យទាំងបែបគុណភាព និងបរិមាណ រួមមានព័ត៌មានអំពីហេតុការណ៍ ទីតាំង មនុស្សដែលពាក់ព័ន្ធរួមទាំងប្រភេទនៃសមាគម (ប្រសិនបើពាក់ព័ន្ធ) និងប្រភេទនៃការរំលោភបំពានផងដែរ។ ព័ត៌មានសំខាន់ៗ ដែលមាននៅក្នុងទម្រង់រាយការណ៍អំពីហេតុការណ៍នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យនៃយន្តការរាយការណ៍អំពីហេតុការណ៍ដែលនឹងវិភាគដោយក្រុមការងារ។

នៅក្នុងឆ្នាំ២០២២ គម្រោងបានកត់ត្រានូវហេតុការណ៍ជាក់លាក់ចំនួន ២៣៧ ករណីតាមរយៈការរាយការណ៍អំពីហេតុការណ៍។

## ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព

ការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព គឺជាការស្ទង់មតិប្រចាំឆ្នាំដែលត្រូវបានរៀបចំឡើងដើម្បីបង្ហាញពីទស្សនៈ និងបទពិសោធន៍របស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីពអំពីលទ្ធភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋាន។ ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីចូលរួមក្នុងការស្ទង់មតិនេះ តាមរយៈការប្រើប្រាស់នូវសំណាកបច្ចេកទេស ដោយផ្អែកលើព័ត៌មានពីសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលនិងសហព័ន្ធសហជីព។

នៅក្នុងឆ្នាំ២០២២ នេះ ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល/សហជីព ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី២៧ ខែកញ្ញា ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២។ ការស្ទង់មតិគឺត្រូវបានធ្វើតាមអនឡាញ ដែលមានអ្នកឆ្លើយតបសរុបចំនួន ១៥០ នាក់។ លទ្ធផលនៃស្ទង់មតិនេះត្រូវបានវិភាគដើម្បីកំណត់ការវិវត្តផ្សេងៗគ្នារបស់អង្គការសង្គមស៊ីវិល ឬសហជីពដែលបានចូលរួមនៅក្នុងការស្ទង់មតិ រួមទាំងនៅក្នុងសូចនាករនៃឧបករណ៍តាមដានការឃ្លាំមើល។

## ការស្ទង់មតិជាសាធារណៈ

ការស្ទង់មតិជាសាធារណៈត្រូវបានធ្វើឡើងរៀងរាល់ឆ្នាំ ក្នុងគោលបំណងយល់ដឹងអំពីការយល់ឃើញរបស់សាធារណជនទូទៅទាក់ទងនឹងការអនុវត្តសេរីភាពមូលដ្ឋាន។ ការជ្រើសរើសសំណាកដែលមានលក្ខណៈងាយៗ ត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងលើដំណើរការស្ទង់មតិនេះ។ ការស្ទង់មតិនេះធ្វើឡើងនៅទីតាំងសាធារណៈទូទាំងប្រទេសកម្ពុជា។ ក្រុមការងារគម្រោងបានចុះទៅទីតាំងដែលប្រជាពលរដ្ឋ ធ្វើដំណើរទៅមក និងជ្រើសរើសដោយចៃដន្យនូវប្រជាពលរដ្ឋយល់ព្រមចូលរួមនៅក្នុងការស្ទង់មតិនេះ។

ការស្ទង់មតិជាសាធារណៈនៅឆ្នាំ២០២២ នេះ បានចាប់ផ្តើមធ្វើឡើងចន្លោះថ្ងៃទី១ ខែវិច្ឆិកា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ទូទាំង ២៥ ខេត្ត/ក្រុង និងមានអ្នកចូលរួមឆ្លើយចំនួន ១៤២៤ នាក់។ លទ្ធផលនៃការ

ស្ទង់មតិត្រូវបានវិភាគដើម្បីកំណត់ពីនិន្នាការរបស់អ្នកឆ្លើយតបផ្សេងៗគ្នា ដូចជាសូចនាករនៃឧបករណ៍តាមដានការឃ្លាំមើល។

## ការពិនិត្យឡើងវិញទៅលើច្បាប់

ការពិនិត្យឡើងវិញទៅលើច្បាប់ គឺជាការវិភាគទៅលើច្បាប់ ប្រកាស សារាចរ សេចក្តីណែនាំ គោលនយោបាយ របាយការណ៍ និងបទប្បញ្ញត្តិផ្សេងទៀតដែលប៉ះពាល់ដល់ការអនុវត្តសេរីភាពមូលដ្ឋាន។ ការពិនិត្យ និងសិក្សាឯកសារច្បាប់ដើម្បីវាយតម្លៃអំពីកម្រិតដែលក្របខ័ណ្ឌច្បាប់របស់ប្រទេសកម្ពុជា អាចធានាបាននូវសេរីភាពមូលដ្ឋានដូចដែលបានតម្រូវនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដូចនេះការពិនិត្យទៅលើច្បាប់គឺផ្តោតសំខាន់ទៅលើខ្លឹមសារដែលចែងនៅច្បាប់ ជាជាងការអនុវត្តច្បាប់។[106]

របាយការណ៍ចេញពីការសិក្សាលើការពិនិត្យច្បាប់ពាក់ព័ន្ធនេះនឹងធ្វើឡើងជាប្រចាំត្រីមាស ដើម្បីធ្វើបច្ចុប្បន្នភាពនៃការវិភាគច្បាប់និងលិខិតបទដ្ឋានគតិយុត្តិដែលត្រូវបានធ្វើវិសោធនកម្ម ក៏ដូចជាការបញ្ចូលការវិភាគទៅលើច្បាប់ថ្មី ឬលិខិតបទដ្ឋានគតិយុត្តិទាំងឡាយណាដែលបានពិនិត្យឡើងវិញថ្មីៗនេះផងដែរ ។[107]

## ការវាយតម្លៃការចុះបញ្ជីអង្គការ សមាគម និង សហជីព

ការចុះបញ្ជីអង្គការ និង សហជីព គឺជាដំណើរការចាំបាច់មួយដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និង ច្បាប់ស្តីពីសហជីព តម្រូវឱ្យអនុវត្ត។ ដំណើរការចុះបញ្ជីនេះ ក៏ជាឱកាសមួយសម្រាប់រដ្ឋាភិបាលបដិសេធតាមអំពើចិត្ត ក្នុងការបង្កើតសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហជីពផងដែរ។ ការត្រួតពិនិត្យប្រសិទ្ធភាពនៃដំណើរការចុះបញ្ជីបង្ហាញឱ្យឃើញថាតើសិទ្ធិក្នុងការបង្កើតសមាគម និងសហជីពត្រូវបានការពារ និងអនុវត្តដោយរបៀបណា។ ក្រុមការងារអនុវត្តគម្រោងបានកត់ត្រាទិន្នន័យទាំងនេះ តាមរយៈការអនុវត្តដោយ "សាកសួរព័ត៌មានពីដំណើរការចុះបញ្ជី"។ ចំពោះសមាគម និង សហជីពដែលបានជ្រើសរើស និងវាយតម្លៃពីបទពិសោធន៍នៃការចុះបញ្ជីតាមច្បាប់ស្តីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព ដោយប្រើប្រាស់ទម្រង់វាយតម្លៃរបស់ក្រុមការងារគម្រោង។ ទម្រង់វាយតម្លៃ ដែលរៀបចំដោយក្រុមការងារប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់ភាពខុសគ្នារវាងការចុះបញ្ជីសមាគម និងសហជីពនៅពេលដែលកំពុងដំណើរការនៃការចុះបញ្ជី។

នៅក្នុងឆ្នាំ២០២២ ឧបករណ៍វាយតម្លៃបានកត់ត្រាបទពិសាធន៍ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលចំនួន២ ដែលបានព្យាយាមចុះបញ្ជីក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងឆ្នាំ២០២២នេះ។ ដោយឡែកគម្រោងក៏មិនបានកត់ត្រាបទពិសោធន៍ចុះបញ្ជីសហជីពដែលបានព្យាយាមចុះបញ្ជីតាមច្បាប់ស្តីពីសហជីពណាមួយឡើយ។

[106] ឧបសម្ព័ន្ធទី ២។

[107] ព័ត៌មានបន្ថែមទាក់ទងនឹងការពិនិត្យច្បាប់គឺអាចរកបានតាមការស្នើសុំ។

## ឧបសម្ព័ន្ធទី ២ ៖ តារាងលទ្ធផលនៃគម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន

តារាងខាងក្រោមនេះ ផ្តល់នូវទិន្នន័យសង្ខេបដែលគម្រោងបានប្រមូលចងក្រង ក្នុងអំឡុងពេល "ឆ្នាំ២០២២" (ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)។ សូចនាករទាំងនេះសុទ្ធតែពឹងផ្អែកទៅលើប្រភពទិន្នន័យផ្សេងៗ ដូចមាននៅក្នុងឧបសម្ព័ន្ធទី១ ។

<u>ការពិនិត្យមើលទៅលើច្បាប់ដែលពាក់ព័ន្ធ៖</u> នៅពេលបញ្ចប់ការវិភាគច្បាប់ឬលិខិតបទដ្ឋានពាក់ព័ន្ធ ពិន្ទុ ៥ នឹងត្រូវវាស់ទៅលើក្របខ័ណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពមូលដ្ឋានដែលស្របតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ (ពិន្ទុ ១= ស្ថិតក្នុងកម្រិតខ្សោយ, ពិន្ទុ៣= កម្រិតពិន្ទុមធ្យម, ៥= កម្រិតពិន្ទុខ្ពស់)។ គម្រោងឱ្យពិន្ទុដោយមិនលំអៀងទៅលើកម្មវត្ថុនិងសូចនាករ ផ្អែកលើច្បាប់និងលិខិតបទដ្ឋានដែលមានស្រាប់។ ចំពោះច្បាប់ឬលិខិតបទដ្ឋានដែលលំបាកនឹងរកបាន សូចនាករនេះត្រូវបានបញ្ជាក់ថាមិនអាចវាស់វែងបាន។

<u>ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយនិងការរាយការណ៍ពីហេតុការណ៍៖</u> ទិន្នន័យត្រូវបានកត់ត្រារយៈពេលពេញ ១ឆ្នាំ និងជាត្រីមាសដែលត្រូវបានប្រើប្រាស់សម្រាប់ការវិភាគ។

<u>ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ការស្ទង់មតិជាសាធារណៈ ការវាយតម្លៃការចុះបញ្ជីអង្គការសង្គមស៊ីវិល</u> ៖ ការឆ្លើយតបរបស់អ្នកចូលរួមទៅលើការស្ទង់មតិ និងការវាយតម្លៃ ការចុះបញ្ជីត្រូវបានរួមបញ្ចូលនិងវិភាគ។ ចំនួនតួលេខ និងភាគរយដែលបង្ហាញទាំងអស់ត្រូវបានយកចេញពីការវិភាគចម្លើយរបស់អ្នកឆ្លើយតប។

លទ្ធផលរបាយការណ៍ប្រចាំឆ្នាំត្រូវរួមបញ្ចូលគ្នានូវសូចនាករទាំងអស់ ហើយត្រូវបានឱ្យពិន្ទុតាមលេខកូដពណ៌ដូចខាងក្រោម៖

| | |
|---|---|
| (បៃតង) | កម្រិតពិន្ទុខ្ពស់ |
| (លឿង) | កម្រិតពិន្ទុមធ្យម |
| (ក្រហម) | ស្ថិតក្នុងកម្រិតខ្សោយ |
| (ស) | មិនអាចឱ្យពិន្ទុបាន |

ការវាយតម្លៃលើឧបករណ៍តាមដានវាយតម្លៃធ្វើឡើងនៅចុងបញ្ចប់ឆ្នាំ២០១៩ ដែលនាំឱ្យមានការពិនិត្យឡើងវិញសូចនាករមួយចំនួនរួមទាំងការបន្ថែមសូចនាករថ្មីចំនួន១១ ទៀត ។ សូចនាករត្រូវបានសម្គាល់ថា "មិនមានចម្លើយ" សម្រាប់ឆ្នាំផ្សេងៗក្រៅពីឆ្នាំ២០២០។

| ចំណុចគន្លឹះទី១ ៖ ក្របខណ្ឌច្បាប់ពាក់ព័ន្ធសេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ស្របតាមបទដ្ឋានអន្តរជាតិ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ជាតុផ្សំ | សូចនាករ | **ប្រភពទិន្នន័យ** | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | **កំណត់សម្គាល់** |
| សេរីភាពខាងការបង្កើតសមាគម | កម្រិតនៃច្បាប់ជាតិ ឬគោលនយោបាយ បានគោរពដល់សេរីភាពខាង ការបង្កើតសមាគមសេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | ៣ | ៣ | ៣ | ៣ | ២,៥ | ២,៥ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ សិទ្ធិសេរីភាពខាងសមាគម ការជួបប្រជុំ និងការបញ្ចេញមតិត្រូវបានធានាក្នុងមាត្រា៤២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា[108]។ ទោះជាយ៉ាងណាមាត្រា៤២ នេះ អនុវត្តចំពោះប្រជាពលរដ្ឋកម្ពុជា ដោយមិនមានវិសាលភាពសម្រាប់ជនជាតិផ្សេងទៀតដែលកំពុងរស់នៅកម្ពុជានោះឡើយ[109]។ ប៉ុន្តែ ការធានាទាំងនេះត្រូវបានធ្វើឱ្យខ្សោយចុះគួរឱ្យកត់សម្គាល់ដោយសារការធ្វើវិសោធនកម្មលើបទប្បញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៨។[110] ម្យ៉ាងទៀត ច្បាប់ជាតិដែលគ្រប់គ្រងមកលើសេរីភាពខាងសមាគមដូចជាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពក៏មានបទប្បញ្ញត្តិមួយចំនួនរឹតត្បិតលើសេរីភាពមូលដ្ឋានផងដែរ[111]។ វិសោធនកម្មច្បាប់ស្តីពីសហជីពឆ្នាំ២០២០ មានការរឹតត្បិតតិចជាងមុនទៅលើសេរីភាពខាងសមាគម[112]។ សេរីភាពខាងការបញ្ចេញមតិត្រូវបានកាត់បន្ថយយ៉ាងខ្លាំងនៅក្នុងច្បាប់មួយចំនួនដូចជាច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពី ការអប់រំក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ខណៈបញ្ញត្តិខ្លះស្របនឹងបទដ្ឋានអន្តរជាតិនោះ ក៏មានបទប្បញ្ញត្តិមួយចំនួនមានខ្លឹមសារមិនច្បាស់លាស់ដែលអាចធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការជួបប្រជុំ។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន (ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្ន) បានកាត់បន្ថយលទ្ធភាពក្នុងការអនុវត្តសេរីភាពខាងការសមាគម ជួបប្រជុំ និងបញ្ចេញមតិក្នុងកំឡុងពេលអាសន្ន។ នៅឆ្នាំ២០២១ ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ត្រូវបានអនុម័តឡើងដោយផ្តល់អំណាចយ៉ាងខ្លាំងដល់អាជ្ញាធរ ដើម្បីរឹតត្បិតសិទ្ធិសេរីភាពខាងសមាគម និងសេរីភាពខាងការជួបប្រជុំ ក្រោមហេតុផលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។ ការអនុម័តអនុក្រឹត្យស្តីពី ការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិក៏ប៉ះពាល់យ៉ាងខ្លាំងលើសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំតាមអនឡាញ។ ចំណែកឯសង្ឃប្រកាស ដែលបានចេញផ្សាយកាលពីឆ្នាំ២០២១ ប៉ះពាល់ធ្ងន់ធ្ងរទៅលើសេរីភាពខាងការជួបប្រជុំផងដែរ។[113] នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ រដ្ឋាភិបាលបានអនុម័តអនុក្រឹត្យស្តីពីការគ្រប់គ្រង់ និងការប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត ដែលរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ និងមិនអនុលោមតាមច្បាប់អន្តរជាតិ[114]។ ការប្រើប្រាស់ភាសា និងខ្លឹមសារមិនច្បាស់លាស់នៃអនុក្រឹត្យនេះ គឺបើកចំហចំពោះការបកស្រាយផ្សេងៗ និងងាយរងគ្រោះចំពោះការអនុវត្តតាមតែអំពើចិត្ត ឬមិនសមាមាត្រដោយអាជ្ញាធរ ដោយការចុះបញ្ជីដែនឈ្មោះអាចត្រូវបានកំណត់ដោយរដ្ឋាភិបាលតែប៉ុណ្ណោះ ដែលអាចឱ្យអង្គភាពបាត់បង់ឈ្មោះដែនរបស់ខ្លួន ដែលបានចុះបញ្ជី។ ហើយអាចឈានដល់ការបិទខ្ទប់ ការរឹតត្បិត ឬសេរីភាពនិយាយតាមប្រព័ន្ធអ៊ីនធឺណិត និងការបង្រួមលំហសង្គម ស៊ីវិល ជាវិធាន |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ការមិនសមមាត្រ ដែលរំលោភលើកាតព្វកិច្ចរបស់កម្ពុជា ក្នុងនាមជារដ្ឋភាគី។ |
| **សេរីភាពខាងការបង្កើតសមាគម** | | | | | | | | | | |
| ១.២ ដំណើរការចុះបញ្ជីអង្គការ សមាគម មានភាពត្រឹមត្រូវ និងតម្លាភាព | កម្រិតនៃដំណើរការនៃការចុះបញ្ជី និងតារាងតម្លៃសម្រាប់ការចុះបញ្ជីសមាគម ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងចែងយ៉ាងច្បាស់លាស់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ។ លក្ខខណ្ឌនៃការចុះបញ្ជីសម្រាប់អង្គការសង្គមស៊ីវិល និងសហជីពក្រោមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព មានខ្លឹមសារស្រពេចស្រពិល លំបាក និងមានបន្ទុកច្រើន ព្រមទាំងមិនស្របជាមួយបទដ្ឋានអន្តរជាតិ[115]។ ជាពិសេស មាត្រា ៥ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបានរារាំងបុគ្គលមួយចំនួនដូចជា បុគ្គលដែលពុំមែនជាសញ្ជាតិខ្មែរ និងបុគ្គលដែលមានអាយុក្រោម ១៨ ឆ្នាំពីការបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ មាត្រានេះមិនស៊ីសង្វាក់គ្នានឹងមាត្រា ១១ ដែលអនុញ្ញាតឱ្យក្រសួងមហាផ្ទៃត្រូវកំណត់ ដោយប្រកាស ទៅលើនីតិវិធីនៃការបង្កើត និងការចុះបញ្ជីសមាគម ដោយអនីតិជន។ ព្រមទាំង កង្វះវិធានផ្នែកនីតិវិធីការពារក្នុងដំណើរការចុះបញ្ជីដែលកំណត់ក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល[116] ក្នុងនោះរួមទាំងការចែងពុំច្បាស់លាស់ពីមូលហេតុនៃការបដិសេធសំណើសុំចុះបញ្ជីជាដើម ដែលប្រការនេះទុកចន្លោះប្រហោងសម្រាប់ការបដិសេធតាមតែអំពើចិត្ត។ ផ្ទុយពីនេះ វិសោធនកម្មច្បាប់ស្តីពីសហជីពឆ្នាំ ២០២០ បានលុបចោលការរឹតត្បិត២ ចំណុចមកលើសហជីព ប៉ុន្តែនៅតែមានភាពលំបាកក្នុងការចុះបញ្ជីដដែល។ មាត្រា ២០ បានរឹតត្បិតលទ្ធភាពក្នុងការអនុវត្តសកម្មភាព ដោយតម្រូវឱ្យថ្នាក់ដឹកនាំមានអាយុចាប់១៨ ឆ្នាំ មានសេចក្តីប្រកាសផ្ទាល់ខ្លួនអំពីអាសយដ្ឋានរស់នៅដែលទាំងនេះមិនស្របតាមការអនុវត្តអន្តរជាតិល្អបំផុតនោះទេ និងមិនស្របតាមសិទ្ធិក្នុងការជ្រើសរើសតំណាងរបស់ពួកគេដោយសេរី[117]។ ជាចុងក្រោយច្បាប់ស្តីពីសហជីពបង្កើតគ្រាន់តែជានីតិវិធីសម្រាប់សហជីពដែលតម្រូវឱ្យមានការយល់ព្រម |

[108] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧ បានបកស្រាយតាមសមត្ថកិច្ចលើមាត្រា៣១ នៃរដ្ឋធម្មនុញ្ញទាក់ទងនឹងអត្ថន័យសន្ធិសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ក្នុងនោះរួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលត្រូវអនុវត្តដោយផ្ទាល់ក្នុងច្បាប់កម្ពុជា។ សូមមើលសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ កក្កដា ឆ្នាំ២០០៧)។

[109] អនុក្រឹត្យលេខ១៤៨ ស្តីការបង្កើតនិងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសបានពង្រីកវិសាលភាពមកលើកម្មករនិយោជិតដែលធ្វើការនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស។

[110] ការប្រើពាក្យពេចន៍មានអត្ថន័យទូលំទូលាយខ្លាំងពេក តម្រូវឱ្យបុគ្គលនិងគណបក្សនយោបាយ "តម្កល់ផលប្រយោជន៍ជាតិ" និងហាមប្រាមការធ្វើសកម្មភាពណាមួយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋ ទោះដោយផ្ទាល់ឬដោយប្រយោលក្តី"។ ព្រះរាជក្រមនីដ្ឋ 'សេចក្តីព្រាងវិសោធនកម្មក្រមព្រហ្មទណ្ឌពាក់ព័ន្ធនឹងការប្រមាថព្រះមហាក្សត្រ និងវិសោធនកម្មបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ (ព្រះរាជក្រមនីដ្ឋ, ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨) <https://bit.ly/2DZYnKM>

[111] ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់លក្ខខណ្ឌសម្រាប់ការចុះបញ្ជី (មាត្រា៦) ចែងលក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីមានបន្ទុកច្រើន លំបាក និងមិនច្បាស់លាស់ (ជំពូក២ និងជំពូក៣)។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលព្រមទាំងចែងបែបទូលាយពីការត្រួតពិនិត្យរបស់រដ្ឋាភិបាលក្នុងការបដិសេធលើការចុះបញ្ជី (មាត្រា៨) និងកំណត់នូវសកម្មភាពលំបាក និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុ (មាត្រា២៥) ព្រមទាំងកំណត់ទោសទណ្ឌដោយពុំសមាមាត្រ (មាត្រា៣០)។ ច្បាប់ស្តីពីសហជីពកំណត់លក្ខខណ្ឌតម្រូវសម្រាប់ការចុះបញ្ជីមានបន្ទុកច្រើននិងស្មុគស្មាញ និងមូលហេតុទូលំទូលាយសម្រាប់ការបដិសេធលើការចុះបញ្ជី (មាត្រា១៥ និងប្រកាសលេខ២៤៩) និងលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍មានបន្ទុកច្រើន (មាត្រា១៧)។

[112] វិសោធនកម្មបានបន្ថយវិសាលភាពរបស់ច្បាប់ដែលមិនរួមបញ្ចូលការធ្វើដំណើរតាមអាកាសនិងការធ្វើដំណើរទៅបរទេស ហើយបានដកចេញចំណុចដែលតម្រូវឱ្យថ្នាក់ដឹកនាំសហជីពមិនធ្លាប់ត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌពីមុនមក ហើយការតម្រូវឱ្យបង់ប្រាក់ឈ្នួលនិងអត្ថប្រយោជន៍ផ្សេងទៀតត្រូវធ្វើមុនពេលការរំលាយសហជីព និងដកចេញចំណុចដែលសហជីពត្រូវរំលាយនៅពេលមានថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងត្រូវបានកាត់ទោសពីបទល្មើសព្រហ្មទណ្ឌ។ សូមមើលចំណុចគន្លឹះទី១ ។

[113] សូមមើលចំណុចគន្លឹះទី១។

[114] នយ័តករទូរគមនាគមន៍កម្ពុជា 'ការគ្រប់គ្រងនិងការប្រើប្រាស់ឈ្មោះដែនជាតិក្នុងប្រព័ន្ធអ៊ីនធឺណិត' (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១) <https://trc.gov.kh/sub-decree/>។

[115] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីពីរស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង អាយ.ស៊ី.អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ៤-៧ អាចស្វែងរកបានតាមរយៈ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf។

[116] មាត្រា៨ ក្រសួងមហាផ្ទៃអាចបដិសេធការស្នើសុំចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលបានរកឃើញថាមាន "គោលបំណង និងទិសដៅ" ដែលអាចធ្វើឱ្យ "ប៉ះពាល់ដល់សន្តិសុខ ស្ថិរភាពនិងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា"។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ទុកចន្លោះនូវនីតិវិធីចុះបញ្ជីជាក់ស្តែង សម្រាប់ការកំណត់របស់ក្រសួងមហាផ្ទៃ តាមរយៈបញ្ញើរដ្ឋបាល ឬ ប្រកាស។

[117] អនុសញ្ញាលេខ៨៧ នៃអង្គការពលកម្មអន្តរជាតិ ស្តីពីសេរីភាពខាងសមាគម និងការការពារការរៀបចំ អនុម័តថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៤៨, មានសុពលភាពអនុវត្តថ្ងៃទី០៤ ខែកក្កដា ឆ្នាំ១៩៥០) <http://www.refworld.org/docid/425bc1914.html>

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ពីរដ្ឋាភិបាលផ្ទុយពីច្បាប់សិទ្ធិមនុស្សអន្តរជាតិតែប៉ុណ្ណោះ[118]។ |
| ១.៣ ពុំមានការរឹតត្បិតលើចំនួនសមាគមដែលមាន គោលបំណងប្រហាក់ប្រហែលគ្នា | កម្រិតនៃច្បាប់ តែត្រូវមិនឱ្យបង្កើតសមាគមដែលមាន គោលបំណងប្រហាក់ប្រហែលគ្នា | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញចំណុចនេះ ព្រោះពុំមានការកម្រិតលើចំនួនសមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលអាចមានគោលបំណងស្រដៀងគ្នាក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ឬច្បាប់ដទៃទៀតដែរ។ មាត្រា៧ នៃច្បាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលចែងថាឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងនិមិត្តសញ្ញានៃសមាគមឬអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") នឹងមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ ឬអក្សរកាត់របស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីមុនរួចហើយ ឬ រូបសញ្ញា បដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិឡើយ។ ការរឹតត្បិតនេះបង្ហាញពីហេតុផលសមស្រប និងសមាមាត្រដរាបណាត្រូវបានគេអនុវត្តក្នុងលក្ខខណ្ឌត្រឹមត្រូវ តម្លាភាព និងសង្គតិភាព។ |
| ១.៤ សមាគមអាចបង្កើតបណ្តាញនៃអង្គការ សម្ព័ន្ធ សហព័ន្ធ ឬ សហជីពប្រភេទដទៃទៀតដោយសេរី | កម្រិតនៃច្បាប់ ឬគោលនយោបាយអនុញ្ញាត ឱ្យសមាគម បង្កើតបណ្តាញនៃអង្គការ សម្ព័ន្ធ សហព័ន្ធ សហជីពនៃប្រភេទដទៃទៀត | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | កម្ពុជាបានបំពេញផ្នែកខ្លះលើចំណុចនេះ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកំណត់ថា សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបង្កើតឡើងដោយ "រូបវន្តបុ/និងនីតិបុគ្គល" ដែលនេះបង្ហាញថា ទោះជាបណ្តាញរបស់អង្គការមិនមែនរដ្ឋាភិបាល ឬសម្ព័ន្ធនៃអង្គការដើម នឹងទទួលបានការអនុញ្ញាត។ ទន្ទឹមនេះច្បាប់ស្តីពីសហជីព ទទួលស្គាល់ជាក់លាក់នូវសិទ្ធិរបស់សហជីពនិងសមាគមនិយោជកក្នុងការប្រឹក្សាយោបល់គ្នាដោយសេរី និងចូលជាសមាជិកជាមួយសហជីព និងសមាគមនិយោជកដទៃទៀត ច្បាប់ស្តីពីសហជីព ក៏ចែងផងដែរពីលក្ខខណ្ឌរឹតត្បិតដែលពុំអនុលោមតាមច្បាប់ ដែលបង្កជាឧបសគ្គពុំសមហេតុផលចំពោះការបង្កើតបណ្តាញនេះ[119]។ |
| ១.៥ ការចុះបញ្ជីសមាគមគឺជាការស្ម័គ្រចិត្ត | កម្រិតនៃ ច្បាប់ ឬគោលនយោបាយ អនុញ្ញាតដល់ការចុះបញ្ជីសមាគមដោយស្ម័គ្រចិត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ១ | ១ | ១ | ១ | ១ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះ ពីព្រោះថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីគណបក្សនយោបាយ ហើយនិងច្បាប់ស្តីពីសហគមន៍កសិកម្មតម្រូវឱ្យចុះបញ្ជីតាមលក្ខន្តិកៈច្បាប់។ និយមន័យនៃពាក្យសមាគមក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានអត្ថន័យទូលំទូលាយពេកដែលអាចអនុវត្តទៅលើក្រុមក្នុងវិស័យក្រៅប្រព័ន្ធនៅកម្ពុជា[120]។ នៅក្រោមច្បាប់ទាំងនេះ ការខកខានមិនបានចុះបញ្ជីការធ្វើឱ្យសមាគមក្លាយជាសមាគមដែលខុសច្បាប់។ ការបដិសេធលើសមត្ថភាពផ្លូវច្បាប់និងការហាមប្រាម ស្ថាប័ននានាដែលពុំបានចុះបញ្ជីពីការអនុវត្តសកម្មភាពណាមួយគឺពុំស្របជា មួយសិទ្ធិសេរីភាពខាងសមាគម ដែលសមាគមទាំងនោះ គួរតែត្រូវបានចាត់ទុកថាកំពុងធ្វើប្រតិបត្តិការដោយស្របច្បាប់ លើកលែងតែបានបង្ហាញសកម្មភាពផ្ទុយពីនោះ។ ការចុះបញ្ជីគួរតែត្រូវបានធ្វើឡើងតាមការស្ម័គ្រចិត្ត ដោយផ្អែកលើប្រព័ន្ធនៃ |

[118] មាត្រា៨ នៃអនុសញ្ញាសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (អនុម័តថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, មានសុពលភាពអនុវត្តថ្ងៃទី០៣ ខែមករា ឆ្នាំ១៩៧៦)។

[119] មាត្រា១០ នៃច្បាប់ស្តីពីសហជីព។

[120] លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥ និងលិខិតឆ្លើយតបដែលម.ស.ម.កបានទទួលនៅថ្ងៃទី២២ ខែកញ្ញា។ ជាការលើកទឹកចិត្ត លិខិតឆ្លើយតបពីក្រសួងមហាផ្ទៃបានចង្អុលបង្ហាញថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនឹងមិនអនុវត្តចំពោះសហគមន៍មូលដ្ឋានទេ។ ទោះយ៉ាងណាក៏ដោយ នៅតែមានវិសាលភាពគួរឱ្យកត់សំគាល់សម្រាប់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីក្នុងការអនុវត្តផ្ទុយ ដោយសារតែពាក្យដែលមិនច្បាស់លាស់នៃច្បាប់៖ សូមអាន ម.ស.ម.ក លិខិតរបស់ ម.ស.ម.ក ស្នើក្រសួងមហាផ្ទៃបញ្ជាក់ពីការប្រើប្រាស់ពាក្យ (ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៥) <https://cchrcambodia.org/index_old.php?title=CCHR-Open-Letter-Seeks-Clarification-Regarding-Application-of-the-LANGO-to-CBOs-and-Informal-Groups&url=media/media.php&p=press_detail.php&prid=569&id=5>។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ការជូនដំណឹង ជាជាងសុំការអនុញ្ញាត និងក្នុងគោលបំណង ទទួលបានសមត្ថភាពផ្លូវច្បាប់តែប៉ុណ្ណោះ ដែលនេះពុំគួរតម្រូវឱ្យមានការស្នើសុំការអនុញ្ញាតជាមុន ចំពោះការអនុវត្តសកម្មភាពស្របច្បាប់ឡើយ។ |
| ១.៦ បទប្បញ្ញត្តិដែលមានការត្រួតត្រាលើសមាគមអនុលោមតាមបទដ្ឋានអន្តរជាតិ | ក្បួនតែច្បាប់ ឬគោលនយោបាយដែលត្រួតត្រាមកលើសមាគម ដែលស្របទៅតាមបទដ្ឋានអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ១ | ២ | ២ | ២ | ២ | ១,៥ | កម្ពុជាពុំបានបំពេញចំណុចនេះទេ ដោយសារតែមាត្រាខ្លះនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ផ្ទុយនឹងស្តង់ដារអន្តរជាតិ ស្តីពីសិទ្ធិសេរីភាពខាងការបង្កើតសមាគម និងខាងការបញ្ចេញមតិ ដែលជាប់កាតព្វកិច្ចចំពោះរដ្ឋភាគី។ ការអនុវត្តល្អប្រសើរជាអន្តរជាតិបង្ហាញពីតម្រូវការតិចតួចក្នុងការតាមដាន ព្រមទាំងការប៉ុនប៉ងត្រួតពិនិត្យយ៉ាងជិតដល់ដើម្បីរារាំងសមាគម និងសមាជិកក្នុងការបង្កើតជម្រើសសម្រាប់អង្គការនិងការងាររបស់អង្គការ។ ច្បាប់ស្តីពី សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលតម្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជូនដំណឹងជាមុន អំពីសកម្មភាពជាក់លាក់ដែលធ្វើឡើងក្នុងដែនសមត្ថកិច្ចរដ្ឋបាលរាជធានី ឬ ខេត្តណាមួយត្រូវជូនដំណឹងដោយផ្ទាល់ទៅរដ្ឋបាលរាជធានី ខេត្តនោះ និងទាមទារឱ្យអង្គការអន្តរជាតិនៅកម្ពុជាធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល។ ច្បាប់ស្តីពីសហជីពបញ្ជាក់ពីខ្លឹមសារនៃលក្ខន្តិកៈរបស់សហជីព កំណត់ចំនួននៃសមាជិក និងអាណត្តិសម្រាប់អ្នកដឹកនាំគ្រប់គ្រង។ យន្តការត្រួតពិនិត្យច្បាប់នេះនៅមិនបានធ្វើឱ្យថមថយនៅក្នុងវិសោធនកម្មច្បាប់ស្តីពីសហជីពនោះទេ។ ក្រសួងមហាផ្ទៃបានចេញសេចក្តីជូនដំណឹងមួយនៅក្នុងខែតុលា ឆ្នាំ២០១៧ ជាការអនុវត្តលើការជូនដំណឹងជាមុន សម្រាប់សកម្មភាពរបស់អង្គការសង្គមស៊ីវិលទាំងអស់ ដែលសេចក្តីប្រកាសនេះផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ព្រោះជាការគ្រប់គ្រងលើសកម្មភាពសមាគម។ នេះនាំឱ្យពិន្ទុទាក់ទងនឹងការគោរពសេរីភាពមូលដ្ឋានធ្លាក់ចុះហូតមកដល់ ១ ក្នុងរបាយការណ៍អង្កេតនៅក្នុងឆ្នាំទី២ ប៉ុន្តែរបៀបរបបនៃការជូនដំណឹងជាមុននេះ ត្រូវបាននិរាករណ៍វិញតាមរយៈ សេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។ វិសាលភាពនៃសេចក្តីជូនដំណឹងឆ្នាំ២០១៨ នោះ បានកំណត់លើក្រុមសង្គមស៊ីវិលដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃដែលនោះជាការទុកចន្លោះប្រហោង អាចឱ្យអាជ្ញាធរមូលដ្ឋានរារាំងសកម្មភាពនានារបស់ក្រុម ឬសហគមន៍តូចៗដែលពុំបានចុះបញ្ជី។ |
| ១.៧ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ទៅរដ្ឋាភិបាលអនុលោមតាមបទដ្ឋានអន្តរជាតិ | ក្បួនតែលក្ខខណ្ឌធ្វើរបាយការណ៍អនុលោម តាមបទដ្ឋានអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ២ | ២ | ២ | ២ | ២ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ លក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍សម្រាប់អង្គការសង្គមស៊ីវិល និងសហជីពក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពគឺជាលក្ខខណ្ឌលំបាកនិងមិនអនុលោមតាមបទដ្ឋានអន្តរជាតិ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ អនុញ្ញាតរដ្ឋអាចតម្រូវឱ្យសមាគមរាយការណ៍ ប្រសិនបើពួកគេបង្កើតឡើងក្នុងគោលបំណងស្របច្បាប់ តម្លាភាព និងគណនេយ្យភាព[121]។ ទោះជាយ៉ាងណាក៏ដោយបទដ្ឋានអន្តរជាតិតម្រូវឱ្យមាន កាតព្វកិច្ចរាយការណ៍ដោយមិនតាមទំនើងចិត្ត[122]ឬជាបន្ទុក[123]។ អង្គការតូចៗ ឬក្រុមនៅ |

[121] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, ( ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២ កថាខណ្ឌទី៦៥ ) <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[122] ដូចយោងខាងលើ។

[123] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិឡើកឡើងថាកាតព្វកិច្ចរាយការណ៍មិនត្រូវរារាំងដល់ស្វយ័តភាពរបស់សមាគម។ UN Doc A/HRC/២២/L.១៣ (ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០១៣ កថាខណ្ឌទី៨) <https://documents-dds-ny.un.org/doc/RESOLUTION/LTD/G13/120/26/PDF/G1312026.pdf?OpenElement>

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | តាមមូលដ្ឋានអាចរងការប៉ះពាល់ដោយពុំសមាមាត្រ ព្រោះពួកគេមានធនធានតិចតួច ក្នុងការគោរពតាមលក្ខខណ្ឌតម្រូវជាច្រើនទាំងនោះ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីពតម្រូវឱ្យអង្គការសង្គមស៊ីវិល ឬសហជីពផ្ញើរបាយការណ៍សកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុទៅក្រសួងមហាផ្ទៃ[124]។ នៅឆ្នាំ២០១៩ មាត្រា១៧ នៃច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពសម្រាប់សវនករ តាមសំណើរបស់ម្ចាស់ជំនួយឬសំណើរបស់សមាជិកសរុបយ៉ាងតិច១០% សម្រាប់សហជីពមូលដ្ឋាន ឬ ៥% នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា១៧ ដដែលនេះក៏នៅតែបន្តរឹតត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគមដដែល។ |
| ១.៨ ទណ្ឌកម្មមក លើសមាគម ត្រូវបានចែងដោយច្បាប់ សមាមាត្រ ផ្សព្វផ្សាយជាសាធារណៈ មាននិយមន័យច្បាស់លាស់ មានតម្លាភាព និងងាយស្រួលយល់ | ក្បួននៃ ទណ្ឌកម្មលើសមាគមដែលត្រូវបានកំណត់ដោយច្បាប់ដែលមានលក្ខណៈសមាមាត្រ ផ្សព្វផ្សាយជាសាធារណៈ មានន័យច្បាស់លាស់ មានតម្លាភាព និងងាយស្រួលយល់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ១,៥ | ១,៥ | ១,៥ | ១ | ១ | ១ | កម្ពុជាពុំបានបំពេញចំណុចនេះទេ។ ទោសទណ្ឌចំពោះអង្គការសង្គមស៊ីវិលនិងគណបក្សនយោបាយក្រោមច្បាប់ស្តីពី សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីពនិងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ពុំសមាមាត្រ និងពុំស្របតាមបទដ្ឋានអន្តរជាតិ[125]។ ទោសទណ្ឌជាច្រើនក្រោមច្បាប់ស្តីពីសហជីព ហើយនិងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏ពុំបានពន្យល់អត្ថន័យឱ្យបានល្អិតល្អន់ ងាយយល់ និងតម្លាភាព។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់ទោសទណ្ឌជាច្រើន រួមទាំងការរំលាយសហជីព និងការលុបបញ្ជិកា ដែលមានខ្លឹមសារស្រពេចស្រពិល និយមន័យមិនច្បាស់លាស់ ហើយពិបាកយល់ពីចំណាត់ការទាំងនោះដូចជា "ពាក្យអព្យាក្រឹតផ្នែកនយោបាយ" ជាដើម។ ខណៈដែលវិសោធនកម្មច្បាប់ស្តីពីសហជីពនៅក្នុងឆ្នាំ២០១៩ បានដកចេញការរំលាយដោយស្វ័យប្រវត្តិ ប្រសិនបើថ្នាក់ដឹកនាំឬគណៈគ្រប់គ្រងណាម្នាក់ប្រព្រឹត្តបទឧក្រិដ្ឋ[126] ច្បាប់ស្តីពីសហជីពក៏ចែងចំណាត់ការដែលនាំទៅរកការដាក់ទោសទណ្ឌដោយស្រដៀងគ្នានេះដែរពីនិយមន័យមិនច្បាស់លាស់និងចំណាត់ការដូចជាការហាមប្រាមការក្នុងការរៀបចំទាំងឡាយណាក្នុងគោលបំណងបំរើនិន្នាការនយោបាយ ឬមហិច្ឆតាផ្ទាល់ខ្លួនជាដើម។ម្យ៉ាងវិញទៀត ក្រមព្រហ្មទណ្ឌពិពណ៌នាអំពីទោសទណ្ឌក្នុងអត្ថន័យមិនច្បាស់លាស់ និងពុំសមាមាត្រដែលអាចអនុវត្តទៅលើសមាគមនិងអ្នកដឹកនាំដូចជា "ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស" "ការប្រមាថ" "ការរិះគន់លើសេចក្តីបង្គាប់របស់តុលាការ" និងបទបរិហារកេរ្តិ៍។ ច្បាប់ស្តីពីទូរគមនាគមន៍[127] ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម[128] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រនិងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ក៏មានចែងពីទោសទណ្ឌនានាចំពោះចំណាត់ការដែលពុំសមាមាត្រ ទូលំទូលាយនិង |

[124] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ផលិតរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ២០១៨) ទំព័រ ៤ - ៧ អាចស្វែងរកបានតាមរយៈ: https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

[125] សូមមើលរបាយការណ៍ប្រចាំឆ្នាំលើកទីមួយស្តីពីការឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក និងមជ្ឈមណ្ឌលសាមគ្គីភាព និង ICNL (ខែសីហា ឆ្នាំ ២០១៨) ទំព័រ៤ - ៧ អាចស្វែងរកបានតាមរយៈ: https://cchrcambodia.org/ admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

[126] មាត្រា២៩ នៃច្បាប់ស្តីពីសហជីព។

[127] មាត្រា១០៧ នៃច្បាប់ស្តីពីទូរគមនាគមន៍។

[128] មាត្រា៧ មាត្រា ៧៦ មាត្រា៧៧ និងមាត្រា៧៨ នៃច្បាប់ស្តីពីប្រឆាំងនឹងអំពើភេរវកម្ម។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | មិនច្បាស់លាស់នេះផងដែរ[129]។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្នបង្កើតការដាក់ទោសទណ្ឌមកលើអង្គការនិងអាជីវករដែលមិនគោរពតាមវិធានការពេលប្រទេសជាតិជួបប្រទះភាពអាសន្ន។ នីតិបុគ្គលដែលប្រព្រឹត្តិទោសព្រហ្មទណ្ឌដោយចេតនា "ការប៉ុនប៉ងប្រព្រឹត្តអំពើរាំងដល់កិច្ចប្រត្តិការ ពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន"[130] និង "ការប៉ុនប៉ងមិនគោរពតាមវិធានដែលដាក់ចេញដោយ រាជរដ្ឋាភិបាល"[131]។ ទោសទណ្ឌក្រោមបញ្ញត្តិច្បាប់រួមបញ្ចូលទាំងការពិន័យដ៏ធំរហូតដល់១លានរៀល បន្ថែមពីលើ "ទោសមួយឬច្រើនដូចមានចែមក្នុងមាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌ"។ មាត្រា១៦៨ នៃក្រមព្រហ្មទណ្ឌផ្តល់អំណាចក្នុងការរំលាយឬបង្ខំឱ្យបិទស្ថាប័ន។ ការរំលាយឬបិទស្ថាប័នអង្គការសង្គមស៊ីវិលជាការរំលោភបំពានច្បាប់មួយផ្នែកដែលមិនស្របនឹងសេរីភាពខាងការបង្កើតសមាគម[132]។ មាត្រា៥ នៃច្បាប់កូវីដ-១៩ អាជ្ញាធរអាចផ្អាកឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម និងអាចបិទអាជីវកម្មដែលជាទណ្ឌកម្មប្រឆាំងនឹងជនដែលមិនអនុវត្តតាមបទបញ្ញតិ វិធានការសុខភាព និងវិធានការរដ្ឋបាលនេះ"។ |
| ១.៩<br>ការការពារផ្នែកនីតិវិធីត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សមាគមដែលប្រឈមនឹងទណ្ឌកម្ម | កម្រិតនៃការការពារត្រូវបានដាក់ឱ្យអនុវត្តសម្រាប់សមាគមដែលប្រឈមនឹងទណ្ឌកម្ម | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ២ | ២ | ២ | ២ | ២ | ២ | | កម្ពុជាមិនបំពេញចំណុចនេះទេ។ មានកិច្ចការពារមួយចំនួនត្រូវបានបញ្ចូលក្នុងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដូចជាការបង្កើនទោស និងសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងករណីលុបឈ្មោះចេញពីបញ្ជី ប៉ុន្តែកិច្ចការពាររួមទាំងនេះពុំទាន់គ្រប់គ្រាន់នៅឡើយ។ ច្បាប់ស្តីពីសហជីពពុំមានចែងពីសិទ្ធិប្តឹងទាស់ទៅសាលាឧទ្ធរណ៍ចំពោះការពិន័យផ្នែករដ្ឋបាលឡើយ ទោះបីជាប្រកាសលេខ ២៥១ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតសិទ្ធិមានដែនកំណត់ទាក់ទងនឹងបណ្តឹងទាស់ផ្នែករដ្ឋបាលទៅក្រសួងការងារនៅពេលទទួលបានលិខិតព្រមាន ឬការផាកពិន័យក៏ដោយ។ សម្រាប់ទោសមានចែងក្នុងក្រមព្រហ្មទណ្ឌមានសិទ្ធិប្តឹងទាស់។ ច្បាប់ស្តីពីគណបក្សនយោបាយចែងពីកិច្ចការពារមានដែនកំណត់ចំពោះទោសទណ្ឌនានា បើទោះជាស្ថាប័ននីតិប្រតិបត្តិទទួលបានឆន្ទានុសិទ្ធិខ្ពស់ក្នុងការដាក់ទោសទណ្ឌ ដែលមានអត្ថន័យទូលំទូលាយ និងមិនច្បាស់លាស់យ៉ាងណាក៏ដោយ។ |
| ១.១០<br>សិទ្ធិក្នុងការរំលាយដោយស្ម័គ្រចិត្តត្រូវបានការពារដោយច្បាប់ | កម្រិតនៃការរំលាយដោយស្ម័គ្រចិត្តត្រូវបានការពារដោយច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ជាទូទៅកម្ពុជាបានបំពេញចំណុចនេះ។ មាត្រា២៦ នៃច្បាប់ស្តីពីសមាគម និងអង្គាការមិនមែនរដ្ឋាភិបាលក្នុងស្រុក "អាចផ្អាកសកម្មភាពរបស់ខ្លួនដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ ក្រសួងមហាផ្ទៃ ហើយមុននឹងផ្អាកសកម្មភាពត្រូវធ្វើរបាយការណ៍សកម្មភាពការងារនិងរបាយការណ៍ហិរញ្ញវត្ថុ"។ ប៉ុន្តែបទប្បញ្ញត្តិមិនច្បាស់លាស់នៃមាត្រា ២៦ (២) អាចបង្កើតជាឧបសគ្គដល់ការរំលាយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដោយស្ម័គ្រចិត្ត ព្រោះបទប្បញ្ញត្តិទាំងនោះតម្រូវថា "សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមុននឹងរំលាយត្រូវជម្រះកាតព្វកិច្ចតាមនីតិវិធី និងបទប្បញ្ញត្តិជាធរមាន"។ ជាងនេះទៅ |

[129] មាត្រា៧៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់។

[130] មាត្រា៧ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

[131] មាត្រា៨ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

[132] ការរំលាយដោយមិនស្ម័គ្រចិត្តគឺជាវិធីចុងក្រោយដែលគួរប្រើប្រាស់តែចំពោះការបំពានធ្ងន់ធ្ងរនិងគួរតែធ្វើបន្ទាប់ពីបានជូនដំណឹងនិងឱកាសក្នុងការតវ៉ា។ សូមអាន គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ A/HRC/20/27, 'របាយការណ៍អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី និងសេរីភាពខាងសមាគម', Maina Kiai' ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២, កថាខណ្ឌទី៧៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ទៀត អត្ថបទនេះផ្ទុយនឹងកថាខណ្ឌទី ១ នៃមាត្រា ២៥ ដែលសំដៅតែលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មិនមែនទៅលើសមាគមក្នុងស្រុក ដោយមាត្រានេះមិនបានពន្យល់បន្ថែមអំពីភាពខុសគ្នាចំពោះតម្រូវការរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ក្រមរដ្ឋប្បវេណីធានាដល់ការរំលាយស្ថាប័ននីតិបុគ្គលដោយស្ម័គ្រចិត្តមាត្រា៦៤។ តាមមាត្រា៦៤ (១) "ដោយមូលហេតុនៃការរំលាយដែលបានកំណត់នៅក្នុងលក្ខន្តិកៈ"។ សមាគមឬអង្គការមិនមែនរដ្ឋាភិបាលអាចរំលាយតាមសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ដោយទទួលបានការគាំទ្រភាគច្រើនពីសមាជិកទាំងអស់ ត្រូវមានការយល់ព្រមពីសមាជិកចាប់ពីពាក់កណ្តាលឡើងទៅ ដោយមានសំឡេងចាប់ទី ៣ ភាគ ៤ ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ មាត្រា ៦៤ (២) និង (៣)។ |
| ១.១១<br>ការរំលាយអាចធ្វើទៅបានបន្ទាប់ពីបានប្រើប្រាស់ច្បាប់ដទៃទៀតអស់លទ្ធភាពនិងបង្ហាញថាសមាគមអាចបង្កគ្រោះថ្នាក់ | កម្រិតនៃ ដំណើរការរំលាយ សមាគមត្រូវបានដាក់ឱ្យអនុវត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ១ | ១ | ១ | ១ | ១ | ១ | ១ | កម្ពុជាខកខានបំពេញចំណុចនេះ។ ការរំលាយសមាគមឬអង្គការមិនមែនរដ្ឋាភិបាលអាចធ្វើទៅបាន ក្រោមក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីសហជីព។ ក្នុងករណីនីមួយៗ ការរំលាយអាចត្រូវបានគេកំណត់ថាជាវិធានការវិន័យតែប៉ុណ្ណោះ ពុំមែនជាការឆ្លើយតបដោយសមាមាត្រ និងជាដំណោះស្រាយចុងក្រោយចំពោះគ្រោះថ្នាក់លើការបន្តប្រតិបត្តិការ របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលឡើយ។ ជាពិសេស វិធានការនៃការផ្អាក ឬការរំលាយសហជីពតាមអំណាចផ្នែករដ្ឋបាលបង្កការប៉ះពាល់ធ្ងន់ធ្ងរលើគោលការណ៍សេរីភាពខាងសមាគម[133]។ មាត្រា ២៤ និង ២៥ អាចជាហេតុផល ក្នុងមាត្រា ៣០ ដើម្បីផ្អាក ឬលុបឈ្មោះចេញពីបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ លើសពីនេះ ពាក្យកំពុងប្រើក្នុងមាត្រា៣០ នឹងអនុញ្ញាតឱ្យក្រសួងមហាផ្ទៃផ្អាក ឬលុបឈ្មោះចេញពីបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដោយសារតែមិនគោរពតាមលក្ខន្តិកៈរបស់ខ្លួន ទោះបី ជាការមិនគោរពតាមលក្ខន្តិកៈនេះមិនមែនជាបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ជាតិក៏ដោយ។ |
| ១.១២<br>សមាគមត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពសេដ្ឋកិច្ច | កម្រិតនៃច្បាប់ ឬគោលនយោបាយ អនុញ្ញាតឱ្យសមាគមធ្វើ សកម្មភាពសេដ្ឋកិច្ច | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ៥ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ជាទូទៅកម្ពុជាបំពេញចំណុចនេះ។ ពុំមានច្បាប់កំណត់ឱ្យមានការចូលរួម របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងសកម្មភាពសេដ្ឋកិច្ចនោះទេ។ ទោះបីជាសិទ្ធិនេះពុំត្រូវបានការពារ តែសិទ្ធិនេះក៏ពុំត្រូវបានហាមប្រាមផងដែរ។ តែយ៉ាងណាក្តី ច្បាប់ស្តីពីសហជីពរារាំងសហជីពក្នុងការបង្កើតមុខជំនួញលើកលែងតែបុគ្គលដែលទទួលបានភាពជាតំណាងបំផុតនៅកន្លែងការងារ។ |
| ១.១៣<br>ការទទួលមូលនិធិបរទេស ត្រូវបានអនុញ្ញាត នៅក្រោមច្បាប់ | កម្រិតនៃការទទួលមូលនិធិបរទេសត្រូវ បានអនុញ្ញាតដោយច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញចំណុចនេះ។ ពុំមានការហាមប្រាមផ្នែកច្បាប់លើសមាគម ក្នុងការទទួលមូលនិធិបរទេសឡើយ។ ប៉ុន្តែជាការសំខាន់ត្រូវកត់សម្គាល់ថា មាត្រា ២៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលកំណត់បន្ថែមទៀតនូវលក្ខខណ្ឌតឹងរ៉ឹងក្នុងការធ្វើរបាយការណ៍ សម្រាប់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលដែលស្វែងរក និង/ឬទទួលមូលនិធិបរទេស។ ម្យ៉ាងទៀត មាត្រា ២៥ នៃច្បាប់ដដែលតម្រូវថាសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលទទួលការគាំទ្រពីម្ចាស់ជំនួយ ត្រូវធ្វើរបាយ |

[133] អត្ថបទស្តីពីសេរីភាពខាងសមាគមរបស់អង្គការពលកម្មអន្តរជាតិឆ្នាំ២០១៦ កថាខ័ណ្ឌ៦៨៣ <http://www.ilo.org/wcmsp5/groups/public/@ed_norm/@normes/documents/publication/wcms_090632.pdf>។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ការណ៍ដែលចម្លងចេញពីឯកសារដើម ដែលផ្ញើទៅកាន់ម្ចាស់ជំនួយមកក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងការបរទេស ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទានជាមួយម្ចាស់ជំនួយដោយចម្លងចេញពីឯកសារដើមឱ្យបានក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃម្ចាស់ជំនួយបានឯកភាពយល់ព្រម ។ ព្រោះថាការផ្តល់មូលនិធិពីភាគីទី៣ភាគច្រើនបំផុត សម្រាប់សមាគមគឺមានប្រភពមកពីបរទេស ដែលការអនុវត្តនេះអាចបង្កជាឧបសគ្គ ក្នុងការទទួលមូលនិធិពីបរទេសជាពិសេសសម្រាប់អង្គការតូចៗ។ |
| ១.១៤ សមាគមមិនប្រឈមនឹងការរឹតត្បិតមិនសមហេតុផលពីទទួល មូលនិធិឯកជន (ក្នុងស្រុក) | កម្រិតនៃ ច្បាប់ ឬគោលនយោបាយអនុញ្ញាតឱ្យ សមាគមទទួលមូលនិធិពី ប្រភពឯកជនដោយគ្មានការរឹតត្បិតមិនសមហេតុផល | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញចំណុចនេះ។ កម្ពុជាពុំមានច្បាប់ហាមប្រាមក្នុងការទទួលមូលនិធិពីប្រភពឯកជនក្នុងស្រុកឡើយ។ ប៉ុន្តែការទទួលការគាំទ្រពីម្ចាស់ជំនួយទោះក្រៅប្រទេស ឬ ក្នុងប្រទេសនឹងនាំឱ្យមានលក្ខខណ្ឌធ្វើរបាយការណ៍ ដែលតាមការអនុវត្តជាក់ស្តែងអាចបង្កជាឧបសគ្គមួយ ជាពិសេសចំពោះអង្គការតូចៗ។ ជាងនេះទៅទៀត មាត្រា ២៥ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តម្រូវថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលទទួលការគាំទ្រពីម្ចាស់ជំនួយត្រូវបញ្ជូនច្បាប់ថតចម្លងនៃឯកសារដើម ដែលបានបញ្ជូនទៅម្ចាស់ជំនួយមកក្រសួងមហាផ្ទៃ ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេសឱ្យបានក្នុងអំឡុងពេល៣០ ថ្ងៃ គិតចាប់ពីថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ |
| ១.១៥ កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ មិនមានលក្ខណៈស្មុគស្មាញ | កម្រិតនៃ លក្ខខណ្ឌតម្រូវសម្រាប់ការធ្វើ របាយការណ៍ហិរញ្ញវត្ថុ ស្របទៅតាមបទអនុវត្តល្អ | ការពិនិត្យនិងសិក្សាឡើងវិញនូវ ឯកសារច្បាប់ | ២ | ២ | ២ | ២ | ២ | ២ | ២ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញទេ។ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលកំណត់កាតព្វកិច្ចក្នុងការធ្វើរបាយការណ៍ហិរញ្ញវត្ថុក្នុងនោះរួមទាំងបទប្បញ្ញត្តិទាក់ទងនឹងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងព័ត៌មានលម្អិតអំពីការទទួលមូលនិធិផងដែរ។ ការកំណត់លក្ខខណ្ឌតម្រូវក្នុងការធ្វើរបាយការណ៍ផ្នែកហិរញ្ញវត្ថុនេះក៏មានចែងក្នុងច្បាប់ស្តីពីសហជីពផងដែរ និងជាកម្មវត្ថុអាចត្រូវកែប្រែពីក្រសួងការងារនៅពេលណាមួយក៏បាន។ មាត្រា១៧ នៃវិសោធនកម្មច្បាប់ស្តីពីសហជីពត្រូវបានកែសម្រួលឡើងវិញពីប្រើពាក្យថា "រៀបចំ" ជំនួសឱ្យ "ដាក់ជូន" នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនិងរបាយការណ៍សកម្មភាពសម្រាប់សវនកតាមសំណើរបស់ម្ចាស់ជំនួយឬសំណើរបស់សមាជិកសរុបយ៉ាងតិច១០% សម្រាប់សហជីពមូលដ្ឋាន ឬ៥%នៃសមាជិកសរុបសម្រាប់សហព័ន្ធឬសហភាព។ មាត្រា ១៧ ដដែលនេះក៏នៅបន្តរឹតត្បិតនៃដល់កិច្ចការផ្ទៃក្នុងរបស់សមាគម ដដែល។ ទាំងអង្គការសង្គមស៊ីវិលនិងសហជីពឱ្យយោបល់ដែលពួកគេបានប្រឹងប្រែងគោរពតាមតម្រូវការរបាយការណ៍របស់រាជរដ្ឋាភិបាលក្រោមច្បាប់អង្គការសមាគម និងច្បាប់ស្តីពីសហជីព។ ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយក៏ចែងពីកាតព្វកិច្ចថ្មីមួយក្នុងការប្រកាសទ្រព្យសម្បត្តិ និងទំនួលខុសត្រូវចំពោះអង្គភាពប្រឆាំងអំពើពុករលួយ។ ជាចុងក្រោយលក្ខខណ្ឌតម្រូវឱ្យធ្វើរបាយការណ៍ ក៏មានចែងក្នុងសេចក្តីប្រកាសស្តីពីគោលការណ៍ណែនាំអនុវត្តកាតព្វកិច្ចសារពើពន្ធ របស់សមាគមនិងអង្គការមិនមែនរដ្ឋា ភិបាលចាត់ទុកជាបន្ទុកការងារបន្ថែមទៀតលើលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលអាចរឹត |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ត្បិតលើសេរីភាពខាងសមាគមដែលពុំអនុលោមតាមច្បាប់។ |
| ១.១៦ យន្តការសម្រាប់ការដោះស្រាយការរំលោភទៅលើសេរីភាពខាងការបង្កើតសមាគម ត្រូវបានអនុវត្ត | កម្រិតនៃប្រព័ន្ធដោះស្រាយសម្រាប់ការរំលោភលើសេរីភាពខាងការបង្កើតសមាគម ត្រូវបានធានាដោយច្បាប់ និងគោលនយោបាយ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | ៣ | ២,៥ | ២,៥ | ២,៥ | ២,៥ | ២,៥ | ២,៥ | កម្ពុជាពុំបានបំពេញចំណុចនេះឱ្យបានពេញលេញនៅឡើយទេ។ រដ្ឋធម្មនុញ្ញផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋឱ្យតតាំង នឹងការរំលោភបំពានណាមួយលើសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែ នីតិវិធីត្រួតពិនិត្យផ្នែកតុលាការពុំត្រូវបានពន្យល់ឱ្យបានច្បាស់លាស់ ដែលធ្វើឱ្យការធានានេះមានប្រសិទ្ធភាពតិចតួច។ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញអនុញ្ញាតឱ្យពលរដ្ឋតតាំងចំពោះច្បាប់ឬសេចក្តីសម្រេចដែលបង្កឱ្យមានការរំលោភលើសិទ្ធិក្នុងរដ្ឋធម្មនុញ្ញ។ ប៉ុន្តែច្បាប់នេះត្រូវបានធ្វើវិសោធនកម្មក្នុងខែកុម្ភៈ ឆ្នាំ២០១៨ លុបចេញបញ្ញត្តិដែលអនុញ្ញាតឱ្យគណបក្សនយោបាយអាចប្តឹងទាស់ទៅនឹងសេចក្តីសម្រេច របស់ក្រសួងមហាផ្ទៃដែលបដិសេធលើសំណើសុំចុះបញ្ជី។ ក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនមានយន្តការដាក់ទោសរដ្ឋបាលមកលើការបដិសេដការចុះបញ្ជីសមាគមនោះទេ។ សម្រាប់សមាគមក្នុងស្រុកមានវិធានការមួយប៉ុណ្ណោះសម្រាប់តវ៉ាមកលើការបដិសេធការចុះបញ្ជីរបស់ពួកគេដែលត្រូវតវ៉ា ចំពោះការបដិសេធតាមប្រព័ន្ធតុលាការ។ សម្រាប់សមាគមបរទេសឬអង្គការអន្តរជាតិ ពួកគេអាចតវ៉ាពីការសម្រេចនេះទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ប្រកាសលេខ២៥០ និង២៥១ ពង្រីកវិសាលភាពដល់ច្បាប់ស្តីពីសហជីព ដែលកម្រិតការតវ៉ាត្រឹមតែក្រសួងបណ្តុះបណ្តាលការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែមិនបានផ្តល់សិទ្ធិឱ្យពួកគេតវ៉ាពីការសម្រេចនេះដល់តុលាការនោះទេ។ ហើយទាំងនេះគឺមិនស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិដែលអនុញ្ញាតឱ្យ “សមាគមអាចតវ៉ាអំពីការបដិសេធមិនចុះបញ្ជីដោយមិនលំអៀង និងឯករាជ្យ”[134]។ |
| ១.១៧ សមាជិកភាពនៅក្នុងអង្គការ សមាគម សម្ព័ន្ធឬសហព័ន្ធមិនមែនជាកាតព្វកិច្ចឡើយ | កម្រិតនៃសមាជិកភាពនិងការដកខ្លួនពីសមាជិកភាពដោយស្ម័គ្រចិត្តក្រោមការកំណត់របស់ច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៤ | ៤ | ៤ | កម្ពុជាបំពេញបានផ្នែកខ្លះនៃធាតុផ្សំនេះ។ ទាំងច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីសហជីពធានា សេរីភាពក្នុងការមិនចូលរួមនិងចាកចេញពីសហជីពកម្មករឬសមាគមនិយោជក[135]។ ច្បាប់ស្តីពីសហជីពតម្រូវឱ្យបុគ្គលនីមួយៗដាក់លិខិតជាមួយហត្ថលេខាឬក៏ស្នាមមេដៃរបស់ពួកគេទៅសហជីពនិងនិយោជក ដើម្បីប្រាប់ពីការចាកចេញពីសមាជិកភាពនោះ។ ច្បាប់នោះក៏បានសង្កត់ធ្ងន់ថា “គ្មាននរណាម្នាក់អាចជ្រៀតជ្រែកសិទ្ធិរបស់កម្មករនិយោជិតក្នុងការចូលរួមឬចាកចេញពីសហជីពឡើយ”[136]។ ស្រដៀងគ្នានេះ ច្បាប់ស្តីពីគណបក្សនយោបាយបានចែងថា “ការចូលជាសមាជិកភាពនៃគណបក្សនយោបាយគឺជាការស្ម័គ្រចិត្ត”។ សមាជិកនៃគណបក្សនយោបាយអាចលាឈប់ពីសមាជិកភាពបានគ្រប់ពេលវេលា ដោយមិនតម្រូវឱ្យមានបង្ហាញពីមូលហេតុ។ [137] ច្បាប់ស្តីពីអង្គការសមាគមនៅតែបន្តស្ងៀមស្ងាត់ អំពីការដកខ្លួនចេញពីសមាជិកភាពដោយស្ម័គ្រចិត្ត។ ផ្នែកមួយនៃ |

[134] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,’របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,’ UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២(, កថាខណ្ឌ៩៥ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[135] ˝ សេរីភាពសហជីពរបស់បុគ្គលម្នាក់ៗក៏បង្ហាញពីសេរីភាពនៃការមិនចូលរួមជាមួយសហជីពកម្មករឬនិយោជក និងសេរីភាពក្នុងការចាកចេញពីសមាគមបានគ្រប់ពេល˝ មាត្រា២៧៣ នៃច្បាប់ស្តីពីការងារ និង˝ សេរីភាពរបស់បុគ្គលម្នាក់ក្នុងមាត្រា៥ (សិទ្ធិក្នុងការបង្កើតនិងចូលរួមជាមួយសហជីពឬសមាគមនិយោជក) នៃច្បាប់នេះហើយក៏បង្កប់នូវសេរីភាពក្នុងការមិនចូលរួមជាមួយសហជីពកម្មករឬសមាគមនិយោជកនិងសេរីភាពក្នុងការដកខ្លួនចេញពីសហជីពឬសមាគមនិយោជកនោះបានគ្រប់ពេលទាំងអស់˝ មាត្រា៧ នៃច្បាប់ស្តីពីសហជីព។

[136] មាត្រា១៣ នៃច្បាប់ស្តីពីសហជីព។

[137] មាត្រា៧ នៃច្បាប់ស្តីពីគណបក្សនយោបាយ។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | សមាគមទាំងបីប្រភេទរួមមាន សហជីព សមាគមនិយោជក និងគណបក្សនយោបាយ សិទ្ធិក្នុងការចាកចេញពីសមាជិកភាព គឺមិនត្រូវបានការពារនៅក្នុងច្បាប់នោះទេ។ ទោះជាបែបនេះក្តីសូចនាករមួយនេះបានឱ្យពិន្ទុចំនួន៤ ។ មាត្រា៤២ នៃរដ្ឋធម្មនុញ្ញធានានិងការពារប្រជាជនខ្មែរក្នុងការបង្កើតសមាគម និងគណបក្សនយោបាយ ប៉ុន្តែមិនបាននិយាយពីការដកខ្លួនចេញពីសមាជិកភាពរបស់សមាគមនោះទេ។ ស្របពេលដែលសិទ្ធិក្នុងការមិនចូលរួមគួរតែបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់ជាតិដើម្បីធានាការការពាររបស់ខ្លួន។ |
| សេរីភាពខាងការជួបប្រជុំ | | | | | | | | | | |
| ១.១៨<br><br>ការសន្មតមុនដែលគាំទ្រដល់ការរៀបចំការប្រមូលផ្តុំដោយសន្តិវិធី គឺត្រូវបានកំណត់យ៉ាងច្បាស់លាស់ | ក្របខ័ណ្ឌច្បាប់កំណត់នូវការសន្មតមុន ដែលគាំទ្រចំពោះការប្រមូលផ្ដុំដោយសន្តិវិធីដែលត្រូវបានអនុញ្ញាត | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ២,៥ | ២ | ២ | កម្ពុជាខកខានក្នុងការគោរពចំណុចនេះឱ្យបានពេញលេញ។ ច្បាប់កម្ពុជាចែងពុំច្បាស់លាស់ពីការសន្មតជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធី។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងពីការសន្មតទុកជាមុនក្នុងការគាំទ្រដល់ការរៀបចំបាតុកម្មដោយសន្តិវិធីដែលចែងថា អាជ្ញាធរមានសមត្ថកិច្ច "ត្រូវឆ្លើយតបជាវិជ្ជមានជាលាយលក្ខណ៍អក្សរ"[138]។ ប៉ុន្តែការសន្មតទុកជាមុននេះមិនអនុវត្តទោះការប្រមូលផ្តុំដោយសន្តិវិធីធ្វើឡើងនៅក្នុងអំឡុងពេលថ្ងៃឈប់សម្រាក (ពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ពិធីឡើងគ្រងរាជ បុណ្យឯករាជ្យជាតិ បុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ)[139]។ ម្យ៉ាងទៀតច្បាប់នេះមានវិសាលភាពតូចចង្អៀតពេក ដែលមិនរាប់បញ្ចូលការជួបប្រជុំក្នុងយុទ្ធនាការបោះឆ្នោត ឬការជួបប្រជុំទាក់ទងនឹងវិវាទការងារជាដើមដែលផ្ទុយទៅនឹងគោលការណ៍សន្មតទុកជាមុនដែលបានលើកឡើងខាងលើ។[140]<br><br>ស្រដៀងគ្នានេះច្បាប់ការងារ ក៏មិនរាប់បញ្ចូលនូវសកម្មភាពមួយចំនួនក្រៅពីវិសាលភាពនៃកិច្ចការពារដែលមានចែងក្នុងច្បាប់នេះដែរ[141]។ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន បន្ថែមពីលើនូវការសន្មតនៃការអនុញ្ញាតឱ្យមានការប្រជុំដោយសន្តិវិធីដោយកំណត់អំណាចយ៉ាងទូលាយនិងគ្មាន "ហាមឃាត់ឬរឹតត្បិតសិទ្ធិជួបប្រជុំនិងជាក្រុម" នៅក្នុងពេលប្រទេសជាតិភាពអាសន្ន[142]។ ការវិវឌ្ឍបទបញ្ញត្តិនៅឆ្នាំ២០២១ បង្កើតបានជាមូលដ្ឋានបន្ថែមសម្រាប់ជំទាស់នឹងអ្នករិះគន់។ មាត្រា៤ នៃច្បាប់កូវីដ-១៩ ផ្តល់អំណាចដ៏សម្បើមដល់អាជ្ញាធរក្នុងការរឹតត្បិតឬហាមឃាត់ "ការប្រជុំ និងការប្រមូលផ្តុំរបស់មនុស្ស ដែលសកម្មភាពនេះអាច បណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩"។ បន្ថែមពីនេះមានត្រា ៦ នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ រដ្ឋាភិបាលអាចប្រើប្រាស់ ក្នុងការបិទអ៊ីនធឺណិតឬបិទការផ្តល់ |

[138] មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[139] ក្នុងករណីនេះ ក្រោមមាត្រា ១១ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថាអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរដែនដីរាជធានី ឬខេត្ត ត្រូវធ្វើការឆ្លើយតបដោយជូនដំណឹង "ជាបន្ទាន់" ទៅអ្នកដែលបានដាក់លិខិតជូនដំណឹង "ដើម្បីឱ្យពួកគេអាចមានពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ធ្វើការពិចារណាដើម្បីពិភាក្សាគ្នាដោះស្រាយ" ។ ប្រសិនបើពុំមានការឯកភាពគ្នាទេ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវផ្តល់សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលយ៉ាងយូរត្រឹមម្ភៃបួន (២៤) ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី (មាត្រា១២)។

[140] មាត្រា ៣ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[141] ទន្ទឹមនេះ ច្បាប់ការងារចែងក្នុងមាត្រា៣២០ ថា សិទ្ធិធ្វើកូដកម្ម ត្រូវបាន "ធានា" សិទ្ធិនេះក៏ត្រូវបានអនុវត្តដែរ នៅពេលដែលសហជីពជាតំណាងកម្មករនិយោជិតយល់ឃើញថាត្រូវយកសិទ្ធិនេះ មកប្រើដើម្បីបង្ខំឱ្យមានការគោរពតាមអនុសញ្ញារួម ឬតាមច្បាប់។ ជាពិសេស សិទ្ធិធ្វើកូដកម្មអាចអនុវត្តទៅបាន លុះត្រាតែបានប្រើប្រាស់អស់លទ្ធភាពក្នុងការដោះស្រាយជម្លោះដោយមធ្យោបាយសន្តិវិធីជាមួយនិយោជក។

[142] មាត្រា ១៥ នៃច្បាប់ពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន (២០២០)។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | សេវាដែលប្រើប្រាស់សម្រាប់អនុវត្តការជួបប្រជុំ។ ហើយជាចុងក្រោយ សង្ឃប្រកាស បានហាមឃាត់ព្រះសង្ឃពីការចូលរួមក្នុងការតវ៉ាផ្សេងៗ។ ដោយសារមូលហេតុនេះ ពិន្ទុត្រូវបានធ្លាក់ចុះមកត្រឹម ២ ដែលបង្ហាញពីការប្រើអំណាចខ្លាំងក្នុងការរឹតត្បិតនិងហាមឃាត់ដល់ការជួបប្រជុំដោយសន្តិវិធី។ |
| ១.១៩<br>ការរឹតត្បិត តម្រូវឱ្យមានហេតុផលច្បាស់លាស់ និងទាន់ពេលវេលា | កម្រិតនៃ ក្របខ័ណ្ឌច្បាប់តម្រូវឱ្យមានហេតុផលច្បាស់លាស់ទាន់ពេលវេលាចំពោះការរឹតត្បិត លើការជួបប្រជុំ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣,៥ | ៤ | ៤ | ៣ | ៣ | ៣ | កម្ពុជាខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី[143] ច្បាប់ស្តីពីការងារ[144] និងច្បាប់ស្តីពីការបោះឆ្នោតបង្ហាញពីនីតិវិធីនៃការជូនដំណឹងមុនសម្រាប់ការជួបប្រជុំ[145] ដែលស្របតាមច្បាប់អន្តរជាតិអំពីនីតិវិធីនៃការជូនដំណឹងមុន។ ទោះជាបែបនេះក្តីការអនុវត្តល្អជាអន្តរជាតិបានផ្តល់អនុសាសន៍ អំពីការជូនដំណឹងមុនចំពោះការជួបប្រជុំដែលមានចំនួនអ្នកចូលរួមច្រើន ឬការជួបប្រជុំដែលអ្នករៀបចំរំពឹងថាមានការរំខានតែប៉ុណ្ណោះ[146]។ ខណៈដែលច្បាប់ជាតិមិនបានអនុវត្តការអនុញ្ញាតជាមុន ការពិតដែលថាការជួបប្រជុំដោយសន្តិវិធី អាចត្រូវបានបញ្ឈប់ដោយអាជ្ញាធរ ប្រសិនបើមានការជូនដំណឹងត្រឹមត្រូវមិនបានដាក់ស្នើ មិនស្របតាមច្បាប់និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ[147]។ ច្បាប់ស្តីពីការបោះឆ្នោតរឹតត្បិតមកលើការជួបប្រជុំដោយមិនសមាមាត្រ ដូចជាតម្រូវឱ្យជូនដំណឹងមុនដែលនេះមិនមែនជាការតម្រូវផ្លូវការដែលទាមទារឱ្យមានការជូនដំណឹងគ្រប់ការជួបប្រជុំ ដូចជាការជួបប្រជុំដែលមានអ្នកចូលរួមតិចតួចដោយមិនមានការវិនិច្ឆ័យត្រឹមត្រូវ[148]។ ទោះជាបែបនេះក្តីច្បាប់ស្តីពីគណបក្សនយោបាយទាមទារឱ្យបង្ហាញអត្តសញ្ញាណអ្នកដឹកនាំចំនួន៣ នាក់ បាតុកម្មដោយសន្តិវិធីក៏តម្រូវឱ្យមានព័ត៌មានលំអិតនៃអត្តសញ្ញាណរបស់ថ្នាក់ដឹកនាំទាំងបីដែលជាតម្រូវការមួយដែលហាក់ដូចជាមិនសមាមាត្រនិងមិនចាំបាច់[149]។ នេះដូចមិនច្បាស់ថាហេតុអ្វីបានជាព័ត៌មានលម្អិតអំពីបុគ្គលចំនួន ៣ នាក់ចាំបាច់ត្រូវទាមទារ សម្រាប់ការជួបប្រជុំតូចៗ អាចមិនពាក់ព័ន្ធឬជាបន្ទុក ដូច្នេះវាជាឧបសគ្គដល់សេរីភាពខាងការជួបប្រជុំ។ លើសពីនេះទៀត ច្បាប់តម្រូវឱ្យមានការជូនដំណឹងជាមុនត្រូវធ្វើយ៉ាងហោចណាស់ប្រាំថ្ងៃនៃថ្ងៃធ្វើការមុនពេលព្រឹត្តិការណ៍កើតឡើង[150]។ ការកំណត់រយៈពេលបែបនេះគឺជាសកម្មភាពនៃការរឹតត្បិតសេរីភាពខាងការជួបប្រជុំដែលរារាំងអ្នករៀបចំក្នុងការទទួលបានការឆ្លើយតបមកលើព្រឹត្តិការណ៍ដែលពួកគេបានរៀបចំ។ខណៈ ដែលច្បាប់ជាតិក្រោមសូចនាករនេះមិនមានការផ្លាស់ប្តូរឡើយនៅក្នុងឆ្នាំទី៥ នេះ ហើយពិន្ទុបានផ្តល់ឱ្យនៅក្នុងកម្រិតពិន្ទុទាប ៣ ការវាយតម្លៃឡើងវិញនូវច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី និងការឆ្លើយតបតាមបទដ្ឋានអន្តរជាតិ។ |

[143] មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[144] មាត្រា៣២៤ និង៣២៧ នៃច្បាប់ស្តីពីសហជីព។

[145] មាត្រា៧៨, ៧៩ និង៨១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា។ មាត្រា៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់។

[146] OSCE-ODIHR and Venice Commission, 'គោលការណ៍ណែនាំអំពីសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី', (បោះពុម្ពលើកទី២ ២០១០), កថាខណ្ឌ១១៥។ <https://www.osce.org/odihr/73405?download=true> គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍លើកទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai' (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣) UN Doc A/HRC/23/39 កថាខណ្ឌ៥២។

[147] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍លើកទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai' (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១២) UN Doc A/HRC/20/27, កថាខណ្ឌ២៩ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf> ។

[148] មាត្រា៦,៧,១០,១៤,២០ និង២៨ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[149] មាត្រា៦ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

[150] មាត្រា៧ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១.២០ ការហាមឃាត់ការប្រមូលផ្តុំត្រូវបានកំណត់ថាជាវិធានការចុងក្រោយចាំបាច់ និងសមាមាត្រទៅនឹងគោលបំណង | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលហាមឃាត់ក្នុងលក្ខខណ្ឌដែលបានកំណត់ថាជាជម្រើសចុងក្រោយសមាមាត្រទៅនឹងគោលបំណង | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ២៥, | ៣ | ៣ | ២,៥ | ២ | ២ | កម្ពុជាពុំបានគោរពចំណុចនេះឱ្យបានពេញលេញ។ មាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចែងនូវលក្ខខណ្ឌចំនួនពីរដែលការជូនដំណឹងពីការប្រមូលផ្តុំអាចត្រូវបានបដិសេធដែលលក្ខខណ្ឌទាំងពីរនោះមានខ្លឹមសារស្រពិចស្រពិល[151]។ សៀវភៅណែនាំការអនុវត្តច្បាប់ស្តីពី ការធ្វើបាតុកម្មដោយសន្តិវិធីកំណត់ពីស្តង់ដារ អនុវត្តលើប្រភេទព័ត៌មានដែលអាចនាំទៅរកការហាមប្រាម ហើយបើមានសំណើដែលមិនស្ថិតក្នុងការហាមប្រាមត្រូវពិភាក្សាជាមុន[152]។ នៅក្នុងផ្នែកទាក់ទងនឹងការណែនាំការអនុវត្តនេះក៏គួសបញ្ជាក់ផងដែរថា ប្រសិនបើអាជ្ញាធរជឿថាមានព័ត៌មានដូចបានបញ្ជាក់ក្នុងមាត្រា៩ (២) អាជ្ញាធរត្រូវ "ពិចារណា និងវាយតម្លៃលើព័ត៌មាននោះដើម្បីកំណត់ថាតើព័ត៌មាននោះមានភស្តុតាងដែរឬយ៉ាងណា" ហើយអាជ្ញាធរត្រូវជូនដំណឹងនិងផ្តល់កិច្ចសហប្រតិបត្តិការតាមការបង្កើត "ដំណោះស្រាយដែលលុបបំបាត់គ្រោះថ្នាក់ដែលអាចកើតឡើង ធ្វើយ៉ាងណាឱ្យបាតុកម្មនោះអាចដំណើរការទៅបាន"[153]។ ផ្ទុយទៅវិញ ប្រសិនបើមានការអនុវត្តតាមមាត្រា៩ (២) នេះក៏ពុំមានបទប្បញ្ញត្តិដើម្បីអាចឱ្យអាជ្ញាធរឆ្លើយតបវិញឡើយ។ ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចដ៏ធំក្នុងការហាមឃាត់ការជួបប្រជុំក្នុងពេលដែលប្រទេសជួបភាពអាសន្នផ្ទុយពីច្បាប់អន្តរជាតិ។ ច្បាប់នេះមិនបានពិចារណាទៅលើពីភាពចាំបាច់ឬសមាមាត្រ ដែលអាចឱ្យអាជ្ញាធរមានសិទ្ធិហាមឃាត់មិនឱ្យមានការជួបប្រជុំ នៅពេលដែលការជួបប្រជុំមិនមែនជាវិធានការចុងក្រោយឬរឹតត្បិតតិចតួចបំផុត។ មាត្រា៤ នៃច្បាប់ស្តីពីកូវីដ-១៩ អនុញ្ញាតឱ្យរដ្ឋាភិបាលមានអំណាចក្នុងការហាមឃាត់បណ្តោះអាសន្ន "ការប្រជុំ និងការប្រមូលផ្តុំមនុស្ស ដែលសកម្មភាពនោះនាំឱ្យមានការរីករាលដាលជំងឺកូវីដ-១៩"។ កង្វះខាតនៃការពន្យល់អំពីមូលហេតុដែលហាមឃាត់ការជួបប្រជុំ ដែលអាចបណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩ គួបផ្សំនឹងអំណាចដែលផ្តល់ឱ្យអាជ្ញាធរក្នុងការហាមឃាត់ការជួបប្រជុំ។ ទោះបីជាវិធានការកាត់បន្ថយការរីករាលដាល ក៏បង្កើតជាលក្ខខណ្ឌហាមឃាត់ការប្រមូលផ្តុំ។[154] បន្ថែមពីនេះ ការហាមឃាត់ព្រះសង្ឃក្នុងការចូលរួមការជួបប្រជុំតាមរយៈសង្ឃប្រកាស គឺមិនសមាមាត្រនិងមិនស្របតាមគោលបំណងស្របច្បាប់នោះទេ។ នេះបង្ហាញថាបទបញ្ញត្តិទាំង២នេះ ទទួលបានពិន្ទុមកត្រឹមតែ ២ ប៉ុណ្ណោះ ។ |
| ១.២១ ការរឹតត្បិតតម្រូវឱ្យមានហេតុផលច្បាស់លាស់និងទាន់ពេលវេលា | កម្រិតនៃ ក្របខ័ណ្ឌច្បាប់តម្រូវឱ្យមានហេតុផលច្បាស់លាស់ទាន់ពេលវេលា ចំពោះការរឹតត្បិតលើការជួបប្រជុំ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣៥, | ៤ | ៤ | ៣ | ២,៥ | ២,៥ | កម្ពុជាបានបំពេញតាមចំណុចនេះបានខ្លះ។ ក្របខ័ណ្ឌច្បាប់ដែលមានស្រាប់តម្រូវឱ្យមានការឆ្លើយតបពីអាជ្ញាធរមកលើការជូនដំណឹងអំពីការជួបប្រជុំ។ ការឆ្លើយតបចាំបាច់ត្រូវប្រាប់ពីមូលហេតុដែលអាជ្ញាធររឹតត្បិត ទោះជាបែបនេះក្តីក៏នៅតែមិនមានចែងជាក់លាក់នោះទេ។ ច្បាប់ជាតិបានសន្មត់ថាបានផ្តល់សិទ្ធិប្រសិនបើមិនទទួលបានការឆ្លើយតបពីការជូនដំណឹងនោះទេ[155]។ នៅក្នុងមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចត្រូវតែឆ្លើយតបនូវលិខិត ជូនដំណឹងយ៉ាងយូរត្រឹម៣ថ្ងៃនៃការងារ ដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានដាក់ជូន។ ប្រសិនបើអាជ្ញា |

[151] មាត្រា ៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ចែងថាអាជ្ញាធរដែនដីរាជធានី ឬខេត្ត មានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមាន ចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែៈ ១) ការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវចំលើថ្ងៃប្រារព្ធព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូក ពិធីបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ២) មានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

[152] ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[153] ផ្នែក៣ មាត្រា ២ មាត្រា៤ មាត្រា៧ នៃសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[154] សូមមើលចំណុចគន្លឹះទី១។

[155] សូមមើលមាត្រា៩ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ធរដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី "មានន័យថាអាជ្ញាធ ដែនដីរាជធានី ឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ"[156]។ លើសពីនេះទៀត ក្នុងករណីដែលចែងនៅក្នុងមាត្រា៩ (២) ប្រសិនបើមិនមានការព្រមពៀងគ្នា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់គត់ដែលជាអ្នកធ្វើសេចក្តីសម្រេចចុងក្រោយ ជាលាយលក្ខណ៍អក្សរនិងយ៉ាងយូរបំផុតម្ភៃបួន (២៤) ម៉ោងមុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី[157]។ សេចក្តីសម្រេចនេះមិនបានអនុញ្ញាតឱ្យមានការតវ៉ា នៅមុខតុលាការមិនលំអៀងដូចមានចែងក្នុងច្បាប់អន្តរជាតិនោះទេ[158]។ ច្បាប់គ្រប់ គ្រងប្រទេសក្នុងភាពអាសន្នខកខានក្នុងការរាប់បញ្ចូលការទទួលខុសត្រូវ ឬតម្លាភាពរបស់អាជ្ញាធរដែលកំណត់ថាតើត្រូវដាក់កម្រិតលើការជួបប្រជុំគ្នាទេច្បាប់មិនតម្រូវឱ្យអាជ្ញាធរផ្តល់ហេតុផលណាមួយ ឡើយ។ មិនខុសពីការពន្យល់ខាងលើច្បាប់កូវីដ-១៩ បានអនុញ្ញាតឱ្យអាជ្ញាធររឹត្បិត "ការប្រជុំ និងការប្រមូលផ្តុំមនុស្សដែលនាំឱ្យមានរីករាលដាលជំងឺកូវីដ-១៩"។ កង្វះខាតនៃការពន្យល់អំពីមូលហេតុដែលហាមឃាត់ការជួបប្រជុំ ដែលអាចបណ្តាលឱ្យមានការរីករាលដាលជំងឺកូវីដ-១៩ ប៉ុន្តែមិនបានផ្តល់មូលហេតុគ្រប់គ្រាន់ពីក្រោយការហាមឃាត់ដោយអាជ្ញាធរនោះទេ។[159]ពិន្ទុនេះត្រូវបានបន្ថយត្រឹម ២ពិន្ទុ។ |
| ១.២២ ការរឹតត្បិតលើពេលវេលា និង ទីកន្លែងមិនមែនជាកាតព្វកិច្ចនោះទេ | កម្រិតនៃច្បាប់ដែលរឹតត្បិតមកលើពេលវេលា និង/ឬទីកន្លែង ត្រូវបានចែងនៅក្នុងក្របខណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | ៣ | ២,៥ | ២,៥ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ មាត្រា៩ (១) នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីការហាមឃាត់ ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីនៅថ្ងៃបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ព្រះរាជពិធីរាជាភិសេកព្រះមហាក្សត្រ ព្រះរាជពិធីបុណ្យអុំទូកបុណ្យឯករាជ្យជាតិ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ការហាមឃាត់ទាំងអស់នេះមិនមាននៅក្នុងគោលបំណងណាមួយដែលមាននៅក្នុងមាត្រា២១ ក.អ.ស.ព.ន ប៉ុន្តែនៅតែអាចធ្វើបាន។ ករណីខ្លះទៀត ការហាមឃាត់ទៅលើការធ្វើបាតុកម្មដោយសន្តិវិធីទាំងអស់នៃថ្ងៃទាំងនោះ មិនបំពេញតាមតម្រូវការចាំបាច់និងសមាមាត្រនៃផ្នែកទី ៣ នៃលក្ខខណ្ឌទាំងបីចំណុច វាអាចមានការជំទាស់គំនិតគ្នាក្នុងការពិចារណាអំពីកាលៈទេសៈជាក់លាក់នៃការប្រមូលផ្តុំនីមួយៗហើយដូច្នេះនឹងមានវិសមភាពនិងការរើសអើង (វាប៉ះពាល់ដល់ពលរដ្ឋដែលមានបំណងអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំ)[160]។ អំណាចក្នុងការរឹតត្បិតនិងហាមឃាត់ការជួបប្រជុំទាំងអស់នេះដែលមានចែងក្នុងមាត្រា៥ (២) នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន អាចដំណើរការជារបាំង ក្នុងការហាមឃាត់ការជួបប្រជុំទាំងអស់ក្នុងពេលមានអាសន្ន។ ពាក្យពេចន៍នៃច្បាប់នេះមានលក្ខណៈទូលំទូលាយនិង ត្រូវបានគេមើលឃើញថារាល់ការជួបប្រជុំមួយចំនួនឬទាំងអស់អាចត្រូវបានហាមឃាត់ដោយសេរីនៅក្នុងមាត្រា៥ (២)។ ស្រដៀង |

[156] មាត្រា១០ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[157] មាត្រា១២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[158] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម ,Maina Kiai,' UN Doc. A/HRC/២០/២៧, (ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១) , កថាខណ្ឌ ៤២ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session20/A-HRC-20-27_en.pdf>

[159] មាត្រា១២ នៃច្បាប់ស្តីកូវីដ-១៩។

[160] គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'របាយការណ៍រួមគ្នារបស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម និងការដោះស្រាយក្រៅប្រព័ន្ធច្បាប់ដោយ សង្ខេប ឬតាមទំនើងចិត្តដើម្បីគ្រប់គ្រងការប្រមូលផ្តុំ, ( ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦( , UN Doc. A/HRC/៣១/៦៦ កថាខណ្ឌ៣០។ សូមអានគណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ, 'របាយការណ៍ជុំទី២របស់អ្នករាយការណ៍ពិសេសលើការជួបប្រជុំដោយសន្តិវិធី និងសមាគម Maina Kiai,' UN Doc. A/HRC/២៣/៣៩, ( ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣, កថាខណ្ឌ៦៣ <https://www.ohchr.org/Documents/HRBodies/HRCouncil/RegularSession/Session23/A.HRC.23.39_EN.pdf>

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | គ្មានេះ មាត្រា៤ នៃច្បាប់កូវីដ-១៩ ផ្តល់ឱ្យអាជ្ញាធរនូវ "អំណាចបណ្ដោះអាសន្ន" ក្នុងការហាមឃាត់ការជួបប្រជុំដែលអាចបណ្ដាលឱ្យមានការរីករាលដាលកូវីដ-១៩ ហាក់ដូចជាអនុញ្ញាតឱ្យមានការហាមឃាត់ដាច់ខាត ប៉ុន្តែមិនបានកំណត់ជាក់លាក់អំពីពេលណាដែលការហាមឃាត់នេះនឹងត្រូវបញ្ចប់នោះទេ។ ហើយនេះ អាជ្ញាធរអាចហាមឃាត់ការជួបប្រជុំគ្នាដោយប្រើរយៈពេលយូរតាមទំនើងចិត្ត។[161] ពិន្ទុនេះត្រូវបានធ្លាក់មកត្រឹម ២,៥ ។ |
| ១.២៣<br>ការជួបប្រជុំស្រប ពេលគ្នានៅទីតាំង និងពេលវេលាតែមួយ ត្រូវបានអនុញ្ញាត | កម្រិតនៃ ក្របខណ្ឌច្បាប់ដែល អនុញ្ញាតឱ្យមានការជួបប្រជុំ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ គ្មានច្បាប់ការហាមឃាត់ទៅលើការជួបប្រជុំដែលបានធ្វើក្នុងពេលជាមួយគ្នានោះទេ។ មាត្រា១៤ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបានចែងថា ការធ្វើបាតុកម្មដោយសន្តិវិធីមានពីរក្រុមផ្សេងគ្នាហើយធ្វើនៅកន្លែងតែមួយនិងពេលវេលាតែមួយ អាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចត្រូវសម្រេចឱ្យក្រុមអ្នកដែលបានដាក់សេចក្តីជូនដំណឹងមុនទទួលបានសិទ្ធិធ្វើមុន ឬអាចអនុញ្ញាតឱ្យធ្វើនៅកន្លែងមួយផ្សេងទៀតដែលមានចម្ងាយយ៉ាងតិចប្រាំរយ (៥០០) ម៉ែត្រពីគ្នា។ ការផ្តល់ជូននេះគឺជាផ្នែកមួយនៃមាត្រា១៤ ដែលទាក់ទងនឹងករណីបាតុកម្មជាក់ស្តែងនៅ "កន្លែងមញ្ញមតិជាសាធារណៈ" ឬនៅកន្លែងឯកជន។ ប៉ុន្តែ នៅក្នុងផ្នែកទី២ នៃមាត្រា២.៤.៥ នៃការណែនាំការអនុវត្តបានបង្ហាញច្បាស់លាស់ថាអាជ្ញាធរគួរតែ "ប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងដ៏ល្អបំផុតរបស់ពួកគេ" ដើម្បីធានាថាក្រុមដែលចង់ធ្វើបាតុកម្មទាំងអស់អាចធ្វើបាតុកម្មបាន "ក្នុងកម្រិតដែលអាចធ្វើទៅបាន" ដែលពួកគេអាចធ្វើដូច្នោះក្នុងលក្ខណៈ ពេលវេលា និងទីតាំងដែលពួកគេបានស្នើសុំ។ |
| ១.២៤<br>នីតិវិធីប្តឹងជំទាស់ មុនពេលមាន ស្ថាប័នឯករាជ្យ និងមិនលម្អៀងត្រូវបានបង្កើតឡើងសម្រាប់ការដាក់កំហិតលើការប្រមូលផ្តុំ | កម្រិតនៃនីតិវិធីជំទាស់ដែលត្រូវបាន កំណត់នៅក្នុងក្របខណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br>ឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ២,៥ | ២,៥ | ២,៥ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ នៅក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី អាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចត្រូវតែឆ្លើយតបទៅនឹងលិខិតជូនដំណឹងយ៉ាងយូរត្រឹមបី (៣)ថ្ងៃនៃថ្ងៃការងារដោយគិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងត្រូវបានគេដាក់ជូន[162]។ អាជ្ញាធរដែនដី រាជធានីឬខេត្តមានសមត្ថកិច្ចខកខានក្នុងការឆ្លើយតបរហូតដល់ពេលកំណត់ដែលនឹងត្រូវធ្វើបាតុកម្មដោយសន្តិវិធី "មានន័យថាអាជ្ញាធរដែនដីរាជធានីឬខេត្តមានសមត្ថកិច្ចបានព្រមព្រៀងហើយ"[163]។ បើកន្លែងណាមានព័ត៌មានច្បាស់ថាការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ អាជ្ញាធរដែនដីរាជធានីឬខេត្តត្រូវតែជូនដំណឹងទៅអ្នករៀបចំកម្មវិធី"ភ្លាមៗ" ហើយមានរយៈពេលបីថ្ងៃដើម្បីជួបជាមួយអ្នកដឹកនាំបាតុកម្មដើម្បីឈានទៅរកកិច្ចព្រមព្រៀងមួយ។ បើសិនមិនមានការព្រមព្រៀងគ្នានោះទេ មាត្រា១២ បានចែងថារដ្ឋមន្ត្រីក្រសួងមហាផ្ទៃនឹងជាបុគ្គលម្នាក់ដែលជាអ្នកសម្រេចចុងក្រោយជាលាយលក្ខណ៍អក្សរនិងយ៉ាងយូរបំផុតម្ភៃបួនម៉ោង (២៤) មុនពេលកំណត់នៃការធ្វើបាតុកម្មដោយសន្តិវិធី ប៉ុន្តែមិនអាចត្រូវបានចាត់ទុកថាជា "ស្ថាប័នឯករាជ្យ និងមិនលំអៀងឡើយ"។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គឺជាសមាជិកនៃអង្គនីតិប្រតិបត្តិមិនមែនជា "ស្ថាប័នឯករាជ្យ"។ មិនអាចប្តឹងទៅស្ថាប័នតុលាការបន្ថែមទៀតបានទេ។ ដូច្នេះមិនមាននីតិវិធីបណ្តឹងឧបាស្រ័យឯក |

[161] សូមមើលចំណុចគន្លឹះទី១។

[162] មាត្រា១២ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[163] មាត្រា១០ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | រាជ្យឬមិនលំអៀងត្រូវបានកំណត់ដោយច្បាប់ទេ។ នៅលើការវាយតម្លៃឡើងវិញនៃចំណុចនេះពិន្ទុនេះត្រូវបានទម្លាក់មកត្រឹម ២,៥ ។ លើសពីនេះទៅទៀតច្បាប់ស្តីពីកូវីដ-១៩ មិនមាននីតិវិធីបណ្តឹងឧបាស្រ័យណាមួយត្រូវបានផ្តល់មកលើការដាក់កម្រិតការជួបប្រជុំទេ ចំណុចនេះមិនច្បាស់ថាតើនីតិវិធីបណ្តឹងឧបាស្រ័យធម្មតាក្រោមច្បាប់បាតុកម្មដោយសន្តិវិធីឬយ៉ាងណា[164]។ |
| ១.២៥ អ្នករៀបចំមិនប្រឈមនឹងទោសព្រហ្មទណ្ឌ ឬទណ្ឌកម្ម រដ្ឋបាលការខកខានមិនបានជូនដំណឹងដល់អាជ្ញាធរ | កម្រិតនៃ ក្របខ័ណ្ឌច្បាប់ដែលកំណត់អំពីការដាក់ទោសព្រហ្មទណ្ឌនិង/ឬ រដ្ឋបាលចំពោះអ្នករៀបចំដែលខកខានមិនបានជូនដំណឹងអាជ្ញាធរ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | កម្ពុជាមិនបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ផ្តល់នូវការព្រមានដល់អ្នករៀបចំបាតុកម្មដែលមិនផ្តល់នូវការជូនដំណឹង[165]។ ច្បាប់ស្តីពីសហជីពនិងច្បាប់ស្តីពីការងារបានចែងថាការធ្វើកូដកម្មដែលមិនស្របតាមបទប្បញ្ញត្តិរបស់ខ្លួនរួមទាំងតម្រូវឱ្យជូនដំណឹងជាមុនត្រូវចាត់ទុកថាខុសច្បាប់[166]។ ប៉ុន្តែមានតែស្ថាប័នតុលាការតែមួយគត់អាចកំណត់ពីភាពស្របច្បាប់និងមិនស្របច្បាប់នៃការធ្វើកូដកម្ម[167]។ យ៉ាងណាក៏ដោយ ច្បាប់ស្តីពីសហជីពចែងថា ប្រសិនបើអ្នកធ្វើកូដករបន្តធ្វើកូដកម្ម ត្រូវបានតុលាការការងារប្រកាសថាខុសច្បាប់និងមិនបានអនុវត្តតាមការព្រមាន ពួកគេនឹងត្រូវទទួលរងការផាកពិន័យជាអន្តរការណ៍ ជាទឹកប្រាក់មិនលើសពី៥លានរៀល (ប្រមាណ ១២៥០ ដុល្លាសហរដ្ឋអាមេរិក)[168]។ នៅពេលដែលការពិន័យគឺជាជម្រើសចុងក្រោយទៅតាមការព្រមានពីរបី ដង ចំនួនការផាកពិន័យបង្កើតឱ្យមានការដាក់កំហិតដោយមិនសមហេតុផលទៅលើសិទ្ធិសេរីភាពកម្មករ ក្នុងការប្រើប្រាស់សេរីភាពខាងសមាគម។ |
| ១.២៦ នគរបាលមានកាតព្វកិច្ចសម្របសម្រួលដល់ការជួបប្រជុំដោយសន្តិវិធី | កម្រិតនៃអនុវត្តច្បាប់និងគោលនយោបាយ គាំទ្រដល់ ការជួបប្រជុំដោយសន្តិវិធី | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថា អាជ្ញាធរដែនដីរាជធានីឬខេត្ត មានសមត្ថកិច្ចគួរតែទទួលខុសត្រូវក្នុងការការពារនៅបាតុកម្មដោយសន្តិវិធី និងមិនជ្រៀតជ្រែកនៅការធ្វើបាតុកម្មដោយសន្តិវិធីនេះ[169]។ អាជ្ញាធរមានសមត្ថកិច្ចឆ្លើយតបទៅនឹងសំណើសម្រាប់ជំនួយដល់អ្នករៀបចំបាតុកម្មដើម្បីធានាថា "សិទ្ធិសេរីភាពក្នុងការធ្វើបាតុកម្មដោយសន្តិវិធីនិងការអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈរបស់ពួកគេដោយមានសេចក្តីថ្លៃថ្នូរ"[170]។ ក្នុងករណីមានអំពើហិង្សា សេចក្តីណែនាំឱ្យមានការអនុវត្តចែងយ៉ាងច្បាស់ថាបាតុកម្មអាចត្រូវបានបំបែកនៅពេលដែលគ្មានជម្រើសផ្សេងទៀត[171] បន្ថែមទៀតថារាល់សកម្មភាពរបស់នគរបាលត្រូវតែមានសមាមាត្រទៅនឹងស្ថានភាព ហើយត្រូវបានប្រើក្នុងករណីចាំបាច់[172]។ |
| ១.២៧ អ្នករៀបចំការប្រមូលផ្តុំមិនទទួលខុសត្រូវលើបន្ទុកហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាសាធាណៈ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលការពារអ្នករៀបចំមិនឱ្យទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះការផ្តល់សេវាសាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៥ | ៥ | ៥ | ៥ | ៥ | ៥ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីមិនបានចែងថា អ្នករៀបចំបាតុកម្មគឺទទួលខុសត្រូវចំពោះការគិតថ្លៃផ្នែកហិរញ្ញវត្ថុសម្រាប់ការផ្តល់សេវាសាធារណៈនោះទេ។ |

[164] មាត្រា៥(២) នៃច្បាប់ស្តីពីគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។ មាត្រា ៤ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

[165] មាត្រា២១ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, សូមមើលផ្នែកទី៣ មាត្រា៤-៤-១ នៃសេចក្តីណែនាំឱ្យអនុវត្ត។

[166] មាត្រា៩២ នៃច្បាប់ស្តីពីសហជីព។

[167] មាត្រា៣៣៧ នៃច្បាប់ស្តីពីការងារ។

[168] មាត្រា៩២ នៃច្បាប់ស្តីពីសហជីព។

[169] មាត្រា១៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[170] មាត្រា១៨ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។

[171] ផ្នែកទី២ នៃចំនុច ៣.៦.៤ នៃសៀវភៅណែនាំការអនុវត្ត។

[172] ផ្នែកទី២ នៃចំនុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១.២៨ អ្នករៀបចំការប្រមូលផ្តុំ និងអ្នកចូលរួមមិនទទួលខុសត្រូវចំពោះ ទង្វើខុសច្បាប់របស់អ្នកដទៃ ឬចំពោះការថែរក្សាសណ្តាប់ធ្នាប់សាធារណៈឡើយ | កម្រិតនៃក្របខ័ណ្ឌច្បាប់ដែលអ្នករៀបចំ និងអ្នកចូលរួមមានទំនួលខុសត្រូវផ្លូវច្បាប់ចំពោះទង្វើខុសច្បាប់របស់អ្នកដទៃនិង/ឬ ចំពោះការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ អ្នករៀបចំការជួបជុំមិនត្រូវមានទំនួលខុសត្រូវចំពោះការខូចខាតទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍មួយដែលបានប្រែជាអំពើហិង្សានោះឡើយ។ ក្នុងករណីមានការប្រជុំដោយសន្តិវិធីប្រែជាហិង្សាដូចដែលមានចែងក្នុងមាត្រា២០ (២) នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី អ្នករៀបបាតុកម្ម ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរ។ មាត្រា ២៣ ដល់ ២៧ ចែងទាក់ទងនឹងការកាន់អាវុធ ឬសារធាតុគ្រោះថ្នាក់ ការខូចខាតទ្រព្យសម្បត្តិឯកជនឬសាធារណៈអំពើហិង្សាដែលបណ្តាលឱ្យមានរបួសឬស្លាប់។ ក្នុងករណីទាំងអស់នេះច្បាប់ចែងយ៉ាងច្បាស់ថា បុគ្គលដែលជាអ្នកធ្វើសកម្មភាពនោះជាអ្នកត្រូវទទួលខុសត្រូវ។ នេះមិនអាចចាត់ទុកថាជាការទទួលខុសត្រូវរបស់អ្នករៀបចំនិងអ្នកចូលរួមដទៃទៀតនោះទេ។ |
| ១.២៩ ការប្រើប្រាស់កម្លាំងរបស់រដ្ឋអាចធ្វើទៅបានលុះត្រាតែចាំបាច់ដើម្បីគ្រប់គ្រង ស្ថានភាពក្នុងលក្ខណៈសមហេតុផល និងសមាមាត្រ | កម្រិតនៃក្របខ័ណ្ឌច្បាប់កំណត់ពីការប្រើប្រាស់កងកម្លាំងរបស់រដ្ឋនៅក្នុងស្ថានភាពដែលចាំបាច់ដើម្បីគ្រប់គ្រងស្ថានភាពក្នុងលក្ខណៈសមហេតុផល និងសមាមាត្រ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៤ | ៤ | ៤ | ៤ | ៤ | ៤ | កម្ពុជាបានបំពេញតាមចំណុចនេះ។ ប្រសិនបើការជួបប្រជុំដោយសន្តិវិធីប្រែជាហិង្សាអាជ្ញាធរត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់និងបញ្ឈប់ការធ្វើបាតុកម្មភ្លាមៗ[173]។ មាត្រា ២៣-២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីបង្ហាញពីរបៀបដែលអាជ្ញាធរគួរតែឆ្លើយតបប្រសិនបើបាតុកម្មប្រែទៅជាអំពើហិង្សាឬបាតុករប្រព្រឹត្តិបទឧក្រិដ្ឋ។ ការឆ្លើយតបរួមមានការរឹបអូសយកអាវុធ ផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌ។ ការអន្តរាគមន៍ណាមួយរបស់ប៉ូលីសត្រូវតែសមាមាត្រទៅនឹងស្ថានភាព ហើយត្រូវបានប្រើតែក្នុងកម្រិតចាំបាច់ដើម្បីស្តារសណ្តាប់ធ្នាប់ភ្លាមៗ[174]។ លើសពីនេះទៅទៀតច្បាប់មិនបានចែងពីការប្រើប្រាស់កម្លាំងដោយអាជ្ញាធរទេ ទោះបីជាមិនបានហាមឃាត់យ៉ាងច្បាស់ក៏ដោយ។ |
| ១.៣០ ប្រព័ន្ធកត់ត្រាការប្រាស្រ័យទាក់ទងដើម្បីឃ្លាំមើល បញ្ហាអ្នកទទួលខុសត្រូវលើការបញ្ជា និងអ្នកអនុវត្តបញ្ជាជាកាតព្វកិច្ច | កម្រិតនៃ ប្រព័ន្ធកត់ត្រាការប្រាស្រ័យទាក់ទងត្រូវបានបង្កើតឡើងដោយក្របខ័ណ្ឌច្បាប់ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ២ | ២ | ២ | ២ | ២ | ២ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី មិនចែងពីប្រព័ន្ធកំណត់ត្រាការប្រាស្រ័យទាក់ទងនោះទេ តែមាត្រា ១៩ ចែងថា "អាជ្ញាធរ ដែលត្រូវបានចាត់ឱ្យរក្សាសន្តិសុខសុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈនៅកន្លែងបាតុកម្មប្រជុំដោយសន្តិវិធី ត្រូវពាក់ឯកសណ្ឋានឱ្យបានត្រឹមត្រូវ ព្រមទាំងមានស្លាកឈ្មោះនិងអត្តលេខសម្គាល់ខ្លួននៅផ្នែកខាងមុខ ដែលលើកកម្ពស់គណនេយ្យភាពនិងសម្របសម្រួលការកំណត់អត្តសញ្ញាណអ្នកធ្វើខុស"។ |
| ១.៣១ ក្របខ័ណ្ឌច្បាប់ទាក់ទងនឹងកូដកម្មស្របតាមស្តង់ដារអន្តរជាតិ | កម្រិតក្របខ័ណ្ឌច្បាប់ទាក់ទងនឹងកូដកម្មស្របតាមស្តង់ដារអន្តរជាតិ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៣ | ៣ | ៣ | កម្ពុជាមិនបានបំពេញតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិសម្រាប់កូដកម្មនោះទេ។ រដ្ឋធម្មនុញ្ញចែងពីសិទ្ធិធ្វើបាតុកម្មនៅមាត្រា ៣៧ មាត្រា ៤១ និង ៤២ និងបន្តការពារសិទ្ធិជួបប្រជុំនិងសិទ្ធិចូលរួម "ក្នុងអង្គការមហាជន" ដែលទាំងពីរនេះការពារដល់សិទ្ធិធ្វើកូដកម្ម។ ទោះយ៉ាងណាជំពូកទី៣ នៃរដ្ឋធម្មនុញ្ញអនុវត្តតែចំពោះ "ប្រជាពលរដ្ឋខ្មែរ" ជំនួសឱ្យសិទ្ធិទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ប្រទេសកម្ពុជា។ ដូចនេះការការពារសិទ្ធិធ្វើកូដកម្មនៅក្នុងរដ្ឋធម្មនុញ្ញគឺមិនគ្រប់គ្រាន់ទេសម្រាប់ពលរដ្ឋដែលមិនមែនជាពលរដ្ឋរស់នៅក្នុងប្រទេសកម្ពុជាដូចជាជនចំណាកស្រុកនិងជនភៀសខ្លួនជាដើម។ សិទ្ធិធ្វើកូដកម្មក្នុងជំពូកទី១៣ នៃច្បាប់ស្តីពីការងារ[175] មាត្រា៣២០ បានចែងថាសិទ្ធិក្នុងការធ្វើកូដកម្ម "អាចអនុវត្តក្នុងលក្ខណៈទូទៅដើម្បីការពារផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គមរបស់កម្ម |

[173] មាត្រា២០(២) ២៣ ដល់២៧ នៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី
[174] ចំនុច ៣.៦.៥ នៃសៀវភៅណែនាំការអនុវត្ត
[175] មាត្រា ៣១៩ នៃច្បាប់ស្តីពីការងារ។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ករ”[176] ទោះយ៉ាងណាមាត្រា៣២៤ តម្រូវឱ្យ មានកូដកម្មជាច្រើនរួមទាំងការជូនដំណឹងជាមុន ៧ ថ្ងៃនៃថ្ងៃធ្វើការដល់សហគ្រាស ឬគ្រឹះស្ថានសមាគមនិយោជកដែលដូចគ្នានឹងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ការជូនដំណឹងមុនត្រូវបានបន្ថែមរហូតដល់១៥ថ្ងៃ នៃថ្ងៃធ្វើការតាមរយៈមាត្រា៣២៧ ក្នុងករណីដែលកូដកម្ម នោះប៉ះពាល់ដល់ផ្នែកសំខាន់ៗ។ ការជូនដំណឹងមុនត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់នូវការទាមទារដែលជាមូលហេតុ នៃកូដកម្ម។ ខណៈពេលដែលនីតិវិធីនៃការជូនដំណឹងជាមុនមិនមានការរំលោភបំពានដោយផ្ទាល់ នៃស្តង់ដារអន្តរជាតិ រយៈពេលនៃការជូនដំណឹងមិនមែនជាហេតុផលសមរម្យនោះទេ[177]។គណៈកម្មាធិការខាងសេរីភាពខាងសមាគមបានកំណត់ថាការជូនដំណឹងជាមុន ៤៨ ម៉ោងគឺសមហេតុផលដូចជាការជូនដំណឹងជាមុន ២០ ថ្ងៃ សម្រាប់សេវាកម្មផលប្រយោជន៍សាធារណៈ[178]។ ព័ត៌មានដែលបានស្នើសុំនៅក្នុងសេចក្តីជូនដំណឹងស្តីពីកូដកម្មគួរតែសមហេតុផលឬបកស្រាយក្នុងលក្ខណៈសមហេតុផលហើយការកាត់សេចក្តីជាលទ្ធផលមិនគួរត្រូវបានប្រើក្នុងលក្ខណៈដូចជាដើម្បីបង្ហាញសកម្មភាពសហជីពស្របច្បាប់ដែលស្ទើរតែមិនអាចធ្វើអ្វីបាននោះទេ[179]។ ដូច្នេះការជូនដំណឹងជាមុនដែលមានចែងក្នុងច្បាប់ស្តីពីការងារនឹងរំលោភលើស្តង់ដារអន្តរជាតិប្រសិនបើត្រូវអនុវត្តតាមទាំងបំពាន។ លើសពីនេះទៅទៀត នៅពេលដែលស្តង់ដារអន្តរជាតិអនុញ្ញាតឱ្យមានសិទ្ធិធ្វើកូដកម្ម ការកំណត់បែបនេះអាចទទួលយកបានលុះត្រាតែការពឹងផ្អែកលើអាជ្ញាកណ្តាលមិនមានកាតព្វកិច្ចហើយក្នុងករណីដែលការកំណត់នេះមិនអនុវត្តជាក់ស្តែងរារាំងការអំពាវនាវឱ្យធ្វើកូដកម្ម[180]។ មាត្រា៣២០ នៃច្បាប់ស្តីពីការងារកម្រិតលើសិទ្ធិក្នុងការធ្វើកូដកម្មនៅស្ថានភាព ដែល “រាល់វិធីសាស្ត្រដោះស្រាយដោយសន្តិវិធីប្រើប្រាស់ក្នុងការដោះស្រាយវិវាទជាមួយនិយោជក”។ បទប្បញ្ញត្តិនេះមិនអនុលោមតាមស្តង់ដារអន្តរជាតិដែលថាការចូលរួមក្នុងការដោះស្រាយវិវាទ គួរតែជាការស្ម័គ្រចិត្ត។ បទប្បញ្ញត្តិនេះមិនបានអនុលោមតាមតាមស្តង់ដារអន្តរជាតិ ដែលការចូលរួមក្នុងការដោះស្រាយវិវាទគួរតែជាការស្ម័គ្រចិត្ត។ លើសពីនេះទៀតដោយកំណត់សិទ្ធិធ្វើកូដកម្មទៅនឹងស្ថានភាពដែលវិធីសាស្ត្រទាំងអស់ត្រូវបានប្រើប្រាស់ ដោយសន្តិវិធីច្បាប់ការងារមិនអនុលោមតាមស្តង់ដារអន្តរជាតិនោះទេ។ វាបង្កើតការរឹតត្បិតទូលំទូលាយទៅវិញ[181]។ លើសពីនេះទៀតមាត្រា ១៣ នៃច្បាប់សហជីពបានចែងថាលក្ខន្តិកៈសហជីពទាំងអស់រួមមាន “លក្ខន្តិកៈដែលសន្លឹកឆ្នោតសំងាត់ត្រូវបានបោះឆ្នោតដោយយ៉ាងហោចណាស់៥០ភាគរយបូក១នៃសមាជិកសរុបដែលចូលរួមក្នុងការប្រជុំធ្វើសេចក្តីសម្រេចចិត្តធ្វើកូដកម្ម”។ ហើយនេះជាការរឹតត្បិតហួសហេតុ ដែលជាចំនួនកំណត់សិទ្ធិធ្វើកូដកម្មបានបន្ថយការការពារកូដកម្មនៅកម្ពុជា។ |

[176] មាត្រា ៣២០ នៃច្បាប់ស្តីពីការងារ។

[177] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចរួមរបស់គណកម្មការធិការខាងសេរីភាពខាងសមាគម (បោះពុម្ពលើទី៦ការិយាល័យពលកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ២០១៨) កថាខណ្ឌ៧៩៩ , “កាតព្វកិច្ចផ្តល់ការជូនដំណឹងមុនទៅនិយោជកមុនពេលរៀបចំកូដកម្មត្រូវបានពិចារណានិងទទួលយករហូតដល់មានហេតុផលសមរម្យ”។

[178] ដូចខាងលើ កថាខណ្ឌ៨០០ និង៨០១។

[179] ដូចខាងលើ កថាខណ្ឌ៨០៣។

[180] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចរួមរបស់គណកម្មការធិការខាងសេរីភាពខាងសមាគម ( ឆ្នាំ២០១៨) កថាខណ្ឌ៧៩៣។

[181] អង្គការពលកម្មអន្តរជាតិ, សេរីភាពខាងសមាគម: សេចក្តីសម្រេចនិងគោលការណ៍របស់គណៈកម្មាធិការខាងសេរីភាពខាងសមាគមនៃគណៈ អង្គការពលកម្មអន្តរជាតិ។ ( បោះពុម្ពលើទី៥ការិយាល័យពលកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ ឆ្នាំ២០០៦) កថាខណ្ឌ៥៤៧។

| សេរីភាពខាងការបញ្ចេញមតិ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១.៣២ ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចយោងតាមមាត្រា ១៩ នៃ កន.ព.ស.អ. | កម្រិតនៃ ច្បាប់ដែលប៉ះពាល់សេរីភាព ខាងការបញ្ចេញមតិ ផ្អែកតាមលក្ខខណ្ឌ ៣ ចំណុចពី មាត្រា ១៩ នៃ ក.អ.ស.ព.ន | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | ១ | ច្បាប់សំខាន់ៗរបស់កម្ពុជាបានរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិដែលមិនអនុលោមទៅតាមលក្ខខណ្ឌបីចំណុចនៃមាត្រា១៩ នៃកន.ព.ស.អ.។ ដូច្នេះកម្ពុជាពុំបានបំពេញសូចនាករមួយនេះឡើយ[182]។ ជាពិសេស ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ ការប្រមាថ ញុះញង់ និងកាលពីខែកុម្ភៈ ឆ្នាំ ២០១៨ នៅបទល្មើសប្រមាថអង្គព្រះមហាក្សត្រ) ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ច្បាប់ស្តីពីទូរគមនាគមន៍ ច្បាប់ស្តីពីការអប់រំ ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសារព័ត៌មាន និងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ២០១៨ ដែលមិនអនុលោមតាមលក្ខខណ្ឌបីចំនុចនៃមាត្រា១៩ (៣) នៃ ក.អ.ស.ព.ន[183]។ លើសពីនេះទៀត ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និង បណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអិនធឺណិតរឹតត្បិតលើសិទ្ធិសេរីភាពបញ្ចេញមតិ។ ការហាមឃាត់នៅក្នុងប្រកាសអន្តរក្រសួងគឺមានលក្ខណៈទូលំទូលាយពេកនិងមិនច្បាស់លាស់សម្រាប់ប្រជាពលរដ្ឋដើម្បីកំណត់ថាតើខ្លឹមសារណាមួយដែលអនុញ្ញាតឬមិនអនុញ្ញាត។ លើសពីនេះទៅទៀតគោលបំណងនៃប្រកាសនេះមិនបានការពារសិទ្ធិនិងកេរ្តិ៍ឈ្មោះរបស់នរណាម្នាក់ឡើយឬដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈឬសុខភាពសាធារណៈនិងសីលធម៌។ ចុងក្រោយមានការផ្តន្ទាទោសសម្រាប់ការផ្សព្វផ្សាយរួមមានបិទគេហទំព័រនិងចំណាត់ការផ្លូវច្បាប់ចំពោះបុគ្គលនិងនីតិបុគ្គល[184]។ ការផ្តន្ទាទោសទាំងនេះមិនមែនជាមធ្យោបាយរឹតត្បិតដែលចាំបាច់ដើម្បីសម្រេចបាននូវគោលបំណងនៃប្រកាសនេះ[185]។មាត្រា៥ (១១)នៃច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចទៅរាជរដ្ឋាភិបាលក្នុងការហាមឃាត់ការនិយាយស្តីឬបញ្ចេញមតិដែលនាំឱ្យមាន "ភ័យស្លន់ស្លោឬវឹកវរឬនាំឱ្យខូចខាតដល់សន្តិសុខជាតិ" ឬអាច "បង្កការភាន់ច្រឡំ" ក្នុងចំណោមសាធារណជន។ ប្រភេទនៃការនិយាយទាំងនេះគឺមិនច្បាស់លាស់គ្មានការកំណត់និងរំលោភបំពាន។ ស្ទើរតែគ្រប់ប្រភេទនៃការបញ្ចេញមតិអំពីស្ថានភាពអាសន្ន អាចត្រូវបានបកស្រាយថាជា "បង្កឱ្យមានការភ័ន្តច្រឡំ"។ ការហាមឃាត់រាល់និយាយដែលអាចបង្ក "ភាពច្របូកច្របល់" ឬ "ភាពវឹកវរ" មិនអាចត្រូវបានគេចាត់ទុកថាចាំបាច់នៅក្នុងភាពអាសន្នណាមួយឡើយ។ មាត្រា ៥ (១១) ដូច្នេះច្បាប់នេះនឹងស្របនឹងគោលការណ៍ សមាមាត្រ |

[182] មាត្រា២(១) នៃក.អ.ស.ព.ន តម្រូវឱ្យរដ្ឋភាគី ការគោរពនិងដើម្បីធានាដល់បុគ្គលទាំងអស់នៅក្នុងទឹកដីនិងក្រោមយុត្តាធិការរបស់ខ្លួននូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ។ លើសពីនេះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្ងៃទី១០ខែកក្កដាឆ្នាំ ២០០៧ បានបកស្រាយមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញថាសន្ធិសញ្ញាអន្តរជាតិដែលបានផ្តល់សច្ចាប័នដោយកម្ពុជារួមមានអ.ស.ព.ន ត្រូវបានអនុវត្តនៅក្នុងច្បាប់ជាតិ។ សូមមើលសេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

[183] សូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី១ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែសីហា ឆ្នាំ២០១៧) ទំព័រ ៧-៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf និងសូមអានសូមមើល "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖
https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

[184] សូមអាន អាយ. ស៊ី .អិន.អិល "ការវិភាគប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត" ខែកក្កដា ឆ្នាំ២០១៨ ដែលអាចរកបាន៖ http://sithi.org/judicial/docs/ICNL-Analysis-Prakas-on-Websites-and-Social-Media_July-2018.pdf ។

[185] ដូចខាងលើ។ ទំព័រ៥ ដល់ទី៨ ។

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | នៃ ក.អ.ស.ព.ន ឡើយ។ មាត្រា ១ នៃ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ អនុញ្ញាតឱ្យបង្កើតរចនាសម្ព័ន្ធ ដែលអាចនាំឱ្យមានការរំលោភបំពានឯកជនភាព និងសេរីភាពខាងការបញ្ចេញមតិ។ មាត្រា១៨ដែលមិនមានភាពច្បាស់លាស់ ដែលអនុញ្ញាតការរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ មិនមានគោលបំណងស្របច្បាប់និងមិនសមាមាត្រ។ មាត្រា៦ នៃអនុក្រឹត្យនេះបានអនុញ្ញាតឱ្យអាជ្ញាធរអាចតាមដានទំនាក់ទំនងតាមអនឡាញ ក្នុងករណីមានការសង្ស័យថាមាតិកានោះអាច "ប៉ះពាល់ដល់សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ភាពថ្លៃថ្នូរវប្បធម៌ ទំនៀមទំលាប់ប្រពៃណី"។ ការអនុញ្ញាតឱ្យមានការរាំងខ្ទប់មាតិកាប្រឆាំងនឹងគោលដៅ ដែលមិនបានកំណត់ជាក់លាក់ ដែលលើសពីភាពចាំបាច់។ ការរឹតត្បិតមកលើសេរីភាពខាងការបញ្ចេញមតិក្រោមអនុក្រឹត្យនេះ មិនបានអនុវត្តតាមលក្ខខណ្ឌ៣ចំណុចនៃ ក.អ.ស.ន.ពនោះទេ។ [186] |
| ១.៣៣ ការនិយាយបង្ខូចកេរ្តិ៍មិនត្រូវមានទោស ព្រហ្មទណ្ឌទេ | កម្រិតនៃការបង្ខូចកេរ្តិ៍មិនត្រូវជាប់ទោស ព្រហ្មទណ្ឌទេ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមាន ចម្លើយ | ២ | ២ | ២ | ១ | ១ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ ដូចមាត្រា៣០៥ និង៣០៧ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានបទបរិហារកេរ្តិ៍និងការប្រមាថ។ ការបរិហារកេរ្តិ៍ត្រូវបានកំណត់ថា គ្រប់ការអះអាងបំផ្លើសឬ ទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គលឬស្ថាប័ន។ ការប្រមាថមានន័យថាពាក្យមើលងាយឬគ្រប់ពាក្យត្រគោះដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយគឺជាការប្រមាថ។ ការដាក់ទោសនៃការបរិហារកេរ្តិ៍នៅក្នុងច្បាប់ជាតិគឺមានបញ្ហាពីព្រោះនិយមន័យមិនច្បាស់លាស់ដោយមិនតម្រូវចាំឱ្យមានគ្រោះថ្នាក់ណាមួយកើតឡើងឡើយ។ ការដាក់ទោសនេះមិនបានការពារអំពីការពិតឬផលប្រយោជន៍សាធារណៈតម្រូវដោយច្បាប់និងបទដ្ឋានអន្តរជាតិនោះដែរ[187]។ លើសពីនេះទៀតក្នុងការអនុវត្ត ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ព្រហ្មទណ្ឌអាចប្រើលើបុគ្គល "ស្ថាប័ន" ដែលមិនបានគោរពតាមច្បាប់អន្តរជាតិ។ ខណៈដែលការពិន័យចំពោះការបរិហារកេរ្តិ៍ឬការជេរប្រមាថមិនបានបញ្ចូលទោសជាប់ពន្ធនាគារ ប៉ុន្តែបទល្មើសទាំងនេះត្រូវផ្តន្ទាទោសដោយការផាកពិន័យក្នុងក្រមព្រហ្មទណ្ឌ[188]។ លើសពីនេះនៅខែកុម្ភៈ ឆ្នាំ ២០១៨ ការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌរួមទាំងមាត្រា ៤៣៧ស្ទួន "បទប្រមាថអង្គព្រះមហាក្សត្រ"។ បទល្មើសនេះផ្ទុយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលចែងច្បាស់ថាបុគ្គលសាធារណៈ ត្រូវតែប្រឈមនឹងការរិះគន់កម្រិតខ្ពស់ដោយគ្រាន់តែថាទម្រង់នៃការបញ្ចេញមតិបែបនេះត្រូវបានគេចាត់ទុកថា ជាការប្រមាថដល់បុគ្គលសាធារណៈដែលគួរនឹងមានការដាក់ទណ្ឌកម្មនោះទេ[189]។ ការបំពានមាត្រានេះ នាំឱ្យមានការពិន័យមិនស្មើគ្នាពោលគឺត្រូវជាប់ពន្ធនាគារពី ១ ឆ្នាំទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ២ ទៅ ១០ លានរៀល។ មាត្រា ៧១ នៃ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា និងមាត្រា ៧១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើស |

186 សូមមើលចំណុចគន្លឹះទី១។

187 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ អនុសាសន៍ទូទៅលេខ៣៤ UN Doc. CCPR/C/GC/34, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១), កថាខណ្ឌ៤៧, <https://www2.ohchr.org/english/bodies/hrc/docs/gc34.pdfhttps://bit.ly/1xmySgV>.

188 សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៨ ដែលអាចរកបាន៖ https://cchrcambodia.org/admin/media/report/report/english/2017-08-10-CCHR-FFMP-Annual-Report-Eng.pdf

189 គណៈកម្មការសិទ្ធិមនុស្សអន្តរជាតិ,'អនុសាសន៍ទូទៅលេខ៣៤' , UN Doc. CCPR/C/GC/៣៤, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១), កថាខណ្ឌ៣៨ <https://www2.ohchr.org/english/bodies/hrc/docs/gc34.pdfhttps://bit.ly/1xmySgV>

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | រើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏មានទោសព្រហ្មទណ្ឌចំពោះការបរិហារកេរ្តិ៍ដោយការរឹតត្បិតលើគណបក្សនយោបាយនិងបេក្ខជនឬអ្នកគាំទ្រនៅពេលថ្លែងដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរថាបានប្រើពាក្យ "អសីលធម៌" ឬ "ប្រមាថ" ក្នុងអំឡុងពេលឃោសនាបោះឆ្នោត[190]។ ខណៈដែលច្បាប់អន្តរជាតិអនុញ្ញាតឱ្យមានការរឹតត្បិតក្នុងការប្រើប្រាស់ពាក្យពេចន៍ក្នុងពេលបោះឆ្នោត លក្ខណៈមិនច្បាស់នៃបទប្បញ្ញត្តិនេះមិនត្រូវបានគោរពតាមស្តង់ដារអន្តរជាតិនោះទេ ពីព្រោះច្បាប់នេះផ្តល់ឱកាសឱ្យមានការរំលោភបំពាន-ការមិនយល់ស្របជាមួយគណបក្សនយោបាយអាចត្រូវបានកំណត់ថាជា"អំពើអសីលធម៌ឬប្រមាថ"[191]។ មាត្រា ៧១ បានចែងទាំងការពិន័យជាប្រាក់និងការលុបបេក្ខភាព។ ការពិនិត្យឡើងវិញនៃសូចនាករនេះត្រូវបានធ្វើនៅក្នុងឆ្នាំ២០២០ ហើយខណៈពេលដែលគ្មានការវិវឌ្ឍផ្នែកច្បាប់ពិន្ទុនេះត្រូវបានទម្លាក់មកត្រឹម ១ ពិន្ទុនៅពេលធ្វើការវាយតម្លៃឡើងវិញ។ នេះត្រូវបានគេកឃើញពិន្ទុចំនួន ២ ដោយសារបទបរិហារកេរ្តិ៍មិនអនុវត្តទោសជាប់ពន្ធនាគារតាមក្រមព្រហ្មទណ្ឌទោះយ៉ាងណាសេចក្តីផ្តើមនៃការប្រព្រឹត្តបទល្មើស "ច្បាប់ប្រមាថអង្គព្រះមហាក្សត្រ" ក្នុងឆ្នាំ២០១៨ ផ្តន្ទាទោសដាក់ពន្ធនាគារជាការដាក់ទោសចំពោះទិដ្ឋភាពនៃបទបរិហារកេរ្តិ៍នេះ។ |
| ១.៣៤ ច្បាប់ការពារប្រឆាំងនឹងបណ្តឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ | ក្របខ័ណ្ឌច្បាប់ដែលការពារប្រឆាំងនឹងបណ្ដឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១ | ១ | ១ | កម្ពុជាខកខានបំពេញតាមធាតុផ្សំនេះ ។ បច្ចុប្បន្ននេះមិនមានច្បាប់ដែលបានអនុម័តបទប្បញ្ញត្តិឬគោលនយោបាយហាមឃាត់បណ្តឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈ និងមិនមានបទល្មើស ឬការដាក់ទណ្ឌកម្មសម្រាប់បុគ្គលឬនីតិបុគ្គលដែលដាក់ពាក្យបណ្តឹងនោះទេ។ លើសពីនេះក្រមព្រហ្មទណ្ឌមានបទល្មើសជាច្រើន ដែលត្រូវបានកំណត់ដោយមិនច្បាស់លាស់រួមទាំងការបរិហារកេរ្តិ៍ដែលមិនគោរពតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិហើយដូច្នេះធ្វើឱ្យការប្រើប្រាស់បណ្តឹងយុទ្ធសាស្ត្រប្រឆាំងនឹងការចូលរួមដើម្បីប្រយោជន៍សាធារណៈនៅក្នុងប្រទេសកម្ពុជាកើតមានញឹកញាប់។ |
| ១.៣៥ ការតាមដានមកលើការប្រាស្រ័យទាក់ទងអាចធ្វើបានក្រោយពេលមានការត្រួតពិនិត្យពីតុលាការតែប៉ុណ្ណោះ | ក្របខ័ណ្ឌច្បាប់ធានាថាការតាមដានមកលើការប្រាស្រ័យទាក់ទងអាចធ្វើបានក្រោយពេលមានការត្រួតពិនិត្យពីតុលាការតែប៉ុណ្ណោះ | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | ១ | ច្បាប់កម្ពុជាពុំបានបំពេញតាមចំណុចនេះទេ។ ច្បាប់ស្តីពីទូរគមនាគមន៍ដែលបានប្រកាសឱ្យប្រើនៅឆ្នាំ ២០១៦ បានផ្តល់អំណាចទូលាយឱ្យរដ្ឋាភិបាលនូវក្នុងការតាមដានទូរគមនាគមន៍ដោយគ្មានការត្រួតពិនិត្យពីប្រព័ន្ធតុលាការឬស្ថាប័នឯករាជ្យផ្សេងទៀត។ មាត្រា៦ ចែងថា "ប្រតិបត្តិករទូរគមនាគមន៍និងអ្នកដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ត្រូវផ្តល់ឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នូវទិន្នន័យសេវាកម្មបច្ចេកវិជ្ជាទូរគមនាគមន៍និងទិន្នន័យសេវាទូរគមនាគមន៍"។ យោងតាមបទបញ្ញត្តិនេះប្រតិបត្តិករទូរគមនាគមន៍មិនចាំបាច់ត្រូវឆ្លងកាត់ការពិនិត្យពីតុលាការឬស្ថាប័នឯករាជ្យឡើយ។ ពាក្យថា "ទិន្នន័យសេវា" មិនត្រូវបានកំណត់នៅក្នុងច្បាប់ទេហើយអាចត្រូវបានបកស្រាយគ្រប់ប្រព័ន្ធបញ្ចូលការកំណត់ត្រាទំនាក់ទំនងអ្នកប្រើទាំងអស់ ប្រវត្តិស្វែងរក និងព័ត៌មានសម្ងាត់ផ្សេងទៀត។ នេះក៏រំលោភលើមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញដែលធានានូវសិទ្ធិរក្សាការសម្ងាត់។ មាត្រា៩៧ ច្បាប់ស្តីពីទូរគមនាគមន៍ចែងអំពីការលួចស្តាប់ ថតសម្លេងការសន្ទនាបានលុះត្រាតែមានការ |

[190] យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល២១ថ្ងៃ (មាត្រា៧២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិករដ្ឋសភា) និងរយៈពេល១៤ថ្ងៃសំរាប់ការបោះឆ្នោតឃុំ-សង្កាត់ (មាត្រា៧០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់)។

[191] សហភាពអឺរ៉ុប, របាយការណ៍បញ្ចប់បេសកកម្មការត្រួតពិនិត្យនៅកម្ពុជា ឆ្នាំ២០១៥ <https://eeas.europa.eu/sites/eeas/files/efm_cambodia_2015_final_report_publ.pdf>

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | អនុញ្ញាតពី“អាជ្ញាធរធម្មានុរូប” ហើយការផ្សព្វផ្សាយពីកិច្ចសន្ទនាទាំងនោះក៏ចាំបាច់មានត្រូវមានការអនុញ្ញាតពី“អាជ្ញាធរធម្មានុរូប”។ បទបញ្ញត្តិទាំងនេះមានលក្ខណៈទូលាយងាយស្រួលក្នុងការបំពានព្រោះពួកគេអនុញ្ញាតឱ្យមានការឃ្លាំមើលដោយគ្មានគណនេយ្យភាពសាធារណៈឬការការពារសុវត្ថិភាព។ ស្រដៀងគ្នានេះច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយឆ្នាំ២០១០ បានផ្តល់អំណាចដល់អង្គភាពដោយមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់តុលាការ[192]។ មាត្រា២៧នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយត្រូវបានអនុញ្ញាតឱ្យ “ឃ្លាំមើល ត្រួតត្រា ស្តាប់សម្លេង ថតចម្លងនិងថតរូបនិងថតសម្លេងទូរស័ព្ទ” ដែលមានព័ត៌មានច្បាស់លាស់នៃអំពើពុករលួយ។ ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សាយតាមគេហទំព័រនិងបណ្តាញសង្គមបានបរាជ័យនៅក្នុងសូចនាករនេះដោយសារការបង្កើត “ក្រុមការងារតាមដាន” រួមគ្នាជាមួយតំណាងក្រសួងដើម្បី “ត្រួតពិនិត្យ” និងចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងការផ្សព្វផ្សាយខុសច្បាប់នៅលើគេហទំព័រនិងប្រព័ន្ធផ្សព្វផ្សាយសង្គម។ មិនមានការនិយាយពីការត្រួតពិនិត្យតាមនីតិវិធីតុលាការឡើយ[193]។ មាត្រា ១ នៃ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិអនុញ្ញាតឱ្យបង្កើតរចនាសម្ព័ន្ធដែលជួយសម្រួលដល់ការតាមដានលើការចែករំលែកព័ត៌មានឬសកម្មភាពតាមអនឡាញ រួមទាំងទំនាក់ទំនងឯកជន ដោយមិនមានការដឹកាពីតុលាការ។ |
| ១.៣៦<br><br>សិទ្ធិទទួលព័ត៌មានត្រូវបានការពារ និងលើកកម្ពស់ | កម្រិតនៃក្របខណ្ឌច្បាប់ ការពារ<br>និងលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន | ការពិនិត្យនិងសិក្សាឡើងវិញនូវ<br><br>ឯកសារច្បាប់ | មិនមានចម្លើយ | ១ | ១ | ១ | ១ | ១ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះពីព្រោះសិទ្ធិទទួលព័ត៌មានមិនត្រូវបានការពារដោយច្បាប់ឡើយ[194]។ ទោះយ៉ាងណា រដ្ឋាភិបាលកំពុងធ្វើការលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ច្បាប់ជាច្រើនមានឥទ្ធិពលទៅលើសិទ្ធិទទួលព័ត៌មាន រួមមានច្បាប់ស្តីពីរបបសារព័ត៌មាន និងក្រមព្រហ្មទណ្ឌ។ ច្បាប់ស្តីពីរបបសារព័ត៌មានហាមឃាត់និងផ្តន្ទាទោសការបោះពុម្ពផ្សាយនូវការបញ្ចេញមតិជាច្រើន។ មាត្រា ១២ នៃច្បាប់នេះបង្កើតឱ្យមានការរឹតត្បិតលើរាល់ព័ត៌មាន ដែលអាចប៉ះពាល់ដល់សន្តិសុខជាតិនិងស្ថេរភាពនយោបាយ តែមិនតម្រូវថាទាល់តែមានទំនាក់ទំនងរវាងការបោះពុម្ពផ្សាយ និងហានិភ័យនៃគ្រោះថ្នាក់ឡើយ។ នេះបង្ហាញពីការខកខានក្នុងការការពារសិទ្ធិទទួលព័ត៌មាន។ បទល្មើសនៃការ “ក្លែងព័ត៌មាន” ក្រោមមាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានដាក់ជាបទល្មើសព្រហ្មទណ្ឌនូវអំពើដែលផ្តល់ឬបើកកកាយព័ត៌មានក្លែងដើម្បីធ្វើឱ្យជឿថា នឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យខូចខាតប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស។ ការប្រើប្រាស់ពាក្យដែលមានន័យទូលំទូលាយ មិនច្បាស់លាស់នៃបទល្មើសបែបនេះ បណ្តាលឱ្យមានការអនុវត្តប្រឫកប្របល់ ដល់ការបញ្ចេញមតិដែលមិនមែនក្លែងក្លាយ ឬព័ត៌មានដែលជាមតិយោបល់។ នេះនឹងបង្កើនវិសាលភាពច្បាប់លើសពីកម្រិតនៃការរឹតត្បិតលើសេរីភាពនៃការបញ្ចេញមតិដែលត្រូវបានអនុញ្ញាត។ បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ ឆ្នាំទៅ ២ ឆ្នាំនិង |

[192] សូមអាន "របាយការណ៍ប្រចាំឆ្នាំលើកទី២ របស់គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាននៅកម្ពុជា" ដែលចងក្រងរួមគ្នាដោយ ម.ស.ម.ក អាដហុក មជ្ឈមណ្ឌលសាមគ្គីភាព និងអាយ. ស៊ី .អិន.អិល (ខែកញ្ញា ឆ្នាំ២០១៨) ទំព័រ ៤ ដែលអាចរកបាន៖ https://cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=128&id=5

[193] ប្រកាសអន្តរ, ចំណុចទី៤ សូមមើល កាន់ វិច្ឆិកា, 'កម្ពុជាបង្កើតក្រុមការងារតាមដានការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយតាមប្រព័ន្ធផ្សព្វផ្សាយនិងបណ្តាញសង្គម' (វីអូអេ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨), <https://www.voacambodia.com/a/cambodia-forms-task-force-to-monitor-fake-news-on-social-media/4425534.html>

[194] ខែមីនា ឆ្នាំ២០១៨ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានបញ្ជាក់ថាសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល។ សូមមើល ខ្មែរថាមស៍ 'ការត្រៀមរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន', ដោយ តាំង វីដា (ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩) <https://www.khmertimeskh.com/50577422/access-to-information-draft-law-ready/> ។ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន អាចរកបាននៅ https://www.phnompenhpost.com/Assets/doc/Doc-Jan-31-2018-15-30-en.pdf

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | ពិន័យជាប្រាក់ពី ២ ទៅ ៤ លាន រៀល ការពិន័យនេះមើលទៅដូចជាមិនសមាមាត្រចំពោះសកម្មភាពព្រហ្មទណ្ឌទាល់តែសោះ។ ច្បាប់គ្រប់គ្រងប្រទេសក្នុងភាពអាសន្នផ្តល់អំណាចដល់រាជរដ្ឋាភិបាល ក្នុងការហាមឃាត់ឬរឹតត្បិតការចែករំលែកឬប្រព័ន្ធផ្សព្វផ្សាយ[195] ដែលរារាំងសិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មានក្នុងពេលមានអាសន្ន។ ច្បាប់នេះអនុញ្ញាតឱ្យរាជរដ្ឋាភិបាលដាក់រឹតត្បិតលើព័ត៌មាន ដែលអាចរារាំងដល់ការរាយការណ៍ប្រកបដោយតម្លាភាព ធ្វើឱ្យខូចខាតដល់ប្រជាពលរដ្ឋ ។ មាត្រា៦ នៃ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិអនុញ្ញាតឱ្យមានការបិទខ្ទប់ និងផ្តាច់មាតិកាអនឡាញទាំងឡាយណាដែលអាជ្ញាធរគិតថាប៉ះពាល់ដល់ "សុវត្ថិភាព ចំណូលរបស់រដ្ឋ សណ្តាប់ធ្នាប់សាធារណៈ ភាពថ្លៃថ្នូរ វប្បធម៌ ទំនៀមទំលាប់ប្រពៃណី" ដែលនេះនាំឱ្យមានការរឹតត្បិតមកលើមាតិកាទាំងនោះ រួមទាំងមាតិកាដែលមិនមានកំហុសដែលចាត់ទុកថាជំទាស់នឹងគោលបំណងទាំងនេះ។ [196] |
| ១.៣៧ សិទ្ធិប្រើប្រាស់អ៊ិនធឺណិតមិនអាចត្រូវបានកាត់ផ្តាច់តាមអំពើចិត្តនោះទេ | កម្រិតនៃសិទ្ធិប្រើប្រាស់អ៊ីនធឺណិតត្រូវបានធានាដោយច្បាប់ និងការពារពីការរឹតត្បិតតាមអំពើចិត្ត | ការពិនិត្យនិងសិក្សាឡើងវិញនូវឯកសារច្បាប់ | មិនមានចម្លើយ | ៣ | ៣ | ៣ | ៣ | ១ | ១ | កម្ពុជាបានខកខានក្នុងការបំពេញតាមចំណុចនេះ។ ខណៈដែលគ្មានបទប្បញ្ញត្តិផ្តល់អំណាចដល់រដ្ឋាភិបាលអាចបិទប្រព័ន្ធអ៊ិនធើណិត មាត្រា៧ នៃច្បាប់ស្តីពីទូរគមនាគមន៍អាចនាំឱ្យមានអនុវត្តតាមអំពើចិត្តដើម្បីបិទអ៊ីនធឺណិតបាន។ មាត្រា៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ចែងថា "ក្នុងករណីដែលមានភាពមិនប្រក្រតី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឬក្រសួងឬស្ថាប័នដែលមានសមត្ថកិច្ចអាចបញ្ជាឱ្យប្រតិបត្តិករទូរគមនាគមន៍ពាក់ព័ន្ធចាត់វិធានការចាំបាច់ដោយផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល"។ បន្ថែមពីលើនេះក៏បានផ្តល់ឱ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្រោមមាត្រា២៤ ដែលចែងថា "រចនាសម្ព័ន្ធទូរគមនាគមន៍ និងបណ្តាញទូរគមនាគមន៍ និងរចនាសម្ព័ន្ធគាំទ្រដល់ទូរគមនាគមន៍នឹងស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍"។ ក្រោមបទប្បញ្ញត្តិទាំងនេះរដ្ឋាភិបាលទំនងជាទទួលបានការត្រួតពិនិត្យគ្រប់ឧស្សាហកម្មទូរគមនាគមន៍រួមមានសកម្មភាពនិងហេដ្ឋារចនាសម្ព័ន្ធ។ ក្រុមការងារពិសេសដែលបង្កើតឡើងដោយប្រកាសអន្តរក្រសួងក៏មានអំណាចផ្តាច់សេវាប្រព័ន្ធអ៊ីនធឺណិតដោយមិនចាំបាច់មានការត្រួតពិនិត្យពីតុលាការដើម្បីទប់ស្កាត់ការអនុវត្តន៍តាមអំពើចិត្តឡើយ[197]។ អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ អនុញ្ញាតឱ្យមានការបង្កើតរចនាសម្ព័ន្ធដែលប្រមូលផ្តុំការគ្រប់គ្រងប្រព័ន្ធអ៊ីនធឺណិត របស់រាជរដ្ឋាភិបាល[198]។ ហើយនេះ ក៏បានផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការកាត់ផ្តាច់អ៊ីនធឺណិត។[199] |

[195] មាត្រា ៥ (១១) នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន។

[196] សូមមើលចំណុចគន្លឹះទី១។

[197] ប្រកាសអន្តរក្រសួងស្តីពីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ប្រការ ៤ ។

[198] មាត្រា១នៃអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ។

[199] សូមមើលចំណុចគន្លឹះទី១។

| ចំណុចគន្លឹះទី២៖ ក្របខណ្ឌច្បាប់ជាតិពាក់ព័ន្ធនឹងសេរីភាពខាងសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិត្រូវបានអនុវត្តនិងប្រតិបត្តិតាមត្រឹមត្រូវឬទេ? | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ធាតុផ្សំ | សូចនាករ | ប្រភពទិន្នន័យ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | *កំណត់សម្គាល់* |
| ២.១ ស្ថាប័នរដ្ឋាភិបាលយល់ពីសិទ្ធិ និងកាតព្វកិច្ចទាក់ទិននឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | %នៃការថ្លែងតាមប្រព័ន្ធផ្សព្វផ្សាយបង្ហាញឱ្យឃើញពីកង្វះការយល់ដឹង ឬការបកស្រាយមិនត្រឹមត្រូវអំពីសេរីភាពខាងការបង្កើតសមាគមជួបប្រជុំ និងបញ្ចេញមតិ របស់តំណាងរដ្ឋាភិបាល | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ៤៨% | ២៣% | ១៥% | ១៤% | ៧៤% | ៨៧% | ៨២% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាការថ្លែង១៧ ករណី ក្នុងចំណោមនោះការថ្លែងចំនួន១៤ របស់មន្ត្រីរដ្ឋាភិបាលបង្ហាញពីកង្វះការយល់ដឹង ឬបកស្រាយមិនត្រឹមត្រូវអំពីសេរីភាពមូលដ្ឋាន។ |
| ២.២ អជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | # របាការណ៍បន្ថែមឱ្យឃើញថាអជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ០ | ១ | ០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយមិនបានកត់ត្រានូវករណីណាមួយអាជ្ញាធរឬភាគីទីបីដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានឡើយ។ |
| | # របាការណ៍បន្ថែមឱ្យឃើញថាអជ្ញាធរ និងភាគីទីបីទទួលខុសត្រូវចំពោះការរំលោភបំពានច្បាប់ដែលពាក់ព័ន្ធនឹងសេរីភាពខាងការបង្កើតសមាគម ជួបប្រជុំ និងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ០ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រានូវករណីណាមួយរបស់អាជ្ញាធរឬភាគីទីបីដែលត្រូវទទួលខុសត្រូវចំពោះការរំលោភបំពាន ឡើយ។ |
| ២.៣ សេរីភាពអាចអនុវត្តដោយគ្មានជ្រៀតជ្រែកនិងគំរាមកំហែង | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានកោះហៅសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១៩៩ | ៦៦ | ១១៥ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ១៥៥ ករណីនៃការកោះហៅ។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានកោះហៅសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ១៦ | ៦ | ៨ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា៨ ករណីដែលត្រូវបានកោះហៅ។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានសាកសួរសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ១១៥ | ១៣៧ | ៩១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៩១ ករណីដែលត្រូវបានសាកសួរ។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានសាកសួរសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ២ | ២៦ | ៨ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៨ ករណីដែលត្រូវបានសាកសួរ។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានឃាត់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ១១៤ | ១១៩ | ២៤៦៧ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ២៤៦៧ ករណីដែលត្រូវបានឃុំខ្លួន។ ចំនួននេះរាប់បញ្ចូលទាំងការឃុំខ្លួនដោយយន្តការកូវីដ១៩។ |
| | # នៃបុគ្គលម្នាក់ៗបានឃាត់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ២ | ០ | ១៥៩ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១៥៩ ករណីដែលត្រូវបានឃុំខ្លួន។ ចំនួននេះរាប់បញ្ចូលទាំងការឃុំខ្លួនដោយយន្តការកូវីដ១៩។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវធ្វើសេចក្ដីយល់ព្រមដោយរដ្ឋាភិបាលដើម្បីចុះហត្ថលេខា និងផ្ដិតមេដៃលើលិខិតយល់ព្រមសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ។ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ៥៤ | ៥៨ | ១០៣ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយដែលត្រូវបានកត់ត្រា ១០៣ ករណីដែលត្រូវបានធ្វើសេចក្ដីយល់ព្រម ចុះហត្ថលេខា និងផ្ដិតមេដៃ។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗត្រូវធ្វើសេចក្ដីយល់ព្រមដោយរដ្ឋាភិបាលដើម្បីចុះហត្ថលេខា និងផ្ដិតមេដៃលើលិខិតយល់ព្រមសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ៣ | ១ | ១ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា១ករណីដែលត្រូវធ្វើសេចក្ដីយល់ព្រមចុះហត្ថលេខា និងផ្ដិតមេដៃ។ |
| | # នៃបុគ្គលម្នាក់ៗនិងអង្គភាពបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានកាត់ទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ៥២ | ៦០ | ២៧ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ២៧ ករណីដែលបានកាត់ទោស។ |
| | # នៃបុគ្គលម្នាក់ៗនិងអង្គភាពត្រូវបានកាត់ទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ១ | ១ | ០ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រាករណីណាមួយដែលបានកាត់ទោស។ |
| | # នៃបុគ្គលម្នាក់ៗបានរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយត្រូវបានចាប់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ៨១ | ១៣៨ | ៧៧ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៧៧ ករណីដែលបានចាប់ខ្លួន។ |
| | # នៃបុគ្គលម្នាក់ៗត្រូវបានចាប់ខ្លួនសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំនិងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពីហេតុការណ៍ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ១ | ០ | ២១ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រាករណីដែលត្រូវបានចាប់ខ្លួន។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាង បង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ១៦ | ៧២ | ៧៦ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៧៦ ករណីដែលត្រូវបានផ្តន្ទាទោស។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលផ្តន្ទាទោសពីបទ ឧក្រិដ្ឋសម្រាប់ការអនុវត្តសេរីភាពខាងបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពី ហេតុការណ៍ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ១ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍មិនបានកត់ត្រាករណីដែលត្រូវបានផ្តន្ទាទោស។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពដែលរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែល ស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាលសម្រាប់ការអនុវត្តសេរីភាពខាង ការបង្កើតសមាគម សេរីភាពខាងជួបប្រជុំ សេរីភាពខាងបញ្ចេញមតិ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ១ | ២១ | ៨ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៨ ករណី បុគ្គលឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាល។ |
| | # នៃបុគ្គលម្នាក់ៗឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការ ដាក់ទណ្ឌកម្មរដ្ឋបាលក្នុងការអនុវត្តសេរីភាពខាងការបង្កើត សមាគម សេរីភាពខាងជួបប្រជុំ និងសេរីភាពខាងបញ្ចេញមតិ | ការរាយការណ៍ពី ហេតុការណ៍ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | មិនមាន ចម្លើយ | ០ | ១ | ០ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ០ ករណី អំពីបុគ្គលឬអង្គភាពណាមួយដែលស្ថិតនៅក្រោមការដាក់ទណ្ឌកម្មរដ្ឋបាល ។ |
| សេរីភាពខាងការបង្កើតសមាគម | | | | | | | | | | |
| ២.៤ ស្ថាប័នរដ្ឋាភិបាលគោរពសិទ្ធិកាតព្វកិច្ច និងការប្រើប្រាស់សេរីភាព | # រាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលបង្ហាញថា រដ្ឋាភិបាល គោរពសិទ្ធិ កាតព្វកិច្ចនិងការប្រើប្រាស់ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | ២០២ | ៣៣ | ៣៣ | ៣ | ១ | ១ | ០ | ការតាមដានប្រព័ន្ធផ្សព្វផ្សាយមិនបានកត់ត្រាករណីណាមួយដែររដ្ឋាភិបាលការពារសេរីភាពខាងសមាគម។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ខាងការបង្កើតសមាគម | # ការណ៍រាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ដែលរដ្ឋាភិបាល រំលោភលើសេរីភាពខាងការបង្កើតសមាគម | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៦១ | ៧០ | ៧៩ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៧៩ ករណីនៃហេតុការណ៍ដែលស្ថាប័នរដ្ឋាភិបាលបានរំលោភលើសេរីភាពខាងសមាគម។ |
| | # ចំនួនហេតុការណ៍ ដែលរដ្ឋាភិបាលរំលោភលើសេរីភាពខាងការបង្កើតសមាគម | ការរាយការណ៍ពីហេតុការណ៍ | ១១៤ | ១២២ | ១០១ | ៤៨ | ៤៣ | ៥០ | ៧០ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៧០ ករណីនៃហេតុការណ៍ដែលស្ថាប័នរដ្ឋាភិបាលបានរំលោភលើសេរីភាពខាងសមាគម។ |
| ២.៥ ការចុះបញ្ជីសមាគមត្រូវបានអនុវត្តដោយយុត្តិធម៌ និងតម្លាភាព | កម្រិតនៃ ដំណើរការចុះបញ្ជីសមាគមត្រូវបានអនុវត្តដោយយុត្តិធម៌និងតម្លាភាព | ការតាមដានពីនីតិវិធីចុះបញ្ជីអង្គការសមាគម | មិនមានចម្លើយ | ១ | ១ | មិនមានចម្លើយ | ២ | ៣ | ០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាថាពុំមានករណីណាមួយដែលលិខិតចុះបញ្ជីត្រូវបានបដិសេធដោយសារតែមានសមាគមជាច្រើនដែលមានរូបរាងស្រាប់ដែលមានគោលដៅស្រដៀងៗគ្នា។ |
| ២.៦ មានសមាគមច្រើនដែល គោលបំណងស្រដៀងគ្នា | # ពាក្យសុំចុះបញ្ជីត្រូវបានបដិសេធដោយសារតែមានសមាគមច្រើនដែលមានគោលបំណងស្រដៀងគ្នា | ការរាយការណ៍ពីហេតុការណ៍ | ១ | ១ | ០ | ០ | ០ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រាថាពុំមានករណីណាមួយដែលលិខិតចុះបញ្ជីត្រូវបានបដិសេធដោយសារតែមានសមាគមជាច្រើនដែលមានរូបរាងស្រាប់ដែលមានគោលដៅស្រដៀងៗគ្នា។ |
| | | ការតាមដានពីនីតិវិធីចុះបញ្ជីអង្គការសមាគម | មិនមានចម្លើយ | ០ | ០ | ០ | ០ | ០ | ០ | ឧបករណ៍វាយតម្លៃការចុះបញ្ជីអង្គការសមាគមមិនបានកត់ត្រាករណីបដិសេធចុះបញ្ជីដោយសារមូលហេតុបែបនេះទេ។ |
| ២.៧ សមាគមអាចបង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព ដោយសេរី | % នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ អំពីការជ្រៀតជ្រែក មកលើគោលបំណង បង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀតនៃសហជីព | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៣៨% | ៤៥% | ៤១% | ២៦% | ២៦% | ៣៤% | សូមមើលសំណួរ៤.១ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # ហេតុការណ៍ ដែលមានការ ជ្រៀតជ្រែក មកលើគោល បំណង សមាគមក្នុងការបង្កើតបណ្តាញ សម្ព័ន្ធ សហព័ន្ធ ឬប្រភេទផ្សេងទៀត | ការរាយការណ៍ពីហេតុការណ៍ | ០ | ១៤ | ០ | ៣ | ២ | ១ | ០ | ការរាយការណ៍ពីហេតុការណ៍ពុំបានកត់ត្រាករណីនៃការជ្រៀតជ្រែកដែលសមាគមប៉ុនប៉ងដើម្បីបង្កើតបណ្តាញសម្ព័ន្ធ សហព័ន្ធ សហជីព ឬប្រភេទផ្សេងទៀតនៃសហជីព។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២.៨ សមាជិកនៃអង្គការ សមាគម សម្ព័ន្ធ សហព័ន្ធ មានសិទ្ធិដកខ្លួនចេញបាន | % នៃថ្នាក់ដឹកនាំសមាគមបានរាយការណ៍អំពីល័ក្ខខណ្ឌដកខ្លួនចេញពីសមាជិក | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៥០% | សូមមើលសំណួរ៤.៣.១ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| ២.៩ សមាគមដំណើរការដោយពុំមានការជ្រៀត ជ្រែកពីរដ្ឋាភិបាល | % នៃថ្នាក់ដឹកនាំសមាគមបានរាយការណ៍អំពីការជ្រៀតជ្រែងលើសលុបពីសំណាក់រដ្ឋាភិបាលក្នុងឆ្នាំមុន | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៧៦% | ៧៤% | ៧៩% | ៧៥% | ៦៧% | ៦៤% | សូមមើលសំណួរ៤.៥ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # ហេតុការណ៍ដែលរដ្ឋាភិបាលជ្រៀតជ្រែកមកលើសមាគម រំលោភលើបទដ្ឋានអន្តរជាតិ បង្ហាញក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | ១៨៨ | ១៨៤ | ៤៣ | ១០៤ | ៥៦ | ៤៣ | ៩ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៦ ករណី នៃការត្រួតត្រារបស់រដ្ឋាភិបាលលើសមាគមដែលជាការរំលោភលើស្តង់ដារអន្តរជាតិ។ |
| | # ហេតុការណ៍ដែលរដ្ឋាភិបាលជ្រៀតជ្រែកមកលើសមាគម រំលោភលើបទដ្ឋានអន្តរជាតិបង្ហាញក្នុងការរាយការណ៍ហេតុការណ៍ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៣៥ | ៣៦ | ៣៥ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ៣៥ ករណី នៃការត្រួតត្រារបស់រដ្ឋាភិបាលលើសមាគមដែលជាការរំលោភលើស្តង់ដារអន្តរជាតិ។ |
| ២.១០ បុគ្គលពុំបានក្លាយជាគោលដៅ ដោយសារតែការចូលរួមជាមួយ សមាគមនោះទេ។ | %នៃបុគ្គលដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះដោយសារតែការចូលរួមជាមួយសមាគម | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៣% | ៣៥% | ៣៦% | ៣០% | ២៦% | ២៤% | ៣៧% | សូមមើលសំណួរ៥.៦ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | %នៃបុគ្គលដែលរាយការណ៍អំពីការក្លាយជាជនរងគ្រោះដោយសារតែការចូលរួមជាមួយសមាគម | ការស្ទង់មតិជាសាធារណៈ | មិនមានចម្លើយ | ១៤% | ១៩% | ២៥% | ២៦% | ២២% | ២២% | សូមមើលសំណួរ៣.៤ នៃការស្ទង់មតិសាធារណៈ។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២.១១<br>សមាគមត្រូវបានការពារពីការជ្រៀតជ្រែករបស់ភាគីទីបី។ | % នៃថ្នាក់ដឹកនាំសមាគមដែលរាយការណ៍ការជ្រៀតជ្រែកពីភាគីទីបី | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ២៣% | ២៥% | ១៧% | ១៤% | ៨% | ១៦% | ៣៣% | សូមមើលសំណួរ៤.៧ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # នៃហេតុការណ៍របស់ភាគីទីបីបានជ្រៀតជ្រែកសមាគម | ការតាមដានតាមប្រព័ន្ធ<br>ផ្សព្វផ្សាយ | ២៤ | ៣៥ | ១០ | ១៥ | ១៤ | ២៥ | ៣៩ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៣៩ ករណី ដែលបង្ហាញថាសមាគមត្រូវបានរំខានធ្វើទុក្ខបុកម្នេញដោយ ភាគីទីបី។ |
| | # នៃហេតុការណ៍របស់ភាគីទីបីបានជ្រៀតជ្រែកសមាគម។ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៨ | ១៤ | ១២ | ២២ | ១៩ | ៤៩ | ការរាយការណ៍ហេតុការណ៍បានកត់ត្រា ៤៩ ករណី ដែលបង្ហាញថាថ្នាក់ដឹកនាំសមាគមត្រូវបានរំខានធ្វើទុក្ខបុកម្នេញដោយភាគីទីបី។ |
| ២.១២<br>សមាគមមិនប្រឈមនឹងលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលជាបន្ទុក និងស្មុគស្មាញ | % នៃថ្នាក់ដឹកនាំសមាគមដែលប្រឈមនឹងលក្ខខណ្ឌតម្រូវធ្វើរបាយការណ៍ដែលជាបន្ទុក និងស្មុគស្មាញ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៦០% | ៥៨% | ៦០% | ៦០% | ៤៥% | ៥៨% | សូមមើលសំណួរ៤.១២ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| ២១.៣<br>ការដាក់ទណ្ឌកម្មលើសមាគមត្រូវបានអនុវត្តស្របតាមច្បាប់របស់កម្ពុជា | # ការរាយការណ៍ហេតុការណ៍ដែលការដាក់ទោសដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា | ការតាមដានតាមប្រព័ន្ធ<br>ផ្សព្វផ្សាយ | មិនមានចម្លើយ | ១២ | ១ | ០ | ០ | ០ | ១ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ១ ករណីនៃការដាក់ទណ្ឌកម្មលើសមាគមណាមួយដែលមិនត្រូវបានអនុវត្តស្របតាមច្បាប់កម្ពុជាឡើយ។ |
| | # ការរាយការណ៍ហេតុការណ៍ដែលការទណ្ឌកម្មដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា។ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៣ | ០ | ០ | ០ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍ពុំបានកត់ត្រាករណីនៃការដាក់ទណ្ឌកម្មលើស្ថាប័ន សមាគម ដោយពុំបានអនុវត្តស្របទៅតាមច្បាប់របស់កម្ពុជា។ |
| ២១.៤<br>សមាគមបានឧបត្ថម្ភ ប្រសិនបើពួកគេត្រូវបានដាក់ទោស | % នៃថ្នាក់ដឹកនាំសមាគមរាយការណ៍ថាអាចទទួលបានគាំទ្រនិងជំនួយផ្លូវច្បាប់ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៥០% | ៤២% | ៩% | ៣២% | ២០% | ៨៣% | ៤៩% | សូមមើលសំណួរ៤.១៩ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។<br>ចំនួនឆ្លើយតបតិចតួចចំពោះសំណួរនេះមានន័យថាមានភាពប្រសើរឡើងពី១ឆ្នាំទៅ១ឆ្នាំ។ សំណួរនេះបានផ្លាស់ទៅ ៤.១៦.១ ក្នុងកម្រងសំណួរឆ្នាំ ២០២២។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២១.៥ ការរំលាយសមាគម ធ្វើបានក្រោយពេលមធ្យោបាយ ផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | # ហេតុការណ៍រាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយនៃការរំលាយណាមួយក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | ការតាមដានតាមប្រព័ន្ធ ផ្សព្វផ្សាយ | ០ | ០ | ០ | ០ | ១ | ១ | ០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយពុំបានកត់ត្រាករណីនៃការរំលាយសមាគមដោយមិនស្ម័គ្រចិត្ត។ |
| | # ការរាយការណ៍ពីហេតុការណ៍ការរំលាយណាមួយក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ០ | ០ | ០ | ០ | ០ | ០ | ការរាយការណ៍ពីហេតុការណ៍ពុំបានកត់ត្រាករណីនៃការរំលាយណាមួយក្រោយពេលមធ្យោបាយផ្លូវច្បាប់ត្រូវបានប្រើប្រាស់និងបង្ហាញថាអាចនឹងមានគ្រោះថ្នាក់។ |
| ២១.៦ សមាគមមិនត្រូវបានរឹតត្បិតមិនឱ្យធ្វើសកម្មភាពសេដ្ឋកិច្ចឡើយ | %នៃថ្នាក់ដឹកនាំសមាគមដែលថាសមាគមត្រូវបានរឹតត្បិតមិនឱ្យធ្វើសកម្មភាពសេដ្ឋកិច្ចឡើយ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៤% | ៧% | ៣% | ៤% | ០% | ៥% | ១១% | សូមមើលសំណួរ៤.២២ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ សំណួរនេះបានប្តូរទៅ ៤.២១ ក្នុងកម្រងសំណួរឆ្នាំ២០២២។ |
| ២១.៧ សមាគមមិនត្រូវបានរឹតត្បិតក្នុងការទទួលបានមូលនិធិ | %នៃថ្នាក់ដឹកនាំសមាគមដែលថាសមាគមពុំត្រូវបានរឹតត្បិតក្នុងការទទួលបានមូលនិធិ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៨៣% | ៧២% | ៧៩% | ៨០% | ៧៦% | ៦២% | សូមមើលសំណួរ៤.២៤ និង៤.២៦ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព។ សំណួរនេះបានប្តូរទៅ ៤.២២ និង ៤.២៣ ក្នុងកម្រងសំណួរឆ្នាំ២០២២។ មូលនិធិក្នុងស្រុក = ៦២% និង មូលនិធិបរទេស = ៦២% |
| ២១.៨ សមាគមពុំតម្រូវឱ្យ បំពេញតាមលក្ខខណ្ឌរបាយការណ៍ហិរញ្ញវត្ថុដ៏ច្រើនលើសលប់នោះទេ | %នៃថ្នាក់ដឹកនាំសមាគមដែលថាសមាគមត្រូវធ្វើរបាយការណ៍ហិរញ្ញវត្ថុដ៏លើសលប់ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | ៦០% | ៥៨% | ៦០% | ៦៩% | ៥៤% | ៥៩% | សូមមើលសំណួរ៤.១៥ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ *ចំណាំ* សំណួរនេះបានប្តូរទៅ ៤.១៣ ក្នុងកម្រងសំណួរឆ្នាំ២០២២។ |
| | % នៃថ្នាក់ដឹកនាំសមាគមបង្ហាញថាមិនអាចបំពេញ របាយការណ៍ហិរញ្ញវត្ថុ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ៦២% | ៣៦% | ១៦% | ១៩% | ២៥% | ២៧% | ២១% | សូមមើលសំណួរ៤.១៣ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២.១៩<br>ស្ថាប័នរដ្ឋាភិបាលបង្ហាញសកម្មភាពការគោរពនិងការលើកកម្ពស់សិទ្ធិក្រុមអ្នកងាយរងគ្រោះសេរីភាពខាងសមាគម | % នៃថ្នាក់ដឹកនាំសមាគមបង្ហាញថាការសហការជាដៃគូជាមួយរដ្ឋាភិបាលដើម្បីគោរពនឹងលើកកម្ពស់សិទ្ធិរបស់ក្រុមងាយរងគ្រោះ | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | មិនមានចម្លើយ | ៤២% | សូមមើលសំណួរ១.៥.១. នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # របាយការណ៍បន្ថែមតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលរដ្ឋាភិបាលបានថ្លែងចេញឬបង្ហាញសកម្មភាពលើកកម្ពស់ឬការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះ | ការតាមដានតាមប្រព័ន្ធ<br>ផ្សព្វផ្សាយ | មិនមានចម្លើយ | ០ | ០ | ០ | ០ | ០ | ០ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយពុំបានកត់ត្រាករណីដែលរដ្ឋាភិបាលបង្ហាញសកម្មភាពលើកកម្ពស់សេរីភាពខាងការបង្កើតសមាគម ឬការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះ។ |
| សេរីភាពខាងការជួបប្រជុំ | | | | | | | | | | |
| ២.២០<br>តំណាងសមាគមបុគ្គល ឬតាម រយៈអង្គការអាចអនុវត្តសេរីភាពខាងការជួបប្រជុំដោយសន្តិវិធី | % ថ្នាក់ដឹកនាំសមាគមដែលបានរាយការណ៍ថាអាចអនុវត្តដោយសេរីនូវសេរីភាពការជួបប្រជុំដោយសន្តិវិធី | ការស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីព | ១៩% | ១០% | ៤% | ៧% | ៧% | ៤% | ១១% | សូមមើលសំណួរ៥.២ នៃការស្ទង់មតិថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីព។ |
| | # នៃហេតុការណ៍បានបង្ហាញថាការកំណត់ការរឹតត្បិតទៅលើសេរីភាពនៃការជួបប្រជុំ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៤៥ | ៥៧ | ៥ | ១០ | ១៥ | ១៨ | ការរាយការណ៍ពីហេតុការណ៍បានកត់ត្រា ១៨ ករណីដែលរដ្ឋាភិបាលបានរឹតត្បិតការជួបប្រជុំ។ |
| | % នៃប្រធានបទការជួបប្រជុំទៅនឹងការជ្រៀតជ្រែកហួសហេតុដែលត្រូវបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៦% | ៩% | ១០% | ៣៣% | ២៦% | ៩០% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៦៦ ករណីនៃការជួបប្រជុំត្រូវបានជ្រៀតជ្រែកដោយរដ្ឋាភិបាលក្នុងចំណោម ៧៣ នៃការជួបប្រជុំ។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២.២១ ក្រុមនានាអាចជួបប្រជុំដោយពុំចាំបាច់សុំឬទទួលការអនុញ្ញាតពី អាជ្ញាធរជាមុនឡើយ | # ការរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយនៃការជួបប្រជុំត្រូវបានរឹតត្បិតឬហាមឃាត់ធ្ងន់ធ្ងរដោយសារតែកង្វះការអនុញ្ញាតជាមុន | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៧ | ៦ | ០ | ០ | ០ | ៦ | ការតាមដានប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៦ ករណី នូវហេតុការណ៍នៃការជួបប្រជុំដែលត្រូវបានហាមឃាត់ឬមានការរឹតត្បិតដែលត្រូវបានធ្វើឡើងដោយសារតែមិនទទួលបានការអនុញ្ញាតជាមុន។ |
| | # នៃហេតុការណ៍បង្ហាញអំពីការជួបប្រជុំដែលត្រូវបានរឹតត្បិតនិងហាមឃាត់ធ្ងន់ធ្ងរដោយសារតែកង្វះការអនុញ្ញាតជាមុន | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ២ | ១០ | ០ | ០ | ០ | ០ | មិនមានហេតុក្នុងការរាយការណ៍ពីហេតុការណ៍អំពីនៃការជួបប្រជុំដែលត្រូវបានហាមឃាត់ឬមានការរឹតត្បិតដោយសារតែពុំមានការអនុញ្ញាតជាមុន។ |
| | # នៃហេតុការណ៍តាមរយៈប្រព័ន្ធផ្សព្វផ្សាយអំពីការជួបប្រជុំដែលត្រូវបានជ្រៀតជ្រែកជាមួយនឹងកង្វះការអនុញ្ញាតជាមុន | ការតាមដានតាមប្រព័ន្ធ<br>ផ្សព្វផ្សាយ | មិនមានចម្លើយ | ៦ | ១៦ | ០ | ៤ | ២ | ៤ | ការតាមដានប្រព័ន្ធផ្សព្វផ្សាយកត់ត្រា ៤ ករណីនៃការជួបប្រជុំដែលត្រូវបានជ្រៀតជ្រែកដោយសារតែមិនទទួលបានការអនុញ្ញាតជាមុន។ |
| | # នៃហេតុការណ៍បង្ហាញថាការជួបប្រជុំត្រូវបានជ្រៀតជ្រែកជាមួយកង្វះការអនុញ្ញាតជាមុន | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៩ | ៥ | ០ | ០ | ០ | ១ | មានហេតុការណ៍ ១ ករណី ក្នុងការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រាករណីការប្រមូលផ្តុំដែលត្រូវបានរឹតត្បិត ឬហាមឃាត់ ដោយសារតែពុំមានការអនុញ្ញាតមុន។ |
| ២.២២ ការហាមឃាត់ការជួបប្រជុំគឺជាវិធានការជម្រើសចុងក្រោយក្នុងករណីចាំបាច់ និងសមស្របទៅតាមគោលបំណងដែលចង់បាន | % នៃការជួបប្រជុំដែលគ្រោងទុកតាមប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញថាត្រូវបានហាមឃាត់ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៣% | ៣% | ២% | ៦% | ២% | ៥% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៤ ករណីនៃការជួបប្រជុំត្រូវបានហាមឃាត់ក្នុងចំណោមការជួបប្រជុំដែលបានគ្រោងទុកចំនួន ៧៥ ។ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | % នៃការហាមឃាត់បានបង្ហាញតាមរយៈប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការផ្តល់ជូនដំណឹងច្បាស់លាស់ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ២% | ២% | ២៥% | ៦០% | ០% | ៧៥% | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយបានកត់ត្រា ៣ ករណីការជួបប្រជុំត្រូវបានហាមឃាត់ដែលមានការបញ្ជាក់ពីមូលហេតុច្បាស់លាស់។ |
| | %នៃការហាមឃាត់បានបង្ហាញតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដែលជាផែនការចុងក្រោយ ចាំបាច់និងសមមាត្រ | ការតាមដានតាមប្រព័ន្ធផ្សព្វផ្សាយ | មិនមានចម្លើយ | ៣% | ០% | ០% | ២០% | ០% | ០% | ការតាមដានប្រព័ន្ធផ្សព្វផ្សាយមិនបានកត់ត្រាករណីនៃការជួបប្រជុំត្រូវបានហាមឃាត់ ដែលការហាមឃាត់នោះជាផែនការជម្រើសចុងក្រោយក្នុងករណីចាំបាច់ និងសមស្របទៅតាមគោលបំណងដែលចង់បាន។ |
| | # ការរាយការណ៍ករណីដែលហាមឃាត់ នៃការជួបប្រជុំដែលបានគ្រោងទុក | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ១០ | ១០ | ១០ | ០ | ០ | ០ | មិនមានហេតុការណ៍ក្នុងការរាយការណ៍កត់ត្រាអំពីករណីហាមឃាត់ នៃការជួបប្រជុំដែលបានគ្រោងរួច។ |
| | # ការរាយការណ៍ករណីដែលហាមឃាត់ ដោយគ្មានការផ្តល់ជូនដំណឹងច្បាស់លាស់ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ៩ | ៥ | ១ | ០ | ០ | ០ | មិនមានហេតុការណ៍ក្នុងការរាយការណ៍កត់ត្រាអំពីករណីហាមឃាត់ នៃការជួបប្រជុំដែលបានគ្រោងរួចដោយគ្មានការអនុញ្ញាតនោះទេត្រឹមត្រូវនោះទេ។ |
| | # ការរាយការណ៍ករណីដែលហាមឃាត់ ដែលមិនមែនជាផែនការចុងក្រោយ ដែលចាំបាច់ និងសមមាត្រ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ១០ | ២ | ១ | ០ | ០ | ០ | មិនមានហេតុការណ៍ក្នុងការរាយការណ៍កត់ត្រាអំពីករណីហាមឃាត់នៃការជួបប្រជុំដែលមិនមែនជាភាពសមស្របនៃមធ្យោបាយចុងក្រោយដែលចាំបាច់និងត្រឹមត្រូវ។ |
| | # ការជួបប្រជុំ ត្រូវបានហាមឃាត់ ព្រោះជាជម្រើសចុងក្រោយ ដែលចាំបាច់ និងសមស្របទៅតាមគោលបំណង។ | ការរាយការណ៍ពីហេតុការណ៍ | មិនមានចម្លើយ | ០ | ០ | ០ | ០ | ០ | ០ | មិនមានហេតុការណ៍ក្នុងការរាយការណ៍កត់ត្រាអំពីករណីហាមឃាត់នៃការជួបប្រជុំដែលមិនមែនជាភាពសមស្របនៃមធ្យោបាយចុងក្រោយដែលចាំបាច់និងសមស្របទៅនឹងគោលបំណងដែលបានអនុវត្ត។ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
